# ការបញ្ឈប់គ្រោះថ្នាក់នៅ **កម្ពុជា**

ភស្តុតាងនៃការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ




Funded by End Violence Against Children

Implemented by ECPAT INTERPOL unicef Office of Research-Innocenti

## ការជូនដំណឹង៖

គម្រោងស្តីពីការបញ្ឈប់គ្រោះថ្នាក់ឆ្លើយតបចំពោះប្រធានបទដ៏ស្មុគស្មាញ និងរសើបពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។ នៅពេលរៀបចំរបាយការណ៍នេះ ព័ត៌មានលម្អិតប្រកបដោយភាពតានតឹងក្នុងចិត្តត្រូវបានអធិប្បាយ រួមទាំងការប្រើប្រាស់ពាក្យសម្តីផ្ទាល់របស់អ្នករស់រានមានជីវិត។ អ្នកអានមួយចំនួន ជាពិសេស អ្នកទាំងឡាយដែលបានជួបប្រទះនឹងអំពើហិង្សាផ្លូវភេទ អាចមានការលំបាកក្នុងការអានផ្នែកមួយចំនួននៃរបាយការណ៍នេះ។ អ្នកទទួលបានការលើកទឹកចិត្តឱ្យតាមដានត្រួតពិនិត្យការឆ្លើយតបរបស់អ្នក និងអានរបាយការណ៍ក្នុងលក្ខណៈដែលមានផាសុកភាព។ សូមស្វែងរកការគាំទ្រផ្លូវចិត្ត សម្រាប់ភាពតានតឹងផ្លូវចិត្តស្រួចស្រាវ។

### សំណើសម្រាប់ដំណាក់ស្រង់៖

ECPAT, INTERPOL, and UNICEF. (២០២២). *Disrupting Harm in Cambodia: Evidence on online child sexual exploitation and abuse*. Global Partnership to End Violence Against Children.

កម្មសិទ្ធិបញ្ញា © ECPAT, GPEVAC, INTERPOL, UNICEF, ឆ្នាំ២០២២។ ការប្រើប្រាស់របាយការណ៍នេះត្រូវបានអនុញ្ញាត ក្នុងករណីមានការទទួលស្គាល់ចំពោះប្រភពនៃឯកសារ ហើយឯកសារនេះមិនត្រូវបានប្រើប្រាស់ សម្រាប់គោលបំណងពាណិជ្ជកម្មឡើយ។

មូលនិធិពីភាពជាដៃគូសកល ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ តាមរយៈគំនិតផ្តួចផ្តើមសុវត្ថិភាពអនឡាញ មិនមែនជាធាតុផ្សំដែលបង្កើតឱ្យមាននូវការយល់ព្រមឡើយ។

# តារាងមាតិកា


អារម្ភកថាដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ 2
អារម្ភកថាដោយភាពជាដៃគូដើម្បីបញ្ចប់អំពើហិង្សា 4
សេចក្តីសង្ខេប 6
វិធីសាស្រ្តនៃគម្រោងស្តីពីការបញ្ឈប់គ្រោះថ្នាក់ 11
អំពីការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ 16
ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត 18
ទិដ្ឋភាពទូទៅនៃច្បាប់ និងគោលនយោបាយ 22

## ១. កុមារនៅតាមប្រព័ន្ធអនឡាញនៅកម្ពុជា 24

១.១ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងឧបសគ្គ 25
១.២ សកម្មភាពអនឡាញរបស់កុមារ 29
១.៣ ការយល់ឃើញ និងបទពិសោធន៍អំពី សកម្មភាពអនឡាញប្រកបដោយហានិភ័យ 30
១.៤ ចំណេះដឹង និងជំនាញ សម្រាប់សុវត្ថិភាពតាមប្រព័ន្ធអនឡាញ 39

## ២. ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា 40

២.១ ទិន្នន័យនៃការអនុវត្តច្បាប់ 42
២.២ បទពិសោធន៍របស់កុមារអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារនៅកម្ពុជា 47
២.៣ បទពិសោធន៍ដទៃទៀតរបស់កុមារ ដែលអាចមានទំនាក់ទំនងជាមួយនឹង OCSEA 66
២.៤ ការយល់ដឹងស៊ីជម្រៅអំពីជនរងគ្រោះ និងជនល្មើសនៃករណី OCSEA និង CSEA ដែលបានដឹង 71
២.៥ ឧបសគ្គនានាចំពោះកុមារក្នុងការនិយាយជាមួយមនុស្សពេញ 74

## ៣. ការឆ្លើយតបចំពោះការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា 77

៣.១ យន្តការរាយការណ៍ផ្លូវការ 78
៣.២ ការឆ្លើយតបរបស់ទីភ្នាក់ងារអនុវត្តច្បាប់ 82
៣.៣ ការទទួលបានយុត្តិធម៌ និងការទទួលបានឧបាស្រ័យ 89
៣.៤ ការសម្របសម្រួល និងកិច្ចសហការ 95

## ៤. ការឆ្លើយតបចំពោះ OCSEA នៅកម្ពុជា 100

៤.១ ការយល់ដឹងស៊ីជម្រៅជាគន្លឹះចំនួន៦ និងអនុសាសន៍សម្រាប់ធ្វើសកម្មភាព 101

តារាងឯកសារយោង 111

# អារម្ភកថាដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

កម្ពុជាបានបោះជំហានទៅមុខក្នុងការស្តារសង្គម និងសេដ្ឋកិច្ចឡើងវិញដែលក្នុងពីរទសវត្សរ៍ចុងក្រោយនេះ សម្រេចបានកំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់ និងកំពុងសមាហរណកម្មខ្លួនចូលក្នុងតំបន់និងពិភពលោក ដែលធ្វើឱ្យ កម្ពុជាទទួលបានឱកាសជាច្រើន ក្នុងការកសាងនិងអភិវឌ្ឍប្រទេសជាតិ។ ស្របពេលជាមួយគ្នានេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយធ្វើការវិភាជន៍ធនធានបន្ថែមដល់វិស័យសុខាភិបាល អប់រំ សង្គមកិច្ច និងវិស័យផ្សេងៗទៀតសម្រាប់ជំរុញការអភិវឌ្ឍធនធានមនុស្ស រួមទាំងការអភិវឌ្ឍកុមារ សំដៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០១៦-២០៣០។ ទន្ទឹមនឹងនេះកម្ពុជាបានត្រៀមខ្លួនជាស្រេចក្នុងការចូលរួមក្នុងបដិវត្តឧស្សាហកម្មទី៤ដែលផ្តោតជាពិសេសលើវិស័យបច្ចេកវិទ្យា ដែលពិភពលោកកំពុងប្រើប្រាស់សម្រាប់វិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ចបានយ៉ាងមានប្រសិទ្ធភាព។

ការរីកចម្រើនផ្នែកបច្ចេកវិទ្យាព័ត៌មាន ដូចជាប្រព័ន្ធអ៊ីនធឺណិត និងឧបករណ៍ទំនាក់ទំនងឌីជីថល បានជំរុញដល់ការរីកលូតលាស់ ការងារ នយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច ដែលធ្វើឱ្យកម្ពុជាមានទំនាក់ទំនងជាមួយបណ្តាប្រទេសក្នុងតំបន់និងពិភពលោកថែមទៀតផង ជាពិសេសបានបង្កភាពងាយស្រួលដល់កុមារក្នុងការទំនាក់ទំនង ស្រាវជ្រាវ សិក្សា និងចូលរួមក្នុងបរិយាកាសឌីជីថលចំពោះជីវិត និងសិទ្ធិរបស់កុមារ។ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងបច្ចេកវិទ្យាឌីជីថលក្នុងលក្ខណៈមិនសមស្រប បានបង្កើតឱ្យមានការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញដែលជាទម្រង់ថ្មីមួយកំពុងរាលដាលនៅលើពិភពលោក រួមទាំងកម្ពុជាផងដែរ។

ដោយមើលឃើញបញ្ហាប្រឈម និងផលប៉ះពាល់ពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចូលជារដ្ឋភាគីហត្ថលេខីនៃសេចក្តីថ្លែងការណ៍ WePROTEC នៅទីក្រុងអាប៊ុយដាប៊ី ក្នុងឆ្នាំ២០១៥ ពាក់ព័ន្ធនឹងសកម្មភាពទប់ស្កាត់ ការកេងប្រវ័ញ្ច និងការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ និងបានចូលជាសមាជិកនៃប្រទេសភាពជាដៃគូសកល ដើម្បីលុបបាត់អំពើហិង្សាលើកុមារ (Pathfinding Countries) នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩។ បន្ថែមពីនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានចូលរួមអនុម័តលើ សេចក្តីថ្លែងការណ៍ នាកិច្ចប្រជុំកំពូល នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្នុងគោលបំណងអំពាវនាវឱ្យរដ្ឋជាសមាជិកអាស៊ានទាំងអស់ប្រើប្រាស់បទដ្ឋានកម្រិតខ្ពស់ ដើម្បីការពារកុមារទាំងអស់នៅក្នុងអាស៊ានពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ។ លើសពីនេះទៀត ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានចេញផ្សាយរបាយការណ៍វិភាគស្ថានភាពដំបូង ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា និងបានរៀបចំផែនការសកម្មភាពដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (ឆ្នាំ២០២១-២០២៥) និងផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ដែលបានលើកទឹកចិត្តឱ្យមានសកម្មភាពទប់ស្កាត់អំពើហិង្សានិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានដឹកនាំក្រុមការងារបច្ចេកទេសអន្តរក្រសួង OCSE ដើម្បីពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងរបាយការណ៍ការសិក្សាស្រាវជ្រាវស្ដីពី "*ការបញ្ឈប់គ្រោះថ្នាក់* ក្នុងប្រទេសកម្ពុជា (Disrupting Harm Study)"  នៃការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។ របាយការណ៍នេះ ផ្ដល់នូវភស្តុតាងគ្រប់ជ្រុងជ្រោយអំពីហានិភ័យដែលកុមារជួបប្រទះនៅតាមប្រព័ន្ធអនឡាញ របៀបដែលហានិភ័យកើតឡើង របៀបដែលហានិភ័យទាំងនេះមានអន្តរទំនាក់ទំនងជាមួយទម្រង់ដទៃទៀតនៃអំពើហិង្សា និងអ្វីដែលអាចធ្វើបាន ដើម្បីទប់ស្កាត់និងកាត់បន្ថយហានិភ័យ។ របកគំហើញទាំងនេះ បានជួយឱ្យកម្ពុជាចាត់វិធានការបន្ថែម ដើម្បីធានាថាប្រព័ន្ធអ៊ីនធឺណិតមានសុវត្ថិភាពសម្រាប់កុមារ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងអ្នកពាក់ព័ន្ធ ដែលបានចូលរួមផ្ដល់ធាតុចូលនៅអំឡុងពេលសិក្សាស្រាវជ្រាវ និងក្រុមការងារបច្ចេកទេសអន្តរក្រសួងដើម្បីពិនិត្យផ្ដល់យោបល់លើការសិក្សាស្រាវជ្រាវការកេងប្រវ័ញ្ចផ្លូវភេទលើ កុមារតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា (OCSE Technical Working Group) ដែលបានចូលរួមពិនិត្យ និងកែលម្អរបាយការណ៍នេះឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយ។ ខ្ញុំក៏សូមថ្លែងអំណរចំពោះអង្គការយូនីសេហ្វប្រចាំកម្ពុជា (UNICEF Cambodia) និងអង្គការសកម្មភាពដើម្បីកុមារ (APLE Cambodia) ដែលបានសម្របសម្រួល និងគាំទ្របច្ចេកទេស និងថវិកាដល់ក្រុមការងារបច្ចេកទេសអន្តរក្រសួង។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សូមឯកភាពលទ្ធផលនៃរបាយការណ៍សិក្សាស្រាវជ្រាវនេះ។

ថ្ងៃពុធ ១កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២



**អគ្គលេខាធិការ**

**ញៀម សុគាព**

# អារម្ភកថាដោយភាពជាដៃគូដើម្បីបញ្ចប់អំពើហិង្សា

ជីវិតនៅលើប្រព័ន្ធអនឡាញរបស់យើងកំពុងរីកចម្រើនឥតឈប់ឈរ។ ប្រព័ន្ធអ៊ីនធឺណិត និងឧបករណ៍ទំនាក់ទំនងឌីជីថល ដែលកំពុងវិវឌ្ឍយ៉ាងរហ័ស កំពុងបង្កឱ្យមនុស្សពីគ្រប់ទិសទីមានទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយគ្នា។ កុមារស្គាល់បច្ចេកវិទ្យាទាំងនេះកាន់តែច្បាស់ និងពឹងផ្អែកកាន់តែខ្លាំងលើបច្ចេកវិទ្យាទាំងនេះ ហើយការរាតត្បាតជំងឺកូវីដ១៩ បានបង្កើនការផ្លាស់ប្តូរទៅរកប្រព័ន្ធអនឡាញក្នុងទិដ្ឋភាពជាច្រើននៃជីវិតរបស់កុមារ។

ប្រព័ន្ធអ៊ីនធឺណិត អាចជាឧបករណ៍ដ៏មានឥទ្ធិពល សម្រាប់កុមារក្នុងការទំនាក់ទំនង ស្រាវជ្រាវ សិក្សា និងចូលរួមដោយភាពច្នៃប្រឌិត និងអង់អាច។ សារសំខាន់នៃបរិយាកាសឌីជីថលចំពោះជីវិត និងសិទ្ធិរបស់កុមារត្រូវបានគូសបញ្ជាក់ដោយគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ នៅក្នុងយោបល់ទូទៅលេខ ២៥ ដែលត្រូវបានអនុម័តនៅឆ្នាំ២០២១។ យោបល់ទូទៅនេះក៏សង្កត់ធ្ងន់នូវការពិតដែលថា ការចំណាយពេលតាមប្រព័ន្ធអនឡាញនាំមកនូវហានិភ័យ និងការគំរាមកំហែងពាក់ព័ន្ធនឹងគ្រោះថ្នាក់ដែលមិនអាចទទួលយកបានដោយជៀសមិនផុត ក្នុងនោះក៏មានហានិភ័យ និងការគំរាមកំហែងមួយចំនួន ដែលកុមារក៏បានជួបប្រទះនៅក្នុងកន្លែងដទៃទៀតផងដែរ ហើយហានិភ័យ និងការគំរាមកំហែងមួយចំនួនមានលក្ខណៈដោយឡែកចំពោះតែបរិបទអនឡាញប៉ុណ្ណោះ។

ហានិភ័យមួយនៃហានិភ័យទាំងនេះ គឺការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងបច្ចេកវិទ្យាឌីជីថល មិនសមស្របក្នុងគោលបំណងកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារ។ ការលួងលោមតាមប្រព័ន្ធអនឡាញ ការចែកចាយសម្ភាររំលោភបំពានផ្លូវភេទកុមារ និងការផ្សាយបន្តផ្ទាល់នូវការរំលោភបំពានកុមារ គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងកុមារ ដែលត្រូវការការឆ្លើយតបពហុវិស័យ និងសកលជាបន្ទាន់។ ជាទូទៅ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានថតចម្លងក្នុងទម្រង់ជារូបភាព ឬវីដេអូឌីជីថល ដែលរមែងតែងត្រូវបានចែកចាយ និងចែកចាយម្តងហើយម្តងទៀតនៅតាមប្រព័ន្ធអនឡាញ ហើយការទប់ស្កាត់ និងកិច្ចការពារកាន់តែមានលក្ខណៈពិបាក សម្រាប់រដ្ឋាភិបាល មន្ត្រីសាធារណៈ និងអ្នកផ្តល់សេវាសាធារណៈដល់កុមារ ប៉ុន្តែក៏សម្រាប់ឪពុកម្តាយ និងអ្នកថែទាំដែលព្យាយាមធ្វើអ្វីៗ ដើម្បីតាមឱ្យទាន់ការប្រើប្រាស់បច្ចេកវិទ្យារបស់កូនៗរបស់ពួកគេផងដែរ។

ជាមួយនឹងវឌ្ឍនភាពឆ្ពោះទៅរកទំនាក់ទំនងអ៊ីនធឺណិត ជាសកល ការវិនិយោគលើសុវត្ថិភាព និងកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ គឺជាការងារបន្ទាន់ជាងពេលណាៗទាំងអស់។ បណ្តារដ្ឋាភិបាលនៅជុំវិញពិភពលោកទទួលស្គាល់កាន់តែខ្លាំងលើការគំរាមកំហែងនៃការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ហើយប្រទេសមួយចំនួនបានចាត់វិធានការ ដើម្បីណែនាំអំពីច្បាប់ចាំបាច់ និងរៀបចំឱ្យមានវិធានការទប់ស្កាត់។ ក្នុងពេលជាមួយគ្នានេះដែរ សម្ពាធកំពុងកើតមានទៅលើឧស្សាហកម្មបច្ចេកវិទ្យា ដើម្បីដាក់បញ្ហាសុវត្ថិភាពកុមារជាចំណុចសំខាន់នៃដំណើរការរចនា និងអភិវឌ្ឍ ជាជាងការចាត់ទុកបញ្ហានេះជាការគិតនៅពេលក្រោយ។ សុវត្ថិភាពដោយការរចនាបែបនេះ ត្រូវតែទទួលបានភស្តុតាងអំពីការកើតឡើងនូវ OCSEA ហើយគម្រោងស្តីពី*ការបញ្ឈប់គ្រោះថ្នាក់*រួមចំណែកគួរឱ្យកត់សម្គាល់ចំពោះភស្តុតាងនោះ។

ភាពជាដៃគូសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ តាមរយៈគំនិតផ្តួចផ្តើមសុវត្ថិភាពអនឡាញ បានវិនិយោគថវិកាប្រាំពីរលានដុល្លារអាមេរិកលើគម្រោងស្តីពី*ការបញ្ឈប់គ្រោះថ្នាក់*។ គម្រោងស្តីពី*ការបញ្ឈប់គ្រោះថ្នាក់* បានប្រើប្រាស់បច្ចេកវិទ្យា និងអភិក្រមគ្រប់ជ្រុងជ្រោយ និងប្រកបដោយនវានុវត្តន៍ ដើម្បីធ្វើការវាយតម្លៃគ្រប់ជ្រុងជ្រោយទៅលើបរិបទ ការគំរាមកំហែង និងការយល់ឃើញរបស់កុមារអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។ គម្រោងដែលមិនធ្លាប់មានពីមុនមកនេះប្រើប្រាស់ឯកទេសស្រាវជ្រាវរបស់ ECPAT នគរបាលអន្តរជាតិ ការិយាល័យស្រាវជ្រាវរបស់ UNICEF – Innocenti និងបណ្តាញរបស់ពួកគេ។ ដៃគូសកលទាំងបីនេះទទួលបានការគាំទ្រពីអង្គការសមាជិករបស់ ECPAT ការិយាល័យកណ្តាលជាតិនៃនគរបាលអន្តរជាតិ និងការិយាល័យប្រចាំប្រទេស និងតំបន់របស់ UNICEF ។ គម្រោងនេះមានចេតនាថា វិធីសាស្ត្រដែលត្រូវរៀបចំ និងសាកល្បងពេលនេះត្រូវបានអនុវត្តចំពោះប្រទេសបន្ថែមទៀតនៅជុំវិញពិភពលោក។

គម្រោងស្តីពី*ការបញ្ឈប់គ្រោះថ្នាក់* តំណាងឱ្យគម្រោងស្រាវជ្រាវគ្រប់ជ្រុងជ្រោយបំផុត និងមានទំហំធំ ដែលធ្លាប់ត្រូវបានធ្វើឡើងអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅថ្នាក់ជាតិ និងបានផ្តល់លទ្ធផលជារបាយការណ៍ប្រចាំប្រទេសចំនួន ១៣ និងរបាយការណ៍ប្រចាំតំបន់ចំនួនពីរ។ គម្រោងនេះផ្តល់នូវភស្តុតាងគ្រប់ជ្រុងជ្រោយអំពីហានិភ័យដែលកុមារជួបប្រទះនៅតាមប្រព័ន្ធអនឡាញ របៀបដែលហានិភ័យទាំងនេះកើតឡើង របៀបដែលហានិភ័យទាំងនេះមានអន្តរទំនាក់ទំនងជាមួយទម្រង់ដទៃទៀតនៃអំពើហិង្សា និងអ្វីដែលអាចធ្វើបាន ដើម្បីទប់ស្កាត់ និងកាត់បន្ថយហានិភ័យទាំងនេះ។

គំហើញទាំងនេះជួយដល់រដ្ឋាភិបាល ឧស្សាហកម្ម អ្នករៀបចំគោលនយោបាយ និងសហគមន៍ក្នុងការចាត់វិធានការដ៏ត្រឹមត្រូវ ដើម្បីធានាថា ប្រព័ន្ធអ៊ីនធឺណិត មានសុវត្ថិភាពសម្រាប់កុមារ។ កិច្ចការនេះរួមមានការផ្តល់ភស្តុតាងសម្រាប់យុទ្ធសាស្ត្រទប់ស្កាត់ និងឆ្លើយតបជាតិ ការពង្រីកការគ្របដណ្តប់គម្រោងស្តីពី*ការបញ្ឈប់គ្រោះថ្នាក់* ទៅកាន់ប្រទេស និងតំបន់ដទៃទៀត និងការកសាងទិន្នន័យនិងចំណេះដឹងថ្មីៗនៃភាពជាដៃគូជុំវិញបញ្ហានេះ។

ការបញ្ឈប់គ្រោះថ្នាក់ចំពោះកុមារគឺជាទំនួលខុសត្រូវរបស់មនុស្សគ្រប់គ្នា។



**បណ្ឌិត Howard Taylor**
នាយកប្រតិបត្តិ
ភាពជាដៃគូដើម្បីបញ្ចប់អំពើហិង្សា

# សេចក្តីសង្ខេប

ដោយទទួលបានមូលនិធិពីភាពជាដៃគូសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ តាមរយៈគំនិតផ្តួចផ្តើមសុវត្ថិភាពអនឡាញ ECPAT, INTERPOL និងការិយាល័យស្រាវជ្រាវរបស់ UNICEF - Innocenti បានធ្វើការងារក្នុងភាពជាដៃគូ ដើម្បីរចនា និងអនុវត្តគម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* ដែលជាគម្រោងស្រាវជ្រាវមួយស្តីពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (OCSEA)។ ភាពជាដៃគូដោយឡែកនេះនាំយកអភិក្រមពហុជំនាញ ដើម្បីមើលឃើញឱ្យបានគ្រប់ជ្រុងនៃបញ្ហាដ៏ស្មុគស្មាញនេះ។ OCSEA សំដៅទៅដល់ស្ថានភាពនានា ដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថល ឬបច្ចេកវិទ្យាទំនាក់ទំនងនៅពេលណាមួយនៅក្នុងអំឡុងពេលនៃ ការរំលោភបំពាន ឬការកេងប្រវ័ញ្ចដែលកំពុងបន្តកើតឡើង។វាអាចកើតនៅតាមប្រព័ន្ធអនឡាញទាំងស្រុង ឬតាមរយៈភាពចម្រុះគ្នានៃទំនាក់ទំនងតាមប្រព័ន្ធអនឡាញ និងទំនាក់ទំនងដោយជួបគ្នាផ្ទាល់រវាងជនល្មើស និងកុមារ។ ការស្រាវជ្រាវនៃគម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* ត្រូវបានធ្វើឡើងនៅក្នុងប្រទេសអាស៊ីអាគ្នេយ៍ចំនួនប្រាំមួយ រួមទាំងប្រទេសកម្ពុជា និងប្រទេសនៅអាហ្វ្រិកខាងកើត និងខាងត្បូងចំនួនប្រាំពីរ។ ទិន្នន័យត្រូវបានសំយោគពីសកម្មភាពស្រាវជ្រាវចំនួនប្រាំបួនខុសៗគ្នា ដើម្បីបង្កើតរបាយការណ៍ប្រចាំប្រទេសដែលប្រាប់រឿងរ៉ាវនៃការគំរាមកំហែង និងបង្ហាញអនុសាសន៍ច្បាស់លាស់សម្រាប់ការធ្វើសកម្មភាព។

## ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត

ការអង្កេតតាមខ្នងផ្ទះដែលតំណាងថ្នាក់ជាតិបានបង្ហាញឱ្យឃើញថា កុមារកម្ពុជាអាយុពី ១២ ទៅ ១៧ឆ្នាំចំនួនជាង ៨០% គឺជាអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ដែលមានន័យថា ពួកគេបានប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត នៅក្នុងកំឡុងពេលបីខែមុន។ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត មានប្រេវ៉ាឡង់នៅក្នុងចំណោមកុមារធំៗ (១៤-១៧ឆ្នាំ) ខ្ពស់ជាងកុមារតូចៗ (១២-១៣ឆ្នាំ) និងគ្មានភាពខុសគ្នារវាងយេនឌ័រឡើយ។ ការប្រើប្រាស់អ៊ីនធឺណិត មានប្រេវ៉ាឡង់នៅក្នុងចំណោមកុមារទៅតាមទីក្រុង (៨៦%) ខ្ពស់ជាងកុមារនៅតាមទីជនបទបន្តិច (៨០%)។

ទិន្នន័យពីការអង្កេតតាមខ្នងផ្ទះជាតំណាងទៅលើកុមារកំពុងប្រើប្រាស់អ៊ីនធឺណិត (ចំនួន ៩៩២នាក់) និងអ្នកថែទាំរបស់ពួកគេ (ចំនួន ៩៩២នាក់) បានបង្ហាញថា កុមារទំនងជាអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតច្រើនជាងអ្នកថែទាំរបស់ពួកគេ។ អ្នកថែទាំត្រឹមតែ ៦១% ប៉ុណ្ណោះ ដែលជាអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ហើយពួកគេចំនួន ៤២% ប៉ុណ្ណោះ ដែលប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ជារៀងរាល់ថ្ងៃ ធៀបកុមារប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ចំនួន ៧៧%។ ៣៩% នៃអ្នកថែទាំមិនដែលចូលប្រើប្រព័ន្ធអនឡាញឡើយ ហើយ ១៩% ចូលប្រើប្រព័ន្ធអនឡាញក្នុងកម្រិតមិនញឹកញាប់ខ្លាំង។ ភាពខុសគ្នានេះមានភាពពាក់ព័ន្ធ ដោយសារឪពុកម្តាយគឺជាប្រភពយ៉ាងសំខាន់នៅក្នុងការជួយកុមារឱ្យចេះដឹកនាំជីវិតរបស់ពួកគេនៅតាមប្រព័ន្ធអនឡាញ កំណត់រកហានិភ័យ និងទប់ស្កាត់ពួកគេពីការធ្លាក់ទៅក្នុងគ្រោះថ្នាក់។

កុមារច្រើនលើសលប់ប្រើប្រាស់ទូរស័ព្ទឆ្លាតវៃ (៩៩%) ដើម្បីប្រើប្រាស់ប្រព័ន្ធអនឡាញ ហើយជាញឹកញាប់ ពួកគេចែកចាយទូរស័ព្ទជាមួយអ្នកដទៃទៀត។ នៅកម្ពុជា ភាគច្រើនកុមារដែលកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត (៨៧%) បានរៀបរាប់អំពី ឧបសគ្គនានា ដូចជាសេវាខ្សោយ ឬល្បឿនយឺត។ ២៧% បាននិយាយថា ឪពុកម្តាយរបស់ពួកគេ ដាក់ការរិតត្បិតចំពោះការប្រើប្រាស់ប្រព័ន្ធអនឡាញរបស់ពួកគេ។ សកម្មភាពអនឡាញដែលមានប្រជាប្រិយភាពជាងគេនៅក្នុងចំណោមកុមារ គឺការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម (៧៩%) និងការមើលវីដេអូ (៧៩%)។

## ការយល់ឃើញ និងសកម្មភាពអនឡាញប្រកបដោយហានិភ័យ

កុមារមួយចំនួនដែលបានចូលរួមនៅក្នុងការអង្កេតនេះ បានចូលរួមនៅក្នុងអាកប្បកិរិយាប្រកបដោយហានិភ័យដ៏មានសក្តានុពលកាលពីឆ្នាំមុន។ ប្រហែល ៩% បានជួបជាមួយនរណាម្នាក់ដោយផ្ទាល់ ដែលពួកគេបានស្គាល់ដំបូងនៅតាមប្រព័ន្ធអនឡាញ។ ភាគច្រើននៃពួកគេ (៧៥%) ដែលបានប្រព្រឹត្តអាកប្បកិរិយាទាំងនេះនៅក្នុងជីវិតជាក់ស្តែង បានរាយការណ៍ថា ពួកគេសប្បាយចិត្ត ឬរំភើបចិត្តចំពោះលទ្ធផលនៃទង្វើនេះ។ បទពិសោធន៍របស់កុមារកំពុងប្រើប្រាស់អ៊ីនធឺណិត នៅកម្ពុជា និងប្រទេសដទៃទៀតដែលការស្រាវជ្រាវនៃគម្រោងស្តីពី ការបញ្ឈប់គ្រោះថ្នាក់ ត្រូវបានធ្វើឡើង ហាក់បង្ហាញថាហានិភ័យនៃគ្រោះដែលពាក់ព័ន្ធនឹងមនុស្សមិនធ្លាប់ស្គាល់នៅតាមអនឡាញគឺអាចមានកម្រិតទាប។ នេះប្រហែលជារបៀបដែលមនុស្សវ័យក្មេងបង្កើតមិត្តភក្តិថ្មីនៅពេលខ្លះ។ ទោះបីជាយ៉ាងណាក៏ដោយ កុមារទាំងអស់ត្រូវដឹងអំពីហានិភ័យនៅតាមប្រព័ន្ធអនឡាញដែលអាចកើតមាន និងត្រូវបានបង្រៀនអំពីរបៀបចូលប្រើប្រាស់ដោយការទទួលខុសត្រូវ និងដើម្បីចាត់វិធានការប្រកបដោយសុវត្ថិភាព ដូចជាការជូនដំណឹងដល់មនុស្សធំដែលទុកចិត្ត ឬការជួបនៅតែទីសាធារណៈ ប៉ុណ្ណោះ។

បន្ថែមលើនេះ ៩% នៃកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតដែលបានចូលរួមក្នុងការអង្កេតនៅកម្ពុជា បានរាយការណ៍ថា ពួកគេបានចែកចាយ

## សេចក្តីសង្ខេប

រូបភាព ឬវីដេអូអាក្រាតរបស់ខ្លួនឯងផ្ទាល់នៅតាមប្រព័ន្ធអនឡាញ។ បើទោះបីជាកុមារមួយចំនួនបានចែកចាយរូបភាពទាំងនេះជាមួយបុគ្គលទាំងឡាយដែលពួកគេមិនស្គាល់ក្តី ជាញឹកញាប់ណាស់ រូបភាពបែបនេះត្រូវបានចែកចាយនៅក្នុងចំណោមមិត្តភក្តិ និងមិត្តភក្តិជិតស្និទ្ធរបស់ពួកគេ ដោយសារកុមារធ្លាក់ក្នុងក្តីស្រឡាញ់ មានការចែចង់ ឬកំពុងមានភាពរីករាយ។ ដោយមិនគិតអំពីស្ថានភាពដំបូង ហានិភ័យនៃមាតិកាដែលកំពុងត្រូវបានចែកចាយដោយគ្មានការអនុញ្ញាត នៅតែនឹងអាចមានភាពពាក់ព័ន្ធគួរឱ្យខ្លាច។ គួរឱ្យព្រួយបារម្ភ សមាមាត្រនៃកុមារដែលបានរាយការណ៍ថា ពួកគេចែកចាយមាតិកាផ្លូវភេទ ដោយសារការគំរាមកំហែង (៧%) ឬការដាក់សម្ពាធ (៨%)។

### បទពិសោធន៍របស់កុមារអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ

ក្នុងការអង្កេតតាមខ្នងផ្ទះនៃគម្រោងស្តីពីការបញ្ឈប់គ្រោះថ្នាក់ កុមារដែលចូលរួមនៅក្នុងការអង្កេតក៏ត្រូវបានសួរថា តើពួកគេទទួលរងគ្រោះនូវទម្រង់ខុសៗគ្នានៃ OCSEA កាលពីឆ្នាំមុន ពេលប្រមូលទិន្នន័យ។ នៅក្រោមគម្រោងស្តីពីការបញ្ឈប់គ្រោះថ្នាក់ OCSEA គឺត្រូវបានសំដៅទៅដល់ស្ថានភាពនានា ដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថល ឬបច្ចេកវិទ្យាទំនាក់ទំនង*នៅពេលណាមួយ*នៅក្នុងអំឡុងពេលនៃការរំលោភបំពាន ឬការកេងប្រវ័ញ្ចដែលកំពុងបន្តកើតឡើង។ នៅត្រឹម១ឆ្នាំមុនតែប៉ុណ្ណោះ ១១% នៃកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតអាយុពី ១២ដល់១៧ឆ្នាំនៅកម្ពុជា គឺជាជនរងគ្រោះនៃហេតុការណ៍ដ៏អាក្រក់ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ។ ហេតុការណ៍ទាំងនេះរួមមានទាំងការគំរាមទាមទារកុមារឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទ ការចែកចាយរូបភាពផ្លូវភេទរបស់ពួកគេដោយគ្មានការអនុញ្ញាត ឬការបង្ខិតបង្ខំពួកគេឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទ តាមរយៈការសន្យាផ្តល់លុយកាក់ ឬអំណោយ។ វាស់ធៀបទៅនឹងចំនួនប្រជាជនសរុបនៃកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា ចំនួននេះតំណាងឱ្យកុមារចំនួនប្រមាណ ១៦០.០០០នាក់។ វាក៏ទំនងដែរថា តួលេខពិតគឺអាចខ្ពស់ជាងនេះដោយសារកុមារអាចស្ទាក់ស្ទើរក្នុងការនិយាយចេញដោយបើកចំហអំពីបញ្ហាដ៏រសើបនេះ។

បទពិសោធន៍ទាំងនេះបានកើតឡើង ទាំងនៅតាមប្រព័ន្ធអនឡាញ ឬជួបគ្នាដោយផ្ទាល់ ប៉ុន្តែទាំងអស់នេះគឺត្រូវបានសម្របសម្រួលដោយបច្ចេកវិទ្យាឌីជីថល។ ករណី OCSEA ដែលត្រូវបានកំណត់នៅក្នុងការអង្កេតតាមខ្នងផ្ទះ ជាញឹកញាប់បំផុត ពាក់ព័ន្ធបណ្តាញទំនាក់ទំនងសង្គម ជាទូទៅគឺកម្មវិធី Facebook (រួមទាំង Facebook Messenger) បន្ទាប់មក គឺ TikTok និង YouTube។

កុមារវ័យក្មេងដែលមានអាយុពី ១២ដល់១៣ឆ្នាំ ក៏ទំនងជាបានជួបប្រទះនូវទម្រង់ខុសៗគ្នានៃ OCSEA ខ្ពស់ជាងកុមារធំៗផងដែរ។ ភាពខុសគ្នានៃយេនឌ័រត្រូវបានកត់សម្គាល់នៅក្នុងសំណាកនៃកុមារកំពុងប្រើប្រាស់អ៊ីនធឺណិត នៅកម្ពុជា។ កុមារាបានរាយការណ៍អំពីការរងផលប៉ះពាល់ពីហេតុការណ៍សក្តានុពល ឬជាក់ស្តែងនៃ OCSEA ក្នុងអត្រាខ្ពស់ជាងកុមារីស្ទើរតែពីរដង។

នៅក្នុងចំណោមកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ដែលចូលរួមនៅក្នុងការអង្កេត ភាគច្រើននៃការស្នើសុំមាតិកាផ្លូវភេទដែលអាចបង្ហាញអំពីការប៉ុនប៉ងលួងលោម បានទទួលការបដិសេធពីកុមារ ទោះបីជាយ៉ាងណា

ក្តី កុមារមួយចំនួនអនុវត្តតាម។ ពីការអង្កេតតាមខ្នងផ្ទះ ២៩% នៃកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត បានធ្វើតាមការស្នើទាំងនោះក្នុងការនិយាយអំពីផ្លូវភេទ ស្របពេលដែលកុមារចំនួន ១៤% បាននិយាយថាពួកគេបានធ្វើតាមការស្នើឱ្យចែកចាយរូបភាព ឬវីដេអូបង្ហាញផ្នែកឯកជនរបស់ពួកគេ។ នៅគ្រានេះដែរ កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតអាយុពី១៥ដល់១៧ឆ្នាំ ចំនួន៦% បានរាយការណ៍ថា បានទទួលយកលុយកាក់ ឬអំណោយជាថ្នូរនឹងរូបភាព ឬវីដេអូផ្លូវភេទខ្លួនឯងផ្ទាល់។

### ជនល្មើសនៃការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានតាមប្រព័ន្ធអនឡាញ

ជនល្មើសភាគច្រើនគឺជាមនុស្សដែលកុមារបានស្គាល់ ដោយយោងតាមភស្តុតាងទាក់ទងនឹងអំពើហិង្សាលើកុមារនៅក្រៅអនឡាញ និងភាគច្រើនគឺជាជនល្មើសទាក់ទងនឹង OCSEA ដែលត្រូវបានកំណត់នៅក្នុងការអង្កេតតាមខ្នងផ្ទះ។ អ្នកទាំងនេះច្រើនតែជាសមាជិកគ្រួសារ មិត្តភក្តិពេញវ័យ និងមិត្តភក្តិ ឬដៃគូស្នេហា។ ករណី១ក្នុងចំណោម៥ ទាក់ទងនឹង OCSEA ដែលត្រូវបានកំណត់នៅក្នុងការអង្កេតតាមខ្នងផ្ទះ គឺពីដំបូងមិនមានការស្គាល់គ្នារវាងជនល្មើស និងកុមារទេ។ របបគំហើញនេះមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ទៅលើកិច្ចខិតខំនៃកម្មវិធីបង្ការទប់ស្កាត់ដែលផ្តោតលើការគំរាមកំហែងនៃគ្រោះថ្នាក់ពីមនុស្សចម្លែកមុខជាជាងមនុស្សដែលកុមារស្គាល់រួចហើយ។ ទាំងនេះគួរជាការពិចារណាសម្រាប់ប្រព័ន្ធឆ្លើយតបផងដែរព្រោះវាអាចជាការលំបាករបស់ជនរងគ្រោះក្នុងការស្វែងរកជំនួយ ប្រសិនបើជនរងគ្រោះមានមនោសញ្ចេតនា និងស្ថិតក្រោមការផ្គត់ផ្គង់ផ្នែកសេដ្ឋកិច្ចពីជនល្មើស។

## សេចក្តីសង្ខេប

### ការលាតត្រដាង និងការរាយការណ៍អំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ

ក្នុងការអង្កេតតាមផ្ទះ ភាគច្រើននៃកុមារដែលបានជួបប្រទះនឹង OCSEA ពិតជាបានលាតត្រដាងអំពីអ្វីដែលបានកើតឡើងចំពោះនរណាម្នាក់។ ជាញឹកញាប់បំផុត កុមារបានទុកចិត្តលើមិត្តភក្តិ អ្នកថែទាំជាបុរស ឬបងប្អូនបង្កើតរបស់ពួកគេ។ ការស្រាវជ្រាវបានបង្ហាញថា ហេតុការណ៍បែបនេះតិចតួចណាស់ត្រូវបានរាយការណ៍តាមរយៈយន្តការរាយការណ៍ផ្លូវការ ដូចជា៖ នគរបាល សេវាទូរស័ព្ទបន្ទាន់ ឬសេវាសង្គម។ កុមាររងផលប៉ះពាល់ពីទម្រង់ផ្សេងៗនៃ OCSEA ចំនួនរវាង 0% និង ៣% បានរាយការណ៍ជាផ្លូវការ។

ការស្រាវជ្រាវនេះបានរកឃើញថា OCSEA មួយចំនួននៅតែមិនត្រូវបានលាតត្រដាង។ សម្រាប់បទពិសោធន៍ដូចជា ការស្នើដែលមិនត្រូវបានស្វាគមន៍ដើម្បីពិភាក្សាអំពីបញ្ហាផ្លូវភេទ ឬផ្ញើមាតិកាផ្លូវភេទ កុមារចំនួនច្រើនរហូតដល់ ២៣% មិនប្រាប់អ្នកណាម្នាក់អំពីហេតុការណ៍នេះឡើយ។ មូលហេតុចម្បង សម្រាប់ការមិនលាតត្រដាង គឺកង្វះការយល់ដឹងអំពីកន្លែងដែលត្រូវទៅ និងអ្នកណាដែលត្រូវប្រាប់។ ការភ័យខ្លាច និងភាពអាម៉ាស ភាពគ្មានផាសុកភាពក្នុងការពិភាក្សាដោយបើកចំហអំពីផ្លូវភេទ និងបញ្ហាផ្លូវភេទ ព្រមទាំងភាព

រសើបនៃការលាតត្រដាងអំពីការរំលោភបំពាន ដែលប្រព្រឹត្តដោយសមាជិកគ្រួសារគឺជាកត្តាមួយផ្សេងទៀត ដែលគាំទ្រឱ្យមានភាពស្ទាក់ស្ទើររបស់កុមារក្នុងការត្រដាងអំពីហេតុការណ៍នេះ។

### ការអនុវត្តច្បាប់

ស្ថិតិជាតិអំពីបទល្មើសពាក់ព័ន្ធនឹង OCSEA មិនត្រូវបានផ្តល់ដោយទីភ្នាក់ងារអនុវត្តច្បាប់ជាតិឡើយ ហេតុនេះមិនត្រូវបានបញ្ចូល ឬវិភាគនៅក្នុងរបាយការណ៍នេះឡើយ។

នៅក្នុងជួរកងកម្លាំងនគរបាលកម្ពុជា មានអង្គភាពសំខាន់ៗចំនួនពីរ ដែលទទួលខុសត្រូវចំពោះការស៊ើបអង្កេតបទល្មើសពាក់ព័ន្ធនឹង OCSEA នោះគឺនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា។ អង្គភាពទាំងពីរមានមន្ត្រីនគរបាលយុត្តិធម៌ ទោះបីជាយ៉ាងណាក្តី ការទទួលខុសត្រូវ និងនីតិវិធីជាក់លាក់ សម្រាប់ការឆ្លើយតបចំពោះបទល្មើសពាក់ព័ន្ធនឹង OCSEA មិនមានភាពច្បាស់លាស់ឡើយ និងច្បាស់ណាស់មិនសមស្របទៅនឹងអាណត្តិរបស់អង្គភាពតែមួយណាឡើយ។ បើនិយាយឱ្យទូលំទូលាយ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនទទួលខុសត្រូវចំពោះករណីកេងប្រវ័ញ្ចផ្លូវភេទកុមារ។ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាគ្របដណ្តប់លើករណីនានា ដែលពាក់ព័ន្ធនឹងគ្រប់ទម្រង់នៃបទល្មើសបច្ចេកវិទ្យា ដូច្នេះនាយកដ្ឋាននេះនឹងចូលរួមនៅក្នុងករណីនានា ដែលពាក់ព័ន្ធនឹង OCSEA ក្នុងហេតុការណ៍មួយចំនួន ដើម្បីគាំទ្រនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។

សមត្ថភាពអនុវត្តច្បាប់កម្ពុជា ក្នុងការឆ្លើយតបចំពោះបទល្មើសពាក់ព័ន្ធនឹង OCSEA ត្រូវបានរារាំងដោយលទ្ធភាពនៅមានកំណត់ក្នុងការទទួលបានការបណ្តុះបណ្តាល និងសមត្ថភាពទាបពាក់ព័ន្ធនឹងបុគ្គលិក និងបរិក្ខារ ដើម្បីប្រមូល និងវិភាគភស្តុតាងឌីជីថលប្រកបដោយប្រសិទ្ធភាព។

ចំនួននៃសេចក្តីរាយការណ៍អំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ដែលបានរាយការណ៍ទៅកាន់មជ្ឈមណ្ឌលជាតិការពារកុមារបាត់ខ្លួន និងរងគ្រោះដោយការកេងប្រវ័ញ្ច (ដែលត្រូវបានគេស្គាល់ថាជា CyberTips) ពាក់ព័ន្ធនឹងកម្ពុជា បានកើនឡើងចំនួន ២៦១% នៅរវាងឆ្នាំ២០១៧ និងឆ្នាំ២០១៩។ ការកាន់កាប់ ការផលិត និងការចែកចាយសម្ភាររំលោភបំពានផ្លូវភេទកុមារមានចំនួនស្ទើរតែស្មើនឹងសេចក្តីរាយការណ៍ទាំងអស់របស់កម្ពុជា ទាក់ទងនឹងសេចក្តីរាយការណ៍អំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ នៅក្នុងរយៈពេលនេះ។

ការអង្កេតជាមួយអ្នកផ្តល់សេវាសង្គមជួរមុខបានបង្ហាញថា បុគ្គលិកបានវាយតម្លៃការយល់ដឹងអំពីការអនុវត្តច្បាប់ ហើយចម្លើយ គឺមធ្យម ឬល្អ។ ឧទាហរណ៍ច្បាស់លាស់មួយចំនួននៃនីតិវិធីកុមារមេត្រី ដែលអនុវត្តយ៉ាងល្អដោយនគរបាល និងនៅក្នុងតុលាការ ត្រូវបានកំណត់ឃើញ ទោះបីជាយ៉ាងណាយុវជន និងអ្នកថែទាំរបស់ពួកគេដែលបានសម្ភាសសម្រាប់គម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* ក៏បានកត់សម្គាល់នូវតម្រូវការចាំបាច់ក្នុងការពង្រឹងនៅក្នុងផ្នែកនេះផងដែរ។

ពាក់ព័ន្ធនឹងកិច្ចសហការអន្តរជាតិ ភស្តុតាងបានកំណត់ថា នគរបាលជាតិកម្ពុជាដែលបានសហការជាមួយទីភ្នាក់ងារអនុវត្តច្បាប់អន្តរជាតិ បានផ្តោតជាទូទៅបំផុតទៅលើបញ្ហានានាពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍ ដូចជា ចំនួននៃហេតុការណ៍ដែលត្រូវបានកត់ត្រាអំពី ការទប់ស្កាត់ជនល្មើសអន្តរជាតិពីការចូលមកក្នុងប្រទេស។

### បទពិសោធន៍របស់ជនរងគ្រោះនៅក្នុងប្រព័ន្ធយុត្តិធម៌

ការសម្ភាសជាមួយកុមារប្រាំមួយនាក់ និងអ្នកថែទាំពួកគេអំពីបទពិសោធន៍របស់ពួកគេក្នុងការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ សម្រាប់ OCSEA ត្រូវបានធ្វើឡើង។ បញ្ហាប្រឈមមួយចំនួនត្រូវបានកំណត់នៅក្នុងអំឡុងពេលនៃការធ្វើដំណើរឆ្លងកាត់ប្រព័ន្ធយុត្តិធម៌។ កុមារបួននាក់ក្នុងចំណោមប្រាំមួយនាក់បានរាយការណ៍ថា នគរបាលបានធ្វើការសម្ភាសពួកគេ ដោយមិនបានគិតគូរពេញលេញដល់ឯកជនភាព និងការរក្សាការសម្ងាត់ឡើយ។ ទំនាក់ទំនងជាមួយមន្ត្រីនគរបាល និងមន្ត្រី

តុលាការក៏បានធ្វើឱ្យយុវជនមួយចំនួន និងឪពុកម្តាយរបស់ពួកគេមានអារម្មណ៍មិនសូវទទួលបានការគាំទ្រផងដែរ។

បើទោះបីជាកុមារមួយចំនួនថ្លែងអំណរគុណចំពោះឱកាសក្នុងការជ្រើសរើសមន្ត្រីនគរបាលដែលពួកគេចង់បានក្តី មិនមែនកុមារទាំងអស់សុទ្ធតែទទួលបានឱកាសនេះទេឡើយ។ ពួកគេក៏បានរាយការណ៍ថា ពួកគេត្រូវប្រាប់រឿងរ៉ាវរបស់ពួកគេម្តងហើយម្តងទៀត។ អ្នកថែទាំមួយចំនួនបានបង្ហាញកង្វល់អំពីការផាត់ចេញពី ដំណាក់កាលមួយចំនួននៃដំណើរការយុត្តធម៌ និងមិនអាចផ្តល់ការគាំទ្រពេញលេញដល់កូនៗរបស់ពួកគេបានឡើយ។ នៅទីបំផុត គ្មានគ្រួសារណាមួយដែលត្រូវបានសម្ភាសសម្រាប់គម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* បានបន្តចូលរួមដល់ដំណាក់តុលាការ ដោយកុមារបាននិយាយអំពីរឿងរ៉ាវនានា ដូចជាកង្វះឆន្ទៈ ឬសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់ក្នុងការបន្តនីតិវិធី ហើយនៅក្នុងករណីមួយ គ្រួសារបានដោះស្រាយក្រៅផ្លូវការក្រៅប្រព័ន្ធតុលាការ។

ចាប់តាំងពីឆ្នាំ២០០៨មក កម្ពុជាមានបទប្បញ្ញត្តិច្បាប់នានា ដើម្បីធានានូវតុលាការបែបកុមារមេត្រី ទោះបីជាយ៉ាងណាក្តី អ្នកវិជ្ជាជីវៈខាងច្បាប់ដែលត្រូវបានសម្ភាសសម្រាប់គម្រោងស្តីពីការបញ្ឈប់គ្រោះថ្នាក់ បានកត់សម្គាល់ថា បទប្បញ្ញត្តិច្បាប់ទាំងនេះមិនបានអនុវត្តប្រកបដោយសង្គតភាពឡើយ។ កង្វល់នានាក៏ត្រូវបានលើកឡើងពាក់ព័ន្ធនឹងសក្តានុពលក្នុងការបង្កការប៉ះទង្គិចផ្លូវចិត្តសារជាថ្មីចំពោះជនរងគ្រោះនៅទូទាំងដំណើរការតុលាការផងដែរ ហើយជាទូទៅ ដំណើរការបែបនេះមានរយៈយូរ។ កុមារដែលមានការគាំទ្រយ៉ាងជិតដល់របស់អង្គការមិនមែនរដ្ឋាភិបាលទំនងជាមានបទពិសោធន៍វិជ្ជមានច្រើន។

### សេវាគាំទ្រសង្គម សម្រាប់ជនរងគ្រោះ

នៅកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលមានសារសំខាន់ក្រៃលែងនៅក្នុងការគាំទ្រកុមាររងគ្រោះនៃការកេងប្រវ័ញ្ចផ្លូវភេទជាច្រើន ហើយអង្គការទាំងនេះអាចផ្តល់សេវាជាច្រើន រួមមាន ការថែទាំផ្នែកវេជ្ជសាស្ត្រ ជម្រកការផ្តល់ប្រឹក្សាយោបល់ ការគាំទ្រផ្នែកច្បាប់ និងការគាំទ្រផ្លូវចិត្ត។ ជាទូទៅ បុគ្គលិកជួរមុខបានវាយតម្លៃលើការអាចទទួលបាន និងគុណភាពនៃសេវាផ្លូវច្បាប់ និងសេវាចិត្តសាស្ត្រដែលផ្តល់ដល់កុមាររងគ្រោះថា ល្អ ឬល្អណាស់ សេវាសមាហរណកម្មថា មធ្យម ឬល្អ និងសេវាវេជ្ជសាស្ត្រថា ខ្សោយ ឬមធ្យម។ ការប្រមូលផ្តុំសេវាគាំទ្រនៅតំបន់ទីក្រុង បន្ទុកចំណាយ និងគុណភាពសេវា ព្រមទាំងសមត្ថភាពរបស់ពួកគេក្នុងឆ្លើយតបនឹងតម្រូវការរបស់ជនរងគ្រោះទាំងអស់ (មិនត្រឹមតែកុមារីប៉ុណ្ណោះឡើយ) ត្រូវកំណត់ថា ជាឧបសគ្គគន្លឹះចំពោះការទទួលបានការគាំទ្ររបស់ជនរងគ្រោះនៃ OCSEA ។

### ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ

នៅកម្ពុជា មានភស្តុតាង ដែលបង្ហាញថាទាំងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលមានបំណងសហប្រតិបត្តិការ ដើម្បីដោះស្រាយបញ្ហា

ប្រឈមពាក់ព័ន្ធនឹង OCSEA ដែលកំពុងលេចឡើង។ កិច្ចសហប្រតិបត្តិការល្អ រវាងរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ជាមួយក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត គឺមានសក្តានុពលក្នុងការពង្រឹងកិច្ចខិតខំប្រឹងប្រែងនៃការបង្ការ ទប់ស្កាត់ និងការឆ្លើយតប។ ការប្រកាសឱ្យអនុវត្តផែនការសកម្មភាពជាតិ ដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា ឆ្នាំ២០២១-២០២៥ នាពេលថ្មីៗនេះ បង្ហាញនូវឱកាសសម្រាប់អ្នកធ្វើការពាក់ព័ន្ធទាំងអស់ក្នុងការពង្រឹងកិច្ចខិតខំប្រឹងប្រែងសហការគ្នា និងត្រួសត្រាយអភិក្រមថ្មីៗ ដើម្បីដោះស្រាយបញ្ហា OCSEA ។

គំនិតផ្តួចផ្តើមសក្តានុពលមួយចំនួន ដែលដឹកនាំដោយរដ្ឋាភិបាល និងសង្គមស៊ីវិល កំពុងស្ថិតនៅក្នុងដំណើរការអនុវត្តរួចហើយនៅកម្ពុជា ហើយបើទោះបីជាមានបញ្ហាប្រឈមគួរឱ្យកត់សម្គាល់ក្តី ច្បាស់ណាស់មានសន្ទុះ និងការប្តេជ្ញាចិត្តកាន់តែច្រើនក្នុងការធានាថា កុមារកម្ពុជាទទួលបានកិច្ចការពារពី OCSEA ។

### ការយល់ដឹងស៊ីជម្រៅ

របាយការណ៍នេះធ្វើសេចក្តីសន្និដ្ឋានតាមរយៈការគូសបញ្ជាក់នូវការយល់ដឹងស៊ីជម្រៅសំខាន់ៗចំនួនប្រាំមួយ ចេញពីការសិក្សាស្រាវជ្រាវនេះ៖

១. នៅឆ្នាំមុន ១១% នៃកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតអាយុ ១២-១៧ឆ្នាំនៅកម្ពុជា គឺជាជនរងគ្រោះនៃការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ ដែលរួមមានការគំរាមទាមទារកុមារឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទ ការចែកចាយរូបភាពផ្លូវភេទរបស់ពួកគេដោយគ្មានការអនុញ្ញាត ឬការបង្ខិតបង្ខំពួកគេឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទ តាមរយៈការសន្យាផ្តល់លុយកាក់ ឬអំណោយផ្សេងៗ។ ប្រសិនបើវាស់ធៀបទៅនឹងចំនួនប្រជាជនសរុប ចំនួននេះតំណាងឱ្យកុមារចំនួនប្រមាណ ១៦០.០០០នាក់។ កុមារាបានរាយការណ៍អំពីបទពិសោធន៍បែបនេះញឹកញាប់ជាងកុមារីស្ទើរតែពីរដង។

## សេចក្តីសង្ខេប

២. យោងតាមការអង្កេតតាមខ្នងផ្ទះ ជាញឹកញាប់បំផុត ជនល្មើសនៃ OCSEA ជាមនុស្សដែលស្គាល់កុមាររួចហើយ។ អ្នកទាំងនេះច្រើនតែជាសមាជិកគ្រួសារ មិត្តភក្តិពេញវ័យ និងមិត្តភក្តិ ឬដៃគូស្នេហា។ ករណី១ ក្នុងចំណោម៥ ទាក់ទងនឹង OCSEA ដែលត្រូវបានកំណត់នៅក្នុងការអង្កេតតាមខ្នងផ្ទះ គឺពីដំបូងមិនមានការស្គាល់គ្នារវាងជនល្មើស និងកុមារទេ។

៣. កុមារបានជួបប្រទះនឹង OCSEA ភាគច្រើនតាមរយៈបណ្តាញទំនាក់ទំនងសង្គម ជាទូទៅ គឺកម្មវិធី Facebook និង Facebook Messenger និង WhatsApp ។

៤. កុមារដែលបានទទួលរងគ្រោះពី OCSEA ទំនងជាទុកចិត្តលើបុគ្គលនានានៅក្នុងបណ្តាញទំនាក់ទំនងអន្តរបុគ្គលរបស់ពួកគេ ជាពិសេស មិត្តភក្តិ អ្នកថែទាំជាបុរស និងបងប្អូនបង្កើតរបស់ពួកគេ។ កុមារតិចតួចណាស់ ដែលបានប្រើប្រាស់យន្តការរាយការណ៍ផ្លូវការនានា ដូចជា បណ្តាញទូរស័ព្ទបន្ទាន់ បណ្តាញទូរស័ព្ទជំនួយ ឬនគរបាល។

៥. គំនិតផ្តួចផ្តើមសក្តានុពលមួយចំនួន ដែលដឹកនាំដោយរដ្ឋាភិបាល និងសង្គមស៊ីវិល កំពុងស្ថិតនៅក្នុងដំណើរការអនុវត្តរួចហើយនៅកម្ពុជា ទោះបីជាយ៉ាងណាក្តី បញ្ហាប្រឈមគួរឱ្យកត់សម្គាល់នៅតែកើតមាន។ សន្ទុះ និងការប្តេជ្ញាចិត្តកាន់តែច្រើនក្នុងការធានាថា កុមារកម្ពុជាទទួលបានកិច្ចការពារពី OCSEA គប្បីត្រូវបានប្រើប្រាស់ ដើម្បីបង្កើនការយល់ដឹង ជំនាញ និងធនធាន សម្រាប់មន្ត្រីអនុវត្តច្បាប់ តុលាការ និងអ្នកធ្វើការគាំទ្រផ្នែកសង្គម ក្នុងការឆ្លើយតប។

៦. បើទោះបីជាការប្រកាសឱ្យអនុវត្ត និងការអនុវត្តជាបន្តបន្ទាប់នូវផែនការសកម្មភាពស្តីពី OCSEA គឺជាជំហានមួយយ៉ាងសំខាន់ក្តី ច្បាប់ គោលនយោបាយ និងបទដ្ឋានដទៃទៀតនៅតែចាំបាច់ត្រូវអនុម័តឱ្យបាននៅកម្ពុជា។

របាយការណ៍នេះបញ្ចប់ជាមួយនឹងផែនទីលម្អិតសម្រាប់ចំណាត់ការដែលត្រូវធ្វើឡើងដោយរដ្ឋាភិបាល ទីភ្នាក់ងារអនុវត្តច្បាប់ តុលាការ និងវិស័យសេវាសង្គម និងអ្នកពាក់ព័ន្ធទាំងឡាយ ដែលបំពេញការងារនៅក្នុងអង្គភាពទាំងនោះនៅតាមសហគមន៍ គ្រូបង្រៀន និងអ្នកថែទាំ និងថ្នាលបច្ចេកវិទ្យាឌីជីថល ព្រមទាំងអ្នកផ្តល់សេវា។ ចំណាត់ការទាំងនេះមានលក្ខណៈលម្អិតខ្លាំង ដែលមិនអាចបរិយាយនៅក្នុងសេចក្តីសង្ខេបបាន ប៉ុន្តែមាននៅក្នុងទំព័រ ១៤០ នៃរបាយការណ៍នេះ។

# វិធីសាស្ត្រនៃគម្រោងស្តីពីការបញ្ឈប់គ្រោះថ្នាក់

ដូចគ្នាជាមួយនឹងគ្រប់កន្លែងទាំងអស់ដែលកុមាររស់នៅ និងធំលូតលាស់ដែរ បរិយាកាសអនឡាញអាចធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យចំពោះការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ។ ទោះបីជាយ៉ាងណាក្តី កង្វះភស្តុតាងធ្វើឱ្យពិបាកក្នុងការយល់អំពីចរិតនៃគ្រោះថ្នាក់ដែលត្រូវបានបង្កឡើង ឬក្នុងការផ្តល់អនុសាសន៍បែបស្ថាបនា សម្រាប់អភិក្រមរបស់រដ្ឋាភិបាលចំពោះការទប់ស្កាត់ និងឆ្លើយតប។ ដោយទទួលបានភស្តុតាងពីការវាយតម្លៃអំពីការគំរាមកំហែង ដែលត្រូវបានធ្វើឡើងដោយសម្ព័ន្ធភាពសកល WeProtect នៅឆ្នាំ២០១៨ តាមរយៈគំនិតផ្តួចផ្តើមប្រព័ន្ធអនឡាញប្រកបដោយសុវត្ថិភាពរបស់ខ្លួន មូលនិធិដើម្បីបញ្ចប់អំពើហិង្សាលើកុមារបានសម្រេចចិត្តវិនិយោគលើការស្រាវជ្រាវ ដើម្បីពង្រឹងមូលដ្ឋានភស្តុតាង ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់ជាក់លាក់លើប្រទេសចំនួន ១៣ នៅអាហ្វ្រិកខាងកើត និងអាហ្វ្រិកខាងត្បូង និងអាស៊ីអាគ្នេយ៍។

ប្រទេសនានា ដែលទទួលបានផ្តោតការយកចិត្តទុកដាក់នៅតំបន់អាស៊ីអាគ្នេយ៍ គឺប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងវៀតណាម។ ប្រទេសនានាដែលទទួលបានផ្តោតការយកចិត្តទុកដាក់នៅតំបន់អាហ្វ្រិកខាងកើត និងអាហ្វ្រិកខាងត្បូង គឺ ប្រទេសអេត្យូពី កេនយ៉ា ម៉ូហ្សំប៊ិក ណាមីប៊ី អាហ្វ្រិកខាងត្បូង តង់ហ្សានី និងអ៊ូហ្គង់ដា។

អង្គការ ECPAT, នគរបាលអន្តរជាតិ (INTERPOL) និង ការិយាល័យស្រាវជ្រាវ Innocenti នៃអង្គការUNICEF បានធ្វើការរួមគ្នាដើម្បីអភិវឌ្ឍ និងអនុវត្តគម្រោងស្តីពីការបញ្ឈប់គ្រោះថ្នាក់។ ជារួម ស្ថាប័នទាំង៣នេះ បានប្រមូលទិន្នន័យសម្រាប់សកម្មភាពអង្កេតចំនួនប្រាំបួន ដាច់ដោយឡែកពីគ្នា។ ការប្រមូលទិន្នន័យយ៉ាងទូលំទូលាយសម្រាប់សកម្មភាពដោយឡែកទាំងប្រាំបួន បានធ្វើឡើងពីដើមឆ្នាំ២០២០ រហូតដល់ដើមឆ្នាំ២០២១ និងបានផ្តោតលើរយៈពេលបីឆ្នាំ ចាប់ពីឆ្នាំ២០១៧-២០១៩។ ក្នុងអំឡុងពេលនៃការវិភាគយ៉ាងទូលំទូលាយ ទិន្នន័យពីសកម្មភាពស្រាវជ្រាវទាំងអស់ត្រូវបានផ្ទៀងផ្ទាត់ពីប្រភពច្រើនផ្សេងៗគ្នា ហើយកម្រងនៃរបាយការណ៍ជាតិចំនួន១៣ត្រូវបានរៀបចំ។ ការវិភាគ សម្រាប់កម្ពុជាត្រូវបានបញ្ចប់នៅ ខែកញ្ញា ឆ្នាំ២០២១។

ក្រៅពីវិសាលភាព និងដោយអនុញ្ញាតឱ្យមានការប្រៀបធៀបតាមប្រទេស គម្រោងនេះក៏មានលក្ខណៈដោយឡែកផងដែរ ដោយសារវាប្រមូលផ្តុំអ្នកជំនាញជាក់លាក់ និងបំពេញឱ្យគ្នាទៅវិញទៅមកនៃបណ្តាញសកលចំនួនបី គឺ ECPAT នគរបាលអន្តរជាតិ និង UNICEF ។

លទ្ធផលជាទីចង់បាននៃរបាយការណ៍នេះ គឺដើម្បីផ្តល់ទិន្នន័យដើមគ្រា និងភស្តុតាង សម្រាប់អ្នករៀបចំគោលនយោបាយកម្ពុជាក្នុងការដោះស្រាយការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និងពង្រឹងការគាំទ្រដល់ជនរងគ្រោះ។ បន្ថែមលើនេះ របកគំហើញ និងអនុសាសន៍ត្រូវបានរំពឹងថា មានភាពពាក់ព័ន្ធសម្រាប់អ្នកធ្វើការពាក់ព័ន្ធថ្នាក់សកលកាន់តែទូលំទូលាយ។ អនុសាសន៍ ដែលត្រូវបានផ្តល់នៅក្នុងរបាយការណ៍នេះ គឺស្របជាមួយនឹងគំរូនៃការឆ្លើយតបជាតិនៃ WeProtect និងរួមចំណែកចំពោះរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

## សេចក្តីសង្ខេបនៃវិធីសាស្ត្រ ដែលត្រូវបានប្រើប្រាស់ដោយ ECPAT អន្តរជាតិ នៅកម្ពុជា

### ការសម្ភាសជាមួយមន្ត្រីមានភារកិច្ចមកពីជួររដ្ឋាភិបាល

ការសម្ភាសនានាត្រូវបានធ្វើឡើងនៅរវាងខែឧសភា និងខែមិថុនា ឆ្នាំ២០២០ ជាមួយនឹងមន្ត្រីមានភារកិច្ចជាន់ខ្ពស់នៅថ្នាក់ជាតិចំនួនប្រាំបួននាក់ ដែលមានអាណត្តិនានា ក្នុងនោះរួមបញ្ចូលទាំងអាណត្តិលើបញ្ហា OCSEA ផងដែរ។ ដោយសារការរាតត្បាតជំងឺកូវីដ ១៩ ការសម្ភាសមួយចំនួនត្រូវបានធ្វើឡើងនៅទល់មុខ

ដោយផ្ទាល់ និងមួយចំនួនទៀតត្រូវបានធ្វើឡើងពីចម្ងាយ។ ព័ត៌មានបន្ថែមស្តីពីវិធីសាស្ត្រមាននៅ ទីនេះ ចំណែកឯរបាយការណ៍បឋមអំពីទិន្នន័យនេះមាននៅ ទីនេះ។ ធាតុផ្សំនៃទិន្នន័យពីសកម្មភាពនេះមានលេខសម្គាល់ ដែលចាប់ផ្តើមពី RA១ នៅទូទាំងរបាយការណ៍នេះ។

* អ្នកចូលរួមតំណាងអោយ៖ ក្រសួងអប់រំ យុវជន និងកីឡា នគរបាលជាតិកម្ពុជានៃក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងព័ត៌មាន ក្រសួងយុត្តិធម៌និយ័តករទូរគមនាគមន៍កម្ពុជា និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

* ទម្រង់ RA១-CA-០១-A ត្រូវបានប្រើសម្រាប់លេខសម្គាល់។ 'RA១' បង្ហាញពីសកម្មភាពស្រាវជ្រាវ 'CA' តំណាងឱ្យប្រទេសកម្ពុជា '០១' គឺជាលេខសម្គាល់អ្នកចូលរួម ហើយ 'A' បង្ហាញពីអ្នកចូលរួមនៅពេលសម្ភាសន៍ដែលមានអ្នកចូលរួមច្រើនជាងម្នាក់។

## ការវិភាគទិន្នន័យមិនពាក់ព័ន្ធនឹងអ្នកអនុវត្តច្បាប់ និងការពិគ្រោះយោបល់

កម្រងនៃអ្នកពាក់ព័ន្ធដែលមិនមែនជាអ្នកអនុវត្តច្បាប់មានទិន្នន័យ និងការយល់ដឹងស៊ីជម្រៅអំពីចរិត និងទំហំនៃ OCSEA ។ ទិន្នន័យទទួលបានមកពី INHOPE មូលនិធិឃ្លាំមើលប្រព័ន្ធអ៊ីនធឺណិត និងបណ្តាញទូរស័ព្ទជំនួយកុមារអន្តរជាតិ (CHI)។ ការយល់ដឹងស៊ីជម្រៅបែបគុណភាព ត្រូវបានផ្តល់ដោយ ថ្នាលបច្ចេកវិទ្យាសកលមួយចំនួន។ នៅពេលពាក់ព័ន្ធព័ត៌មាននេះបំពេញបន្ថែមលើការវិភាគ ដែលចូលរួមចំណែកដោយនគរបាលអន្តរជាតិ។

## ការអង្កេតជាមួយអ្នកផ្តល់សេវាសង្គមជួរមុខ

សំណាកសមស្របនៃបុគ្គលិកជួរមុខនៅកម្ពុជាចំនួន ៥០នាក់ ដែលធ្វើការងារជាមួយអតិថិជន ដូចជា បុគ្គលិកធ្វើការងារជាមួយយុវជននៅតាមសហគមន៍ បុគ្គលិកសង្គម អ្នកគ្រប់គ្រងករណី អ្នកចិត្តសាស្ត្រ និងអ្នកវិជ្ជាជីវៈផ្នែកសុខភាព និងផ្នែកផ្លូវច្បាប់មួយចំនួន ដែលធ្វើការងារដោយផ្ទាល់ជាមួយករណីកុមារ បានចូលរួមនៅក្នុងការអង្កេតតាមប្រព័ន្ធអនឡាញនៅរវាងខែមីនា និងខែកក្កដា ឆ្នាំ២០២០។ សកម្មភាពស្រាវជ្រាវនេះមានបំណងស្វែងយល់អំពី វិសាលភាព និងបរិបទនៃ OCSEA ពីអ្នកទាំងឡាយ ដែលធ្វើការងារជួរមុខដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះបញ្ហានេះ។ ព័ត៌មានបន្ថែមអំពីវិធីសាស្ត្រមាននៅ ទីនេះ ចំណែកឯរបាយការណ៍សង្ខេបបឋមនៃទិន្នន័យនេះមាននៅ ទីនេះ។ ធាតុផ្សំនៃទិន្នន័យពីសកម្មភាពនេះមានលេខសម្គាល់ ដែលចាប់ផ្តើមពី RA៣ នៅទូទាំងរបាយការណ៍នេះ។

## ការសម្ភាសជាមួយជនរងគ្រោះនៃ OCSEA និងអ្នកថែទាំរបស់ពួកគេអំពីការទទួលបានយុត្តិធម៌

ការសម្ភាសចំនួនប្រាំមួយត្រូវបានធ្វើឡើងនៅរវាងខែមីនានិងខែសីហា ឆ្នាំ២០២០ជាមួយកុមារ (កុមារីបីនាក់និងកុមារាបីនាក់) ដែលមានអាយុរវាង១៧និង២៣ឆ្នាំដែលបានប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ចំពោះករណី OCSEA។ អ្នកថែទាំរបស់កុមារចំនួនបីនាក់ក៏ត្រូវបានសម្ភាសផងដែរ។ កុមារ និងអ្នកថែទាំបានសម្រេចចិត្តដោយខ្លួនឯងថា តើត្រូវផ្តល់ការសម្ភាសដោយឡែកពីគ្នា ឬរួមគ្នា។ សកម្មភាពស្រាវជ្រាវនេះមានបំណងផ្តល់ការយល់ដឹងកាន់តែច្បាស់អំពីរបៀប និងកម្រិតដែលកុមាររងគ្រោះនៃ OCSEA អាចទទួលបានយុត្តិធម៌ និងសំណងតាមផ្លូវច្បាប់នៅកម្ពុជា។ អ្នកចូលរួមមកពីរាជធានី-ខេត្តចំនួនពីរគឺខេត្តសៀមរាប និងភ្នំពេញ។

ការសម្ភាសទាំងអស់ត្រូវបានធ្វើឡើងទល់មុខគ្នា ដោយមានវត្តមានរបស់បុគ្គលិកសង្គមនៃអង្គការមិនមែនរដ្ឋាភិបាល។

គប្បីកត់សម្គាល់ថា ក្រុមស្រាវជ្រាវក្នុងប្រទេសបានទំនាក់ទំនងទៅកាន់អង្គការជាង ៤០ ដែលអាណត្តិរបស់ពួកគេនឹងអាចបង្ហាញនូវការផ្តល់ការគាំទ្រចំពោះកុមារដែលរងផលប៉ះពាល់ពី OCSEA ក្នុងគោលបំណងដើម្បីកំណត់សំណាកដែលអាចមាន។ ទោះបីជាយ៉ាងណាក្តី ការឆ្លើយតបជាផ្លូវការបានបង្ហាញថា ភាគច្រើននៃអង្គការទាំងនេះមិនធ្លាប់បានធ្វើការលើករណី OCSEAឡើយ។ ក្រុមស្រាវជ្រាវនេះបានកត់សម្គាល់នូវភាពខុសគ្នាចំពោះព័ត៌មាននេះដោយសារស្ទើរតែមួយភាគបីនៃបុគ្គលិកជួរមុខ ដែលបានចូលរួមនៅក្នុងការអង្កេតសម្រាប់គម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* បានបង្ហាញថា ពួកគេធ្លាប់បានធ្វើការងារជាមួយករណីពាក់ព័ន្ធនឹង OCSEA។ ទោះបីជាយ៉ាងណាក្តី ការមិនផ្តល់ការភ្ជាប់ទំនាក់ទំនងទៅកាន់ជនរងគ្រោះ និងអ្នកថែទាំមិនបង្ហាញកង្វះ ឬអវត្តមាននៃករណី OCSEA ដែលត្រូវបានដោះស្រាយដោយអង្គការទាំងនេះ ឬដែលកើតឡើងនៅកម្ពុជាឡើយ។ បញ្ហាប្រឈមដទៃទៀតនៅក្នុងការកំណត់រកកុមារ ដែលបានប្រើប្រាស់ប្រព័ន្ធយុត្តិធម៌សម្រាប់ករណីពាក់ព័ន្ធនឹង OCSEA គឺថា កុមារមានអាយុក្រោមលក្ខខណ្ឌវិនិច្ឆ័យនៃអាយុ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលមិនអាចស្វែងរក ឬទំនាក់ទំនងជាមួយកុមារដែលពួកគេបានធ្វើការងារជាមួយបាន ឬថា អ្នកថែទាំមិនចង់ឱ្យកូនរបស់ពួកគេចូលរួមនៅក្នុងការស្រាវជ្រាវនេះ។

ព័ត៌មានបន្ថែមអំពីវិធីសាស្ត្រមាននៅ ទីនេះ ចំណែកឯរបាយការណ៍សង្ខេបបឋមនៃទិន្នន័យនេះមាននៅ ទីនេះ។ ធាតុផ្សំនៃទិន្នន័យពីសកម្មភាពនេះមានលេខសម្គាល់ដែលចាប់ផ្តើមពី RA៤ នៅទូទាំងរបាយការណ៍នេះ"កុមារ"  ឬ "អ្នកថែទាំ"  ក៏ត្រូវបានបញ្ចូលនៅក្នុងលេខសម្គាល់ ដើម្បីបង្ហាញការសម្ភាសជាមួយកុមារ ឬអ្នកថែទាំផងដែរ។

## ការសម្ភាសជាមួយអ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌អំពីការទទួលបានយុត្តិធម៌

ការសម្ភាសជាមួយអ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌចំនួនដប់នាក់ ត្រូវបានធ្វើឡើងនៅរវាងខែមិថុនា និងខែតុលា ឆ្នាំ២០២០។ សំណាកនេះរួមមានអ្នកឆ្លើយតបមកពីជួររដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ដែលមានបទពិសោធន៍ជាមួយនឹងករណីព្រហ្មទណ្ឌ OCSEA។ព័ត៌មានបន្ថែមអំពីវិធីសាស្ត្រមាននៅ ទីនេះ ចំណែកឯរបាយការណ៍សង្ខេបបឋមនៃទិន្នន័យនេះមាននៅ ទីនេះ។ ធាតុផ្សំនៃទិន្នន័យពីអ្នកឆ្លើយតបទាំងនេះ

* បណ្តាញសកលដែលមាន Hotlines ជាសមាជិកចំនួន៤៦: INHOPE គាំទ្របណ្តាញក្នុងការប្រយុទ្ធប្រឆាំងនឹងសម្ភារៈរំលោភបំពានផ្លូវភេទកុមារ។ សម្រាប់ព័ត៌មានបន្ថែមសូមមើល៖ https://www.inhope.org/EN

* អង្គការដែលមានមូលដ្ឋាននៅចក្រភពអង់គ្លេស និងធ្វើការដើម្បីលុបចេញនូវមាតិការំលោភបំពានផ្លូវភេទកុមារតាមអ៊ីនធឺណិតដែលបង្ហោះនៅទីកន្លែងណាមួយក្នុងពិភពលោក។ សម្រាប់ព័ត៌មានបន្ថែមសូមមើល៖ https://www.iwf.org.uk/

* បណ្តាញទូរស័ព្ទជំនួយកុមារអន្តរជាតិប្រមូលចំណេះដឹង និងទិន្នន័យពីសមាជិកបណ្តាញជំនួយកុមារ ដៃគូ និងប្រភពខាងក្រៅ។ សម្រាប់ព័ត៌មានបន្ថែម សូមមើល៖ https://www.childhelplineinternational.org/about/

* ពាក្យថាជនរងគ្រោះនៃ OCSEA សំដៅលើតួនាទីរបស់ពួកគេជាជនរងគ្រោះនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

* អ្នកចូលរួមតំណាងឱ្យ៖ អង្គការលីកាដូ អង្គការ APLE កម្ពុជា អង្គភាពការពារកុមារកម្ពុជា អង្គការ Terre des Hommes ហូឡង់ អង្គការម្លប់តាប៉ាង អង្គការ Hagar កម្ពុជា សាលាដំបូងរាជធានីភ្នំពេញ។.

មានលេខសម្គាល់ដែលចាប់ផ្ដើមពី RA៥ នៅទូទាំងរបាយការណ៍នេះ។ សូមកត់សម្គាល់ថា ពាក្យខាងក្រោយថា "យុត្តិធម៌" ក៏ត្រូវបានបញ្ចូលនៅក្នុងលេខសម្គាល់នេះដើម្បីបង្ហាញការសម្ភាសជាមួយអ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌។

### ការពិនិត្យឯកសារសំណេរពីមុន និងការវិភាគផ្លូវច្បាប់

ការពិនិត្យឯកសារសំណេរពីមុនត្រូវបានធ្វើឡើង ដើម្បីផ្ដល់ជាភស្តុតាងដល់ក្រុមស្រាវជ្រាវនៅមុនពេលនៃការប្រមូលព័ត៌មានបឋម។ ការវិភាគគ្រប់ជ្រុងជ្រោយទៅលើច្បាប់ គោលនយោបាយ និងប្រព័ន្ធនានា ដែលឆ្លើយតបចំពោះ OCSEA នៅកម្ពុជាត្រូវធ្វើឡើង និងបញ្ចប់នៅខែមិថុនា ឆ្នាំ២០២០។ ព័ត៌មានបន្ថែមអំពីវិធីសាស្ត្រមាននៅ ទីនេះ ចំណែកឯរបាយការណ៍ពេញលេញស្ដីពីការវិភាគផ្លូវច្បាប់មាននៅ ទីនេះ។

### ការសន្ទនាជាមួយអ្នករស់រានមានជីវិតពី OCSEA

ការសន្ទនាមួយទល់មួយដោយគ្មានលក្ខណៈជារចនាសម្ព័ន្ធ ដែលដឹកនាំដោយអ្នកប្រតិបត្តិការងារឯកទេសដែលមានការយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត ត្រូវបានរៀបចំឡើងជាមួយអ្នករស់រានមានជីវិតក្មេងៗនៃ OCSEA ចំនួន ៣៣នាក់ នៅក្នុងប្រទេសចំនួនប្រាំដែលអនុវត្តគម្រោងស្ដីពីការបញ្ឈប់គ្រោះថ្នាក់ (កុមារីចំនួនប្រាំបួននាក់នៅប្រទេសកេនយ៉ា កុមារាចំនួនប្រាំនាក់ និងកុមារីចំនួនប្រាំពីរនាក់នៅប្រទេសកម្ពុជា កុមារីចំនួនប្រាំពីរនាក់នៅប្រទេសណាមីប៊ី កុមារីចំនួនបួននាក់នៅប្រទេសម៉ាឡេស៊ី និងកុមារាម្នាក់នៅប្រទេសអាហ្វ្រិកខាងត្បូង)។ ទោះបីជាមិនបានរៀបចំឡើងនៅក្នុងប្រទេសទាំងអស់ក្ដី ការសន្ទនាទាំងនេះ គឺដើម្បីគូសបញ្ជាក់នូវមាតិកា និងបញ្ហាទូទៅនៅក្នុងប្រទេសអនុវត្តគម្រោងស្ដីពីការបញ្ឈប់គ្រោះថ្នាក់ទាំង១៣។ អ្នកចូលរួមមានអាយុចន្លោះពី ១៦ និង ២៤ឆ្នាំ ប៉ុន្តែពួកគេសុទ្ធតែធ្លាប់ទទួលរង OCSEA នៅពេលពួកគេនៅជាកុមារ។ ការសន្ទនាជាមួយអ្នករស់រានមានជីវិតទាំងនេះត្រូវបានវិភាគរួមគ្នា សម្រាប់ប្រទេសទាំងអស់ ហើយមេរៀននានាត្រូវបានបង្កើតឡើងតាមរយៈរបាយការណ៍ប្រចាំប្រទេសទាំងអស់។ របាយការណ៍ប្រចាំប្រទេសកម្ពុជាបង្ហាញទិន្នន័យពីកិច្ចសន្ទនាជាមួយអ្នករស់រានមានជីវិតចំនួន ១២នាក់នៅកម្ពុជា។

ព័ត៌មានបន្ថែមអំពីវិធីសាស្ត្រមាននៅ ទីនេះ។ របាយការណ៍ដែលបង្ហាញអំពី ការវិភាគលើការសន្ទនាជាមួយ ឧត្តរជីវីចំនួន៣៣នាក់ នឹងត្រូវបញ្ចេញដោយឡែកនៅចុងឆ្នាំ២០២១។ ធាតុផ្សំនៃទិន្នន័យពីសកម្មភាពនេះមានលេខសម្គាល់ ដែលចាប់ផ្ដើមពី RA៥ នៅទូទាំងរបាយការណ៍នេះ។

## សេចក្ដីសង្ខេបនៃវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់នៅកម្ពុជាដោយនគរបាលអន្តរជាតិ

### ការវិភាគទិន្នន័យករណីបែបបរិមាណ

ទិន្នន័យស្ដីពីករណីពាក់ព័ន្ធនឹង OCSEA ត្រូវបានស្វែងរកពីអាជ្ញាធរអនុវត្តច្បាប់ តាមរយៈការិយាល័យកណ្ដាលជាតិនៃនគរបាលអន្តរជាតិនៅក្នុងប្រទេសនីមួយៗ។ ទិន្នន័យក៏ទទួលបានមកពីរបាយការណ៍ជាកាតព្វកិច្ចនៃក្រុមហ៊ុនបច្ចេកវិទ្យាដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិកជូនដល់ NCMEC និងពីអង្គការដៃគូដទៃមួយចំនួនទៀតផងដែរ ដើម្បីស្វែងយល់កាន់តែស៊ីជម្រៅអំពីបទល្មើសពាក់ព័ន្ធដែលត្រូវបានប្រព្រឹត្តនៅក្នុងប្រទេស អាកប្បកិរិយារបស់ជនល្មើស និងជនរងគ្រោះ កត្តាដែលបង្កលក្ខណៈនៃបទល្មើស និងភាពងាយរងគ្រោះ។ ទិន្នន័យអំពីបទល្មើសសម្រាប់កម្ពុជានៅរយៈពេលបីឆ្នាំ ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ មិនត្រូវបានអង្គភាពអនុវត្តច្បាប់ជាតិនៅកម្ពុជាបានផ្ដល់ឱ្យឡើយ។

### ការវាយតម្លៃសមត្ថភាពបែបគុណភាព

បន្ថែមលើការស្វែងរកទិន្នន័យអំពីករណី OCSEA នគរបាលអន្តរជាតិបានស្នើសុំទិន្នន័យអំពីសមត្ថភាពរបស់អាជ្ញាធរអនុវត្តច្បាប់ជាតិ ក្នុងការឆ្លើយតបចំពោះបទល្មើសប្រភេទនេះ និងបានសម្ភាសជាមួយមន្ត្រីបម្រើការងារការសង្កត់ធ្ងន់ត្រូវបានផ្ដោតទៅលើធនធានមនុស្ស ការទទួលបានបរិក្ខារឯកទេស និងការបណ្ដុះបណ្ដាល នីតិវិធីស៊ើបអង្កេតការប្រើប្រាស់ឧបករណ៍សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិសមិទ្ធផល និងបញ្ហាប្រឈមនានា។ ធាតុផ្សំនៃទិន្នន័យពីសកម្មភាពនេះមានលេខសម្គាល់ ដែលចាប់ផ្ដើមជាមួយនឹង RA៨ នៅទូទាំងរបាយការណ៍នេះ។

ព័ត៌មានបន្ថែមអំពីវិធីសាស្ត្ររបស់នគរបាលអន្តរជាតិមាននៅ ទីនេះ។

## សេចក្ដីសង្ខេបនៃវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់នៅកម្ពុជា ដោយការិយាល័យស្រាវជ្រាវរបស់ UNICEF - Innocenti

### ការអង្កេតតាមខ្នងផ្ទះរបស់កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងអ្នកថែទាំរបស់ពួកគេ

ដើម្បីស្វែងយល់អំពីការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតរបស់កុមារ ហានិភ័យ និងឱកាសដែលពួកគេប្រឈមមុខនៅតាមប្រព័ន្ធអនឡាញ ជាពិសេស OCSEA ការអង្កេតតាមខ្នងផ្ទះដែលតំណាងឱ្យប្រទេសត្រូវបានធ្វើឡើងដោយផ្ទាល់ជាមួយកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ចំនួន

* ពាក្យថា អ្នកនៅរស់រានមានជីវិតនៃ OCSEA សំដៅលើកុមារដែលរងគ្រោះ ប៉ុន្តែប្រហែលជាមិនត្រូវបានសម្គាល់ថាជាជនរងគ្រោះបន្តទៀតទេ ដោយសារពួកគេកំពុងស្ថិតក្នុងដំណើរនៃការជាសះស្បើយ។

៩៩២នាក់។ ក្រុមប្រជាជនគោលដៅសម្រាប់ការអង្កេតនេះ គឺកុមារអាយុ ១២-១៧ឆ្នាំនៅកម្ពុជា ដែលបានប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត នៅក្នុងរយៈពេលបីខែមុន។ បន្ថែមលើនេះ ឪពុក ឬម្ដាយ ឬអ្នកថែទាំម្នាក់របស់កុមារម្នាក់ត្រូវបានសម្ភាស។ ពាក្យ"ការអង្កេតតាមខ្នងផ្ទះ" ត្រូវបានប្រើប្រាស់នៅទូទាំងរបាយការណ៍នេះ ដើម្បីបង្ហាញរបកគំហើញនានាដែលបានមកពីសកម្មភាពស្រាវជ្រាវជាក់លាក់នេះ។ សំណាកនៃការអង្កេតដែលត្រូវបានស្ទង់មតិ គឺមានកុមារា ចំនួន៥១៨នាក់ (៥២%) និងកុមារីចំនួន៤៧៤នាក់ (៤៨%)។ ការបែងចែកអាយុមានដូចជា កុមារ ៣១១នាក់ (៣១%)អាយុពី១២ដល់១៣ឆ្នាំ កុមារ ៣៣៩នាក់ (៣៤%) អាយុពី១៤ដល់១៥ឆ្នាំ និងកុមារ ៣៤២នាក់ (៣៥%) អាយុ១៦ដល់១៧ឆ្នាំ។

ដើម្បីសម្រេចបាននូវសំណាកដែលត្រូវជ្រើសរើសដោយចៃដន្យតំណាងប្រទេស ការអង្កេតនេះបានប្រើប្រាស់ការកំណត់សំណាកប្រូបាប៊ីលីតេដោយចៃដន្យជាមួយនឹងការគ្របដណ្ដប់នៅទូទាំងប្រទេស។ នៅកម្ពុជា អត្រានៃការគ្របដណ្ដប់នៃការងារតាមមូលដ្ឋាន គឺ ១00% ។ ការគ្របដណ្ដប់ត្រូវបានកំណត់ជាសមាមាត្រនៃចំនួនប្រជាជនសរុប ដែលមានឱកាសមួយនៃការបញ្ចូលនៅក្នុងសំណាកសម្រាប់ការអង្កេតនេះ ដែលមានន័យថា ការងារតាមមូលដ្ឋាននឹងគ្របដណ្ដប់លើតំបន់ដែលពួកគេរស់នៅ ប្រសិនបើ ត្រូវបានកំណត់ជាសំណាក។

ការកំណត់សំណាកបានអនុវត្តតាមការរចនាសំណាកចង្កោមប្រូបាប៊ីលីតេដោយចៃដន្យជាបីដំណាក់កាល ក្នុងការជ្រើសរើសឯកតាសំណាកបឋម (PSUs) ចំនួន ១00។ ឯកតាសំណាកបឋម (PSUs) ត្រូវបានកំណត់នៅកម្ពុជា គឺភូមិ១ (ប្រជាជនចំនួន ១0៩0)។ បញ្ជី PSU (សំណាកគំរូ) ផ្អែកលើគំរូនៃការអង្កេតប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គមឆ្នាំ២0១៧ដែលត្រូវបានផ្ដល់ដោយវិទ្យាស្ថានជាតិស្ថិតិ។ ជាដំណាក់កាលដំបូងប្រហែល៣0%នៃខេត្តក្នុងប្រទេសបានយកគំរូ មុនពេលដែលឯកតាសំណាកបឋម (PSUs)។ ហេតុផលសម្រាប់ការរួមបញ្ចូលដំណាក់កាលនេះគឺដើម្បីផ្ដល់គំរូដែលមានលក្ខណៈជាចង្កោម មានន័យថា ការងារតាមមូលដ្ឋានគឺអាស្រ័យទៅលើតែខេត្តដែលត្រូវបានជ្រើសរើសប៉ុណ្ណោះ។ ចំនួននៃ PSUs ដែលត្រូវបានយកជាគំរូតាមខេត្តដែលបានជ្រើសរើសបានបែងចែកតាមសមាមាត្រដោយផ្អែកលើចំនួនសរុបនៃ PSUs សម្រាប់ខេត្ត។ ចំនួននៃ PSUs ដែលត្រូវការគឺត្រូវបានជ្រើសរើសសំណាកតាមប្រព័ន្ធប្រូបាប៊ីលីតេដោយចៃដន្យសមាមាត្រទៅនឹងទំហំ (PPS)។ នីតិវិធីនេះប្រាកដថា ការបែងចែកតាមកម្រិតនៃទីប្រជុំជនអាចសម្រេចបានគ្របដណ្ដប់ទូទាំងប្រទេស។

ឯកតាសំណាកបឋម (PSUs)នីមួយៗ អ្នកសម្ភាសបានជ្រើសរើសអាសយដ្ឋាននៅក្នុងមូលដ្ឋាន ដោយប្រើប្រាស់នៅនីតិវិធីដើរដោយចៃដន្យ និងព្យាយាមទាក់ទងនៅអាសយដ្ឋានដែលត្រូវបានជ្រើសរើស ដើម្បីជ្រើសរើសសមាជិកនៃប្រជាជនដែលត្រូវអង្កេត ដោយប្រើប្រាស់សំណួរជ្រើសរើស ដែលត្រូវបានរៀបចំឡើង សម្រាប់គោលបំណងនេះ។ កុមារម្នាក់ និងអ្នកថែទាំម្នាក់ត្រូវបានជ្រើសរើសនៅក្នុងគ្រួសារដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដោយប្រើប្រាស់វិធីសាស្ត្រជ្រើសរើសដោយចៃដន្យ។

នៅក្នុងគ្រប់ខ្នងផ្ទះដែលបានចុះទៅដល់ ទិន្នន័យត្រូវបានប្រមូលអំពីចំនួនយេនឌ័រ និងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនៅរយៈពេលបីខែមុនរបស់កុមារអាយុ១២-១៧ឆ្នាំនៅក្នុងខ្នងផ្ទះនេះ។ ការធ្វើបែបនេះអនុញ្ញាតឱ្យ យើងប៉ាន់ប្រមាណលើអត្រានៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតសម្រាប់កុមារអាយុ១២-១៧ឆ្នាំទាំងអស់នៅកម្ពុជា។

ការងារតាមមូលដ្ឋានបានកើតឡើងនៅរវាងថ្ងៃទី១១ ខែតុលា និងថ្ងៃ៣១ ខែធ្នូ ឆ្នាំ២0២0។ ការប្រមូលទិន្នន័យត្រូវបានសម្របសម្រួលដោយ Ipsos MORI និងត្រូវបានប្រតិបត្តិដោយ Indochina Research Ltd ដែលជាដៃគូនៅក្នុងប្រទេសរបស់ Ipsos ជំនួសឱ្យការិយាល័យស្រាវជ្រាវរបស់ UNICEF-Innocenti។

ការពន្យល់លម្អិតអំពីអភិក្រមវិធីសាស្ត្រ និងវិធីសាស្ត្រជាក់លាក់ ដែលត្រូវបានប្រើប្រាស់ សម្រាប់ការវិភាគទិន្នន័យនៃការអង្កេតតាមខ្នងផ្ទះនេះ មាននៅ ទីនេះ។

## ការអនុម័តក្រមសីលធម៌

សមាសធាតុស្រាវជ្រាវនៃ UNICEF-Innocenti និងECPATអន្តរជាតិ ត្រូវបានពិនិត្យដោយក្រុមប្រឹក្សាត្រួតពិនិត្យស្ថាប័ននៃមន្ទីរពិសោធន៍ប្រព័ន្ធផ្សព្វផ្សាយសុខភាព (HML)។ បន្ថែមលើនេះ សមាសធាតុស្រាវជ្រាវនៃ UNICEF-Innocenti ត្រូវបានពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងក្រសួងមហាផ្ទៃ។ សមាសធាតុស្រាវជ្រាវរបស់ ECPAT ត្រូវបានពិនិត្យ និងអនុម័តដោយគណៈកម្មាធិការជាតិក្រមសីលធម៌សម្រាប់ការស្រាវជ្រាវសុខភាពដែលទាក់ទងនឹងមនុស្ស។

នគរបាលអន្តរជាតិបានវាយតម្លៃទាំងលើការគំរាមកំហែងនៃ OCSEA និងសមត្ថភាពរបស់អាជ្ញាធរអនុវត្តច្បាប់ក្នុងការប្រយុទ្ធប្រឆាំងនឹងការគំរាមកំហែងនេះ។ ការវាយតម្លៃទាំងពីរនេះពាក់ព័ន្ធនឹងការសម្ភាសជាមួយមន្ត្រីអនុវត្តច្បាប់នៅក្នុងអង្គភាពពាក់ព័ន្ធដែលដោះស្រាយបទល្មើសនេះ និងអង្គភាពនគរបាលពាក់ព័ន្ធ និងទីភ្នាក់ងារជាតិ ដែលចាត់ចែងលើទិន្នន័យរបស់នគរបាល។ នគរបាលអន្តរជាតិមិនមានទំនាក់ទំនងជាមួយកុមារ ឬជនរងគ្រោះឡើយ។ ទោះបីជាយ៉ាងណាក្ដី ដើម្បីធានានូវការប្រព្រឹត្ត និងបទដ្ឋានស្រាវជ្រាវប្រកប ដោយក្រមសីលធម៌ ក្រុមការងារនៃនគរបាលអន្តរជាតិ បានបញ្ចប់វគ្គអនឡាញស្ដី ពីការធ្វើការស្រាវជ្រាវប្រកបដោយទំនួលខុសត្រូវ ដែលត្រូវបានផ្ដល់ដោយគំនិតផ្ដួចផ្ដើមការបណ្ដុះបណ្ដាលស្ថាប័នបែបសហការគ្នា។ បន្ថែមលើនេះ សកម្មភាពស្រាវជ្រាវទាំងអស់ត្រូវបានអនុវត្ត ដោយអនុលោមទៅតាមក្រមប្រតិបត្តិរបស់នគរបាលអន្តរជាតិ។

## ការពិគ្រោះយោបល់ជាតិ

តាមរយៈដំណើរការរៀបចំសេចក្ដីព្រាងរបាយការណ៍ស្ដីពីការបញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា ក្រុមស្រាវជ្រាវបានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារបច្ចេកទេសអន្តរក្រសួង OCSE នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ ការពិនិត្យយ៉ាងលំអិតលើពង្រាងរបាយការណ៍ដោយក្រុមការងារបច្ចេកទេសអន្តរក្រសួង OCSE ត្រូវបានធ្វើឡើងនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ នៅខេត្តកំពត។

រូបភាពទី ១៖ វិធីសាស្ត្រនៃគម្រោងស្ដីពី*ការបញ្ឈប់គ្រោះថ្នាក់*នៅកម្ពុជា។



# អំពីការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ

*ការរំលោភបំពានផ្លូវភេទកុមារ*សំដៅដល់សកម្មភាពផ្លូវភេទផ្សេងៗ ដែលត្រូវបានប្រព្រឹត្តទៅលើកុមារ (ជនមានអាយុក្រោម ១៨ឆ្នាំ) ដោយមិនគិតថា កុមារដឹងថាអ្វីដែលកំពុងកើតឡើងចំពោះពួកគេមិនមែនរឿងធម្មតា និងមិនអាចទទួលយកបាន ឬអត់ឡើយ។ អំពើនេះអាចត្រូវបានប្រព្រឹត្តដោយមនុស្សពេញវ័យ ឬមិត្តភក្តិ និងជាទូទៅ ពាក់ព័ន្ធនឹងបុគ្គលម្នាក់ ឬក្រុមមួយ ដែលទាញប្រយោជន៍ពីអតុល្យភាពអំណាច។ អំពើនេះអាចត្រូវបានប្រព្រឹត្តដោយគ្មានការបង្ខំដែលបង្ហាញច្បាស់ ដោយជាញឹកញាប់ ជនល្មើលប្រើប្រាស់សិទ្ធិ អំណាច ការបំភាន់ច្រលំ ឬការបោកប្រាស់។

*ការកេងប្រវ័ញ្ចផ្លូវភេទកុមារ*ពាក់ព័ន្ធនឹងសកម្មភាពរំលោភបំពានដូចគ្នា។ ប៉ុន្តែត្រូវតែមានធាតុផ្សំបន្ថែមពាក់ព័ន្ធនឹងការគំរាមកំហែង ឬការផ្លោះប្តូរជាមួយអ្វីមួយ (ឧទា. លុយកាក់ ជម្រក របស់របរជាសម្ភារ របស់របរមិនមែនជាសម្ភារ ដូចជា ការការពារ ឬទំនាក់ទំនង) ឬសូម្បីតែការគ្រាន់តែសន្យាចំពោះការផ្លោះប្តូរបែបនោះក្តី។

**ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (OCSEA)**
សំដៅទៅដល់ស្ថានភាពនានា ដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថល *អ៊ីនធឺណិត និងបច្ចេកវិទ្យាទំនាក់ទំនង* ដែលកើតឡើងពេលណាមួយនៅក្នុងអំឡុងពេលនៃការបន្តការរំលោភបំពាន ឬការកេងប្រវ័ញ្ច។ OCSEA អាចកើតឡើងទាំងស្រុងនៅតាមប្រព័ន្ធអនឡាញ ឬតាមការបញ្ចូលគ្នានៃទំនាក់ទំនងទាំងតាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់ រវាងជនល្មើស និងកុមារ។

ការកំណត់ថាការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារថា នៅតាម "ប្រព័ន្ធអនឡាញ" ឬ "ក្រៅប្រព័ន្ធអនឡាញ (Offline)" ទាំងស្រុងមិនជួយយើងក្នុងការស្វែងយល់ ទប់ស្កាត់ ឬឆ្លើយតបចំពោះបញ្ហានេះឡើយ និងមិនមែនជាចេតនានៃគម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* ដើម្បីបង្កើតការបែងចែកបែបសិប្បនិមិត្តបែបនេះឡើយ។ កុមារអាចរងការរំលោភបំពាន ឬការកេងប្រវ័ញ្ច នៅពេលដែលពួកគេចំណាយពេលនៅក្នុងបរិយាកាសឌីជីថល ប៉ុន្តែដូចគ្នានេះដែរ ជនល្មើសអាចប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីសម្របសម្រួលសកម្មភាពរបស់ពួកគេ ឧទា. រក្សាទុក និងចែកចាយរូបភាពនៃការកេងប្រវ័ញ្ច និងការរំលោភបំពាន ដោយផ្ទាល់ ឬដើម្បីលួងលោមកុមារឱ្យជួបទល់មុខគ្នាផ្ទាល់។

គម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* ក៏ផ្តោតលើរបៀបដែលបច្ចេកវិទ្យាត្រូវបានប្រើប្រាស់ដើម្បី*សម្របសម្រួល* ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារ និងរួមចំណែកជាភស្តុតាងចាំបាច់ ដើម្បីស្វែងយល់ពីតួនាទីរបស់បច្ចេកវិទ្យានៅក្នុងការប្រព្រឹត្តអំពើហិង្សាផ្លូវភេទលើកុមារផងដែរ។

ការពណ៌នាអំពីចរិតលក្ខណៈណាមួយនៃ OCSEA ត្រូវតែទទួលស្គាល់ថា ព្រំដែនរវាងអាកប្បកិរិយា និងសកម្មភាពនៅក្នុង និងក្រៅប្រព័ន្ធអនឡាញ មានលក្ខណៈស្រពិចស្រពិលកាន់តែខ្លាំង និងការឆ្លើយតបនានាចាំបាច់ត្រូវពិចារណាលើវិសាលភាពទាំងមូលនៃសកម្មភាពនានា ដែលអាចមានការចូលរួមរបស់បច្ចេកវិទ្យាឌីជីថល។ ការពណ៌នាអំពីចរិតលក្ខណៈនេះមានសារសំខាន់ជាពិសេសដែលត្រូវចងចាំ ដោយសារកុមារមើលឃើញកាន់តែច្រើនថា ពិភពនៅក្នុង និងក្រៅប្រព័ន្ធអនឡាញរបស់ពួកគេ ជាពិភពប្រទាក់ក្រឡាគ្នា និងកើតឡើងក្នុងពេលដំណាលគ្នា។

សម្រាប់គម្រោងស្តីពី*ការបញ្ឈប់គ្រោះថ្នាក់* OCSEA ត្រូវបានកំណត់និយមន័យយ៉ាងជាក់លាក់ ដើម្បីបញ្ចូលការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទដែលពាក់ព័ន្ធនឹង៖

- ការផលិត ការកាន់កាប់ ឬការចែកចាយ**រូបភាព-សម្ភាររំលោភបំពានផ្លូវភេទលើកុមារ (CSAM)**៖ រូបថត វីដេអូ សម្លេង ឬការថតចម្លងដទៃទៀត ឬការតំណាងដទៃទៀតនៃរូបភាពរំលោភបំពានផ្លូវភេទកុមារ ឬផ្នែកភេទរបស់កុមារជាក់ស្តែង ឬត្រូវបានប្រឌិតឡើងដោយបច្ចេកវិទ្យាឌីជីថល ក្នុងគោលបំណងបឋមសម្រាប់ការកេងប្រវ័ញ្ច។
- **ការផ្សាយផ្ទាល់នៃអំពើរំលោភបំពានផ្លូវភេទលើកុមារ៖** ការរំលោភបំពានផ្លូវភេទកុមារ ដែលត្រូវបានប្រព្រឹត្ត និងទស្សនាក្នុងពេលដំណាលគ្នា តាមរយៈឧបករណ៍ទំនាក់ទំនង ឧបករណ៍សន្និសិទជាវីដេអូ និង/ឬកម្មវិធីជជែកគ្នា។ ក្នុងករណីភាគច្រើន ជនបទល្មើសដែលស្នើសុំសកម្មភាពរំលោភបំពានជាថ្នូរនឹងការផ្តល់លុយកាក់ ឬផលប្រយោជន៍ជាសម្ភារដទៃទៀត ស្ថិតនៅទីតាំងខុសគ្នាពីកុមារ និងអ្នកសម្របសម្រួលការរំលោភបំពាន។

- **ការលួងលោមកុមារតាមប្រព័ន្ធអនឡាញសម្រាប់គោលបំណងផ្លូវភេទ៖** ការទំនាក់ទំនងជាមួយកុមារ តាមរយៈបច្ចេកវិទ្យា ដោយមានចេតនារំលោភបំពាន ឬកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ បើទោះបីជាលិខិតុបករណ៍ផ្លូវច្បាប់អន្តរជាតិ ដែលកំណត់ជាបទល្មើសចំពោះការលួងលោមបង្ហាញថា អំពើនេះត្រូវតែកើតឡើងដោយមានចេតនាជួបជាមួយកុមារផ្ទាល់ក្តី វាកាន់តែមានលក្ខណៈទូទៅយ៉ាងខ្លាំងដែលជនរំលោភបំពានផ្លូវភេទលើកុមារ ជាឧទាហរណ៍ បោកបញ្ឆោតឱ្យពួកគេថតរូបភាព CSAM ដោយខ្លួនឯង និងចែកចាយតាមរយៈបច្ចេកវិទ្យាឌីជីថល ដោយមិនចាំបាច់មានចេតនាជួប និងរំលោភបំពានពួកគេដោយផ្ទាល់ឡើយ។

វ័ញ្ច និងការរំលោភបំពាផ្លូវភេទលើកុមារ ដែលត្រូវសិក្សាដោយគម្រោងស្តីពី*ការបញ្ឈប់គ្រោះថ្នាក់*។

របាយការណ៍នៃគម្រោងស្តីពី*ការបញ្ឈប់គ្រោះថ្នាក់* ក៏ដោះស្រាយបាតុភូតដទៃទៀត ដែលរួមចំណែកចំពោះការយល់ដឹងអំពីបរិបទ និងបរិយាកាសវប្បធម៌សង្គម ដែល OCSEA កើតឡើងផងដែរ។

- **ការចែកចាយមាតិកាផ្លូវភេទដែលត្រូវបានបង្កើតដោយខ្លួនឯងពាក់ព័ន្ធនឹងកុមារ** អាចនាំទៅរក ឬអាចជាផ្នែកមួយនៃ OCSEA ទោះបីជាមាតិកានេះដំបូងឡើយត្រូវបានផលិតឡើង និងចែកចាយរវាងអ្នកស្គាល់គ្នាក្តី  ដោយសារវាអាចត្រូវបានបញ្ជូនបន្តដោយគ្មានការអនុញ្ញាត ឬត្រូវទទួលបានតាមរយៈការបោកប្រាស់ ឬការបង្ខិតបង្ខំ។
- **ការគំរាមកំហែងខាងផ្លូវភេទលើកុមារ** សំដៅដល់ការគំរាមទាមទារ ឬការគំរាមកំហែង ដើម្បីទទួលបានមាតិកាផ្លូវភេទ ឬផលប្រយោជន៍ដទៃទៀត (ឧទា. លុយកាក់) ពីកុមារ ដែលជាញឹកញាប់ ដោយប្រើប្រាស់មាតិកាផ្លូវភេទរបស់កុមារដែលទទួលបានពីមុនមក ជាឥទ្ធិពល។

- **ការបៀតបៀនផ្លូវភេទកុមារ និងការបង្ហាញមាតិកាផ្លូវភេទដែលមិនចង់បានទៅដល់កុមារ** ពាក់ព័ន្ធនឹងបាតុភូតដទៃទៀត ដែល*អាច*តំណាងឱ្យ ឬបង្កលក្ខណៈឱ្យមាន OCSEA ក្នុងករណីខ្លះ។ ឧទាហរណ៍ ជនល្មើសអាចមានចេតនាបង្ហាញមាតិកាផ្លូវភេទដល់កុមារ ដែលជាផ្នែកមួយនៃការលួងលោមឱ្យពួកគេមើលឃើញសកម្មភាពផ្លូវភេទ។ ទោះបីជាយ៉ាងណាក្តី សម្រាប់គោលបំណងនៃការរៀបចំគោលនយោបាយ និងកម្មវិធីផ្អែកលើភស្តុតាង វាជាការចាំបាច់ ដែលត្រូវទទួលស្គាល់ថា មានភាពខុសគ្នារវាងការមើលមាតិកាដោយស្ម័គ្រចិត្តពីសំណាក់កុមារ និងការមើលដោយការបង្ខំ ឬការបង្ខិតបង្ខំ។ ការមើលដោយស្ម័គ្រចិត្តមិនត្រូវបានញូលនៅក្នុងនិយមន័យនៃ OCSEA ដែលត្រូវបានប្រើប្រាស់នៅក្នុងការសិក្សានៃគម្រោងស្តីពី*ការបញ្ឈប់គ្រោះថ្នាក់*ឡើយ។

រូបភាព ២៖ ការកំណត់ទម្រង់សំខាន់ៗនៃការកេងប្រវ័ញ្ច និងការរំលោភបំពាផ្លូវភេទលើកុមារ ដែលត្រូវសិក្សាដោយគម្រោងស្តីពីការបញ្ឈប់គ្រោះថ្នាក់។




* ឧបករណ៍គតិយុត្តអន្តរជាតិចំនួនពីរដែលចែងពីកាតព្វកិច្ចក្នុងការចាត់ជាបទល្មើសនូវអំពើលួងលោមកុមារសម្រាប់គោលបំណងផ្លូវភេទរួមមាន៖ Council of Europe. (២០០៧). Convention on the Protection of Children against Sexual Exploitation and Sexual Abuse. Council of Europe Treaty Series – No. ២០១. Article ២៣; and European Parliament and Council. (២០១១). Directive ២០១១/៩២/EU on combating the sexual abuse and sexual exploitation of children and child pornography, and replacing Council Framework Decision ២០០៤/៦៨/JHA. Article ៦.

# ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត

ថ្វីបើមានការតភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត កាន់តែច្រើននៅជុំវិញពិភពលោកក្តី ប្រទេសមួយចំនួនតូចធ្វើបច្ចុប្បន្នភាពអំពីស្ថិតិនៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ផ្លូវការជាប្រចាំ ឬបំបែកស្ថិតិសម្រាប់ប្រជាជនជាកុមាររបស់ពួកគេ។ ចំណុចនេះបង្ហាញនូវបញ្ហាប្រឈមមួយនៅក្នុងការស្វែងយល់អំពីរបៀបដែលជីវិតរបស់យុវជនរងផលប៉ះពាល់ពីបច្ចេកវិទ្យាឌីជីថល ជាពិសេសនៅក្នុងបណ្តាប្រទេសប្រាក់ចំណូលទាប និងមធ្យម។ ក្រាហ្វិកព័ត៌មានខាងក្រោមសង្ខេបនូវទិន្នន័យចុងក្រោយគេដែលមានអំពីការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមនៅកម្ពុជា ទិន្នន័យនេះមួយចំនួនត្រូវបានប្រមូលដោយផ្ទាល់តាមរយៈការអង្កេតតាមខ្នងផ្ទះប្រចាំប្រទេសអំពីការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត របស់កុមារអាយុ ១២-១៧ឆ្នាំ នៃគម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់*។

ទិន្នន័យខាងក្រោមផ្តល់នូវស្ថានភាពទូទៅយ៉ាងសំខាន់ សម្រាប់ការស្វែងយល់អំពីលក្ខណៈខុសៗគ្នានៃការប្រើប្រាស់អ៊ីនធឺណិតរបស់កុមារ។ ទោះបីជាយ៉ាងណាក្តី គប្បីចងចាំអំពីដែនកំណត់ផ្នែកវិធីសាស្ត្រដែលមានឥទ្ធិពលលើគុណភាពទិន្នន័យ សម្រាប់ប្រភពទិន្នន័យទីពីរមួយចំនួន។ ការពឹងផ្អែកលើបច្ចេកទេសកំណត់សំណាកទៅតាមគោលបំណង ឬបច្ចេកទេសកំណត់សំណាកមិនមានលក្ខណៈប្រូបាប៊ីលីតេដទៃទៀត មានន័យថា ទិន្នន័យមិនអាចត្រូវចាត់ទុកថា មានលក្ខណៈតំណាងឱ្យប្រជាជន ដែលកំពុងសិក្សាឡើយ។ នៅក្នុងករណីដទៃទៀត ភាពខុសគ្នានៅក្នុងវិធីសាស្ត្រប្រមូលទិន្នន័យ និងនិយមន័យនៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត បង្កបញ្ហាប្រឈមសម្រាប់ការប្រៀបធៀបទៅតាមប្រទេស។

ទិន្នន័យរបស់ប្រទេស (ឆ្នាំ២០១៩)៖

ទិន្នន័យរបស់ប្រទេស

១៦.៥២៤.០០០នាក់

ទិន្នន័យរបស់សហប្រជាជាតិ (ឆ្នាំ២០២០)៖

១៦.៧១៩.០០០នាក់

ទិន្នន័យរបស់ប្រទេស (ឆ្នាំ២០១៩)៖

ទិន្នន័យរបស់ប្រទេស

៧.៨៦៩.៩១២នាក់

ទិន្នន័យរបស់សហប្រជាជាតិ (ឆ្នាំ២០២០)

៨.៥៥៧.០០០នាក់

ទិន្នន័យរបស់ប្រទេស (ឆ្នាំ២០១៩)៖

ទិន្នន័យរបស់ប្រទេស

៧.៤១៨.៥៧៧

ទិន្នន័យរបស់សហប្រជាជាតិ (ឆ្នាំ២០២០)

៨.១៦២.០០០

ប្រជាជនអាយុក្រោម ១៨ (ឆ្នាំ២០២០)

ទិន្នន័យរបស់សហប្រជាជាតិ

៦.០៥១.០០០




ប្រជាជននៅតាមទីក្រុង ឆ្នាំ២០១៨៖ ២៣%

ការព្យាករណ៍សម្រាប់ឆ្នាំ២០៣០៖ ២៩%




អាយុជាមធ្យម

(ឆ្នាំ)២០២០

២៦ឆ្នាំ

ការប៉ាន់ស្មានសម្រាប់ឆ្នាំ

GDP សម្រាប់មនុស្សម្នាក់

(ដុល្លារអាមេរិក)

១.៦៤៣

# អំពីកម្ពុជា ប្រជាសាស្ត្រ និងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត

## អត្រាភាពក្រីក្រ

ផលធៀបនៃការរាប់ចំនួនភាពក្រីក្រនៅបន្ទាត់ភាពក្រីក្រជាតិ

(% នៃប្រជាជន)




## ភាសា

ភាសាខ្មែរ

## អត្រានៃកំណើនការលក់ដែលត្រូវបានរាយការណ៍ ការចុះឈ្មោះប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត (ឆ្នាំ២០១៨) ៤០,៥%




ទិន្នន័យនៃគម្រោងស្ដីពីការបញ្ឈប់គ្រោះថ្នាក់

## អត្រានៃកំណើនការលក់ប្រព័ន្ធអ៊ីនធឺណិតនៅក្នុងចំណោមកុមារ

៨១%

ចំនួន ២,៤៣៩ខ្នងផ្ទះ។

ចំនួនអ្នកថែទាំរបស់កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ៩៩២នាក់

ទិន្នន័យនៃគម្រោងស្ដីពីការបញ្ឈប់គ្រោះថ្នាក់

## អត្រានៃកំណើនការលក់ប្រព័ន្ធអ៊ីនធឺណិត នៅក្នុងចំណោមកុមារអាយុ ១២-១៧ឆ្នាំ




ចំនួន ២,៤៣៩ខ្នងផ្ទះ។

ទិន្នន័យនៃគម្រោងស្ដីពីការបញ្ឈប់គ្រោះថ្នាក់

## ឧបករណ៍ពេញនិយមជាងគេ សម្រាប់ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនៅក្នុងចំណោមកុមារអាយុ ១២-១៧ឆ្នាំ




ចំនួនកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ៩៩២នាក់

*សំណួរពហុជម្រើស

# អំពីកម្ពុជា ប្រជាសាស្ត្រ និងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត

## កន្លែងពេញនិយមជាងគេ សម្រាប់ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត នៅក្នុងចំណោមកុមារអាយុ ១២-១៧ឆ្នាំ

ចំនួនកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ៩៩២នាក់




ចំនួនកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ៩៩២នាក់

*សំណួរពហុជម្រើស

## ភាពញឹកញាប់នៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត នៅក្នុងចំណោមកុមារអាយុ ១២-១៧ឆ្នាំ

ចំនួនកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ៩៩២នាក់




ចំនួនអ្នកថែទាំរបស់កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ៩៩២នាក់

ចំនួនកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ៩៩២នាក់

## ភាពញឹកញាប់នៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត នៅក្នុងចំណោមអ្នកថែទាំ




ចំនួនអ្នកថែទាំរបស់កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ៩៩២នាក់

# អំពីកម្ពុជា ប្រជាសាស្ត្រ និងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត

## កុមារដែលប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមជារៀងរាល់សប្តាហ៍

ចំនួនកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ៩៩២នាក់




ចំនួនកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ៩៩២នាក់

## កុមារដែលប្រើប្រាស់ការផ្ញើសារខ្លីៗជារៀងរាល់សប្តាហ៍

ចំនួនកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ៩៩២នាក់




ចំនួនកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ៩៩២នាក់

## ចំណាត់ថ្នាក់សន្ទស្សន៍នៃការអភិវឌ្ឍ ICT (ITU) ឆ្នាំ២០១៧




## ការវាយតម្លៃសន្ទស្សន៍សន្តិសុខបច្ចេកវិទ្យា




* Global Cybersecurity Index វាស់វែងការប្តេជ្ញាចិត្តរបស់ប្រទេសនានាចំពោះសន្តិសុខអ៊ីនធឺណិតដោយផ្អែកលើការអនុវត្តឧបករណ៍ច្បាប់ និងកម្រិតនៃវិធានការបច្ចេកទេស និងស្ថាប័នដែលបានធ្វើឡើង ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងសន្តិសុខអ៊ីនធឺណិត។

# និន្នាការទូទៅនៃច្បាប់ និងគោលនយោបាយ

ការវិភាគផ្លូវច្បាប់ដែលត្រូវបានធ្វើឡើងសម្រាប់គម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* បានរកឃើញថា ច្បាប់ពាក់ព័ន្ធបំផុតនៃច្បាប់កម្ពុជាស្តីពីការកេងប្រវ័ញ្ចផ្លូវភេទទូទៅ ដែលក៏រាប់បញ្ចូលបទល្មើស OCSEA ផងដែរ គឺនៅឆ្នាំ២០០៧ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ បន្ថែមលើនេះ ក្រមព្រហ្មទណ្ឌកំណត់ជាបទល្មើស ចំពោះបទល្មើសជាក់លាក់ពាក់ព័ន្ធនឹង OCSEA ។

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទចែងអំពីនិយមន័យនៅមានកម្រិតអំពីរូបភាព សម្ភាររំលោភបំពានផ្លូវភេទកុមារ (CSAM) និងកំណត់ជាបទល្មើសចំពោះការប្រព្រឹត្តជាក់លាក់ពាក់ព័ន្ធជាមួយនឹងសម្ភារបែបនេះ។ គប្បីកត់សម្គាល់ថា ច្បាប់នេះក៏ហាមឃាត់ការចែកចាយ ការកាន់កាប់ និងការ

ផលិតក្នុងចេតនាចែកចាយរូបភាព ឬវីដេអូអាសអាភាស (រួមទាំងសម្ភារអាសអាភាស ដែលបង្ហាញពីមនុស្សពេញវ័យផងដែរ)។

ក្រមព្រហ្មទណ្ឌក៏មានបទប្បញ្ញត្តិ ដែលកំណត់ការបៀតបៀនផ្លូវភេទជាបទល្មើសផងដែរ ទោះបីជាយ៉ាងណា ក្តី មិនមានលក្ខណៈជាក់លាក់ចំពោះប្រព័ន្ធអនឡាញ និងការប្រព្រឹត្តទៅលើកុមារឡើយ។ ការផ្តន្ទាទោសចំពោះបទល្មើសនេះ (ការជាប់ពន្ធនាគារពីប្រាំមួយថ្ងៃដល់បីខែ និងការពិន័យជាប្រាក់ពី ១០.០០០រៀលទៅ ៥០០.០០០រៀល ប្រហែល ២,៥០ដុល្លារអាមេរិក និង១២៥ដុល្លារអាមេរិក) មិនឆ្លុះបញ្ចាំងនូវចរិតយ៉ាងធ្ងន់ធ្ងរនៃបទល្មើសនេះឡើយ ជាពិសេស នៅពេលដែលត្រូវបានប្រព្រឹត្តទៅលើកុមារ។

ទោះបីជាយ៉ាងណាច្បាប់កម្ពុជាមិនបានកំណត់ជាបទល្មើសយ៉ាងច្បាស់ចំពោះការលួងលោមកុមារតាមប្រព័ន្ធអនឡាញក្នុងគោលបំណងផ្លូវភេទថាជាបទល្មើសដោយឡែកឡើយក្រមព្រហ្មទណ្ឌពិតជាកំណត់ជាបទល្មើសចំពោះ "ការរៀបចំរបស់មនុស្សពេញវ័យ ដើម្បីឱ្យមានការជួបគ្នាដោយផ្ទាល់ ដែលពាក់ព័ន្ធនឹងការជួបជុំបែបមិនសមរម្យ ឬទំនាក់ទំនងផ្លូវភេទ ដែលអនីតិជនមានវត្តមាន ឬចូលរួម។"

ជាសំខាន់ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងក្រមព្រហ្មទណ្ឌមិនកំណត់ជាបទល្មើសយ៉ាងច្បាស់ចំពោះការគំរាមកំហែងក្នុងគោលបំណងពាក់ព័ន្ធនឹងផ្លូវភេទ និងការផ្សាយបន្តផ្ទាល់អំពីការរំលោភបំពានផ្លូវភេទកុមារឡើយ។

អ្នកតំណាងម្នាក់មកពីក្រសួងមហាផ្ទៃ ពោលគឺនគរបាលជាតិកម្ពុជា (RA១-CA-០៣-A) បានបង្ហាញឱ្យឃើញថា គ្មានសេចក្តីត្រូវការឱ្យមានច្បាប់ថ្មីៗឡើយ ដោយសារពួកគេជឿជាក់ថា ច្បាប់ដែលមានស្រាប់ គឺគ្រប់គ្រាន់ហើយ ដែលនេះបង្ហាញថា បញ្ហាប្រឈមធំបំផុត គឺការអនុវត្តច្បាប់ដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាព។ ចំណុចនេះត្រូវបានអះអាងដោយអ្នកតំណាងមកពីក្រសួងកិច្ចការនារី ដែលបានកត់សម្គាល់ថា៖ ច្បាប់របស់យើងអាចមានភាពខ្វះចន្លោះមួយចំនួន ដោយសារនេះគឺជាបញ្ហាថ្មី ហើយច្បាប់យើងចាស់ហើយ។ នៅពេលបច្ចុប្បន្ន ក្រសួងយុត្តិធម៌កំពុងធ្វើការងារលើការពិនិត្យច្បាប់ឡើងវិញក្នុងសេចក្តីសង្ឃឹមធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ និងក្រមរដ្ឋប្បវេណី។ លើសពីនេះ មនុស្សមួយចំនួន សូម្បីតែមន្ត្រីរដ្ឋាភិបាលមួយចំនួន រមែងតែងមិនយកចិត្តទុកដាក់គ្រប់គ្រាន់ចំពោះច្បាប់ទាំងនេះនៅឡើយផងដែរ។ (RA១-CA-០៥-A)

នៅពេលបច្ចុប្បន្ន រដ្ឋាភិបាលកម្ពុជាកំពុងពិនិត្យសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា ដែលត្រូវបានផ្តួចផ្តើមឡើងនៅឆ្នាំ២០១២ ច្បាប់នេះនឹងកំណត់និយមន័យកាន់តែគ្រប់ជ្រុងជ្រោយអំពី CSAM និងកំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះបទល្មើសពាក់ព័ន្ធនឹង CSAM ដែលត្រូវបានប្រព្រឹត្តនៅតាមប្រព័ន្ធអនឡាញ និង/ឬការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ ឬឧបករណ៍ឌីជីថលដទៃទៀត។

ពាក់ព័ន្ធនឹងលទ្ធភាពអនុវត្តនៃបទប្បញ្ញត្តិច្បាប់ ដែលកំណត់ OCSEA ជាបទល្មើស ក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ពង្រីកយុត្តាធិការរបស់តុលាការទៅដល់បទល្មើសនានា ដែលអាចផ្តន្ទាទោសបាននៅក្រោមអំពើ ដែលត្រូវបានប្រព្រឹត្តដោយពលរដ្ឋកម្ពុជានៅបរទេស ឬនៅពេលជនរងគ្រោះ គឺជាពលរដ្ឋកម្ពុជា។ ទោះបីជាយ៉ាងណាក្តី សម្រាប់បទល្មើសពាក់ព័ន្ធនឹង OCSEA ដែលមាននៅក្នុងក្រមព្រហ្មទណ្ឌ យុត្តាធិការក្រៅដែនដីនេះអាចអនុវត្តចំពោះតែក្នុងករណីដែលអំពើបែបនេះរួមផ្សំជាបទល្មើសនៅក្នុងទាំងប្រទេសកម្ពុជា និងប្រទេសមួយ ដែលអំពើនេះត្រូវបានប្រព្រឹត្តបុណ្ណោះ (គោលការណ៍នៃទ្វេពិរុធភាព)។

គោលនយោបាយចម្បងពាក់ព័ន្ធ OCSEA នៅកម្ពុជា គឺផែនការសកម្មភាពដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា ឆ្នាំ២០២១-២០២៥។ ផែនការសកម្មភាពនេះត្រូវបានប្រកាសឱ្យអនុវត្តនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ និងមានអាទិភាពជាយុទ្ធសាស្ត្រចំនួនប្រាំមួយ ដែលផ្តោតលើវិស័យនានា ដូចជា គោលនយោបាយ និងអភិបាលកិច្ច ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ការស្តារនីតិសម្បទាជនរងគ្រោះនៃ OCSEA និងការលើកកម្ពស់ការយល់ដឹងអំពី OCSEA។

មានគោលនយោបាយចំនួនពីរដទៃទៀតនៅកម្ពុជា ដែលមានសកម្មភាពពាក់ព័ន្ធនឹង OCSEA ។ ទីមួយ ផែនការសកម្មភាពដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ ដែលមានសកម្មភាពនានាពាក់ព័ន្ធនឹង OCSEA ដូចជា កម្មវិធីអប់រំ យុទ្ធសាស្ត្រប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនង ឬការពង្រឹងក្របខណ្ឌច្បាប់។ អ្នកតំណាងម្នាក់មកពីក្រសួងកិច្ចការនារី បានកត់សម្គាល់ថា ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិមិនត្រូវបានធ្វើឡើងឡើយ (RA១-CA-០៥-A)។

ទីពីរ គោលនយោបាយអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ឆ្នាំ២០១៦-២០២០ ដែលមានគោលដៅមួយ ដើម្បីកែលម្អសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញត្រឹមឆ្នាំ២០២០។ អ្នកតំណាងពីរដ្ឋាភិបាលដែលត្រូវបានសម្ភាស បានរៀបរាប់ថា បញ្ហាប្រឈមធំបំផុតចំពោះការអនុវត្តផែនការសកម្មភាពនេះ គឺថវិការបស់រដ្ឋាភិបាលនៅមានកម្រិត ហេតុនេះ ការគាំទ្រហិរញ្ញវត្ថុពីអង្គការដៃគូ គឺជាវិធីតែមួយគត់ ដែលអាចធ្វើកិច្ចការនានាបាន។ ការស្រាវជ្រាវដែលត្រូវបានធ្វើជាផ្នែកមួយនៃគម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* បានរកឃើញថា មិនមែនមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ទាំងអស់បានដឹងអំពី ផែនការសកម្មភាពរយៈពេលប្រាំឆ្នាំនេះឡើយ ហើយអ្នកតំណាងម្នាក់នៃនិយ័តករទូរគមនាគមន៍កម្ពុជាបានថ្លែងថា៖ *"ខ្ញុំមិនដឹងអំពីផែនការសកម្មភាពនេះឡើយហើយខ្ញុំក៏មិនបានទទួលព័ត៌មានណាមួយអំពីស្ថានភាពនៃការអនុវត្តនិងលទ្ធផលរបស់វាឡើយ។"* (RA១-CA-០៩-A) បើទោះបីជាមិនមានការវាយតម្លៃក្តី អ្នកតំណាងម្នាក់មកពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានកត់សម្គាល់ថា *"ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានអនុវត្តសកម្មភាពជាច្រើន ដូចមានចែងនៅក្នុងផែនការនេះ ដោយយកចិត្តទុកដាក់យ៉ាងជាក់លាក់លើការផ្តល់សេវា ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្ត ដែលធ្វើឡើងដោយក្រសួងនេះ។"* (RA១-CA-១០-A)

ពាក់ព័ន្ធនឹងការអនុវត្តផែនការអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ឆ្នាំ២០១៦-២០២០ នាយកនៃសន្តិសុខព័ត៌មានបានកត់សម្គាល់ថា គោលដៅក្នុងការពង្រឹងសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញត្រឹមឆ្នាំ២០២០ មិនទាន់សម្រេចបាននៅឡើយ៖ *"ខ្ញុំសង្ស័យថា ផែនការនេះអាចត្រូវពន្យារការអនុវត្ត ដោយសារយើងមិនទាន់សម្រេចបានគោលដៅនៅឡើយទេ។ ហេតុនេះ វាចាំបាច់ត្រូវពន្យារការអនុវត្ត។"* (RA១-CA-០៤-A)

# ១. កុមារនៅតាមប្រព័ន្ធអនឡាញនៅកម្ពុជា

ការផ្ដោតចម្បងនៃរបាយការណ៍ស្ដីពី *ការបញ្ឈប់គ្រោះថ្នាក់* គឺដើម្បីបង្ហាញនូវការយល់ឃើញរបស់យុវជន និងអ្នកមានភារកិច្ចអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារ ដែលត្រូវបានសម្របសម្រួល ឬប្រព្រឹត្តតាមរយៈបច្ចេកវិទ្យាឌីជីថល។ ដើម្បីយល់កាន់តែច្បាស់អំពី បទល្មើសពាក់ព័ន្ធនឹង OCSEA នៅកម្ពុជា ការដាក់បទល្មើសទាំងនេះឱ្យស្ថិតនៅក្នុងបរិបទកាន់តែទូលំទូលាយនៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត របស់កុមារ គឺជាការចាំបាច់។ ហេតុនេះ ជំពូកដំបូងនេះបង្ហាញពីទិដ្ឋភាពទូទៅសង្ខេបអំពីការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងសកម្មភាពដែលកុមារភាគច្រើនចូលចិត្តធ្វើតាមអនឡាញ ហើយបន្ទាប់មក ពណ៌នាអំពីការកើតឡើងនូវសកម្មភាពអនឡាញដែលកាន់តែមានហានិភ័យ និងការយល់ឃើញរបស់កុមារ និងអ្នកថែទាំរបស់ពួកគេអំពីហានិភ័យទាំងនេះ។

# ១.១ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងឧបសគ្គ

### ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត

ទិន្នន័យសំណាកពីការអង្កេតតាមខ្នងផ្ទះនៃគម្រោងស្ដីពី*ការបញ្ឈប់គ្រោះ*ថ្នាក់ទៅលើកុមារអាយុ ១២-១៧ឆ្នាំ (ចំនួន ២៤៣៩នាក់) បង្ហាញថា ៨១%នៃកុមារនៅកម្ពុជា គឺជាអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត។ ភាគរយនៃអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត បានកើនឡើងទៅតាមអាយុពី ៧២% នៅក្នុងចំណោមកុមារអាយុ ១២-១៣ឆ្នាំ ទៅ ៨៤% នៅក្នុងចំណោមកុមារអាយុ ១៤-១៥ឆ្នាំ និង ៩១% នៅក្នុងចំណោមកុមារអាយុ ១៦-១៧ឆ្នាំ។ គ្មានការសង្កេតឃើញអំពី ភាពខុសគ្នាចំពោះយេនឌ័រ ឬទីតាំង (ទីក្រុង/ទីជនបទ) នៅក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតឡើយ។

### ភាពញឹកញាប់នៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត

នៅក្នុងសំណាកបឋមនៃកុមារអាយុ ១២-១៧ឆ្នាំដែលកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា (ចំនួន ៩៩២នាក់) ៧៧% នៃពួកគេប្រើប្រាស់ប្រព័ន្ធអនឡាញយ៉ាងហោចណាស់ម្ដងក្នុងមួយថ្ងៃ។ ស្រដៀងគ្នានឹងប្រទេសភាគច្រើននៅជុំវិញពិភពលោកដែរ កុមារធំៗទំនងប្រើប្រាស់ប្រព័ន្ធនេះញឹកញាប់ជាងកុមារតូចៗ។ គ្មានការសង្កេតឃើញភាពខុសគ្នាផ្នែកយេនឌ័រនៅក្នុងភាពញឹកញាប់នៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ឡើយ (សូមមើលតារាង ៣)។ កុមារកំពុងរស់នៅតាមតំបន់ទីក្រុង (៨២%) ប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ញឹកញាប់ជាងកុមារនៅតាមតំបន់ជនបទ (៧៤%)។

### ការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិតរបស់អ្នកថែទាំ

នៅក្នុងចំណោមអ្នកថែទាំដែលបានចូលរួមនៅក្នុងការអង្កេត ៤២% នៃពួកគេបានរាយការណ៍អំពី ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ជារៀងរាល់ថ្ងៃ។ អ្នកថែទាំដែលមានអាយុ ៥០ឆ្នាំ និងខ្ពស់ជាងនេះ មិនទំនងជាអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ដូចអ្នកថែទាំ ដែលនៅវ័យក្មេងជាងនេះឡើយ។ អ្នកថែទាំជាស្ត្រីក៏ប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតមិនសូវញឹកញាប់ដូចអ្នកថែទាំជាបុរសផងដែរ។ ដោយសារអ្នកថែទាំជាច្រើននៅកម្ពុជាមានបទពិសោធន៍ប្រើប្រាស់ប្រព័ន្ធអនឡាញ (៦១%) វាគឺជាឱកាសមួយ ដែលអ្នកថែទាំអាចដើរតួនាទីយ៉ាងសំខាន់នៅក្នុងការដឹកនាំការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត របស់កូនពួកគេ។ ទោះបីជាយ៉ាងណាក្ដី ៣៩% នៃអ្នកថែទាំដែលបានចូលរួមនៅក្នុងការអង្កេតមិនដែលបានប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ឡើយ។

### ឧបករណ៍សម្រាប់ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត

ដូចគ្នានៅក្នុងប្រទេសភាគច្រើនដទៃទៀតដែរ ទូរស័ព្ទវៃឆ្លាត គឺជាឧបករណ៍ពេញនិយមបំផុត ដែលត្រូវបានប្រើប្រាស់ដោយកុមារអាយុ ១២-១៧ឆ្នាំ ដើម្បីចូលក្នុងប្រព័ន្ធអនឡាញ ទំនងជាដោយសារឧបករណ៍នេះមានតម្លៃទាប និងភាពអាចយកតាមខ្លួនបាន។ នៅកម្ពុជា កុមារដែលបានចូលរួមនៅក្នុងការអង្កេតស្ទើរតែទាំងអស់ (៩៩%) បានរាយការណ៍អំពី ការប្រើប្រាស់ទូរស័ព្ទវៃឆ្លាត ដើម្បីចូលក្នុងប្រព័ន្ធអនឡាញ។ កុមារតែ ២% ប៉ុណ្ណោះ ដែលរាយការណ៍អំពីការប្រើប្រាស់កុំព្យូទ័រ ស្របពេលដែលគ្មានកុមារណាម្នាក់ ដែលបានរាយការណ៍អំពីការប្រើប្រាស់ថេបប្លេត ឬឧបករណ៍ឌីជីថលដទៃទៀតឡើយ។ ក្នុងចំណោមកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ដែលប្រើប្រាស់ទូរស័ព្ទដៃ ពួកគេចំនួន ៤១% ចែកចាយឧបករណ៍នេះជាមួយនរណាម្នាក់ផ្សេងទៀត។ ភាគច្រើន ទូរស័ព្ទដៃត្រូវបានចែកចាយជាមួយអ្នកថែទាំ (៣៣%) បន្ទាប់មក បងប្អូនបង្កើត (១២%) និងមិត្តភក្តិ (២%)។ ការចែកចាយទូរស័ព្ទដៃមានកម្រិតខ្ពស់នៅក្នុងចំណោមកុមារអាយុ ១២-១៣ឆ្នាំ (៦៤%) ធៀបនឹងកុមារអាយុ ១៤-១៥ឆ្នាំ (៤៣%) និងកុមារអាយុ ១៦-១៧ឆ្នាំ (២០%)។ ការចែកចាយទូរស័ព្ទដៃមានកម្រិតទូទៅខ្ពស់បន្តិចចំពោះកុមារី (៤៣%) ធៀបនឹងកុមារា (៣៩%)។

### កន្លែងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត

ដូចការសង្កេតនៅក្នុងប្រទេសដទៃទៀត នៅកម្ពុជា កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ភាគច្រើន (៩១%) ប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ពីផ្ទះ ហើយពួកគេចំនួន ៧៩% ប្រើប្រាស់ជារៀងរាល់ថ្ងៃ។ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត នៅសាលារៀនត្រូវបានរាយការណ៍ដោយកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ដែលបានចូលរួមនៅក្នុងការអង្កេតនេះចំនួន ៣៣% តួលេខទាបនេះអាចដោយសារការបិទសាលារៀនពាក់ព័ន្ធនឹងជំងឺកូវីដ ១៩ នៅកម្ពុជា។ កុមារចំនួនតិចតួច (១៤%) បានប្រើប្រាស់អ៊ីនធឺណិត កាហ្វេ និងផ្សារទំនើបធំៗ (៨%)

* ខណៈពេលកំពុងជ្រើសរើសសំណាកដោយចៃដន្យដើម្បីកំណត់រកកុមារដែលមានសិទ្ធិចូលរួមក្នុងការស្ទង់មតិជាចម្បង យើងក៏បានប្រមូលទិន្នន័យពីគ្រប់ខ្នងផ្ទះដែលបានសាកសួរអំពីចំនួនកុមារស្ថិតក្នុងចន្លោះអាយុ ១២-១៧ឆ្នាំ ដែលរស់នៅទីនោះ ភេទ អាយុរបស់ពួកគេ និងថាតើពួកគេបានប្រើអ៊ីនធឺណិតក្នុងរយៈពេលបីខែកន្លងមកដែរឬទេ។ ការធ្វើដូច្នេះអនុញ្ញាតឱ្យយើងប៉ាន់ប្រមាណពីអត្រានៃការប្រើប្រាស់អ៊ីនធឺណិតរបស់កុមារអាយុ ១២-១៧ឆ្នាំ ទាំងអស់នៅក្នុងប្រទេសកម្ពុជា។ n = ២៤៣៩ គ្រួសារ។.

* សំណួរប្រើដើម្បីកំណត់ថាតើកុមារអាយុ ១២-១៧ឆ្នាំ ជាអ្នកប្រើប្រាស់អ៊ីនធឺណិតដែរឬទេ៖ តើ [បុគ្គល] បានប្រើអ៊ីនធឺណិតក្នុងរយៈពេលបីខែចុងក្រោយនេះដែរឬទេ? វាអាចរួមទាំងការប្រើប្រាស់ទូរសព្ទដៃ ថេប្លេត ឬកុំព្យូទ័រ ដើម្បីផ្ញើ ឬទទួលសារ ប្រើកម្មវិធីដូចជា Facebook WhatsApp Instagram ផ្ញើអ៊ីមែល រុករកលើអ៊ីនធឺណិត ជជែកជាមួយមិត្តភក្តិ និងក្រុមគ្រួសារ ដាក់ចូល ឬទាញយកឯកសារ ឬអ្វីផ្សេងទៀតដែលគេធ្វើនៅលើអ៊ីនធឺណិតជាធម្មតា។

## ១.១ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងឧបសគ្គ

ដើម្បីចូលក្នុងប្រព័ន្ធអនឡាញ។ សែសិបភាគរយនៃកុមារបាននិយាយ ថា ពួកគេចូលក្នុងប្រព័ន្ធអនឡាញពីកន្លែងដទៃទៀត។ តួលេខនេះអាចឆ្លុះបញ្ចាំងនូវទីកន្លែងនានា ដែលត្រូវបានចាប់យកនៅក្នុងការអង្កេតតាមខ្នងផ្ទះ ដូចជា នៅតាមផ្លូវ ផ្ទះរបស់មិត្តភក្តិ ឬសួនច្បារ។

### ឧបសគ្គចំពោះការទទួលបាន និងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត

កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត នៅកម្ពុជាចំនួនរហូតដល់ ៨៧% ប្រឈមមុខនឹងឧបសគ្គនានានៅក្នុងការទទួលបានប្រព័ន្ធអ៊ីនធឺណិត (សូមមើលតារាង៥)។ ល្បឿនយឺត ឬសេវាខ្សោយនៅកន្លែងពួកគេរស់នៅត្រូវបានលើកឡើងជាទូទៅបំផុតថាជាឧបសគ្គ ដោយកុមារចំនួនរហូតដល់ ៥០% រាយការណ៍ថា ឧបសគ្គនេះបានរារាំងពួកគេពីការប្រើប្រាស់ប្រព័ន្ធអនឡាញ នៅពេលពួកគេចង់ ឬត្រូវការប្រើប្រាស់។

ឧបសគ្គនេះមានឥទ្ធិពលលើកុមារធំៗ (១៤-១៧ឆ្នាំ) និងកុមាររស់នៅតាមតំបន់ជនបទក្នុងកម្រិតសមាមាត្រកាន់តែខ្ពស់។ ការរិតត្បិតរបស់ឪពុកម្តាយចំពោះការប្រើប្រាស់ប្រព័ន្ធអនឡាញត្រូវលើកឡើងថាជាឧបសគ្គទូទៅទីពីរ សម្រាប់ការប្រើប្រាស់ប្រព័ន្ធអនឡាញរបស់កុមារជាពិសេស កុមារអាយុ ១២-១៣ឆ្នាំ និងកុមារា។ តម្លៃខ្ពស់របស់ទិន្នន័យ និងប្រព័ន្ធអ៊ីនធឺណិត និងការចែករំលែកឧបករណ៍ជាមួយអ្នកដទៃទៀត គឺជាឧបសគ្គគួរឱ្យកត់សម្គាល់ដទៃទៀតដែលកុមារបានកំណត់ជាពិសេសកុមារអាយុ ១២-១៣ឆ្នាំ។ ចំណុចនេះមានសង្គតភាពជាមួយនឹងទិន្នន័យនៃការអង្កេតរបស់គម្រោងស្តីពី*ការបញ្ឈប់គ្រោះថ្នាក់* អំពី ការចែករំលែកទូរស័ព្ទដៃ ដែលមានកម្រិតខ្ពស់បំផុតនៅក្នុងចំណោមកុមារអាយុ ១២-១៣ឆ្នាំ (៦៤%) និងធ្លាក់ចុះគួរឱ្យកត់សម្គាល់នៅក្នុងចំណោមកុមារអាយុ ១៤-១៥ឆ្នាំ (៤៣%) និង ១៦-១៧ឆ្នាំ (២០%)។

តារាង ៣៖ ភាពញឹកញាប់នៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត របស់កុមារ




មូលដ្ឋាន៖ កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំនៅកម្ពុជា។ ចំនួន ៩៩២នាក់។

## ១.១ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងឧបសគ្គ

តារាង ៤៖ ភាពញឹកញាប់នៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត របស់អ្នកថែទាំ




មូលដ្ឋាន៖ អ្នកថែទាំរបស់កុមារអាយុ១២-១៧ឆ្នាំកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា។ ចំនួន៩៩២នាក់។

## ១.១ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងឧបសគ្គ

តារាង ៥៖ ឧបសគ្គចំពោះការទទួលបានប្រព័ន្ធអ៊ីនធឺណិត សម្រាប់កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ។




មូលដ្ឋាន៖ កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំនៅកម្ពុជា។ ចំនួន ៩៩២នាក់។

> តណភ្ជាប់អ៊ីនធឺណិតយឺត ឬសញ្ញាខ្សោយគឺជាឧបសគ្គ ដ៏ទូទៅបំផុតត្រូវបានលើកឡើង ដែលរារាំងកុមារមិន ឱ្យប្រើអ៊ីនធឺណិត។ ការដាក់កំហិតដោយមាតាបិតា គឺជាឧបសគ្គដែលត្រូវបានលើកឡើងជាទូទៅបន្ទាប់ ជាពិសេសដោយកុមារក្នុងចន្លោះអាយុ ១២-១៣ឆ្នាំ។

## ១.២ សកម្មភាពអនឡាញរបស់កុមារ

សកម្មភាពអនឡាញ ពេញនិយមបំផុត នៅក្នុងចំណោមកុមារ ដែលបានចូលរួមការអង្កេតនៅកម្ពុជា គឺ សកម្មភាពកំសាន្ត ដូចជា ការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម (៧៩%) និងការមើលវីដេអូ (៧៩%) បន្ទាប់មក គឺការប្រើប្រាស់សារខ្លីៗ (៥១%) និងការជជែកជាមួយគ្រួសារ និងមិត្តភក្តិ ដែលរស់នៅឆ្ងាយ (៥០%)។ ជាទូទៅ កុមារអាយុ ១៤-១៧ឆ្នាំបានចូលរួមនៅក្នុងសកម្មភាពអនឡាញច្រើនជាងកុមារអាយុ ១២-១៣ឆ្នាំ។ ដូចគ្នានឹងប្រទេសដទៃទៀតដែរ ការលេងហ្គេមអនឡាញមានលក្ខណៈជាទូទៅនៅក្នុងចំណោមកុមារា (៦៦%) ច្រើនជាងកុមារី (១៦%)។ កុមារីទំនងជាប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម និងការផ្ញើសារខ្លី និងប្រើប្រាស់ប្រព័ន្ធអនឡាញសម្រាប់កិច្ចការសាលារៀនច្រើនជាងកុមារា។ គប្បីពិចារណាថា ប្រភេទទាំងនេះមិនមានលក្ខណៈដាច់ពីគ្នាឡើយ ឧទាហរណ៍ កុមារអាចប្រើប្រាស់ប្រព័ន្ធអនឡាញ ដើម្បីមើលវីដេអូជាផ្នែកមួយនៃកិច្ចការសាលារៀនរបស់ពួកគេ។ ទោះបីជាយ៉ាងណាក្តី តារាង៦ ខាងក្រោមផ្តល់នូវការយល់ដឹងកាន់តែទូលំទូលាយអំពីរបៀបនៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត របស់កុមារអាយុ ១២-១៧ឆ្នាំនៅកម្ពុជា និងសកម្មភាពភាពដែលពួកគេរីករាយក្នុងការធ្វើ។

តារាង ៦៖ សកម្មភាពដែលកុមារចូលរួមនៅក្នុងប្រព័ន្ធអនឡាញយ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍។

| សកម្មភាព | សរុប | ១២-១៣ឆ្នាំ | ១៤-១៥ឆ្នាំ | ១៦-១៧ឆ្នាំ | កុមារា | កុមារី |
|---|---|---|---|---|---|---|
| ប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម | ៧៩% | ៧១% | ៨០% | ៨៦% | ៧៧% | ៨២% |
| មើលវីដេអូ | ៧៩% | ៧៣% | ៧៧% | ៨៦% | ៧៩% | ៧៩% |
| ប្រើប្រាស់សារខ្លីៗ | ៥១% | ៣៤% | ៥១% | ៦៦% | ៤៦% | ៥៦% |
| និយាយជាមួយគ្រួសារ ឬមិត្តភក្តិដែលរស់នៅឆ្ងាយ | ៥០% | ៤៣% | ៤៧% | ៥៩% | ៤៦% | ៥៤% |
| មើលការផ្សាយបន្តផ្ទាល់ | ៤៨% | ៤២% | ៤៧% | ៥៧% | ៥១% | ៤៦% |
| លេងហ្គេមអនឡាញ | ៤២% | ៤០% | ៤៣% | ៤២% | ៦៦% | ១៦% |
| កិច្ចការសាលារៀន | ៣៩% | ២៨% | ៤២% | ៤៨% | ៣៤% | ៤៥% |
| ស្រាវជ្រាវរកព័ត៌មានថ្មីៗ | ៣២% | ២១% | ៣២% | ៤៣% | ៣១% | ៣៤% |
| ស្វែងរកសារព័ត៌មាន | ៣០% | ២១% | ២៧% | ៤២% | ៣៥% | ២៥% |
| តាមដានតារាល្បីៗ និងបុគ្គលសាធារណៈនៅលើបណ្តាញទំនាក់ទំនងសង្គម | ២៩% | ២៤% | ២៨% | ៣៥% | ២៩% | ៣០% |
| ស្វែងរកព័ត៌មានអំពីឱកាសការងារ ឬអប់រំ | ២២% | ១៧% | ២៣% | ២៥% | ២០% | ២៤% |
| ស្វែងរកព័ត៌មាន ឬព្រឹត្តិការណ៍នានានៅក្នុងសហគមន៍ជិតខាង | ១៦% | ១០% | ១១% | ២៦% | ១៩% | ១៣% |
| ស្វែងរកព័ត៌មានអំពីសុខភាព | ១៤% | ១៣% | ១១% | ១៩% | ១៦% | ១២% |
| ចូលរួមនៅក្នុងគេហ៍ទំព័រមួយ ដែលមនុស្សចែកចាយចំណាប់អារម្មណ៍របស់ពួកគេ | ១៣% | ១០% | ១៣% | ១៥% | ១៤% | ១២% |
| បង្កើតវីដេអូ ឬតន្ត្រីរបស់ពួកគេផ្ទាល់ | ១១% | ៩% | ១២% | ១២% | ១៥% | ៧% |
| ស្វែងរកការគាំទ្រផ្លូវចិត្ត | ៥% | ៣% | ៤% | ៩% | ៧% | ៤% |
| ពិភាក្សាអំពីបញ្ហានយោបាយ ឬសង្គម | ៤% | ៥% | ៤% | ៥% | ៧% | ២% |
| បង្កើតអត្ថបទប្លុក ឬគេហ៍ទំព័រ | ៤% | ៤% | ២% | ៥% | ៤% | ៣% |

មូលដ្ឋាន៖ កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំនៅកម្ពុជា។ ចំនួន ៩៩២នាក់។

# ១.៣ ការយល់ឃើញ និងបទពិសោធន៍អំពី សកម្មភាពអនឡាញ ប្រកបដោយហានិភ័យ

ជាញឹកញាប់ ការពិភាក្សាអំពីហានិភ័យនៅតាមប្រព័ន្ធអនឡាញសម្រាប់កុមារច្រើនទទួលរងឥទ្ធិពលពីការយល់ឃើញរបស់មនុស្សពេញវ័យ។ ដើម្បីធានានូវការយល់អំពីការយល់ឃើញរបស់កុមារ ពួកគេ និងអ្នកថែទាំរបស់ពួកគេត្រូវបានសួរអំពីការចូលរួមរបស់ពួកគេនៅក្នុងសកម្មភាពអនឡាញប្រកបដោយហានិភ័យផ្សេងៗគ្នា និងការយល់ឃើញរបស់ពួកគេអំពីសកម្មភាពទាំងនោះ។ កុមារ និងអ្នកថែទាំត្រូវបានសាកសួរពីសកម្មភាពអនឡាញដែលបានរៀបរាប់ខាងក្រោមជា "ហានិភ័យខ្ពស់" "ហានិភ័យតិចតួច" ឬ "គ្មានហានិភ័យ" ចំពោះកុមារ។

### ១.៣.១ ទំនាក់ទំនងជាមួយជនប្លែកមុខនៅតាមប្រព័ន្ធអនឡាញ និងដោយការជួបគ្នាផ្ទាល់

#### ការទំនាក់ទំនងជាមួយមនុស្សប្លែកមុខតាមប្រព័ន្ធអនឡាញ

កង្វល់ទូទៅមួយជុំវិញសកម្មភាពអនឡាញរបស់កុមារ គឺការដែលកុមារអាចនឹងប្រឈមគ្រោះថ្នាក់ពីមនុស្សដែលពួកគេមិនធ្លាប់ស្គាល់គ្នានៅតាមអនឡាញ និងបន្ទាប់មកក៏សម្រេចចិត្តជួបគ្នាផ្ទាល់ ដែលអាចជាហានិភ័យ និងឈានដល់គ្រោះថ្នាក់។ កុមារ និងអ្នកថែទាំត្រូវស្នើឱ្យវាយតម្លៃកម្រិតនៃហានិភ័យសម្រាប់កុមារចំពោះ "ការនិយាយជាមួយនរណាម្នាក់នៅតាមប្រព័ន្ធអ៊ីនធឺណិត ដែលពួកគេមិនធ្លាប់ជួបមុខដោយផ្ទាល់ពីមុនមក"។ នៅក្នុងចំណោមអ្នកថែទាំ ៣៧% បានវាយតម្លៃថាមនុស្សប្លែកមុខតាមប្រព័ន្ធអនឡាញមានហានិភ័យខ្លាំងចំពោះកុមារ។ ផ្ទុយទៅវិញ កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ចំនួនតែ ១៨% ប៉ុណ្ណោះ ដែលបានវាយតម្លៃថា សកម្មភាពនេះមានហានិភ័យខ្លាំងចំពោះកុមារនៅវ័យរបស់ពួកគេ។ បើទោះបីជាកុមារភាគច្រើនបានទទួលស្គាល់ថា ការទំនាក់ទំនងតាមប្រព័ន្ធអនឡាញជាមួយមនុស្សប្លែកមុខតាមប្រព័ន្ធអនឡាញ មានហានិភ័យក្នុងកម្រិតមួយចំនួន ហើយកុមារក្នុងចំនួនសមាមាត្រគួរឱ្យកត់សម្គាល់ (៣៧%) បានមានអារម្មណ៍ថា គ្មានហានិភ័យទាល់តែសោះ ដោយបង្ហាញឱ្យឃើញថា ការភ្ជាប់ទំនាក់ទំនងបែបនេះមិនតែងតែមានគ្រោះថ្នាក់ និងអាចគ្រាន់តែជាវិធីមួយ ដែលយុវជននៅពេលបច្ចុប្បន្ន បង្កើតមិត្តភក្តិថ្មីៗប៉ុណ្ណោះ។ សម្រាប់អ្នកដទៃទៀត ចំណុចនេះអាចបង្ហាញថា កង្វះការយល់ដឹងអំពីរបៀបនិយាយតាមប្រព័ន្ធអនឡាញជាមួយជនដែលមិនធ្លាប់ស្គាល់ អាចនាំទៅរកលទ្ធផលគ្រោះថ្នាក់។ នៅក្នុងការអនុវត្តជាក់ស្តែង កុមារពិតជាទំនាក់ទំនងជាមួយមនុស្សតាមប្រព័ន្ធអនឡាញ ដែលពួកគេមិនធ្លាប់បានជួបគ្នាដោយផ្ទាល់ ដោយកុមារដែលបានចូលរួមនៅក្នុងការអង្កេតចំនួន ៥៧% បង្ហាញថា ពួកគេបានស្វែងរកមិត្តភក្តិថ្មីៗ ឬទំនាក់ទំនងថ្មីៗនៅតាមប្រព័ន្ធអ៊ីនធឺណិត ហើយកុមារចំនួន ៤១% បានបញ្ចូលមនុស្សដែលពួកគេមិនដែលជួប ទៅក្នុងបញ្ជីទំនាក់ទំនងរបស់ពួកគេ។

និន្នាការស្រដៀងគ្នាត្រូវបានសង្កេតឃើញនៅក្នុងការឆ្លើយតបចំពោះសំណួរនានាជុំវិញហានិភ័យពាក់ព័ន្ធនឹងការចែកចាយព័ត៌មានផ្ទាល់ខ្លួនតាមប្រព័ន្ធអនឡាញ ដោយអ្នកថែទាំចំនួន ៥១% និងកុមារចំនួន ២៩% រាយការណ៍ថា ការបញ្ជូនព័ត៌មានផ្ទាល់ខ្លួនទៅកាន់នរណាម្នាក់ ដែលពួកគេមិនដែលជួបគ្នាដោយផ្ទាល់ មានហានិភ័យខ្លាំង (សូមមើលតារាង ៨)។ ទោះជាយ៉ាងណាក្តី កុមារចំនួន ៣១% បានជឿជាក់ថា ការចែកចាយព័ត៌មានផ្ទាល់ខ្លួនជាមួយជនចម្លែកមុខមិនហានិភ័យខ្លាំងទេ។ នៅក្នុងការអនុវត្តជាក់ស្តែង កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតដែលបានចូលរួមនៅក្នុងការអង្កេតចំនួន ១៧% បានចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេជាមួយនរណាម្នាក់ ដែលពួកគេមិនដែលបានជួបគ្នាដោយផ្ទាល់នៅពេលណាមួយនៅក្នុងឆ្នាំមុន។

តារាង ៧៖ កម្រិតនៃហានិភ័យបង្កឡើងដោយកុមារ តាមរយៈការនិយាយតាមប្រព័ន្ធអនឡាញជាមួយមនុស្សចម្លែកមុខ។

ការនិយាយជាមួយនរណាម្នាក់តាមប្រព័ន្ធអ៊ីនធឺណិត ដែលពួកគេមិនធ្លាប់បានជួបគ្នាដោយផ្ទាល់ពីមុន

ខ្ញុំបានបញ្ចូលមនុស្ស ដែលខ្ញុំមិនដែលបានជួបគ្នាដោយផ្ទាល់ ទៅក្នុងបញ្ជីមិត្តភក្តិ ឬបញ្ជីទំនាក់ទំនងរបស់ខ្ញុំ




មូលដ្ឋាន៖ កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំនៅកម្ពុជា។ ចំនួន ៩៩២នាក់។

តារាង ៨៖ កម្រិតនៃហានិភ័យបង្កឡើងដោយកុមារ តាមរយៈការចែកចាយព័ត៌មានផ្ទាល់ខ្លួនជាមួយជនចម្លែកមុខតាមប្រព័ន្ធអនឡាញ។




មូលដ្ឋាន៖ កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំនៅកម្ពុជា។ ចំនួន ៩៩២នាក់។

អ្នកតំណាងរដ្ឋាភិបាលដែលត្រូវបានសម្ភាស បានកំណត់ថា ចរិតជាធម្មជាតិនៃការរីកចម្រើននៃបច្ចេកវិទ្យា គឺជាបញ្ហាប្រឈមពាក់ព័ន្ធនឹងការប្រឈមជាសក្តានុពលចំពោះហានិភ័យ ដោយអ្នកត្រូវបានសម្ភាសបានចែកចាយថា៖ *"នៅពេលបច្ចុប្បន្ន កុមារប្រើប្រាស់កម្មវិធីថ្មីៗជាច្រើន។ ពួកគេអាចកំណត់គណនីរបស់ពួកគេជាគណនីសាធារណៈ ឬឯកជន និងភ្ជាប់ទំនាក់ទំនងជាមួយអ្នកដទៃទៀត។ ពួកគេអាចមើល និងបញ្ជូនរូបភាព និងព័ត៌មាន ព្រមទាំងទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ហេតុនេះ វាពិបាកខ្លាំងណាស់ក្នុងការគ្រប់គ្រង សូម្បីតែសម្រាប់យើង ឪពុកម្តាយ គ្រូបង្រៀន ឬអាជ្ញាធរក្តី។"* (RA១-CA-0៦-A)

## ការជួបនរណាម្នាក់ដោយផ្ទាល់បន្ទាប់ពីទំនាក់ទំនងតាមប្រព័ន្ធអនឡាញ

នៅក្នុងការអង្កេតតាមខ្នងផ្ទះ កុមារ និងអ្នកថែទាំ ត្រូវបានសាកសួរអំពីការយល់ឃើញរបស់ពួកគេពាក់ព័ន្ធនឹងកម្រិតនៃហានិភ័យរបស់កុមារពីការជួបជាមួយនឹងនរណាម្នាក់ដោយផ្ទាល់ដែលពួកគេជួបដំបូងតាមប្រព័ន្ធអនឡាញ។ ពីការអង្កេតនេះ អ្នកថែទាំចំនួន ៤៧% និងកុមារចំនួន ២៦% បានគិតថា ការជួបដោយផ្ទាល់ជាមួយមនុស្ស ដែលពួកគេជួបដំបូងនៅតាមប្រព័ន្ធអនឡាញ មានហានិភ័យខ្លាំងចំពោះកុមារ។ កុមារី(២៩%)ទំនងជាគិតថាការធ្វើបែបនេះជាអាកប្បកិរិយាដែលមានហានិភ័យខ្លាំងក្នុងកម្រិតខ្ពស់ជាងកុមារាបន្តិច (២២%)។ ទោះបីជាយ៉ាងណាក្តី កុមារចំនួន ៣៤% បានមើលឃើញថាអាកប្បកិរិយានេះគ្មានហានិភ័យទាល់តែសោះ។ នៅក្នុងការអនុវត្តជាក់ស្តែង កុមារដែលបានចូលរួមនៅក្នុងការអង្កេតចំនួន ៩% បានជួបជាមួយនរណាម្នាក់ដោយផ្ទាល់ដែលពួកគេបានជួបដំបូងតាមប្រព័ន្ធអនឡាញនៅក្នុងឆ្នាំមុន។ អាកប្បកិរិយាទាំងនេះ កើតឡើងជាទូទៅបំផុតចំពោះកុមារអាយុ១៤-១៥ឆ្នាំ (១១%) និងកុមារអាយុ ១៦-១៧ឆ្នាំ (១២%) ជាជាងកុមារអាយុ ១២-១៣ឆ្នាំ (៣%)។

តារាង ៩៖ កម្រិតនៃហានិភ័យបង្កឡើងដោយកុមារ តាមរយៈការជួបជាមួយនរណាម្នាក់ដោយផ្ទាល់ ដែលពួកគេបានជួបជាដំបូងតាមប្រព័ន្ធអនឡាញ។




មូលដ្ឋាន៖ កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំនៅកម្ពុជា។ ចំនួន ៩៩២នាក់។

## ១.៣ ការយល់ឃើញ និងបទពិសោធន៍អំពី សកម្មភាពអនឡាញប្រកបដោយហានិភ័យ

នៅក្នុងចំណោមកុមារទាំងឡាយ ដែលបានជួបទល់មុខគ្នាជាមួយមនុស្ស ដែលពួកគេបានជួបដំបូងនៅតាមប្រព័ន្ធអនឡាញ ពួកគេភាគច្រើន (៧៥%) សប្បាយចិត្ត ឬរំភើបចំពោះបទពិសោធន៍នេះ (សូមមើលតារាង ១០)។ ការស្រាវជ្រាវ ដែលត្រូវធ្វើឡើងនៅក្នុងប្រទេសជាង៣០នៅជុំវិញពិភពលោក ទទួលបានរបកគំហើញស្រដៀងគ្នា។ បទពិសោធន៍របស់កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ភាគច្រើននៅកម្ពុជា និងប្រទេសដទៃទៀតដែលការស្រាវជ្រាវស្តីពីការបញ្ឈប់គ្រោះថ្នាក់បានធ្វើឡើង ហាក់ដូចជាបង្ហាញថា ជាទូទៅ ហានិភ័យនៃគ្រោះថ្នាក់ពីការជួបជាមួយ "មនុស្សចម្លែកមុខតាមប្រព័ន្ធអនឡាញ" មានកម្រិតទាបសម្រាប់កុមារ។ នេះប្រហែលជា ពេលខ្លះរបៀបដែលមនុស្សវ័យក្មេងបង្កើតមិត្តភក្តិថ្មី។ ទោះបីជាយ៉ាងណាក៏ដោយ កុមារទាំងអស់ត្រូវដឹងអំពីហានិភ័យនៅតាមប្រព័ន្ធអនឡាញដែលអាចកើតមាន និងត្រូវបានបង្រៀនអំពីរបៀបប្រើប្រាស់ដោយការទទួលខុសត្រូវ និងដើម្បីចាត់វិធានការប្រកបដោយសុវត្ថិភាព ដូចជាការជូនដំណឹងដល់មនុស្សធំដែលអាចទុកចិត្តបាន ឬការជួបនៅតែទីសាធារណៈប៉ុណ្ណោះ។

តារាង ១០៖ អារម្មណ៍របស់កុមារអំពីលើកមុនដែលពួកគេជួបដោយផ្ទាល់ជាមួយនរណាម្នាក់ ដែលពួកគេបានជួបដំបូងតាមប្រព័ន្ធអនឡាញ។




មូលដ្ឋាន៖ កុមារដែលបានជួបជាមួយនរណាម្នាក់នៅឆ្នាំមុនដោយផ្ទាល់ ដែលពួកគេបានស្គាល់ដំបូងនៅលើប្រព័ន្ធអ៊ីនធឺណិត ។ កុមារចំនួន ៩២នាក់។

> ៩% នៃកុមារដែលបានស្ទង់មតិបានជួបនរណាម្នាក់ដោយផ្ទាល់ ដែលពួកគេបានជួបជាដំបូងបង្អស់តាមអ៊ីនធឺណិតកាលពីឆ្នាំមុន។ ភាគច្រើននៃកុមារទាំងនេះ (៧៥%) សប្បាយចិត្ត ឬមានអារម្មណ៍រំភើបចំពោះបទពិសោធន៍។

### ការផ្ដល់ភាពអង់អាចដល់អ្នកថែទាំ ដើម្បីដឹកនាំការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត របស់កុមារ

នៅពេលប្រឈមមុខជាមួយការយល់ឃើញទូទៅជាសាធារណៈថា បច្ចេកវិទ្យា និងប្រព័ន្ធអ៊ីនធឺណិត ស្មើនឹងហានិភ័យកាន់តែខ្ពស់ចំពោះ OCSEA ពោលគឺជាទស្សនៈរួមគ្នាមួយរបស់បុគ្គលិកជួរមុខទាំងអស់ដែលបានចូលរួមនៅក្នុងការអង្កេតនៃគម្រោងស្ដីពីការ*បញ្ឈប់គ្រោះថ្នាក់* ជាសភាវគតិ អ្នកថែទាំអាចប្រតិកម្មដោយការរឹតត្បិតការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតរបស់កុមារ ដើម្បីចេតនាការពារកុមារ។ នៅក្នុងការអង្កេតតាមខ្នងផ្ទះ ២៩% នៃអ្នកថែទាំបាននិយាយថា ពួកគេនឹងរឹតត្បិតការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត របស់កូនពួកគេ ប្រសិនបើ កូនរបស់ពួកគេទទួលរងការរំខានពីអ្វីមួយនៅតាមប្រព័ន្ធអ៊ីនធឺណិត។ ដូចការកត់សម្គាល់ពីដំបូង ការរឹតត្បិតរបស់ឪពុកម្ដាយ គឺជាឧបសគ្គធំបំផុតទីពីរ (២៧%) ចំពោះការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត នៅក្នុងចំណោមកុមារនៅកម្ពុជា ជាពិសេសនៅក្នុងចំណោមកុមារអាយុ ១២-១៣ឆ្នាំ (៤២%)។

អភិក្រមនេះអាចកាត់បន្ថយការប្រឈមរបស់កុមារចំពោះហានិភ័យតាមប្រព័ន្ធអនឡាញ នៅក្នុងរយៈពេលខ្លី ប៉ុន្តែវាក៏កាត់បន្ថយជំនាញឌីជីថល និងការយល់ដឹងច្បាស់អំពីបរិយាកាសអនឡាញនៅក្នុងរយៈពេល វែង។ ម្យ៉ាងវិញទៀត *ការចូលរួម និងការសម្របសម្រួលប្រកបដោយការគាំទ្រ* ពីមនុស្សពេញវ័យមានទំនាក់ទំនងជាមួយនឹងការអភិវឌ្ឍជំនាញវិជ្ជមានសម្រាប់កុមារនៅក្នុងប្រទេសដទៃទៀត។ *ការសម្របសម្រួលប្រកបដោយការគាំទ្រ*អាចរួមបញ្ចូលនូវការចូលរួមនៅក្នុងសកម្មភាពនានារួមគ្នាដោយនិយាយជាមួយកុមារអំពីការប្រើប្រាស់អ៊ីនធឺណិតរបស់ពួកគេ និងការអប់រំពួកគេអំពី ហានិភ័យ ដែលមាននៅតាមប្រព័ន្ធអនឡាញ និងវិធីល្អបំផុតក្នុងការជៀសវាងហានិភ័យទាំងនោះ។ ហេតុនេះ អ្នកថែទាំ គឺជាខ្សែរបន្ទាត់ការពារយ៉ាងសំខាន់នៅក្នុងការការពារកុមារពីគ្រោះថ្នាក់តាមប្រព័ន្ធអនឡាញ។

ការយល់ដឹងរបស់អ្នកថែទាំអំពី ហានិភ័យតាមប្រព័ន្ធអនឡាញ និងការចាប់យកជំនាញឌីជីថលមូលដ្ឋាន គឺជាការចាំបាច់នៅក្នុងការធានាថា កូនរបស់ពួកគេមានទទួលបានការបំពាក់បំប៉នយ៉ាងល្អ ដើម្បីបន្តមានសុវត្ថិភាពតាមប្រព័ន្ធអនឡាញ។ នៅក្នុងចំណោមអ្នកថែទាំកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ដែលបានចូលរួមនៅក្នុងការអង្កេត ពួកគេចំនួនតែ ១៨% ប៉ុណ្ណោះ ដែលបានដឹងអំពីរបៀបពិនិត្យមើលថា គេហ៍ទំព័រមួយអាចទុកចិត្តបានដែរឬទេ ២០% ដឹងអំពីរបៀបផ្លាស់ប្ដូរការកំណត់ឯកជនភាព និង ៣៣% ដឹងអំពីរបៀបរាយការណ៍នូវមាតិកាគ្រោះថ្នាក់នៅលើបណ្ដាញទំនាក់ទំនងសង្គម។ អ្នកថែទាំកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ចំនួនតែ ៣៧% ប៉ុណ្ណោះ បានជឿជាក់ថា ពួកគេដឹងអំពីប្រព័ន្ធអ៊ីនធឺណិត ច្រើនជាងកូនរបស់ពួកគេ។ ពាក់ព័ន្ធនឹងការសម្របសម្រួលប្រព័ន្ធអ៊ីនធឺណិត ប្រកបដោយការគាំទ្រ ៤៥% នៃកុមារបានកត់សម្គាល់ថា នៅពេលខ្លះ ឬជាញឹកញាប់ អ្នកថែទាំរបស់ពួកគេស្នើអំពីវិធីក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតប្រកបដោយសុវត្ថិភាព ៤១% បាននិយាយថា ពួកគេបានចូលរួមនៅក្នុងសកម្មភាពអនឡាញរួមគ្នាជាមួយនឹងអ្នកថែទាំរបស់ពួកគេ និង ៣៣% បាននិយាយថា អ្នកថែទាំរបស់ពួកគេជួយ នៅពេលមានអ្វីមួយរំខានពួកគេនៅតាមប្រព័ន្ធអនឡាញ។

ឪពុកម្ដាយ និងអ្នកថែទាំគប្បីទទួលបានការគាំទ្រ ក្នុងការផ្ដល់ការណែនាំឱ្យច្រើនតាមអាចធ្វើបាន ហើយការធ្វើបែបនេះអាចត្រូវបានពង្រឹងតាមរយៈអង្គភាពដទៃទៀត ដូចជាសាលារៀន ឬអង្គការឯកទេស។

## ១.៣ ការយល់ឃើញ និងបទពិសោធន៍អំពី សកម្មភាពអនឡាញប្រកបដោយហានិភ័យ

តារាង ១១៖ កម្រិតនៃហានិភ័យបង្កឡើងដោយកុមារ តាមរយៈការមើលឃើញរូបភាព ឬវីដេអូផ្លូវភេទតាមប្រព័ន្ធអនឡាញ។

ការមើលឃើញរូបភាព ឬវីដេអូផ្លូវភេទនៅតាមប្រព័ន្ធអ៊ីនធឺណិត កុមារចំនួន




ខ្ញុំបានមើលឃើញរូបភាព ឬវីដេអូផ្លូវភេទតាមប្រព័ន្ធអនឡាញ ដោយសារខ្ញុំចង់ឃើញ (ឧទាហរណ៍ ខ្ញុំបានប្រើប្រាស់គេហ៍ទំព័រ ឬបណ្តាញទំនាក់ទំនងសង្គម ដោយរំពឹងថា នឹងរកឃើញមាតិកាបែបនេះនៅទីនោះ)




មូលដ្ឋាន៖ កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំនៅកម្ពុជា។ ចំនួន ៩៩២នាក់។

### ១.៣.២ ការមើលឃើញរូបភាពផ្លូវភេទតាមប្រព័ន្ធអនឡាញ

នៅក្នុងចំណោមអ្នកថែទាំដែលបានចូលរួមនៅក្នុងការអង្កេត ពួកគេចំនួន ៥៧% បានចាត់ទុកថា ការមើលឃើញរូបភាព ឬវីដេអូផ្លូវភេទតាមប្រព័ន្ធអនឡាញមានហានិភ័យខ្លាំង សម្រាប់កុមារ។ នៅក្នុងចំណោមកុមារ ពួកគេចំនួន៣៣% មានការយល់ឃើញដូចគ្នានេះ (សូមមើលតារាង ១១) នៅក្នុងឧទាហរណ៍ទាំងពីរនេះ ភាគរយមានកម្រិតខ្ពស់ជាងសម្រាប់អ្នកទាំងឡាយដែលបានចាត់ទុកថា ការជួបគ្នាដោយផ្ទាល់ជាមួយមិត្តភក្តិអនឡាញមានហានិភ័យខ្លាំង។ កង្វល់ជុំវិញកុមារដែលមើលឃើញរូបភាព ឬវីដេអូផ្លូវភេទនេះ អាចពាក់ព័ន្ធនឹងភាពគ្មានផាសុកភាពជាទូទៅនៃការពិភាក្សាអំពីបញ្ហាផ្លូវភេទ ឬបញ្ហាអាកប្បកិរិយាផ្លូវភេទនៅកម្ពុជា (សូមមើលជំពូក ២.៥.១)។

*"យើងភ័យខ្លាចថា ពួកគេ [កុមារ] ទទួលបានមាតិកាគ្រោះថ្នាក់ [រូបថត និងវីដេអូអនឡាញ] ហើយឪពុកម្តាយរបស់ពួកគេមិនដឹងអំពីបច្ចេកវិទ្យាទំនើប ហេតុនេះ ពួកគេមិនដឹងថា តើកូនរបស់ពួកគេកំពុងប្រើប្រាស់វាដោយសុវត្ថិភាពឬអត់ ទ្បើយ។"*
(RA១-CA-0៩-A).

នៅក្នុងការអនុវត្តជាក់ស្តែង ២៤% នៃកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ដែលបានចូលរួមនៅក្នុងការអង្កេត បាននិយាយថា ពួកគេបានមើលឃើញរូបភាព ឬវីដេអូផ្លូវភេទដោយចេតនា យ៉ាងហោចណាស់ម្តងនៅឆ្នាំមុន។ ការនិយាយបែបនេះនៅក្នុងចំណោមកុមារធំៗអាយុ១៦-១៧ឆ្នាំ (២៧%) មានកម្រិតខ្ពស់ជាងកុមារអាយុ ១៤-១៥ឆ្នាំ (២៣%) និងកុមារអាយុ ១២-១៣ឆ្នាំ (២៣%) ។ កុមារា (២៨%) ក៏បាននិយាយអំពីបញ្ហានេះច្រើនជាងកុមារី (២១%) បន្តិចបន្តួចផងដែរ។ វាអាចទៅរួចដែលកុមារមិនរាយការណ៍ពេញលេញអំពី ការមើលឃើញរូបភាពបែបនេះ ដោយសារវាជាបញ្ហារសើប និងឯកជន។ សមាមាត្រកាន់តែខ្ពស់នៃកុមារ (៣៣%) បានរាយការណ៍អំពី ការមើលឃើញមាតិកាផ្លូវភេទតាមប្រព័ន្ធអនឡាញដោយចៃដន្យ។ កុមារអាយុ ១៦-១៧ឆ្នាំ (៣៩%) និង ១៤-១៥ឆ្នាំ (៣៤%) ទំនងជាមានបទពិសោធន៍ដោយចៃដន្យនេះខ្ពស់ជាងកុមារតូចៗអាយុ ១២-១៣ឆ្នាំ (២៧%)។ គ្មានការសង្កេតឃើញភាពខុសគ្នាផ្អែកយេនឌ័រចំពោះករណីនៃការមើលឃើញរូបភាពផ្លូវភេទតាមប្រព័ន្ធអនឡាញដោយចៃដន្យឡើយ។ កុមារចំនួនពាក់កណ្តាល (៥0%) ដែលបានមើលឃើញរូបភាព ឬវីដេអូផ្លូវភេទតាមប្រព័ន្ធអនឡាញដោយចៃដន្យ បានឃើញមាតិកានេះនៅតាមបណ្តាញទំនាក់ទំនងសង្គម (ការបង្ហោះតាមបណ្តាញទំនាក់ទំនងសង្គម៖ ៣៥% ការផ្ញើសារដោយផ្ទាល់៖ ១៥%)។ កន្លែងដទៃទៀតរួមមានការផ្សាយពាណិជ្ជកម្មតាមប្រព័ន្ធអនឡាញ (២៥%) និងពេលប្រើប្រាស់ក្នុងការស្រាវជ្រាវតាមអ៊ីនធឺណិត  (៣%)។

### ១.៣.៣ ការផលិត និងការចែកចាយមាតិកាផ្លូវភេទអំពីខ្លួនឯង

នៅក្នុងការអង្កេតតាមខ្នងផ្ទះ អ្នកចូលរួមការសម្ភាសបានរៀបរាប់អំពីសកម្មភាពនានាតាមអនឡាញ និងត្រូវបានសាកសួរអំពីកម្រិតនៃហានិភ័យនៃសកម្មភាពនីមួយៗ។ ពីការអង្កេតតាមខ្នងផ្ទះ ៦៦% នៃអ្នកថែទាំ និង៤៥% នៃកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត  បានជឿជាក់ថា វាគឺជាការធ្វើខុស ដែលបុគ្គលម្នាក់ថតរូបភាព ឬវីដេអូអាក្រាតខ្លួនឯង។ ៥៩%នៃអ្នកថែទាំ និង៣៦%នៃកុមារ ត្រូវបានកំណត់ថាការផ្ញើរូបភាព ឬវីដេអូផ្លូវភេទទៅឱ្យនរណាម្នាក់តាមអនឡាញ គឺជាសកម្មភាពប្រកបដោយគ្រោះថ្នាក់បំផុត។ ផ្ទុយទៅវិញ ក៏មានអ្នកថែទាំមួយចំនួនតូច (៧%) និងកុមារ (២៩%) បានគិតថា វាមិនមានហានិភ័យអ្វីទេ។

## ១.៣ ការយល់ឃើញ និងបទពិសោធន៍អំពី សកម្មភាពអនឡាញប្រកបដោយហានិភ័យ

នៅក្នុងការអនុវត្តជាក់ស្តែង កុមារចំនួន ៧% បានរាយការណ៍អំពីការបានថតរូប ឬវីដេអូអាក្រាតខ្លួនឯងនៅឆ្នាំមុន ស្របពេលកុមារចំនួន៦% បានអនុញ្ញាតឱ្យនរណាម្នាក់ផ្សេងទៀតថតរូប ឬវីដេអូអាក្រាតរបស់ពួកគេ។ កុមារាទំនងជាចូលរួមនៅក្នុងអាកប្បកិរិយាទាំងនេះច្រើនជាងកុមារី។ ឧទាហរណ៍ កុមារាចំនួន ៩% បានថតរូបអាក្រាតរបស់ខ្លួនឯង ធៀបនឹងកុមារី ចំនួន ៥% ហើយកុមារាចំនួន ៨% បានអនុញ្ញាតឱ្យនរណាម្នាក់ផ្សេងទៀតថតរូបអាក្រាដរបស់ពួកគេ ធៀបនឹងកុមារីចំនួន ៤%។ បន្ថែមលើនេះ កុមារចំនួន ៩% នៅក្នុងការអង្កេតតាមខ្នងផ្ទះ (កុមារចំនួន៨៧នាក់) បាននិយាយថាពួកគេធ្លាប់ចែករំលែករូបភាព ឬវីដេអូអាក្រាតខ្លួនឯងនៅ

តាមអនឡាញ នៅឆ្នាំមុន។ កុមារាធ្លាប់ចែករំលែករូបភាពផ្លូវភេទច្រើនជាងកុមារី (កុមារា ១១% កុមារី ៦%)។ មូលហេតុទូទៅបំផុត ដែលផ្តល់ដោយកុមារទាំងឡាយ ដែលបានចែកចាយរូបភាព ឬវីដេអូផ្លូវភេទរបស់ពួកគេ គឺដោយសារពួកគេកំពុង "ចែចង់ និងមានភាពរីករាយ" (សូមមើលតារាង ១៤)។ សមាមាត្រនៃកុមារតូចៗ ពោលគឺកុមារទាំងអស់អាយុពី ១២ ទៅ ១៥ឆ្នាំ បានចែកចាយមាតិកាផ្លូវភេទអំពីខ្លួនឯង ដោយសារពួកគេរង "ការគំរាមកំហែង" (៧%) ស្ថិតក្រោមសម្ពាធពីមិត្តភក្តិ" (៨%) ឬធ្វើបែបនេះ "ដើម្បីផ្តោះប្តូរនឹងលុយកាក់ ឬអំណោយ" (៣%)។ នៅក្នុងចំណោម ដែលបានចែកចាយរូបភាពអាក្រាតកាយរបស់ខ្លួនឯង ភាគច្រើនមិនបាននិយាយអំពីអ្នកដែលពួកគេបានចែកចាយមាតិកាបែបនេះជាមួយ (៣២%) ឬបានចែកចាយរូបភាពជាមួយនរណាម្នាក់ដែលពួកគេមិនស្គាល់ (៣១%) ឡើយ។ កុមារចំនួន ១៧% ផ្សេងទៀត បានចែកចាយជាមួយដៃគូស្នេហាបច្ចុប្បន្ន ឬពីមុន និង ១០% បានចែកចាយជាមួយនរណាម្នាក់ ដែលពួកគេបានជួបដំបូងនៅតាមប្រព័ន្ធអនឡាញ និងដែលស្ថិតនៅក្នុងបញ្ជីទំនាក់ទំនងមួយរបស់មិត្តភក្តិ ឬសមាជិកគ្រួសារ។

តារាង ១២៖ កម្រិតនៃហានិភ័យបង្កឡើងដោយកុមារ តាមរយៈចែកចាយមាតិកាផ្លូវភេទតាមប្រព័ន្ធអនឡាញ។




មូលដ្ឋាន៖ កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំនៅកម្ពុជា។ ចំនួន ៩៩២នាក់។

## ១.៣ ការយល់ឃើញ និងបទពិសោធន៍អំពី សកម្មភាពអនឡាញប្រកបដោយហានិភ័យ

តារាង ១៣៖ មូលហេតុសម្រាប់ការចែកចាយរូបភាព ឬវីដេអូអាក្រាតអំពីខ្លួនឯង ដែលកុមារបានប្រាប់។

| មូលហេតុសម្រាប់ការចែកចាយ | សរុប | ១២-១៣ឆ្នាំ | ១៤-១៥ឆ្នាំ | ១៦-១៧ឆ្នាំ | កុមារា | កុមារី |
|---|---|---|---|---|---|---|
| កំពុងចែចង់ ឬកំពុងមានភាពរីករាយ | ៣៣% | ២៩% | ៣៦% | ៣៣% | ៣១% | ៣៥% |
| មិនដឹង | ២៦% | ១៥% | ១៩% | ៤៨% | ២៣% | ៣២% |
| ទុកចិត្តជនដទៃទៀត | ១៦% | ២៦% | ១២% | ១១% | ១៨% | ១៣% |
| ធ្លាក់ក្នុងក្តីស្រឡាញ់ | ១៣% | ១១% | ២១% | ៤% | ១៥% | ៦% |
| រងសម្ពាធឱ្យចែកចាយរូបភាព ឬវីដេអូពីសំណាក់មិត្តភក្តិ | ៨% | ១១% | ១២% | | ៤% | ១៣% |
| រងការគំរាមកំហែង | ៧% | ៧% | ១២% | | ១១% | |
| ព្រួយបារម្ភថា ខ្ញុំនឹងបាត់បង់បុគ្គលនោះ ប្រសិនបើ ខ្ញុំមិនចែកចាយ | ៦% | ៤% | ៦% | ៤% | ៥% | ៦% |
| ចង់បានចំណាប់អារម្មណ៍ពីបុគ្គលនោះ | ៦% | ១១% | ៦% | | ៩% | |
| មិនចង់និយាយ | ៥% | ៤% | ៩% | | ៥% | ៣% |
| មិនគិតថាមានអ្វីខុសចំពោះការចែកចាយរូបភាព ឬវីដេអូឡើយ | ៣% | | ៩% | | ៤% | ៣% |
| ការផ្តល់លុយកាក់ ឬអំណោយជាថ្នូរនឹងការផ្តោះប្តូររូបភាព ឬវីដេអូ | ៣% | ៤% | ៦% | | ៥% | |

មូលដ្ឋាន៖ កុមារដែលបានចែកចាយរូបភាព ឬវីដេអូអាក្រាតកាយរបស់ខ្លួនឯងនៅក្នុងឆ្នាំមុន។ ចំនួនកុមារ៨៧នាក់។

## ១.៣ ការយល់ឃើញ និងបទពិសោធន៍អំពី សកម្មភាពអនឡាញប្រកបដោយហានិភ័យ

### ការកើនឡើងនូវមាតិកាផ្លូវភេទបង្កើតឡើងដោយខ្លួនឯងពាក់ព័ន្ធនឹងកុមារ

កំណើនការប្រើប្រាស់បច្ចេកវិទ្យាកំពុងនាំឱ្យមានការផ្លាស់ប្តូរសញ្ញាណអំពីឯកជនភាព និងអាកប្បកិរិយាផ្លូវភេទនៅក្នុងចំណោមកុមារនៅក្នុងផ្នែកមួយចំនួននៃពិភពលោកនេះ ជាពិសេស យុវវ័យ។ ទម្រង់នៃអាកប្បកិរិយា ដែលកាន់តែមានលក្ខណៈធម្មតាចំពោះយុវវ័យ អាចមិនច្បាស់លាស់ចំពោះមនុស្សពេញវ័យ ដែលបានធំឡើងនៅពេលខុសគ្នាឡើយ។ ឧទាហរណ៍ ការជជែក និងការផ្សាយវីដេអូបន្តផ្ទាល់កើតឡើងជាទូទៅ ទោះជានៅក្នុងចំណោមក្រុមមិត្តភក្តិលក្ខណៈឯកជនតូចៗក្តី ឬនៅក្នុងចំណោមទស្សនិកជនសាធារណៈលក្ខណៈអនាមិកធំៗក្តី។ បើទោះបីជាទង្វើបែបនេះភាគច្រើនគ្មានគ្រោះថ្នាក់ក្តី ការផលិត និងការចែកចាយមាតិកាផ្លូវភេទអំពីខ្លួនឯងដោយប្រើប្រាស់ឧបករណ៍ទាំងនេះក៏បង្កើន និងនាំមកនូវហានិភ័យគួរឱ្យកត់សម្គាល់ផងដែរ។

ការចែកចាយមាតិកាផ្លូវភេទអំពីខ្លួនឯងពីសំណាក់កុមារ គឺស្មុគស្មាញ និងមានបទពិសោធន៍ ហានិភ័យ និងគ្រោះថ្នាក់ខុសៗគ្នាជាច្រើន។ ដូចការបង្ហាញពីទិន្នន័យនៃគម្រោងស្តីពី*ការបញ្ឈប់គ្រោះថ្នាក់* មាតិកាអំពីខ្លួនឯងមួយចំនួនត្រូវបានចែកចាយជាមួយជនដទៃទៀត ដោយសារកុមារធ្លាក់ក្នុងក្តីស្រឡាញ់ ឬកំពុងមានភាពរីករាយ។ ជាសកល ការផ្តោះប្តូរបែបនេះកំពុងក្លាយជាផ្នែកមួយនៃបទពិសោធន៍ផ្លូវភេទរបស់យុវជន។ ទោះបីជាយ៉ាងណាក្តី ទិន្នន័យក៏បង្ហាញថា ការបង្កើត និងការចែកចាយមាតិកាផ្លូវភេទផ្ទាល់ខ្លួនអាចដោយសារការបង្ខិតបង្ខំ តាមរយៈការគំរាមកំហែង ឬសម្ពាធពីមិត្តភក្តិ (សូមមើលជំពូក ២.២) ផងដែរ។

បើទោះបីជាការបង្ខិតបង្ខំអាចត្រូវមើលឃើញថាជាបទល្មើសយ៉ាងច្បាស់ និងនាំដោយផ្ទាល់ទៅរកគ្រោះថ្នាក់ក្តី អាចមានផលវិបាកអវិជ្ជមាន សម្រាប់កុមារ ដែលចែកចាយមាតិកាផ្លូវភេទណាមួយ រួមទាំងក្នុងករណីដែលគ្មានការបង្ខិតបង្ខំឱ្យមានការចែកចាយ។ សម្ភារដែលត្រូវបានចែកចាយដោយចេតនា អាចមិនបង្កគ្រោះថ្នាក់នៅពេលដំបូងឡើយ ប៉ុន្តែនៅតែមានហានិភ័យ ប្រសិនបើ សម្ភារនោះត្រូវបានចែកចាយនៅពេលក្រោយ លើសពីការគ្រប់គ្រងបានរបស់បុគ្គល ដែលបានបង្កើតសម្ភារនោះ។ នៅពេលមានសម្ភារនោះ មាតិកាបែបនេះក៏អាចត្រូវបានទទួលបានដោយការបោកប្រាស់ ឬដោយការបង្ខិតបង្ខំ ឬត្រូវបានជនល្មើសផ្សព្វផ្សាយជាញឹកញាប់ខ្លាំងផងដែរ (សូមមើលរូបភាព ១២)។ ការសម្ភាសជាមួយយុវជនមកពីប្រទេសកម្ពុជាបានបង្ហាញនូវការយល់ដឹងអំពីអ្វី ដែលអាចកើតឡើង ប្រសិនបើ រូបភាពនានាត្រូវបានចែកចាយដោយគ្មានការអនុញ្ញាត៖ *"ខ្ញុំមានការព្រួយបារម្ភ។ ខ្ញុំខ្លាចពួកគេថតរូបទាំងនោះដើម្បីបញ្ចូលក្នុងប្រព័ន្ធអ៊ីនធឺណិត និងចែកចាយ។ ចែកចាយឱ្យអ្នកដទៃទៀតមើល។"* (RA៥-CA-0៨) *ការភ័យខ្លាចអំពីការចែកចាយមានទំនាក់ទំនងជាមួយនឹងភាពតានតឹងក្នុងចិត្តគួរឱ្យកត់សម្គាល់៖ "... ហេតុនេះ ខ្ញុំបានឈប់គិតអំពីវា ប៉ុន្តែគំនិតអំពីអត្តឃាតបានកើតឡើងរួចហើយ..."* (RA៥-CA-0៧)

រូបភាព ១៤៖ ការធ្វើផែនទីផលវិបាកនៃការចែកចាយសម្ភារផ្លូវភេទអំពីខ្លួនឯង ដែលពាក់ព័ន្ធនឹងយុវជន។




នៅកម្ពុជា សមាមាត្រគួរឱ្យកត់សម្គាល់នៃកុមារអាយុ ១២-១៧ឆ្នាំហាក់ដូចជាដឹងថា ការផលិត និងការចែកចាយមាតិកាផ្លូវភេទអាចមានហានិភ័យចំពោះកុមារ។ ទោះបីជាយ៉ាងក្តី កុមារជិតម្នាក់ក្នុងចំណោមកុមារដប់នាក់បានចូលរួមនៅក្នុងអាកប្បកិរិយាបែបនេះនៅឆ្នាំមុន។ ដើម្បីធានាថា កុមារទទួលបានភាពអង់អាចក្នុងការបន្តមានសុវត្ថិភាពតាមប្រព័ន្ធអនឡាញ ការពិភាក្សាជុំវិញសកម្មភាព

ប្រភេទទាំងនេះ និងហានិភ័យដែលអាចមានពីសកម្មភាពទាំងនេះ គប្បីជាចំណុចសំខាន់ក្នុងការបង្ហាញដល់កុមារអំពី ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតរបស់ពួកគេនៅផ្ទះ នៅសាលារៀន និងនៅកម្រិតសហគមន៍។

ការស្វែងរកជំនួយ ក្នុងករណីអ្នកដទៃទៀតចែកចាយមាតិកាផ្លូវភេទរបស់ពួកគេ ក៏អាចជាការពិបាកសម្រាប់កុមារជាច្រើនផងដែរ មូលហេតុមួយផ្នែក គឺដោយសារវប្បធម៌នៃការបន្ទោសកុមារ។ នៅកម្ពុជា ការអង្កេតតាមខ្នងផ្ទះបានបង្ហាញថា ភាគច្រើននៃអ្នកថែទាំ (៦៦%) និងកុមារ (៤៦%) បានជឿជាក់ថា ប្រសិនបើ មានការចែកចាយរូបភាព ឬវីដេអូអំពីខ្លួនឯងបន្ថែមទៀត វាគឺជាកំហុសរបស់ជនរងគ្រោះ។ នៅពេលមាតិកាអំពីខ្លួនឯងត្រូវបានចែកចាយដោយគ្មានការអនុញ្ញាត ភាពស្ទាក់ស្ទើរ ឬអសមត្ថភាពក្នុងការស្វែងរកជំនួយអាចធ្វើឱ្យគ្រោះថ្នាក់ចំពោះកុមារកាន់តែមានលក្ខណៈធ្ងន់ធ្ងរបន្ថែមទៀត។

## ១.៤ ចំណេះដឹង និងជំនាញ សម្រាប់សុវត្ថិភាពតាមប្រព័ន្ធអនឡាញ

ភាគច្រើននៃកុមារដែលបានចូលរួមនៅក្នុងការអង្កេត បានបង្ហាញនូវការយល់ដឹងក្នុងកម្រិតមួយអំពីហានិភ័យនៃប្រព័ន្ធអនឡាញ។ ចំណុចគួរឱ្យកត់សម្គាល់ផងដែរ គឺកម្រិតនៃទំនុកចិត្តលើសមត្ថភាពនៅក្នុងចំណោមកុមារដែលបានចូលរួមក្នុងការអង្កេត ក្នុងការធ្វើឱ្យខ្លួនឯងមានសុវត្ថិភាពតាមប្រព័ន្ធអនឡាញ។ យោងតាមការអង្កេតតាមខ្នងផ្ទះ កុមារចំនួន ៥៧% (ជាពិសេស កុមារធំៗ) មានទំនុកចិត្តលើសមត្ថភាពរបស់ពួកគេក្នុងការវាយតម្លៃថាតើរូបភាពណាមួយរបស់ខ្លួនឯង ឬរបស់មិត្តភក្តិរបស់ពួកគេ ដែលត្រូវចែកចាយតាមប្រព័ន្ធអនឡាញ ហើយកុមារចំនួន ៥៩% មានទំនុកចិត្តក្នុងការដឹងថាតើនៅពេលណាត្រូវដកបុគ្គលនានាចេញពីបញ្ជីទំនាក់ទំនងរបស់ពួកគេ។ ដោយបង្ហាញយ៉ាងច្បាស់ ទាំងនេះគឺជាការវាយតម្លៃបែបអត្តនោម័តចំពោះសមត្ថភាពរបស់ពួកគេផ្ទាល់ និងគប្បីត្រូវបានបកស្រាយដោយប្រុងប្រយ័ត្ន។ គួរកត់សម្គាល់ផងដែរថា ការអង្កេតនេះក៏បានបង្ហាញថា កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ចំនួន ៥២% មិនដែលទទួលបានព័ត៌មានច្បាស់លាស់អំពី របៀបរក្សាឱ្យមានសុវត្ថិភាពនៅតាមប្រព័ន្ធអនឡាញឡើយ។

ពាក់ព័ន្ធនឹងជំនាញ និងចំណេះដឹងឌីជីថល កុមារចំនួនតែប្រមាណមួយភាគបីប៉ុណ្ណោះបានបង្ហាញថា ពួកគេបានដឹងអំពី របៀបផ្លាស់ប្តូរការកំណត់ឯកជនភាពរបស់ពួកគេ (៣២%) ឬរបៀបរាយការណ៍អំពីមាតិកាគ្រោះថ្នាក់នៅលើបណ្តាញទំនាក់ទំនងសង្គម (៣៤%)។ កុមារអាយុ ១៦-១៧ឆ្នាំ ទំនងជារាយការណ៍ថា ពួកគេបានដឹងអំពីរបៀបប្រតិបត្តិការទ្រង់ទ្រាយសុវត្ថិភាពទាំងនេះ ច្រើនជាងកុមារអាយុ ១២-១៣ឆ្នាំចំនួនពីរដង។

បើទោះបីជាផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ បានបញ្ចូលការរៀបចំកម្មវិធីអប់រំនានា ដែលមានបំណងកសាងជំនាញសុវត្ថិភាពតាមប្រព័ន្ធអនឡាញរបស់កុមារក្តី មានភស្តុតាងតិចតួច ដែលត្រូវបានកំណត់អំពីសកម្មភាពនានា ដែលត្រូវបានអនុវត្ត (ដោយសារកង្វះសមត្ថភាព និងធនធាន)។

# ២. ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា

ដោយបន្តទៅលើការយល់ឃើញរបស់កុមារ និងការចូលរួមរបស់កុមារនៅក្នុងការអនុវត្តតាមប្រព័ន្ធអនឡាញប្រកបដោយហានិភ័យ ជំពូកនេះនឹងទាក់ទៅរកការគំរាមកំហែងនៃការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) នៅកម្ពុជា។ ជំពូកនេះប្រើប្រាស់ប្រភពចម្រុះគ្នា រួមមានទិន្នន័យអំពីការអនុវត្តច្បាប់ ការរាយការណ៍ជាភាគព្វកិច្ចពីក្រុមហ៊ុនបច្ចេកវិទ្យាដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិកជូនដល់ NCMEC ពាក់ព័ន្ធនឹងប្រទេសកម្ពុជា ការអង្កេតជាមួយបុគ្គលិកជួរមុខ និងការសន្ទនាជាមួយកុមារផ្ទាល់ ព្រមទាំងការអង្កេតតាមខ្នងផ្ទះ ដើម្បីបង្កើតនូវការបង្ហាញយ៉ាងពេញលេញអំពី ចរិតនៃបទល្មើសទាំងនេះលើកុមារ។

## ២. ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា

**ជំពូកនេះបង្ហាញនូវទិន្នន័យអនុវត្តច្បាប់ជាតិពាក់ព័ន្ធនឹង OCSEA (ជំពូក ២.១) បន្ទាប់មកការប៉ាន់ប្រមាណអំពីការកើតឡើងនូវហេតុការណ៍ជាក់លាក់នៃ OCSEA ដោយផ្អែកលើបទពិសោធន៍ស្វ័យរាយការណ៍របស់កុមារ (ជំពូក ២.២ និង២.៣)។ គោលបំណងនៃការប៉ាន់ប្រមាណទាំងនេះ គឺមិនដើម្បីផ្តល់រូបភាពពិតប្រាកដនៃប្រេវ៉ាឡង់នៃ OCSEA ឡើយ។ មានមូលហេតុមួយចំនួនចំពោះបញ្ហានេះ។ ទីមួយ ទិន្នន័យរដ្ឋបាលមានស្រាប់ដែលត្រូវបានប្រើប្រាស់ ដូចជា ទិន្នន័យរបស់អាជ្ញាធរអនុវត្តច្បាប់ កម្រពណ៌នា ឬចាត់ចំណាត់ថ្នាក់លើធាតុផ្សំរបស់ OCSEA ណាស់។ ទីពីរ ពាក់ព័ន្ធនឹងការអង្កេតតាមខ្នងផ្ទះ គេនឹងរំពឹងឃើញអំពីកម្រិតនៃការរាយការណ៍មិនគ្រប់គ្រាន់ ដោយសារកង្វល់ពាក់ព័ន្ធនឹងឯកជនភាព  ភាពស្ទាក់ស្ទើរក្នុងការពិភាក្សាអំពីបញ្ហាផ្លូវភេទ និងអាកប្បកិរិយា ផ្លូវភេទ ព្រមទាំងការភ័យខ្លាចចំពោះការកំណត់ថាខ្លួនឯងពាក់ព័ន្ធនឹងបទល្មើសផ្លូវច្បាប់ ដោយសារការអនុវត្តមួយចំនួនត្រូវបានកំណត់ថាជាបទល្មើស។ បន្ថែមលើនេះ នៅក្នុងគ្រួសារដែលការរំលោភបំពានផ្លូវភេទកើតឡើង អ្នកស្រាវជ្រាវមិនសូវទំនងជាទទួលបានការអនុញ្ញាតឱ្យនិយាយជាមួយកុមារឡើយ។ ចុងក្រោយ ការប៉ាន់ប្រមាណជាច្រើនត្រូវបានផ្អែកលើការវិភាគលើអនុសំណាកនៃទិន្នន័យពីការអង្កេតតាមខ្នងផ្ទះ ដែលមានទំហំតូច ដោយសារ OCSEA នៅតែជាហេតុការណ៍ ដែលកម្រត្រូវបានរាយការណ៍។ អនុសំណាកកាន់តែតូចទាំងនេះបង្កឱ្យមានកំហុសកាន់តែធំ។**

បើទោះបីជាក្រុមការងារគម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* មានទំនុកចិត្តចំពោះទិន្នន័យ និងគុណភាពនៃសំណាកដែលទទួលបានក្តី បញ្ហាប្រឈមនៃការស្រាវជ្រាវលើបាតុភូតជាក់លាក់ និងរសើបនេះ ជាពិសេសជាមួយកុមារ មានន័យថា ជាការបាត់បង់ភាពច្បាស់លាស់មួយចំនួននៅក្នុងការប៉ាន់ប្រមាណចុងក្រោយ។ ចំពោះមូលហេតុទាំងនេះ អ្នកអានគប្បីបកស្រាយរបកគំហើញនានានៅក្នុងជំពូកនេះថាជាការប៉ាន់ស្មានដ៏ល្អមួយនៃការកើតឡើងនូវបទល្មើសជាក់លាក់ទៅលើកុមារពាក់ព័ន្ធនឹង OCSEA នៅកម្ពុជា និងទំហំដែលកុមារអាយុ១២ដល់១៧ឆ្នាំកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជាជួបប្រទះនឹង OCSEA ។

# ២.១ ទិន្នន័យនៃការអនុវត្តច្បាប់

ការវិភាគនៅក្នុងជំពូកនេះប្រើប្រាស់ទិន្នន័យបែបគុណភាព និងបរិមាណពីអាជ្ញាធរអនុវត្តច្បាប់ និងអង្គការដៃគូមួយចំនួន ក្នុងន័យដើម្បីស្វែងយល់អំពី បទល្មើសពាក់ព័ន្ធ អាកប្បកិរិយារបស់ជនល្មើស អាកប្បកិរិយារបស់ជនរងគ្រោះ កត្តាបង្កលក្ខណៈចំពោះបទល្មើស និងភាពងាយរងគ្រោះ។

តារាង ១៥. សេចក្តីរាយការណ៍ពាក់ព័ន្ធនឹងការសង្ស័យអំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅកម្ពុជា។

| | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ភាគរយនៃការផ្លាស់ប្តូរពីឆ្នាំ ២០១៧ ដល់ ២០១៩ | ភាគរយនៃការផ្លាស់ប្តូរពីឆ្នាំ ២០១៨ ដល់ ២០១៩ |
|---|---|---|---|---|---|
| កម្ពុជា | ២៥.៣០៩ | ១៣១.៩០០ | ៩១.៤៥៨ | ២៦១% | -៣១% |
| សរុបទូទាំងសកលលោក | ១០.២១៤.៧៥៣ | ១៨.៤៦២.៤២៤ | ១៦.៩៨៧.៣៦១ | ៦៦% | -៨% |
| % សម្រាប់កម្ពុជាក្នុងចំណោមចំនួនសរុបទូទាំងសកលលោក | 0,២៥% | 0,៧១% | 0,៥៤% | | |

មូលដ្ឋាន៖ ទិន្នន័យនៃសេចក្តីរាយការណ៍ពាក់ព័ន្ធនឹងការសង្ស័យអំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ ដែលផ្តល់ដោយ NCMEC ។

### ២.១.១ បទល្មើស OCSEA ដែលត្រូវបានកត់ត្រា

ជាអកុសល ទិន្នន័យអំពីបទល្មើសពាក់ព័ន្ធនឹង OCSEA មិនត្រូវបានផ្តល់ដោយអង្គភាពអនុវត្តច្បាប់ជាតិ ដែលនគរបាលអន្តរជាតិបានទៅជួប សម្រាប់គម្រោងស្តីពី*ការបញ្ឈប់គ្រោះ*ថ្នាក់ឡើយ។ បន្ទាប់ពីការពិភាក្សាលម្អិតជាមួយអ្នកទាំងឡាយមកពីនគរបាលជាតិកម្ពុជា ដែលត្រូវបានសម្ភាស ទំនងជាគ្មានយន្តការនៃការប្រមូលទិន្នន័យជាប្រព័ន្ធ និងគ្មានប្រព័ន្ធរក្សាទុកឯកសារពាក់ព័ន្ធនឹងករណី OCSEA ឡើយ។ អាណត្តិនៃអង្គភាពនគរបាលមិនមានលក្ខណៈជាក់លាក់ចំពោះ OCSEA ឡើយ ប៉ុន្តែមានទំនាក់ទំនងជាមួយនឹងបញ្ហាសន្តិសុខបច្ចេកវិទ្យាយ៉ាងទូលំទូលាយវិញ។ ដោយសារហេតុនេះ ករណីនានាដែលត្រូវបានចោទប្រកាន់ និងកត់ត្រាថាជាបទល្មើស មិនត្រូវបានកំណត់ប្រភេទជា OCSEA យ៉ាងជាក់លាក់ឡើយ។ មានធាតុផ្សំនានានៃ CSEA តាមអនឡាញ និងក្រៅអនឡាញ រួមទាំងអំពើជួញដូរ និងរត់ពន្ធមនុស្ស ដែលត្រូវបានដាក់បញ្ចូលនៅក្នុងបទល្មើសនានា ដែលត្រូវបានរាយការណ៍ជូនដល់អង្គភាពនានា (នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា)។ អ្នកអនុវត្តច្បាប់ត្រូវតែបញ្ជូនសំណុំរឿងទៅអយ្យការជាដាច់ខាត ទោះបីការ ស៊ើបអង្កេតមានបទល្មើស ឬគ្មានបទល្មើស។

### ១.២ ការរកឃើញ OCSEA ជាអន្តរជាតិ និងការបញ្ជូន

**និន្នាការនៅក្នុងសេចក្តីរាយការណ៍អំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ**

ជំនួសមុខទីភ្នាក់ងារអនុវត្តច្បាប់កម្ពុជាទិន្នន័យត្រូវបានស្នើសុំសម្រាប់គម្រោងស្តីពីការបញ្ឈប់គ្រោះថ្នាក់ពី មជ្ឈមណ្ឌលសហរដ្ឋអាមេរិកសម្រាប់កុមារបាត់ខ្លួននិងកុមាររងការកេងប្រវ័ញ្ច (NCMEC) អំពីសេចក្តីរាយការណ៍នានាពាក់ព័ន្ធនឹងការសង្ស័យអំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅកម្ពុជាសម្រាប់ឆ្នាំ២០១៧ដល់ ២០១៩។

ច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិកតម្រូវថា "អ្នកផ្តល់សេវាអេឡិចត្រូនិក" (ឧទា. ក្រុមហ៊ុនបច្ចេកវិទ្យា) ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក រាយការណ៍អំពីហេតុការណ៍នានានៃការសង្ស័យអំពីការកេងប្រវ័ញ្ចកុមារនៅលើកម្មវិធីរបស់ពួកគេទៅកាន់បណ្តាញរាយការណ៍នៃ NCMEC។ NCMEC ចាត់របាយការណ៍នេះជាក្រុម និងបញ្ជូនសេចក្តីរាយការណ៍ទាំងនេះទៅកាន់អង្គភាពអនុវត្តច្បាប់ជាតិរបស់ប្រទេសពាក់ព័ន្ធ ដើម្បីមានចំណាត់ការ។ ទោះបីជាយ៉ាងណាក្តី ចំពោះអ្នកផ្តល់សេវាកម្មដែលមិនមានមូលដ្ឋាននៅសហរដ្ឋអាមេរិក

សេចក្តីរាយការណ៍បែបនេះត្រូវធ្វើទៅតាមការស្ម័គ្រចិត្ត។ ដោយសារមិនមែនគ្រប់កម្មវិធីទាំងអស់រាយការណ៍អំពីការសង្ស័យអំពីការរំលោភបំពានកុមារជូនដល់ NCMEC ទិន្នន័យខាងក្រោមមិនមានកម្មវិធីពេញនិយមមួយចំនួននៅក្នុងប្រទេសគោលដៅនៃគម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* ឡើយ។

នៅកម្ពុជា សេចក្តីរាយការណ៍នានាពាក់ព័ន្ធនឹងការសង្ស័យអំពីការកេងប្រវ័ញ្ចផ្លូវភេទកុមាររបស់ NCMEC បានទទួលតាមរយៈមន្ត្រីអនុព័ន្ធនៃអង្គភាពស៊ើបអង្កេតសន្តិសុខមាតុភូមិរបស់សហរដ្ឋអាមេរិក មកកាន់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរបស់ប្រទេសកម្ពុជា។

ចំនួនសេចក្តីរាយការណ៍ពាក់ព័ន្ធនឹងការសង្ស័យអំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ សម្រាប់កម្ពុជាបានកើនឡើងចំនួន ២៦១% នៅរវាងឆ្នាំ២០១៧ និងឆ្នាំ ២០១៩ (តារាង ១៥) ជាមួយនឹងកើនឡើងចំនួន ៤២១% នៅរវាងឆ្នាំ២០១៧ និងឆ្នាំ២០១៨ និងបានធ្លាក់ចុះចំនួន ៣១% នៅឆ្នាំ២០១៩។ ការធ្លាក់ចុះនេះមានកម្រិតច្រើនជាងការធ្លាក់ចុះនៃសេចក្តីរាយការណ៍ពាក់ព័ន្ធនឹងការសង្ស័យអំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារជាសកលរួមបញ្ចូលគ្នា (៨%)។

### ប្រភេទនៃបទល្មើស OCSEA

ការវិភាគលើសេចក្តីរាយការណ៍ពាក់ព័ន្ធនឹងការសង្ស័យអំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារទាំងនេះបានបង្ហាញថា ការមាន ការផលិត និងការចែកចាយ CSAM (ដែលច្បាប់សហរដ្ឋអាមេរិកកំណត់ថា ជា "អំពើអាសអាភាសកុមារ" ) មានចំនួនស្មើរតែស្មើនឹងសេចក្តីរាយការណ៍ទាំងអស់សម្រាប់ប្រទេសកម្ពុជានៅរវាងឆ្នាំ២០១៧ និងឆ្នាំ២០១៩។ គ្មានសេចក្តីរាយការណ៍ណាមួយត្រូវកំណត់ថាជាអាទិភាពទី ១ ដែលបង្ហាញថា កុមារកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់ក្នុងពេលឆាប់ៗនេះឡើយ។

សេចក្តីរាយការណ៍នៃ NCMEC ស្ទើរតែទាំងអស់សម្រាប់ប្រទេសកម្ពុជានៅក្នុងរយៈពេលពីឆ្នាំ២០១៧ ដល់ ២០១៩ មានអ្នកផ្តល់សេវាកម្មអេឡិចត្រូនិកជាប្រភពនៃសេចក្តីរាយការណ៍ទាំងនោះ។ អ្នកផ្តល់សេវាកម្មអេឡិចត្រូនិកសរុបចំនួន ៣៧ បានដាក់សេចក្តីរាយការណ៍យ៉ាងហោចណាស់មួយអំពី ការសង្ស័យអំពីការកេងប្រវ័ញ្ចកុមារចំពោះប្រទេសកម្ពុជានៅក្នុងរយៈពេលនៃរបាយការណ៍នេះ (តារាង ១៦)។ ចំណុចនេះនឹងបង្ហាញនូវពិពិធភាពនៅក្នុងកម្មវិធីនានា ដែលជនល្មើស OCSEA បានប្រើប្រាស់។

តារាង ១៦. សេចក្តីរាយការណ៍ពាក់ព័ន្ធនឹងការសង្ស័យអំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅកម្ពុជា អ្នកផ្តល់សេវាកម្មអេឡិចត្រូនិកលំដាប់កំពូលទាំងម្ភៃ។

| | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ |
|---|---|---|---|
| Facebook | ២៤.៧៩០ | ១៣១.១២២ | ៩០.៥៩៦ |
| Google | ៣២៨ | ៤១៦ | ៤៦៧ |
| Instagram.Inc | ២៩ | ១៤៤ | ១៣២ |
| Twitter /Vine.co | ៦៦ | ១០៦ | ១១២ |
| Microsoft Online Operations | ២ | ២៥ | ៩៥ |
| Tumblr | ២៦ | ២៥ | ១៤ |
| Pinterest.Inc | ២ | ៩ | ១០ |
| Imgur LLC | ៣ | ១ | ៥ |
| Discord Inc. | | | ៤ |
| Dropbox Inc. | ២ | | ២ |
| Multi Media LLC/Z Medianow LLC/Chaturbate | | | ២ |
| Smug Mug Flickr | | ២ | ២ |
| Snapchat | | ៣ | ២ |
| Vimeo LLC | | ៤ | ២ |
| Digital Ocean | | ១ | ១ |
| Linked In Corporation | | | ១ |
| Omeagle.com LLC | ១ | | ១ |
| Roblox | | | ១ |
| Tagged.com | | | ១ |
| Tinder Inc | | | ១ |

មូលដ្ឋាន៖ ទិន្នន័យអំពីសេចក្តីរាយការណ៍ ដែលផ្តល់ដោយ NCMEC ដោយរៀបចំទៅតាមការរាប់ចំនួននៅឆ្នាំ២០១៩ លទ្ធផលសូន្យត្រូវបានដកចេញ។

* វាក្យស័ព្ទប្រើក្នុងជួរឈរនេះឆ្លុះបញ្ចាំងពីការចាត់ថ្នាក់ដោយមជ្ឈមណ្ឌលជាតិសម្រាប់កុមារបាត់ខ្លួននិងត្រូវបានគេកេងប្រវ័ញ្ច ស្របតាមច្បាប់របស់សហរដ្ឋអាមេរិក។ ការសិក្សាស្រាវជ្រាវស្តីពីការបញ្ឈប់គ្រោះថ្នាក់តស៊ូមតិអោយប្រើពាក្យសម្ភារៈរំលោភបំពានផ្លូវភេទកុមារជំនួសវិញ ស្របតាមគោលការណ៍ណែនាំលុចហ្សំបើក Luxembourg Guidelines.

* CyberTips នៅក្រោមប្រភេទនេះអាចសំដៅដល់រូបភាព CSAM ច្រើនជាងមួយ។ ឧទាហរណ៍ អ្នកផ្តល់សេវាអេឡិចត្រូនិកដែលរាយការណ៍មួយចំនួនបានដាក់បញ្ចូលរូបភាពជាច្រើនក្នុងរបាយការណ៍តែមួយ ខុសពីរូបភាពមួយក្នុងមួយរបាយការណ៍ និងរបាយការណ៍ជាច្រើនក្នុងសំណុំរឿងជនសង្ស័យតែម្នាក់។

Facebook ទទួលខុសត្រូវលើសេចក្តីរាយការណ៍ពាក់ព័ន្ធនឹងការសង្ស័យអំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ ច្រើនបំផុត ដែលត្រូវបានដាក់ជូន NCMEC នៅរវាងឆ្នាំ២០១៧ និងឆ្នាំ២០១៩។ សេចក្តីរាយការណ៍របស់ Facebook ពាក់ព័ន្ធនឹងកម្ពុជាបានកើនឡើងចំនួន ២៦៥% នៅរវាងឆ្នាំ២០១៧ និងឆ្នាំ២០១៩ និងធ្លាក់ចុះចំនួន ៣១% នៅរវាងឆ្នាំ២០១៨និងឆ្នាំ២០១៩។ ទោះបីជាបរិមាណមានទំហំតូចជាងគួរឱ្យកត់សម្គាល់ក្តី អ្នកផ្តល់សេវាកម្មមួយចំនួនដទៃទៀតមាននិន្នាការផ្ទុយពីនេះ ដោយមានការកើនឡើងជាបន្តបន្ទាប់នៅក្នុងរយៈពេលនេះ។

ភាពខុសគ្នានៃថ្នាលកម្មវិធីក្នុងចំណោមនៃការរាយការណ៍របស់អ្នកផ្តល់សេវាអេឡិចត្រូនិកដែលមានសក្តានុពលនិយាយអំពីលក្ខណៈធម្មជាតិទាក់ទងនឹងការសង្ស័យបទល្មើសពាក់ព័ន្ធករណីOCSEA សេចក្តីរាយការណ៍ពាក់ព័ន្ធនឹងការសង្ស័យអំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ នៅក្នុងប្រទេសកម្ពុជាបង្ហាញថា ការបង្ហោះរូបភាព និងកម្មវិធីជជែកជាវីដេអូមួយចំនួន រួមទាំងកម្មវិធីដែលបង្កលក្ខណៈឱ្យមានការជជែកជាវីដេអូដោយចៃដន្យ (e.g., Omeagle.com) កំពុងរាយការណ៍ករណី OCSEA ជូនដល់ NCMEC ។ ចំណុចនេះបង្ហាញនូវវត្តមានរបស់ជនល្មើស OCSEA ជាមួយនឹងការកំណត់បាននូវកម្រិតបច្ចេកទេស និងចំណាប់អារម្មណ៍ឯកទេសក្នុងកម្រិតមួយ។ ការប្រើប្រាស់កម្មវិធីដែលមានឯកទេសសម្រាប់ការផ្សាយបន្តផ្ទាល់សកម្មភាពផ្លូវភេទមនុស្សពេញវ័យ (ដូចជា Chaturbate) ដែលមែងតែងមានការបង់ប្រាក់ បង្កើនលទ្ធភាពនៃ OCSEA ជាមួយនឹងសមាសធាតុពាណិជ្ជកម្ម។

### ចំនួនអាសយដ្ឋាន IP ដែលត្រូវបានរាយការណ៍៖

អាសយដ្ឋានពិធីសារអ៊ីនធឺណិត (IP) ត្រូវកំណត់ចំពោះឧបករណ៍នីមួយៗនៅលើបណ្តាញជាក់លាក់ នៅពេលវេលាជាក់លាក់។ ទិន្នន័យនៃ NCMEC សម្រាប់កម្ពុជាក៏អនុញ្ញាតឱ្យមានការវិភាគកម្រិតខ្ពស់ទៅលើអាសយដ្ឋាន IP ដោយឡែក ដែលត្រូវបានប្រើប្រាស់ក្នុងការចូលរួមនៅក្នុងការកេងប្រវ័ញ្ចកុមារដែលត្រូវបានសង្ស័យផងដែរ។

តារាង ១៧៖ សេចក្តីរាយការណ៍ពាក់ព័ន្ធនឹងការសង្ស័យអំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ ចំនួននៃអាសយដ្ឋាន IP សម្រាប់ការផ្ទុកដោយឡែក បែងចែកទៅតាមឆ្នាំ។

| | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | % នៃការផ្លាស់ប្តូរពីឆ្នាំ២០១៧ ដល់ ២០១៩ | % នៃការផ្លាស់ប្តូរពីឆ្នាំ២០១៨ ដល់ ២០១៩ |
|---|---|---|---|---|---|
| អាសយដ្ឋាន IP សម្រាប់ការផ្ទុកដោយឡែកនៅកម្ពុជា | ៨.០៥៨ | ១៦.៥៩៤ | ១៩.០២៣ | ១៣៦% | ១៥% |
| របាយការណ៍សរុបសម្រាប់កម្ពុជា | ២៥.៣០៩ | ១៣១.៩០០ | ៩១.៤៥៨ | ២៦១% | -៣១% |
| របាយការណ៍ទៅតាមអាសយដ្ឋាន IP ដោយឡែក | ៣,១៤ | ៧,៩៥ | ៤,៨១ | ៥៣% | -៤០% |

មូលដ្ឋាន៖ ទិន្នន័យនៃសេចក្តីរាយការណ៍ ដែលផ្តល់ដោយ NCMEC។

ចំនួនរបាយការណ៍ខ្ពស់ជាងអាសយដ្ឋាន IP ដោយឡែកនានា (តារាង ១៧) បង្ហាញឱ្យឃើញនូវនិន្នាការ សម្រាប់ជនល្មើសក្នុងការផ្ទុកសម្ភារ CSAM ជាច្រើននៅក្នុងពេលដែលត្រូវបានរកឃើញ ដោយបង្កើតនូវសេចក្តីរាយការណ៍ជាច្រើនជាមួយនឹងអាសយដ្ឋាន IP ផ្ទុកដូចគ្នា។ ដោយសារចំនួននេះ គឺជាចំនួនមធ្យម ការសន្មតថា IPs ដែលត្រូវបានសង្ស័យមួយចំនួននឹងមានទំនាក់ទំនងជាមួយសេចក្តីរាយការណ៍កាន់តែច្រើន ហើយ IPs មួយចំនួននឹងមានទំនាក់ទំនងជាមួយសេចក្តីរាយការណ៍ចំនួនតិច គឺជាការសន្មតយ៉ាងសមហេតុផល។ នៅកម្រិតទូទៅ អត្រានេះនៅកម្ពុជាមានកម្រិតខ្ពស់ជាងប្រទេសដទៃទៀតនៅក្នុងវិសាលភាពនៃគម្រោងស្តីពី*ការបញ្ឈប់គ្រោះថ្នាក់* ដោយឡើងដល់កម្រិតខ្ពស់បំផុតនៅឆ្នាំ២០១៨ នៅចំនួនមធ្យមត្រឹមតែនៅក្រោមសេចក្តីរាយការណ៍ចំនួនប្រាំបីប៉ុណ្ណោះចំពោះអាសយដ្ឋាន IP ដោយឡែកមួយ។ក្នុងពេលជាមួយគ្នានេះដែរ សេចក្តីរាយការណ៍មួយ

---

* ការជជែកជាវីដេអូដំណើរការតាមរយៈកម្មវិធី ឬគេហទំព័រ និងអនុញ្ញាតឱ្យអ្នកប្រើអ៊ីនធឺណិតភ្ជាប់ជាមួយអ្នកប្រើប្រាស់អ៊ីនធឺណិតផ្សេងទៀតនៅគ្រប់ទីកន្លែងក្នុងពិភពលោក សម្រាប់ការប្រាស្រ័យទាក់ទងតាមវីដេអូ។

* ចំណាំ៖ អាសយដ្ឋាន IP ដូចគ្នាអាចត្រូវបានរាប់ក្នុងរយៈពេលច្រើនជាងមួយឆ្នាំ ហើយរបាយការណ៍មួយអាចមានអាសយដ្ឋាន IP ពិតប្រាកដច្រើនជាងមួយ។ វិធានការបច្ចេកទេសដាក់ចេញដោយ ISPs រួមទាំងការកំណត់ប្រើ អាសយដ្ឋាន IP ឌីណាមិច និងការចែករំលែកអាសយដ្ឋាន IP ជំនាន់ទៅ ៤ នៅលើឧបករណ៍មួយចំនួនធំក៏អាចជះឥទ្ធិពលដល់ចំនួនអាសយដ្ឋាន IP ពិតប្រាកដដែលត្រូវបានកត់ត្រាទុក ។

ដែលមានអាសយដ្ឋាន IP ផ្ទុកលើសពីមួយ គឺអាចកើតមាន។ ចំណុចនេះ អាចឆ្លុះបញ្ចាំងហេតុការណ៍នៃសង្ស័យអំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារលើសពីមួយ ដូចដែលនឹងកើតឡើងចំពោះការធ្វើការរាយការណ៍ដោយដៃ ដែលប្រមូលផ្តុំហេតុការណ៍ជាច្រើន សម្រាប់ការសង្ស័យតែមួយ។

ការទទួលបាន និងការចែកចាយ CSAM ស្ទើរតែស្មើនឹងសេចក្តីរាយការណ៍ទាំងអស់សម្រាប់ប្រទេសកម្ពុជា។ ទោះបីជាវិធីសាស្ត្រទំនើបនៃការចែកចាយ CSAM តាមរយៈបណ្តាញទំនាក់ទំនងសង្គម គឺជាវិធីសាស្ត្រទូទៅខ្លាំងក្តី ការចែកចាយក្នុងចំណោមអ្នកស្គាល់តាមបែបបុរាណនៅតែមាន។

ទិន្នន័យពីសម្ព័ន្ធសង្គ្រោះកុមារអំពី ការចែកចាយ CSAM នៅក្នុងចំណោមអ្នកស្គាល់គ្នា ក្នុងអំឡុងពេលចាប់ពីថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៩ ដល់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០ ត្រូវបានបង្ហាញខាងក្រោម។ ភាពតំណាងនៃទិន្នន័យសម្រាប់កម្ពុជារួមជាមួយនឹងទិន្នន័យសម្រាប់ប្រទេសគោលដៅដទៃទៀតនៃគម្រោងស្តីពី*ការបញ្ឈប់គ្រោះ*ថ្នាក់នៅអាស៊ីអាគ្នេយ៍អនុញ្ញាតឱ្យមានការប្រៀបធៀបគ្នាបាន (សូមមើលតារាង ១៨)។

តារាង ១៨. ការចែកចាយ CSAM និងការទាញយកពីប្រទេសគោលដៅនៃគម្រោងស្តីពី*ការបញ្ឈប់គ្រោះ*ថ្នាក់ដែលត្រូវបានសង្កេតទៅលើបណ្តាញចែកចាយឯកសារក្នុងចំណោមអ្នកស្គាល់គ្នា ដែលផ្តល់ដោយសម្ព័ន្ធសង្គ្រោះកុមារ។

| | អាសយដ្ឋាន IP | លេខសម្គាល់ដោយឡែកជាសកល GUIDs |
|---|---|---|
| កម្ពុជា | ១៣១៩ | ៩៥ |
| ឥណ្ឌូនេស៊ី | ១១២៤ | ២០២ |
| ម៉ាឡេស៊ី | ២៧៥៤ | ៥៥៨ |
| ហ្វីលីពីន | ១៩៧១ | ១៤៤៦ |
| ថៃ | ៣០៤៩ | ៦០៩ |
| វៀតណាម | ៩២៥ | ១៤១ |

មូលដ្ឋាន៖ ទិន្នន័យដែលផ្តល់សម្ព័ន្ធសង្គ្រោះកុមារ សម្រាប់រយៈពេលពីថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៩ ដល់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០។

ក្នុងអំឡុងរយៈពេលនៃសេចក្តីរាយការណ៍នេះ ជនល្មើសនៅកម្ពុជាមានទំនោរការលុបចោលកម្មវិធី (សូហ្វវែ) បន្ទាប់ពីការប្រើប្រាស់ម្តងៗហើយ ឬលុបចោលពីពេលមួយទៅពេលមួយ និងបញ្ចូលឡើងវិញ នៅពេលដែលពួកគេចង់ចែកចាយ ឬទាញយកម្តងទៀត។ ភាពខុសគ្នាកម្រិតខ្ពស់អាចបង្ហាញឆ្ពោះទៅរកការប្រើប្រាស់ IP ថាមវន្តរបស់ជនល្មើស។

ការចែកចាយនៅលើបណ្តាញរវាងម្នាក់ទៅម្នាក់ មិនសូវជាសកម្មភាព "ចម្បង" នោះទេ បើធៀបទៅនឹងការចែកចាយនៅតាមកម្មវិធីបណ្តាញសង្គមធំៗ អ្នកប្រើប្រាស់ចាំបាច់ត្រូវទាញយកសូហ្វវែរឯកទេស និងធ្វើការផ្ទុក និងស្វែងរក CSAM យ៉ាងសកម្ម ដែលជាញឹកញាប់ ស្រាវជ្រាវទៅតាមឈ្មោះរបស់ឯកសារ ដែលត្រូវបានចែកចាយនៅក្នុងបណ្តាញជនល្មើស។ នៅពេលជាមួយគ្នានេះដែរ ការចាប់យក

អាសយដ្ឋាន IP ជាច្រើនទៅតាមការតម្លើងកម្មវិធីចែកចាយឯកសារដែលតំណាងដោយចំនួននៃលេខកំណត់សម្គាល់ដោយឡែកជាសកលនៅក្នុងតួលេខខាងលើ បង្ហាញថា ជាមធ្យម ជនល្មើសកម្ពុជាបានចូលរួមនៅក្នុងនៅក្នុងការចែកចាយ CSAM ជាច្រើនដងនៅក្នុងរយៈពេល ដែលត្រូវកំណត់ជាសំណាក។ ការសង្កេតទាំងនេះបង្ហាញនូវ

បទល្មើស OCSEA ដែលមិនថមថយ និងដែលប្រព្រឹត្តដោយអ្នកបុគ្គលមួយចំនួននៅក្នុងប្រទេសកម្ពុជា។

## ការស្វែងរកនៅតាមគេហ៍ទំព័រ ដើម្បីរក CSAM

ការស្រាវជ្រាវត្រូវបានធ្វើឡើងលើ Google Trends ដើម្បីកំណត់កម្រិតនៃចំណាប់អារម្មណ៍ចំពោះ CSAM នៅកម្ពុជា។ ក្នុងឧទាហរណ៍ដំបូង ក្រុមការងារបទល្មើសលើកុមាររបស់នគរបាលអន្តរជាតិបានជ្រើសរើសពាក្យជាសំណាកចំនួន ២០ ដើម្បីធ្វើជាពាក្យគន្លឹះ និងឃ្លាសម្រាប់ចំណាប់អារម្មណ៍ចំពោះ CSAM របស់អ្នកឯកទេស។ ពាក្យទាំងនេះត្រូវបានជ្រើសរើស ដោយផ្អែកលើចំណេះដឹងឯកទេសអំពីឈ្មោះឯកសារពាក់ព័ន្ធនឹង CSAM សំណួររបស់ជនល្មើស និងគ្រាមភាសា ដែលត្រូវបានប្រើប្រាស់នៅក្នុងសហគមន៍ជនល្មើស។ សំណួរនានាអំពីការស្វែងរកនៅកម្ពុជាក្នុងរយៈពេលពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ បានផ្តល់លទ្ធផលត្រលប់ថា "ទិន្នន័យមិនគ្រប់គ្រាន់" សម្រាប់ពាក្យនីមួយៗក្នុងចំណោមពាក្យគន្លឹះទាំង២០នេះ។ ការផ្តល់ត្រលប់ថា "ទិន្នន័យមិនគ្រប់គ្រាន់" ស្មើនឹងពិន្ទុសូន្យនៃភាព

* Globally Unique Identifier (GUID) គឺជាលេខ ១២៨-bit ដែលបង្កើតឡើងដោយប្រព័ន្ធប្រតិបត្តិការ Windows ឬកម្មវិធី Windows ផ្សេងទៀត ដើម្បីកំណត់រកសមាសធាតុជាក់លាក់ ផ្នែករឹង កម្មវិធី ឯកសារ គណនីអ្នកប្រើប្រាស់ ប្រព័ន្ធទិន្នន័យដ្ឋាន និងធាតុផ្សេងទៀត។

* Google Trends (trends.google.com) គឺជាឧបករណ៍ដាក់អោយប្រើជាសាធារណៈដែលផ្តល់លទ្ធផលមកវិញអំពីប្រជាប្រិយភាពនៃពាក្យគន្លឹះស្វែងរក និងខ្សែអក្សរដែលទាក់ទងទៅនឹងអ្វីផ្សេងទៀតនៅក្នុងប៉ារ៉ាម៉ែត្រដែលបានកំណត់។ ជាជាងគ្រាន់តែបង្ហាញចំនួនស្វែងរកសរុប ឧបករណ៍នឹងគណនាពិន្ទុ (ក្នុងចន្លោះពី ១ ដល់ ១០០) ដោយផ្អែកលើពាក្យស្វែងរក ឬសមាមាត្រនៃខ្សែអក្សរចំពោះការស្វែងរកទាំងអស់លើពាក្យ/ខ្សែអក្សរទាំងអស់។ ទិន្នន័យត្រូវបានបែងចែកដោយការស្វែងរកសរុបនៅក្នុងប៉ារ៉ាម៉ែត្រជាភូមិសាស្ត្រ និងពេលវេលាដែលត្រូវបានកំណត់ ដើម្បីសម្រេចបាននូវប្រជាប្រិយភាពនៃការស្វែងរក។ ខណៈពេលដែល Google Trends ទាញយកតែគំរូនៃការស្វែងរករបស់ Google នោះ សំណុំទិន្នន័យត្រូវបានចាត់ទុកដោយក្រុមហ៊ុនថាមានលក្ខណតំណាង ដោយសារតែការស្វែងរករាប់ពាន់លានត្រូវបានដំណើរការក្នុងមួយថ្ងៃ។ សម្រាប់ព័ត៌មានបន្ថែមអំពីទិន្នន័យ និងការដាក់ពិន្ទុ សូមមើល៖ សំណួរគេសួរញឹកញាប់អំពីទិន្នន័យរបស់ Google Trends data.

* ពាក្យជាភាសាអង់គ្លេសត្រូវបានជ្រើសរើសដោយសារគ្រាមភាសាក្នុងស្រុកធ្វើអោយមានលទ្ធផលមិនទៀងទាត់។ បច្ចេកស័ព្ទឯកទេសជាសកលទាំងនេះត្រូវបានកំណត់ដោយក្រុមការងារប្រឆាំងឧក្រិដ្ឋកម្មលើកុមាររបស់ INTERPOL ។ ដើម្បីរក្សាភាពដូចគ្នានៅក្នុងរបាយការណ៍នៃការសិក្សាស្រាវជ្រាវទាំងអស់ ពាក្យជាភាសាដើមមិនត្រូវបានប្រើទេ លុះត្រាតែមានលក្ខខណ្ឌមួយចំនួនត្រូវបានផ្តល់ជូន។

ពេញនិយម ដែលបង្ហាញនូវកម្រិតនៃចំណាប់អារម្មណ៍ទាបដែលអាចប្រៀបធៀបបានចំពោះពាក្យនោះ (ជាជាងថា គ្មានលទ្ធផលទាល់តែសោះសម្រាប់ការស្វែងរកនោះ) នៅក្នុងកម្រិតភូមិសាស្ត្រ និងពេលវេលា ដែលត្រូវបានកំណត់។ នៅពេលប្រៀបធៀបជាមួយលទ្ធផលនៃការស្វែងរកជាសកល សម្រាប់ពាក្យដូចគ្នានេះ និងចំពោះការស្វែងរក ដែលត្រូវបានធ្វើនៅក្នុងប្រទេសដទៃទៀតនៅក្នុងរយៈពេលដូចគ្នា ចំណុចនេះបង្ហាញឱ្យឃើញថា ពាក្យដែលត្រូវបានស្រាវជ្រាវរក CSAM ជាឯកទេស អាចត្រូវបានប្រើប្រាស់នៅកម្ពុជាតិចជាងនៅក្នុងប្រទេសមួយចំនួនដទៃទៀត។ បើទោះបីជា អាចមានការរ៉េកញែកថា អ្នកស្វែងរក CSAM ដែលមានការយល់ដឹងច្រើន មិនទំនងជាស្វែង រកនៅក្នុងគេហ៍ទំព័របែបចំហរក្តី ភាពពេញនិយមពាក់ព័ន្ធនៃពាក្យនៅក្នុងសំណាករបស់នគរបាលអន្តរជាតិនៅ ប្រទេសដទៃទៀតនឹងបង្ហាញឱ្យឃើញថា ការស្វែងរកតាមគេហ៍ទំព័របើកចំហរនៅតែត្រូវបានប្រើប្រាស់ ដើម្បីស្វែងរក CSAM។

ទោះបីជាជនទាំងឡាយនៅកម្ពុជាដែលស្វែងរក CSAM អាចស្វែងរកជាភាសាដទៃទៀតក្រៅពីភាសាអង់គ្លេសក្តី មិនមានព័ត៌មានអំពីការប្រើប្រាស់ពាក្យស្វែងរកជាភាសាក្នុងមូលដ្ឋាន ឬគ្រាមភាសាឡើយ។ អាជ្ញាធរអនុវត្ត ច្បាប់អាចបំពេញភាពខ្វះចន្លោះ តាមរយៈការពិនិត្យឡើងវិញលើការស៊ើបអង្កេត OCSEA នៅកម្ពុជា ដើម្បីកំណត់រកពាក្យបន្ថែមទៀត និងឃ្លាសម្រាប់ការស្វែងរក ដែលជនល្មើសប្រើប្រាស់។ ទោះបីជាយ៉ាងណាក្តី លទ្ធផលដែលត្រូវបានដកស្រង់ខាងលើ ទំនងជាបង្ហាញថា មានតម្រូវការមួយចំពោះ CSAM នៅកម្ពុជា និងបង្ហាញអំពីការប្រើប្រាស់គេហទំព័របើកចំហរ ដើម្បីស្វែងរកសម្ភារប្រភេទនេះ។

### ការបង្ហោះ CSAM

ប្រទេសកម្ពុជាមិនត្រូវបានកំណត់ថាជាប្រទេសប្រភពបង្ហោះរូបភាព និងវីដេអូ ដែលត្រូវបានវាយតម្លៃថាខុសច្បាប់ដោយបណ្តាញរាយការណ៍ជាសមាជិករបស់ INHOPE តាមរយៈប្រព័ន្ធចាត់ចំណាត់ថ្នាក់រូបភាព ICCAM ឡើយ។ លើសពីនេះ មូលនិធិឃ្លាំមើលលើប្រព័ន្ធអ៊ីនធឺណិតបានចាត់វិធានការលើរបាយការណ៍ចំនួនសូន្យពាក់ព័ន្ធនឹងការបង្ហោះរូបភាព CSAM ដែលមានការបញ្ជាក់ នៅប្រទេសកម្ពុជានៅចន្លោះឆ្នាំ២០១៧ និងឆ្នាំ២០១៩។ ដោយសារទិន្នន័យពាក់ព័ន្ធនឹង ICCAM

ត្រូវបានកំណត់ត្រឹមការផ្តល់ជូនតែក្នុងចំណោមបណ្តាញរាយការណ៍ជាសមាជិករបស់ INHOPE និងដោយសារមូលនិធិឃ្លាំមើលតាមប្រព័ន្ធអ៊ីនធឺណិត ប្រតិបត្តិការជាចម្បងបណ្តាញរាយការណ៍អំពី CSAM របស់ចក្រភពអង់គ្លេស ចំណុចនេះមិនគប្បីចាត់ទុកជាភស្តុតាងនៃការគ្មានការបង្ហោះ CSAM នៅក្នុងប្រទេសឡើយ។

## ២.១.៣ ទំនាក់ទំនងជាមួយនឹងវិស័យធ្វើដំណើរ និងទេសចរណ៍

កំណើនសេដ្ឋកិច្ចកម្ពុជាពីវិស័យទេសចរណ៍ ព្រមទាំងការវិនិយោគផ្នែកធុរកិច្ច បានជះឥទ្ធិពលលើចរិតនៃការកេងប្រវ័ញ្ចផ្លូវភេទកុមារ ដែលធ្វើឱ្យប្រទេសកម្ពុជាក្លាយជាគោលដៅដ៏ពេញនិយមបំផុតមួយនៅក្នុងតំបន់នេះ សម្រាប់ជនល្មើសដែលធ្វើដំណើរដើម្បីស្វែងរកសកម្មភាពផ្លូវភេទជាមួយកុមារ។ ភាពខុសគ្នាគួរឱ្យកត់សម្គាល់នៃប្រាក់ចំណូលរវាងអ្នកទេសចរណ៍ដែលមានចំណូលមធ្យម និងកុមារក្នុងមូលដ្ឋាន ធ្វើឱ្យកុមារហានិភ័យចំពោះការកេងប្រវ័ញ្ចផ្លូវភេទ។ សំណើរនានាបង្ហាញថា បរិបទដែលមានការទទួលស្គាល់ជាទូទៅមួយចំនួន ដែលការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅក្នុងវិស័យធ្វើដំណើរការ និងទេសចរណ៍ កើតឡើងរួមមាន ការប្រព្រឹត្តល្មើសក្នុងសហគមន៍ ការធ្វើជាអ្នកស្ម័គ្រចិត្ត ការ

មកលេងរបស់គ្រូបង្រៀនបរទេស ការណាត់ជួបដោយផ្តល់សំណង និងតាមរយៈធុរកិច្ច ដែលប្រតិបត្តិការជាមួយការវិនិយោគសេដ្ឋកិច្ចទំហំធំៗ ពោលគឺ តំបន់សេដ្ឋកិច្ចពិសេស។ ទោះបីជាយ៉ាងណាក្តី មានការសង្កេតឃើញថា ការកេងប្រវ័ញ្ចនៅតាមផ្លូវ ដែលជនល្មើសកំណត់

គោលដៅលើកុមារនៅតាមដងផ្លូវ បានធ្លាក់ចុះនៅក្នុងរយៈពេលកន្លងទៅ។ បើទោះបីជាការធ្លាក់ចុះនេះអាចបណ្តាលមកពីការយកចិត្តទុកដាក់កាន់តែខ្លាំងពីទីភ្នាក់ងារអនុវត្តច្បាប់ និងការផ្តល់ដោយជោគជ័យនូវកម្មវិធីទប់ស្កាត់ កម្មវិធីឃ្លាំមើល និងកម្មវិធីកិច្ចការពារក្តី ប្រហែលបញ្ហានេះអាចត្រូវបានពន្យល់ដោយទិន្នាការជាសកល ដែលបច្ចេកវិទ្យា និងឧស្សាហកម្មធ្វើដំណើរដែលគ្មានការគ្រប់គ្រងពីរដ្ឋាភិបាល បានធ្វើឱ្យជនល្មើសកាន់តែមានភាពងាយស្រួលក្នុងការទំនាក់ទំនងជាមួយកុមារក្នុងលក្ខណៈលាក់បាំងកាន់តែខ្លាំង ហើយការកំណត់រកបទល្មើសរបស់ពួកគេកាន់តែមានការលំបាក។

ការសិក្សានៅឆ្នាំ២០២០ បានរកឃើញថា អាជ្ញាធរនានាកំពុងប្រឈមមុខនឹងបញ្ហាប្រឈមក្នុងការសម្របទៅតាមចរិតកំពុងវិវឌ្ឍនៃការរំលោភបំពានផ្លូវភេទកុមារនៅក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍។ ការយល់ឃើញជាសាធារណៈអំពីប្រធានបទនេះក៏មានឥទ្ធិពលធ្វើឱ្យមនុស្សជាច្រើនរំពឹងគិតថា ជនល្មើសគឺជាបុរសមកពីប្រទេសលោកខាងលិច ទោះបីជាយ៉ាងណាក្តី អ្នកបើកបររ៉ឺម៉ក យុវជន និងមគ្គុទេសក៍ទេសចរណ៍បានកត់សម្គាល់នៅក្នុងការស្រាវជ្រាវនេះថា ជាញឹកញាប់សេចក្តីត្រូវការបែបនេះគឺកើតចេញពីអ្នកទេសចរណ៍អាស៊ី (សម្រាប់ព័ត៌មានបន្ថែមអំពីជនល្មើស សូមមើលជំពូក ២.៤.២)
មជ្ឈមណ្ឌល Angel Watch Center នៃអង្គភាពស៊ើបអង្កេតសន្តិសុខមាតុភូមិសហរដ្ឋអាមេរិក ផ្តល់ការបញ្ជូនទៅដល់មន្ត្រីនានានៅក្នុងប្រទេសគោលដៅអំពី ជនល្មើសផ្លូវភេទកុមារសហរដ្ឋអាមេរិកដែលត្រូវបានផ្តន្ទាទោស ដែលមានការបញ្ជាក់អំពីកាលវិភាគនៃការធ្វើដំណើរ។ នៅឆ្នាំ២០១៧ មានការបញ្ជូនចំនួន១១ និងការបដិសេធការចូលចំនួនប្រាំបួនសម្រាប់កម្ពុជា។ នៅឆ្នាំបន្ទាប់ ការបញ្ជូនមានចំនួន២០ និងការបដិសេធការចូលចំនួន ១៦។ នៅឆ្នាំ២០១៩ ចំនួននេះបានធ្លាក់ចុះមកនៅត្រឹមការបញ្ជូនចំនួន៦ និងការបដិសេធការចូលចំនួន៣។ ការបដិសេធ ការចូលដែលត្រូវបានបញ្ជាក់ បង្ហាញនូវការសម្របសម្រួលវិជ្ជមានរវាងការិយាល័យអន្តោប្រវេសន៍ និងអង្គភាពជំនាញផ្នែកប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរបស់ប្រទេសកម្ពុជា។

# ២.២ បទពិសោធន៍របស់កុមារអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារនៅកម្ពុជា

នៅក្រោមគម្រោងស៊ីពី *ការបញ្ឈប់គ្រោះថ្នាក់* OCSEA ត្រូវបានកំណត់និយមន័យយ៉ាងជាក់លាក់ ដើម្បីបញ្ចូលការលួងលោមតាមប្រព័ន្ធអនឡាញសម្រាប់គោលបំណងផ្លូវភេទ CSAM និងការផ្សាយបន្តផ្ទាល់នៃការរំលោភបំពានផ្លូវភេទកុមារ។ ទស្សនទានទាំងនេះត្រូវបានប្រើប្រាស់នៅក្នុងជំពូកនេះ ដើម្បីរៀបចំ និងបង្ហាញរបកគំហើញនៃការសិក្សានេះ។ នៅក្នុងពេលជាមួយគ្នានេះដែរ ត្រូវទទួលស្គាល់ថា វិធីនានាដែលកុមារទទួលរង OCSEA រមែងតែងមានភាពស្មុគស្មាញខ្លាំងណាស់ដែលមានភាពប្លែកៗពីគ្នា។ បទពិសោធន៍ ឬបទល្មើសពាក់ព័ន្ធរមែងតែងកើតឡើងក្នុងលក្ខណៈរួមបញ្ចូលគ្នា ឬទៅតាមលំដាប់លំដោយ។ លើសពីនេះ ដូចការបង្ហាញនៅក្នុងប្រអប់ស្តីពី ការបន្តការកេងប្រវ័ញ្ច *និងការរំលោភបំពានផ្លូវភេទកុមារក្នុង និងក្រៅប្រព័ន្ធអនឡាញ*នៅទំព័រ ៣៩ OCSEA មិនត្រឹមតែកើតឡើងនៅក្នុងបរិយាកាសឌីជីថលប៉ុណ្ណោះឡើយ បច្ចេកវិទ្យាឌីជីថលក៏អាចត្រូវបានប្រើប្រាស់ជាឧបករណ៍មួយ ដើម្បីសម្របសម្រួល ឬកត់ត្រាការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទដោយផ្ទាល់ផងដែរ។

ការអង្កេតតាមខ្នងផ្ទះនៃគម្រោងស៊ីពី *ការបញ្ឈប់គ្រោះ*ថ្នាក់ទៅលើកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតអាយុ ១២-១៧ ឆ្នាំ បានវាស់វែងអំពីការបង្ហាញរបស់កុមារអំពីផលប៉ះពាល់នៃ OCSEA ដែលនឹងត្រូវបានបង្ហាញជាលក្ខណបុគ្គលដូចខាងក្រោម។ នៅពេលប្របាច់បញ្ចូលគ្នា ទិន្នន័យបានបង្ហាញថា ក្នុងឆ្នាំកន្លងមក ប្រមាណ ១១% នៃកុមារកំពុងប្រើប្រាស់អ៊ីនធឺណិតអាយុ១២-១៧ឆ្នាំនៅកម្ពុជា គឺជាជនរងគ្រោះនៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញដែលមានជាឧទាហរណ៍ច្បាស់។ ស្ថិតិសរុបនេះរួមបញ្ចូលសូចនាករចំនួន៤ នៃ OCSEA ដែលកុមារទទួលរងក្នុងឆ្នាំកន្លងមក៖

១. មានជនណាម្នាក់បានស្នើផ្តល់លុយកាក់ ឬអំណោយ ជាថ្នូរនឹងរូបភាព ឬវីដេអូផ្លូវភេទ

២. មានជនណាម្នាក់បានស្នើលុយកាក់ ឬអំណោយអនឡាញ ដើម្បីជួបគ្នាផ្ទាល់ និងធ្វើសកម្មភាពផ្លូវភេទ

៣. មាជនណាម្នាក់បានចែករំលែករូបភាពផ្លូវភេទរបស់អ្នកដោយគ្មានការអនុញ្ញាតពីអ្នក

៤. មានជនណាម្នាក់បានសំឡុត ឬគំរាមអ្នកនៅលើអនឡាញដើម្បីឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទ

យោងតាមការប៉ាន់ប្រមាណនៃគម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* នៅពេលធ្វើមាត្រដ្ឋានទៅចំនួនកុមារដែលកំពុងប្រើប្រាស់អ៊ីនធឺណិតសម្រាប់អាយុនេះ តំណាងឱ្យកុមារប្រមាណ ១៦០.០០០នាក់នៅកម្ពុជា ដែលជាជនរងគ្រោះទាំងនេះ យ៉ាងហោចណាស់មួយទម្រង់ ក្នុងរយៈពេលត្រឹមតែមួយឆ្នាំ។ ការអង្កេតនេះរួមបញ្ចូលតែអ្នកដែលកំពុងប្រើប្រាស់អ៊ីនធឺណិតដែលរស់នៅផ្ទះប៉ុណ្ណោះ មានន័យថាមានកុមារជាច្រើនទៀតដែលងាយរងគ្រោះ ដូចជាកុមារដែលចូលរួមក្នុងការធ្វើចំណាកស្រុក ឬកុមាររស់នៅតាមថ្នល់ដែលមិនត្រូវបានតំណាងនៅក្នុងតួលេខនេះទេ។

### ២.២.១ ការលួងលោមតាមប្រព័ន្ធអនឡាញ

គម្រោងស្តីពី *ការបញ្ឈប់គ្រោះ*ថ្នាក់ កំណត់និយមន័យនៃការលួងលោមតាមប្រព័ន្ធអនឡាញថា ជាការបង្កលក្ខណសម្រាប់ការចូលរួមរបស់កុមារតាមរយៈបច្ចេកវិទ្យា ជាមួយចេតនារំលោភបំពាន ឬកេងប្រវ័ញ្ចផ្លូវភេទកុមារ ។ អំពើនេះអាចកើតឡើងនៅក្នុងប្រព័ន្ធអនឡាញទាំងស្រុង ឬតាមរយៈទាំងប្រព័ន្ធអនឡាញ និងការជួបគ្នាដោយផ្ទាល់ រួមបញ្ចូលគ្នា។

ការលួងលោមតាមប្រព័ន្ធអនឡាញ គឺជាដំណើរការដ៏ស្មុគស្មាញ ដែលរមែងតែងមានលក្ខណប្រែប្រួល និងពិបាកកំណត់ស្គាល់ ជាពិសេសនៅពេលដែលវាពាក់ព័ន្ធនឹងការកសាងទំនុកចិត្តយឺតៗរវាងជនល្មើស និងកុមារ ក្នុងរយៈពេលយ៉ាងវែង។ ជាញឹកញាប់ កុមារត្រូវបាន "រៀបចំ" សម្រាប់ការរំលោភបំពានផ្លូវភេទ និងចូលរួមនៅក្នុងសកម្មភាពផ្លូវភេទតាមប្រព័ន្ធអនឡាញ ឬដោយជួបគ្នាផ្ទាល់ តាមរយៈមធ្យោបាយនៃការបោកប្រាស់ បង្ខិតបង្ខំ ឬការគំរាមកំហែង។ ទោះបីជាយ៉ាងណាក្តី ការលួងលោមតាមប្រព័ន្ធអនឡាញក៏អាច ឬទំនងជាកើតឡើងភ្លាមៗដោយគ្មានការរំពឹងទុកផងដែរ ដោយជនល្មើសស្នើសុំ ឬដាក់សម្ពាធលើកុមារភ្លាមៗឱ្យចែកចាយមាតិកាផ្លូវភេទអំពីខ្លួនឯង ឬចូលរួមនៅក្នុងសកម្មភាពផ្លូវភេទ រួមទាំងតាមរយៈការគំរាមកំហែង។

ផ្នែកបន្ទាប់ផ្តោតការយកចិត្តទុកដាក់លើបទពិសោធន៍របស់កុមារអំពីទិដ្ឋភាពផ្សេងៗគ្នានៃការលួងលោមតាមប្រព័ន្ធអនឡាញ ដូចដែលបានគូសបញ្ជាក់នៅក្នុងការអង្កេតតាមខ្នងផ្ទះអំពី ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត របស់កុមារអាយុ ១២-១៧ឆ្នាំ។ ដោយទទួលស្គាល់ថា ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារអាចកើតឡើងក្នុងទម្រង់ និងនៅកន្លែងខុសៗគ្នាជាច្រើន ពីន្ទុទិន្នន័យភាគច្រើនខាងក្រោមអនុញ្ញាតឱ្យមានការឆ្លើយតបជាច្រើន និងអាចបន្ថែមលើសពី ១០០%។

## ២.២ បទពិសោធន៍របស់កុមារអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារនៅកម្ពុជា

### ច្បាប់ស្តីពីការលួងលោម

ទោះបីជាច្បាប់កម្ពុជាមិនទាន់បានកំណត់ជាបទល្មើសយ៉ាងច្បាស់ចំពោះការលួងលោមកុមារតាមប្រព័ន្ធអនឡាញសម្រាប់គោលបំណងផ្លូវភេទថាជាបទល្មើសដោយឯកឯងក្តី ក្រមព្រហ្មទណ្ឌបានកំណត់ជាបទល្មើសចំពោះ "ការរៀបចំដោយមនុស្សពេញវ័យ  សម្រាប់ការជួបជុំដែលពាក់ព័ន្ធនឹងការបង្ហាញដោយមិនសមរម្យ ឬទំនាក់ទំនងផ្លូវភេទដោយមានវត្តមានរបស់អនីតិជន ឬការចូលរួមរបស់អនីតិជន។" ទោះបីជាការកំណត់ជាបទល្មើសចំពោះលទ្ធផលមួយក្នុងចំណោមលទ្ធផលដែលអាចមាននៃដំណើរការលួងលោម ពោលគឺការចូលរួមនៅក្នុងសកម្មភាពផ្លូវភេទនៅពេលជួបគ្នាដោយផ្ទាល់ក្តី បទប្បញ្ញត្តិនេះមិនបានកំណត់ជាបទល្មើសចំពោះដំណើរការនៃការកសាងទំនុកចិត្តរវាងជនល្មើស និងកុមារ ព្រមទាំងស្ថានភាពនានា ដែលការរំលោភបំពានផ្លូវភេទកើតឡើងតាមប្រព័ន្ធអនឡាញឡើយ ឧទាហរណ៍ ប្រសិនបើ កុមារម្នាក់ត្រូវស្នើសុំឱ្យបញ្ជូនមាតិកាផ្លូវភេទទៅកាន់ជនល្មើសតាមកម្មវិធីអនឡាញ។

### ការលួងលោមសក្តានុពល - កុមារត្រូវបានស្នើសុំឱ្យនិយាយអំពីបញ្ហាផ្លូវភេទ

នៅក្នុងការអង្កេតតាមខ្នងផ្ទះអំពី កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា កុមារត្រូវបានសួរថា តើពួកគេបានជួបប្រទះនឹងអាកប្បកិរិយាជាក់លាក់នៅឆ្នាំមុន ដែលអាចជាសញ្ញានៃការលួងលោមដែរឬទេ។ បន្ទាប់មក កុមារទាំងឡាយ ដែលអាចបានជួបប្រទះនឹងការលួងលោមត្រូវបានសួរសំណួរបន្តអំពី លើកមុន ដែលអាកប្បកិរិយានោះបានកើតឡើងចំពោះពួកគេ៖ តើពួកគេមានអារម្មណ៍យ៉ាងដូចម្តេច តើវាបានកើតឡើងនៅក្នុង ឬនៅក្រៅប្រព័ន្ធអនឡាញ (ឬទាំងពីរ) តើនរណាដែលប្រព្រឹត្តអាកប្បកិរិយានោះចំពោះអ្នក និងតើពួកគេបានប្រាប់នរណាម្នាក់អំពីអាកប្បកិរិយានោះដែរឬទេ។ ដោយសារកុមារមួយចំនួនតូចបានជួបប្រទះនឹងការលួងលោមដែលអាចមាន សំណួរបន្តទាំងនេះជាច្រើនពាក់ព័ន្ធនឹងអនុសំណាកចំនួនតូច។ ក្នុងករណីបែបនេះ នៅពេលដែលសំណាកមានចំនួនតិចជាង ៥០ ចំនួនទាំងស្រុងត្រូវបានបង្ហាញជំនួសការបង្ហាញជាភាគរយ ដើម្បីជៀសវាងការបកស្រាយទិន្នន័យខុស។ ដោយទទួលស្គាល់ថា OCSEA អាចកើតឡើងតាមមធ្យោបាយ និងទីកន្លែងផ្សេងៗគ្នា ទិន្នន័យភាគច្រើនខាងក្រោមអនុញ្ញាតឱ្យមានការឆ្លើយចម្លើយច្រើនជាងមួយ ហើយអាចបន្ថែមលើសពី១០០%។ ជាចុងក្រោយភាពខុសគ្នារវាងក្រុមអាយុ ក្មេងប្រុស និងក្មេងស្រី នៅតំបន់ទីក្រុង និងជនបទ ត្រូវបានរាយការណ៍ថាមានតែ ៥% ប៉ុណ្ណោះ ឬច្រើនជាងនេះ។

ក្នុងចំណោមកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ចំនួន ៩៩២នាក់នៅកម្ពុជា ៩% (៨៩នាក់) បានទទួលការស្នើសុំដែលពួកគេមិនចង់បានឱ្យនិយាយអំពីបញ្ហាផ្លូវភេទ ឬសកម្មភាពផ្លូវភេទ នៅឆ្នាំមុន។ កុមារាទំនងជារាយការណ៍ថាបញ្ហានេះបានកើតឡើងចំពោះពួកគេ (១១%) ច្រើនជាងកុមារី (៧%) ដោយគ្មានភាពខុសគ្នាទៅតាមអាយុឡើយ។ អាស្រ័យលើបរិបទ បទពិសោធន៍ទាំងនេះអាចថា មានគ្រោះថ្នាក់កម្រិតខុសៗគ្នាចំពោះកុមារ។ ឧទាហរណ៍ កុមារម្នាក់ដែលត្រូវបានមិត្តប្រុស ឬមិត្តស្រីសំណូមពរឱ្យនិយាយអំពីបញ្ហាផ្លូវភេទ ប៉ុន្តែមិនចង់និយាយនៅពេលនោះ អាចមិនប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរពីអន្តរ

ទំនាក់ទំនងនេះឡើយ។ ផ្ទុយទៅវិញ បទពិសោធន៍ទាំងនេះក៏អាចបង្ហាញនូវករណីនៃការប៉ុនប៉ងលួងលោមដែលមានចេតនាបង្កគ្រោះថ្នាក់ផងដែរ ហេតុនេះ ករណីនេះត្រូវបានពណ៌នាថា ជាករណីលួងលោមសក្តានុពល (និងជាក់ស្តែង)។

**ក្នុង ឬក្រៅប្រព័ន្ធអនឡាញ?** ក្នុងចំណោមកុមារទាំង៨៩នាក់នៅក្នុងការអង្កេតតាមខ្នងផ្ទះ ដែលបានទទួលសំណើដែលពួកគេមិនចង់បានឱ្យនិយាយអំពី ផ្លូវភេទនៅឆ្នាំមុន ៣៧%នៃពួកគេបានទទួលសំណើនេះចុងក្រោយគេនៅតាមប្រព័ន្ធអនឡាញ ភាគច្រើនតាមរយៈបណ្តាញទំនាក់ទំនងសង្គម និងមួយចំនួនតូចតាមរយៈកម្មវិធីហ្គេមអនឡាញ។ សម្រាប់កុមារ ដែលបាននិយាយថា ពួកគេបានទទួលសំណើតាមបណ្តាញទំនាក់ទំនងសង្គម សំណើបែបនេះភាគច្រើនត្រូវបានបញ្ជូនមកពួកគេតាមរយៈ Facebook ឬ Facebook Messenger។ ចំណុចនេះបង្ហាញឱ្យឃើញថា កុមារចំនួន៣% (៣១នាក់) នៅក្នុងការអង្កេតតាមខ្នងផ្ទះនៅកម្ពុជា បានទទួលសំណើដែលពួកគេមិនចង់បាន ឱ្យនិយាយអំពី បញ្ហាផ្លូវភេទ នៅឆ្នាំមុន។ គួរឱ្យកត់សម្គាល់ កុមារ ៣២% បានរាយការណ៍អំពី ការទទួលបានសំណើឱ្យនិយាយអំពី ផ្លូវភេទ នៅក្នុងការជួបគ្នាដោយផ្ទាល់ និង២៤% បានរាយការណ៍ថា ពួកគេមិនដឹងអំពីរបៀបនៃការធ្វើសំណើបែបនេះឡើយ ស្របពេល ៩% មិនចង់និយាយ។

ដោយសារការសុំឱ្យកុមារនិយាយអំពីបញ្ហាផ្លូវភេទ អាចកើតឡើងដោយមិនពាក់ព័ន្ធនឹងបច្ចេកវិទ្យា កុមារចំនួនតែ ៣១នាក់ប៉ុណ្ណោះ ដែលបាននិយាយថា ការសំណើបែបនេះបានកើតឡើងតាមបណ្តាញទំនាក់ទំនងសង្គម ឬកម្មវិធីលេងហ្គេមអនឡាញ ដែលមានបង្ហាញនៅក្នុងការវិភាគជាបន្តបន្ទាប់ទៀត ដោយសារកម្មវិធីទាំងនេះតំណាងឱ្យករណី OCSEA សក្តានុពល។

## ២.២ បទពិសោធន៍របស់កុមារអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារនៅកម្ពុជា

**តើកុមារបានមានអារម្មណ៍ និងឆ្លើយតបយ៉ាងដូចម្តេច៖** កុមារចំនួនតែ ៥នាក់ប៉ុណ្ណោះក្នុងចំណោមកុមារទាំង ៣១នាក់ ដែលបានទទួលសំណើមិនជាទីចង់បាន ឱ្យនិយាយអំពីបញ្ហាផ្លូវភេទតាមប្រព័ន្ធអនឡាញ បាននិយាយថា ការស្នើសុំនេះមិនមានឥទ្ធិពលលើពួកគេឡើយ កុមារដទៃទៀតបានមានអារម្មណ៍អវិជ្ជមានចំពោះការស្នើសុំបែបនេះ លើពួកគេលើកឡើងអំពីអារម្មណ៍បន្ទោសខ្លួនឯង អាម៉ាស និងភ័យខ្លាច។ នៅក្នុងការឆ្លើយតប កុមារជាងពាក់កណ្តាលប៉ុណ្ណោះ (១៩នាក់) បានបដិសេធចំពោះការនិយាយបែបនេះ។ កុមារមួយចំនួនបានឈប់ប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត មួយរយៈ កុមារផ្សេងទៀតមិនអើពើចំពោះបញ្ហានេះ ប្លុកជនល្មើស ឬលុបសារពីពួកគេចោល។

*ជនរងគ្រោះម្នាក់បានប្រាប់ឱ្យដឹងថា "នៅពេលខ្លះ ខ្ញុំបានលេងឆាត ហើយនរណាម្នាក់បានហៅមកខ្ញុំ និងបង្ហាញប្រដាប់ភេទរបស់ពួកគេ ខ្ញុំបានប្លុកបុគ្គលនោះចោល។"* (RA៥-CA-១១)

គួរឱ្យព្រួយបារម្ភ កុមារចំនួន ៩នាក់ក្នុងចំណោមកុមារទាំង ៣១នាក់ ជាពិសេសកុមារអាយុ ១២-១៣ ឆ្នាំ និងកុមារី បានទទួលយកការស្នើសុំឱ្យនិយាយអំពីបញ្ហាផ្លូវភេទ។ កុមារដទៃទៀតបានព្យាយាមកុំឱ្យបុគ្គលទាំងនោះរំខានពួកគេទៀត ឬបានផ្លាស់ប្តូរការកំណត់ឯកជនភាពរបស់ពួកគេ។ កុមារតែម្នាក់ប៉ុណ្ណោះ បានរៀបរាប់អំពីអ្វីដែលបានកើតឡើងតាមប្រព័ន្ធអនឡាញ។

**តើនរណាជាអ្នកធ្វើសំណើទាំងនោះ?** ដោយយោងលើករណីចុងក្រោយគេនៅឆ្នាំមុន កុមារភាគច្រើនទំនងជាទទួលបានសំណើដែលពួកគេមិនចង់បាន ឱ្យនិយាយអំពីបញ្ហាផ្លូវភេទ តាមប្រព័ន្ធអនឡាញពីសមាជិកគ្រួសារម្នាក់ បន្ទាប់មកពីមិត្តភក្តិ ដែលជាកុមារដែរ មិត្តភក្តិជាមនុស្សពេញវ័យ ឬដៃគូស្នេហាពីមុន។ ជិតមួយភាគបីនៃកុមារដែលបានរាយការណ៍ថា ការស្នើបែបនេះត្រូវបានធ្វើឡើងដោយនរណាម្នាក់ដែលពួកគេមិនដែលស្គាល់។

**តើកុមារបាននិយាយប្រាប់នរណា៖** នៅក្នុងចំណោមទាំង ៣១នាក់ ដែលបានទទួលសំណើមិនជាទីចង់បានឱ្យនិយាយអំពីបញ្ហាផ្លូវភេទតាមប្រព័ន្ធអនឡាញ ពួកគេភាគច្រើនបង្ហាញអំពីបញ្ហានេះទៅដល់អ្នកថែទាំជាបុរសរបស់ពួកគេ (កុមារ ១២នាក់) ឬមិត្តភក្តិម្នាក់ (៨នាក់)។ កុមារចំនួនតិចតួចបានបង្ហាញទៅដល់គ្រូបង្រៀន (៥នាក់) និងអ្នកថែទាំជាស្ត្រី (៤នាក់) ហើយកុមាររិតតែតួចតួច ដែលបានរាយការណ៍ជាផ្លូវការទៅដល់បុគ្គលិកសង្គម (១នាក់) ឬនគរបាល (១នាក់)។ កុមារាប្រាំនាក់មិនប្រាប់នរណាម្នាក់អំពី អ្វីដែលបានកើតឡើងចំពោះពួកគេឡើយ ភាគច្រើន ដោយសារពួកគេមានអារម្មណ៍អាម៉ាស ខ្មាសអៀន ឬពួកគេមានអារម្មណ៍ថា វាពិបាកនិយាយប្រាប់នរណាម្នាក់។

នៅឆ្នាំមុន

# នៅឆ្នាំមុន ខ្ញុំត្រូវបានសុំឱ្យនិយាយអំពីបញ្ហាផ្លូវភេទ ឬសកម្មភាពផ្លូវភេទជាមួយនរណាម្នាក់ ដែលខ្ញុំមិនចង់និយាយ

កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំនៅកម្ពុជា ពីការស្រាវជ្រាវអំពីការបញ្ឈប់គ្រោះថ្នាក់។ ចំនួន ៩៩២នាក់

## បាទ/ចាស៎[+] ៩%



## ពេលចុងក្រោយរឿងនេះបានកើតឡើងនៅអនឡាញ...

### តើអ្នកបានធ្វើអ្វីខ្លះ?*

- និយាយថា ទេ – ៦០%
- បានធ្វើតាមការស្នើសុំ – ២៩%
- បានឈប់ប្រើប្រាស់ប្រព័ន្ធ អ៊ីនធឺណិត មួយរយៈ – ១៩%

### តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេច?*

- អាម៉ាស – ២៣%
- វាមិនមានឥទ្ធិពលលើខ្ញុំទាល់តែសោះ – ១៧%
- ភ័យខ្លាច – ១០%
- បន្ទោសខ្លួនឯង – ២៧%

### តើនរណាជាអ្នកស្នើសុំ?*+

- សមាជិកគ្រួសារ – ៣៩%
- មិត្តភក្តិ/អ្នកស្គាល់គ្នា (១៨+) – ២៣%
- មិត្តភក្តិ/អ្នកស្គាល់គ្នា (ក្រោមអាយុ) – ២៣%
- ដៃគូស្នេហា (ឬអតីត) – ១០%
- នរណាម្នាក់ដែលកុមារមិនស្គាល់ – ២៣%

កុមារដែលត្រូវបានសុំឱ្យនិយាយអំពីបញ្ហាផ្លូវភេទ ឬសកម្មភាពផ្លូវភេទជាមួយអ្នកម្នាក់ ដែលពួកគេមិនចង់និយាយ នៅតាមប្រព័ន្ធអនឡាញ។ ចំនួន ៣១នាក់

### តើវាបានកើតឡើងនៅកន្លែងណា?*+

- តាមបណ្តាញទំនាក់ទំនងសង្គម – ២៥%
- នៅទល់មុខគ្នាដោយផ្ទាល់ – ៣២%
- នៅក្នុងហ្គេមអនឡាញ – ១២%
- វិធីផ្សេងទៀត – ៩%

កុមារដែលត្រូវបានសុំឱ្យនិយាយអំពីបញ្ហាផ្លូវភេទ ឬសកម្មភាពផ្លូវភេទជាមួយអ្នកម្នាក់ ដែលពួកគេមិនចង់និយាយ។ ចំនួន ៨៩នាក់

### តើបានកើតឡើងនៅក្នុងកម្មវិធីណាមួយ?*+

- Facebook ឬ Facebook Messenger – ៦៥%
- TikTok – ២២%
- YouTube – ២២%

កុមារដែលត្រូវបានសុំឱ្យនិយាយអំពីបញ្ហាផ្លូវភេទ ឬសកម្មភាពផ្លូវភេទជាមួយអ្នកម្នាក់ ដែលពួកគេមិនចង់និយាយ នៅតាមប្រព័ន្ធអនឡាញ។ ចំនួន ២២នាក់

### តើអ្នកបាននិយាយប្រាប់នរណា?**+

លំដាប់កំពូលទាំង ៣

- អ្នកថែទាំជាបុរស – ៣៩%
- មិត្តភក្តិ – ២៧%
- គ្រូបង្រៀន – ១៧%
- (គ្មាននរណាម្នាក់ – ១៦%)

លំដាប់ក្រោមទាំង ៣

- ១៣% Female caregiver
- ១០% បងប្អូនប្រុស ឬបងប្អូនស្រី
- ៣% នគរបាល
- ៣% បុគ្គលិកសង្គម

កុមារដែលត្រូវបានសុំឱ្យនិយាយអំពីបញ្ហាផ្លូវភេទ ឬសកម្មភាពផ្លូវភេទជាមួយអ្នកម្នាក់ ដែលពួកគេមិនចង់និយាយ នៅតាមប្រព័ន្ធអនឡាញ។ ចំនួន ៣១នាក់

### ហេតុអ្វីបានជាអ្នកមិនប្រាប់នរណាម្នាក់?*+

- ខ្ញុំមានអារម្មណ៍អាម៉ាស – ៨០%
- ខ្ញុំមិនគិតថាមាននរណាម្នាក់ជឿខ្ញុំ – ២០%
- ខ្ញុំបារម្ភថា ខ្ញុំនឹងមានបញ្ហា ប្រសិនបើ ខ្ញុំប្រាប់នរណាម្នាក់ – ២០%

កុមារដែលត្រូវបានសុំឱ្យនិយាយអំពីបញ្ហាផ្លូវភេទ ឬសកម្មភាពផ្លូវភេទជាមួយអ្នកម្នាក់ ដែលពួកគេមិនចង់និយាយ នៅតាមប្រព័ន្ធអនឡាញ និងមិនបានប្រាប់នរណាម្នាក់។ ចំនួន ៥នាក់

* ទូរលេខទាំងនេះតំណាងអោយការឆ្លើយតបដែលទូទៅបំផុតដោយកុមារ
** ទូរលេខទាំងនេះតំណាងអោយការឆ្លើយតបដែលទូទៅច្រើន និងតិចបំផុតជ្រើសរើសដោយកុមារ
† សំណួរពហុជម្រើស

Source: Disrupting Harm data

## ២.២ បទពិសោធន៍របស់កុមារអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារនៅកម្ពុជា

### ការល្បួងលោមសក្ដានុពល - កុមារដែលត្រូវបានសុំឱ្យចែកចាយរូបភាព ឬវីដេអូផ្លូវភេទ

ជនល្មើសមួយចំនួនមានចេតនាអូសទាញកុមារឱ្យបង្កើតរូបភាព ឬវីដេអូអំពីខ្លួនឯង និងចែកចាយរូបភាព ឬវីដេអូទាំងនោះតាមរយៈបច្ចេកវិទ្យាឌីជីថលទោះជាពួកគេមានចេតនាជួបកុមារដោយផ្ទាល់ ឬអត់ក្ដី។ នៅឆ្នាំ ២០១៥ ដោយទទួលស្គាល់កង្វល់អំពីបញ្ហានេះ គណៈកម្មាធិការ Lanzarote បានចេញមតិយោបល់មួយ ដែលផ្ដល់អនុសាសន៍ថា រដ្ឋនានាគប្បីពង្រីកបទល្មើសនៃការល្បួងលោមសម្រាប់គោលបំណងផ្លូវភេទ ដើម្បីបញ្ចូល "ករណីនានាដែលរំលោភបំពានផ្លូវភេទមិនមែនជាលទ្ធផលនៃការជួបគ្នាដោយផ្ទាល់ ប៉ុន្តែត្រូវបានប្រព្រឹត្តតាមប្រព័ន្ធអនឡាញ។"

កុមារដែលបានចូលរួមនៅក្នុងការអង្កេតតាមខ្នងផ្ទះត្រូវបានសួរថា តើនៅក្នុងឆ្នាំមុន ពួកគេបានទទួលសំណើរ "សុំរូបថត ឬវីដេអូមួយ ដែលបង្ហាញផ្នែកឯកជននៃរាងកាយរបស់ពួកគេ ដែលពួកគេមិនចង់បង្ហាញដែរឬទេ។"

បើទោះបីជាជាទិន្នន័យទាំងនេះអាចចាប់យកការចែកចាយនូវរូបភាពបែបនេះនៅក្នុងចំណោមអ្នកស្គាល់គ្នាដោយគ្មានគ្រោះថ្នាក់ក្ដី វាក៏អាចបង្ហាញនូវការប៉ុនប៉ង ដើម្បីអូសទាញកុមារឱ្យបង្កើតរូបភាព ឬវីដេអូផ្លូវភេទអំពីខ្លួនឯង និងចែកចាយរូបភាព ឬវីដេអូទាំងនោះតាមរយៈបច្ចេកវិទ្យាឌីជីថលផងដែរ។ នៅក្នុងឆ្នាំមុន កុមារចំនួន ៩% (៨៨នាក់) នៃកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ដែលបានចូលរួមនៅក្នុងអង្កេតនៅកម្ពុជា បានទទួលសំណើរដែលពួកគេមិនចង់បាន ឱ្យចែកចាយរូបថត ឬវីដេអូ ដែលបង្ហាញអំពីផ្នែកឯកជននៃរាងកាយរបស់ពួកគេ។ គ្មានការសង្កេតឃើញភាពខុសគ្នាចំពោះអាយុនៅក្នុងចំណោមកុមារដែលបានរាយការណ៍អំពីបទពិសោធន៍ទាំងនេះឡើយ។ កុមារា (១២%) ដែលបានរាយការណ៍អំពីការទទួលបានសំណើបែបនេះមានចំនួនច្រើនជាងកុមារ (៥%)។

**ក្នុង ឬក្រៅប្រព័ន្ធអនឡាញ?** ក្នុងចំណោមកុមារចំនួន ៨៨នាក់ ដែលបានទទួលបានសំណើមិនជាទីចង់បានឱ្យចែកចាយរូបភាព ឬវីដេអូអំពីផ្នែកឯកជននៃរាងកាយរបស់ពួកគេនៅឆ្នាំមុន សំណើចុងក្រោយគេចំនួន ៤៣% ត្រូវបានធ្វើឡើងតាមប្រព័ន្ធអនឡាញ ទោះជាតាមរយៈបណ្ដាញទំនាក់ទំនងសង្គម ឬហ្គេមអនឡាញក្ដី។ ការស្នើសុំនានា ដែលត្រូវបានធ្វើឡើងតាមបណ្ដាញទំនាក់ទំនងសង្គម គឺភាគច្រើនមកពីកម្មវិធី Facebook ឬ Facebook Messenger ។ គួរឱ្យកត់សម្គាល់ កុមារចំនួន ៣៣% បានបង្ហាញថា សំណើនេះបានកើតឡើងដោយការជួបគ្នាដោយផ្ទាល់ ស្របពេលដែលកុមារ ២០% មិនដឹងអំពីរបៀបនៃការធ្វើសំណើបែបនេះឡើយ ហើយកុមារចំនួន ៨% មិនចង់និយាយ។

**តើកុមារបានបង្ហាញអារម្មណ៍ និងឆ្លើយតបយ៉ាងដូចម្ដេច៖** កុមារចំនួន ៨៨នាក់ ដែលត្រូវបានសុំឱ្យបញ្ជូនមាតិកាផ្លូវភេទ ទំនងជារាយការណ៍អំពីអារម្មណ៍អាម៉ាស ឬការបន្ទោសខ្លួនឯង។ កុមារម្នាក់ក្នុងចំណោមកុមារប្រាំមួយនាក់បាននិយាយថា ពួកគេមិនបានរងឥទ្ធិពលទាល់តែសោះពីសំណើនេះ។ ជាការឆ្លើយតបចំពោះសំណើទាំងនេះ កុមារចំនួនពាក់កណ្ដាលបានបដិសេធ ហើយកុមារចំនួន ១៤% (ភាគច្រើន កុមារអាយុ ១២-១៣ឆ្នាំ និងកុមារី) បានធ្វើតាមការសំណើរបស់ជនល្មើស ដោយឡែកកុមារដទៃទៀតបានព្យាយាមធ្វើឱ្យបុគ្គលនោះឈប់រំខានពួកគេ មិនអើពើចំពោះសំណើនោះ ឬលុបសារនោះចេញ បានរាយការណ៍ បានផ្លាស់ប្ដូរការកំណត់ឯកជនភាពរបស់ពួកគេ បានឈប់ប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតមួយរយៈឬប្លុកជននោះលែងឱ្យទំនាក់ទំនងមកពួកគេ។

**តើនរណាជាអ្នកធ្វើសំណើនេះ?** ពាក់ព័ន្ធនឹងករណីចុងក្រោយគេបំផុតនៅឆ្នាំមុន កុមារទំនងជាទទួលបានសំណើមិនជាទីចង់បានឱ្យចែកចាយរូបភាព ឬវីដេអូផ្លូវភេទអំពីខ្លួនឯង ពីសមាជិកគ្រួសារម្នាក់ (៤០%) បន្ទាប់មក មិត្តភក្ដិជាមនុស្សពេញវ័យ ឬមិត្តភក្ដិជាកុមារដែរ។ កុមារជិតម្នាក់នៅក្នុងចំណោម ៥នាក់ បានទទួលបានសំណើមិនជាទីចង់បានពីនរណាម្នាក់ដែលពួកគេមិនដែលស្គាល់។ គួរឱ្យកត់សម្គាល់ ជាញឹកញាប់ណាស់កុមារអាយុ ១៦-១៧ឆ្នាំ មិនចង់និយាយអំពី អ្នកស្នើសុំនេះឡើយ។

**តើកុមារបាននិយាយប្រាប់នរណា៖** កុមារជាច្រើនក្នុងចំណោមកុមារទាំង ៨៨នាក់ ដែលបានទទួលសំណើមិនជាទីចង់បានឱ្យចែកចាយរូបភាព ឬវីដេអូផ្លូវភេទអំពីពួកគេ បានបង្ហាញទៅដល់អ្នកម្នាក់អំពី អ្វីដែលបានកើតឡើងចំពោះពួកគេ។ មនុស្សទូទៅ ដែលកុមារបាននិយាយប្រាប់រួមមានបងប្អូនបង្កើត ឬអ្នកថែទាំជាបុរស បន្ទាប់មកមិត្តភក្ដិ ឬអ្នកថែទាំជាស្ត្រី។ កុមារទំនងជានិយាយប្រាប់អ្នកថែទាំជាបុរសច្រើនជាង (កុមារា ២៤% កុមារី ៨%) ហើយកុមារីទំនងជានិយាយប្រាប់អ្នកថែទាំជាស្ត្រីច្រើនជាង បើធៀបនឹងកុមារា (កុមារា ៤% កុមារី ១៣%)។ កុមារចំនួនតិចតួចដែលបាននិយាយប្រាប់គ្រូបង្រៀន (៣%) ឬរាយការណ៍ជាផ្លូវការណ៍អំពីហេតុការណ៍នេះជូនដល់នគរបាល (៣%) បណ្ដាញទូរស័ព្ទជំនួយ (១%) ឬបុគ្គលិកសង្គម (១%)។ ទោះបីជាយ៉ាងណាក្ដី កុមារជិតម្នាក់ក្នុងចំណោម៥នាក់មិនបង្ហាញ ឬរាយការណ៍អំពីហេតុការណ៍នេះទៅដល់នរណាម្នាក់ឡើយ ភាគច្រើនគឺដោយសារពួកគេមិនដឹងអំពីកន្លែងដែលត្រូវទៅរាយការណ៍ ឬនរណាដែលត្រូវនិយាយប្រាប់។



នៅឆ្នាំមុន
ខ្ញុំត្រូវបានគេសុំរូបថត ឬវីដេអូ ដែលបង្ហាញផ្នែកឯកជននៃរាងកាយរបស់ខ្ញុំ នៅពេលដែលខ្ញុំមិនចង់
កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំនៅកម្ពុជា ពីការស្រាវជ្រាវអំពីការបញ្ឈប់គ្រោះថ្នាក់។ ចំនួន ៩៩២នាក់
បាទឬចាស់ ៩%†
ពេលចុងក្រោយរឿងនេះបានកើតឡើង
តើអ្នកបានធ្វើអ្វីខ្លះ?*†
និយាយថា ទេ
៥០%
បានធ្វើតាមការស្នើសុំ
១៤%
បានឈប់ប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត មួយរយៈ
១១%
តើអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច?*
អាម៉ាស
២៨%
១៥%
បន្ទោសខ្លួនឯង
១៦%
វាមិនមានឥទ្ធិពលលើខ្ញុំទាល់តែសោះ
តើនរណាជាអ្នកស្នើសុំ?
នរណាម្នាក់នៅក្នុងគ្រួសាររបស់ខ្ញុំ
៤០%
មិត្តភក្តិ/អ្នកស្គាល់គ្នា (១៨+)
១៨%
មិត្តភក្តិ/អ្នកស្គាល់គ្នា (ក្រោមអាយុ)
១៣%
មិនចង់និយាយ
១១%
ដៃគូស្នេហា (ឬអតីតដៃគូស្នេហា) ឧទា. មិត្តស្រី ឬមិត្តប្រុស ឬអតីតមិត្តស្រី ឬមិត្តប្រុស
៩%
នរណាម្នាក់ដែលកុមារមិនស្គាល់
១៨%
កុមារដែលត្រូវបានគេសុំរូបថត ឬវីដេអូដែលបង្ហាញផ្នែកឯកជននៃរាងកាយរបស់ពួកគេ នៅពេលដែលពួកគេមិនចង់។ ចំនួន ៨៨នាក់
តើវាបានកើតឡើងនៅកន្លែងណា?*†
២៣%
តាមបណ្ដាញទំនាក់ទំនងសង្គម
៣១%
នៅទល់មុខគ្នាដោយផ្ទាល់
២០%
នៅក្នុងហ្គេមអនឡាញ
១%
វិធីផ្សេងទៀត
កុមារដែលត្រូវបានគេសុំថតរូប ឬវីដេអូដែលបង្ហាញផ្នែកឯកជននៃរាងកាយរបស់ពួកគេនៅពេលដែលពួកគេមិនចង់។ ចំនួន ៨៨នាក់
តើបានកើតឡើងនៅក្នុងកម្មវិធីណាមួយ?*†
Facebook ឬ Facebook Messenger
៨១%
Twitter
១០%
TikTok
១០%
កុមារដែលត្រូវបានគេសុំរូបថត ឬវីដេអូដែលបង្ហាញផ្នែកឯកជននៃរាងកាយរបស់ពួកគេ នៅពេលដែលពួកគេមិនចង់ តាមរយៈបណ្ដាញទំនាក់ទំនងសង្គម។ ចំនួន ២០នាក់
តើអ្នកបាននិយាយប្រាប់នរណា?**†
TOP 3
មិត្តភក្តិ
១៩%
អ្នកថែទាំជាបុរស
២០%
បងប្អូនបង្កើត
២៣%
គ្មាននរណាម្នាក់
១៨%
៣%
បានរកឃើញ
BOTTOM 3
៣%
គ្រូបង្រៀន
៣%
Other adult
១%
បុគ្គលិកសង្គម
១%
បណ្ដាញទូរស័ព្ទជំនួយ
កុមារដែលត្រូវបានគេសុំរូបថត ឬវីដេអូដែលបង្ហាញផ្នែកឯកជននៃរាងកាយរបស់ពួកគេនៅពេលដែលពួកគេមិនចង់។ ចំនួន ៨៨នាក់
ហេតុអ្វីបានជាអ្នកមិនប្រាប់នរណាម្នាក់?*†
ខ្ញុំមិនដឹងអំពីកន្លែងដែលត្រូវទៅ ឬអ្នកដែលត្រូវនិយាយប្រាប់
៨១%
ខ្ញុំបារម្ភថាខ្ញុំនឹងមានបញ្ហា ប្រសិនបើខ្ញុំប្រាប់នរណាម្នាក់
១៩%
មានអារម្មណ៍អាម៉ាស ខ្មាសអៀន ឬវាពិបាកនិយាយខ្លាំងពេក
១៣%
កុមារដែលត្រូវបានគេសុំរូបថត ឬវីដេអូដែលបង្ហាញផ្នែកឯកជននៃរាងកាយរបស់ពួកគេ នៅពេលដែលពួកគេមិនចង់ និងមិននិយាយប្រាប់នរណាម្នាក់អំពីវា។ ចំនួន ១៦នាក់
* ទូរលេខទាំងនេះតំណាងអោយការឆ្លើយតបដែលទូទៅបំផុតដោយកុមារ
** ទូរលេខទាំងនេះតំណាងអោយការឆ្លើយតបដែលទូទៅច្រើន និងតិចបំផុតជ្រើសរើសដោយកុមារ
† សំណួរពហុជម្រើស
ប្រភព៖ ទិន្នន័យនៃការសិក្សាស្រាវជ្រាវស្ដីពីការបញ្ឈប់គ្រោះថ្នាក់

## ២.២ ទស្សនៈរបស់កុមារអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារនៅកម្ពុជា

### ការផ្តល់លុយកាក់ ឬអំណោយដល់កុមារ ដើម្បីទទួលបានរូបភាព ឬវីដេអូផ្លូវភេទ

ការផ្តល់លុយកាក់ ឬអំណោយដល់កុមារជាថ្នូរនឹងរូបភាព ឬវីដេអូផ្លូវភេទ រួមផ្សំជាភស្តុតាងនៃការលួងលោមជាមួយនឹងគោលបំណង ដើម្បីទទួលបាន CSAM ។ កុមារចំនួនប្រាំមួយភាគរយ (កុមារចំនួន ៦០នាក់) នៃកុមារចំនួន ៩៩២នាក់ ដែលបានចូលរួមនៅក្នុងការអង្កេតតាមខ្នងផ្ទះ បានរាយការណ៍អំពី ការទទួលបានូវការផ្តល់លុយកាក់ ឬអំណោយជាថ្នូររូបភាព ឬវីដេអូផ្លូវភេទ នៅឆ្នាំមុន។ ចំណុចនេះមានភាពទូទៅនៅក្នុងចំណោមកុមារអាយុ ១២-១៥ឆ្នាំ (៩%) ច្រើនជាងកុមារអាយុ ១៦-១៧ឆ្នាំបន្តិច (៧%) និងមានភាពទូទៅនៅក្នុងចំណោមកុមារា (៨%) ច្រើនជាងកុមារី (៤%) ចំនួនពីរដង។

**ក្នុង ឬក្រៅប្រព័ន្ធអនឡាញ?** នៅក្នុងចំណោមកុមារចំនួន ៦០នាក់ ដែលបានរាយការណ៍ថា ពួកគេបានទទួលការផ្តល់លុយកាក់ ឬអំណោយជាថ្នូរនឹងរូបភាព ឬវីដេអូផ្លូវភេទនៅឆ្នាំមុន សំណើរបែបនេះចំនួន ៣២% ត្រូវបានធ្វើឡើងតាមប្រព័ន្ធអនឡាញ ភាគច្រើនតាមរយៈបណ្តាញទំនាក់ទំនងសង្គម ឬក្នុងពេលលេងហ្គេម  អនឡាញ។ កម្មវិធីទូទៅបំផុតសម្រាប់សំណើបែបនេះ គឺ Facebook ឬ Facebook Messenger បន្ទាប់មកគឺ TikTok, YouTube និង Instagram។ កុមារជិតម្នាក់ក្នុងចំណោមកុមារបួននាក់បាននិយាយថា សំណើនេះត្រូវធ្វើឡើងដោយជួបគ្នាផ្ទាល់ ស្របពេលកុមារម្នាក់ក្នុងចំណោម៤នាក់មិនដឹងអំពីរបៀបនៃការផ្តល់លុយកាក់ ឬអំណោយនេះឡើយ។

**តើនរណាជាអ្នកផ្តល់?** សម្រាប់កុមារចំនួន ៣៥% នៃកុមារចំនួន ៦០នាក់ ដែលបានទទួលការផ្តល់អំណោយ ឬលុយកាន់ជាថ្នូរនឹងការផ្តល់មាតិកាផ្លូវភេទអំពីខ្លួនឯង សមាជិកគ្រួសារបានធ្វើការផ្តល់បែបនេះនៅក្នុងពេលថ្មីៗនេះ។ សម្រាប់កុមារមួយចំនួន ការផ្តល់នេះត្រូវបានធ្វើឡើងដោយមិត្តភក្តិ ដែលជាកុមារដែរ មិត្តភក្តិជាមនុស្សពេញវ័យ ឬដៃគូស្នេហា។ គួរឱ្យកត់សម្គាល់ កុមារចំនួន ១៥% មិនចង់និយាយអំពីអ្នកដែលបានធ្វើការផ្តល់បែបនេះឡើយ និង ១៥% បានរាយការណ៍ថាការផ្តល់នេះត្រូវបានធ្វើឡើងដោយនរណាម្នាក់ ដែលពួកគេមិនស្គាល់។

**តើកុមារបាននិយាយប្រាប់នរណា៖** នៅពេលត្រូវបានសួរអំពី លើកមុនដែលពួកគេទទួលបានការផ្តល់លុយកាក់ ឬអំណោយជាថ្នូរនឹងរូបភាព ឬវីដេអូផ្លូវភេទ កុមារទំនងជាបង្ហាញអំពី អ្វីដែលបានកើតឡើងទៅដល់មិត្តភក្តិ បន្ទាប់មកអ្នកថែទាំជាបុរស ឬបងប្អូនបង្កើត។ ភាគរយតិចបំផុតនៃកុមារបានបង្ហាញអំពីអ្វីដែលបានកើតឡើង ទៅដល់គ្រូបង្រៀន ឬមនុស្សពេញវ័យដែលពួកគេទុកចិត្ត ហើយកុមារតែម្នាក់ប៉ុណ្ណោះ ដែលបានធ្វើសេចក្តីរាយការណ៍ផ្លូវការជូននគរបាល។ គួរឱ្យកត់សម្គាល់ កុមារជិតម្នាក់ក្នុងចំណោមបួននាក់មិននិយាយប្រាប់នរណាឡើយ ភាគច្រើនគឺដោយសារពួកគេមិនដឹងអំពីកន្លែងត្រូវទៅរាយការណ៍ ឬអ្នកដែលត្រូវប្រាប់ឡើយ។ ចំណុចនេះត្រូវបានបង្ហាញនៅក្នុងការសន្ទនាជាមួយជនរងគ្រោះផងដែរ៖ *"ខ្ញុំគ្រាន់តែមិននិយាយអំពី អារម្មណ៍ទាំងនោះនៅផ្ទះរបស់ខ្ញុំ ដោយសារគ្មាននរណាម្នាក់សួរអំពីសុខទុក្ខរបស់ខ្ញុំឡើយ។ ពួកគេគ្រាន់តែសួរបន្តិចបន្តួច។ ខ្ញុំប្រាប់អ្នកអំពីបញ្ហានេះ ដោយសារគ្មាននរណាម្នាក់បានដឹងអំពីរឿងនេះឡើយ។ ខ្ញុំមិនបានប្រាប់សូម្បីតែមិត្តភក្តិរបស់ខ្ញុំ ដោយសារនៅពេលនេះ ខ្ញុំបានផ្តាច់ទំនាក់ទំនងពីមិត្តភក្តិទាំងអស់របស់ខ្ញុំ។ ពួកគេមិនបានដឹងទេ ហេតុនេះពួកគេមិនបានដឹង ដោយសារខ្ញុំមិនប្រាប់ពួកគេ។"* (RA៥-CA-0៧) យុវជនម្នាក់បានកត់សម្គាល់ថា៖ *"ខ្ញុំគ្រាន់តែលាក់ទុកក្នុងខ្លួនខ្ញុំ។"* (RA៥-CA-0៥)

OCSEA

កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំនៅកម្ពុជា
ពីការស្រាវជ្រាវអំពីការបញ្ឈប់គ្រោះថ្នាក់។ចំនួន ៩៩២នាក់

# នៅឆ្នាំមុន ខ្ញុំបានទទួលការផ្ដល់លុយកាក់ ឬអំណោយជាថ្នូរនឹងរូបភាព ឬវីដេអូផ្លូវភេទ

## បាទឬចាស៎⁺ ៩%

## ពេលចុងក្រោយរឿងនេះបានកើតឡើង

### តើនរណាជាអ្នកផ្ដល់?*†

| | |
|---|---|
| សមាជិកគ្រួសារ | ៣៥% |
| មិត្តភក្តិ/អ្នកស្គាល់គ្នា (១៨+) | ១៨% |
| មិត្តភក្តិ/អ្នកស្គាល់គ្នា (ក្រោមអាយុ) | ១៥% |
| នរណាម្នាក់ ដែលខ្ញុំមិនស្គាល់ /ជនចម្លែកមុខ | ១៥% |
| ដៃគូស្នេហា (ឬអតីតដៃគូស្នេហា) ឧទា. មិត្តស្រី ឬមិត្តប្រុស ឬអតីត | ១២% |
| មិនចង់និយាយ | ១៥% |

កុមារដែលត្រូវបានផ្ដល់លុយកាក់ ឬអំណោយជាថ្នូរនឹងរូបភាពឬវីដេអូផ្លូវភេទ។ ចំនួន ៦០នាក់

### តើវាបានកើតឡើងនៅកន្លែងណា?*†

| | |
|---|---|
| តាមបណ្ដាញទំនាក់ទំនងសង្គម | ២០% |
| នៅទល់មុខគ្នាដោយផ្ទាល់ | ២៣% |
| នៅក្នុងហ្គេមអនឡាញ | ១២% |
| វិធីផ្សេងទៀត | ១៨% |

កុមារដែលត្រូវបានផ្ដល់លុយកាក់ ឬអំណោ យជាថ្នូរនឹងរូបភាពឬវីដេអូផ្លូវភេទ។ ចំនួន ៦០នាក់

### តើបានកើតឡើងនៅក្នុងកម្មវិធីណាមួយ?*†

| | |
|---|---|
| Facebook ឬ Facebook Messenger | ៦៧% |
| TikTok | ២៥% |
| YouTube | ១៧% |

កុមារដែលត្រូវបានផ្ដល់លុយកាក់ ឬ អំណោយជាថ្នូរនឹងរូបភាព ឬវីដេអូផ្លូវភេទ តាមរយៈបណ្ដាញទំនាក់ទំនងសង្គម។ ចំនួន ១២នាក់

### តើអ្នកបាននិយាយប្រាប់នរណា?**†

លំដាប់កំពូលទាំង ៣

| | |
|---|---|
| មិត្តភក្តិ | ២៨% |
| គ្មាននរណាម្នាក់ | ២៣% |
| អ្នកថែទាំជាបុរស | ២២% |

លំដាប់ក្រោមទាំង ៣

| | |
|---|---|
| គ្រូបង្រៀន | ៥% |
| មិនដឹងនិយាយ | ៣% |
| មនុស្សពេញវ័យផ្សេងទៀត | ២% |
| នគរបាល | ២% |

កុមារដែលត្រូវបានផ្ដល់លុយកាក់ ឬ អំណោយជាថ្នូរនឹងរូបភាពឬវីដេអូផ្លូវភេទ។ ចំនួន ៦០នាក់

### ហេតុអ្វីបានជាអ្នកមិនប្រាប់នរណាម្នាក់?

| | |
|---|---|
| ខ្ញុំមិនដឹងអំពីកន្លែងដែលត្រូវទៅ ឬអ្នកដែលត្រូវនិយាយប្រាប់ | ៦៤% |
| ខ្ញុំមិនបានគិតថាវាធ្ងន់ធ្ងរទេ | ២១% |
| ខ្ញុំបារម្ភថាខ្ញុំនឹងមានបញ្ហា | ២០% |

កុមារដែលត្រូវបានផ្ដល់លុយកាក់ ឬ អំណោយជាថ្នូរនឹងរូបភាព ឬវីដេអូផ្លូវភេទ និងប្រាប់នរណាម្នាក់អំពីវា។ ចំនួន១៤នាក់

* ទូរលេខទាំងនេះតំណាងអោយការឆ្លើយតបដែលទូទៅបំផុតដោយកុមារ
** ទូរលេខទាំងនេះតំណាងអោយការឆ្លើយតបដែលទូទៅច្រើន និងតិចបំផុតជ្រើសរើសដោយកុមារ
† សំណួរពហុជម្រើស

ប្រភព៖ ទិន្នន័យនៃការសិក្សាស្រាវជ្រាវស្តីពីការបញ្ឈប់គ្រោះថ្នាក់

កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំនៅកម្ពុជា ពីការស្រាវជ្រាវអំពីការបញ្ឈប់គ្រោះថ្នាក់។ ចំនួន ៩៩២នាក់

## នៅឆ្នាំមុន ខ្ញុំបានទទួលការផ្ដល់លុយកាក់ ឬអំណោយដើម្បីជួបពួកគេដោយផ្ទាល់ ក្នុងគោលបំណងធ្វើអ្វីមួយពាក់ព័ន្ធនឹងផ្លូវភេទ†

បាទឬចាស់† ៦%



## ពេលចុងក្រោយរឿងនេះបានកើតឡើងនៅអនឡាញ...




កុមារដែលបានទទួលការផ្ដល់លុយកាក់ ឬអំណោយដើម្បីជួបគ្នាដោយផ្ទាល់ ក្នុងគោលបំណងធ្វើអ្វីមួយពាក់ព័ន្ធនឹងផ្លូវភេទតាមប្រព័ន្ធអនឡាញ។ ចំនួន ៣០នាក់

### តើវាបានកើតឡើងនៅកន្លែងណា?*†




កុមារដែលបានទទួលការផ្ដល់លុយកាក់ ឬអំណោយដើម្បីជួបគ្នាដោយផ្ទាល់ ក្នុងគោលបំណងធ្វើអ្វីមួយពាក់ព័ន្ធនឹងផ្លូវភេទតាមរយៈបណ្ដាញទំនាក់ទំនងសង្គម។ ចំនួន ៥៩នាក់

### តើបានកើតឡើងនៅក្នុងកម្មវិធីណាមួយ?*†




កុមារដែលបានទទួលការផ្ដល់លុយកាក់ ឬអំណោយដើម្បីជួបគ្នាដោយផ្ទាល់ ក្នុងគោលបំណងធ្វើអ្វីមួយពាក់ព័ន្ធនឹងផ្លូវភេទតាមរយៈបណ្ដាញទំនាក់ទំនងសង្គម។ ចំនួន ២០នាក់

### តើអ្នកបាននិយាយប្រាប់នរណា?**†




លំដាប់ក្រោមទាំង ៣

| 10% | 10% | 3% | 3% |
|---|---|---|---|
| អ្នកថែទាំជានារី | គ្រូ | បុគ្គលិកសង្គម | ដៃគូស្នេហា (ឬអតីតដៃគូស្នេហា) ឧទា. មិត្តស្រី ឬមិត្តប្រុស ឬអតីត |

កុមារដែលបានទទួលការផ្ដល់លុយកាក់ ឬអំណោយដើម្បីជួបគ្នាដោយផ្ទាល់ ក្នុងគោលបំណងធ្វើអ្វីមួយពាក់ព័ន្ធនឹងផ្លូវភេទតាមប្រព័ន្ធអនឡាញ។ ចំនួន ៣០នាក់

### ហេតុអ្វីបានជាអ្នកមិនប្រាប់នរណាម្នាក់?*†




កុមារដែលបានទទួលការផ្ដល់លុយកាក់ ឬអំណោយដើម្បីជួបគ្នាដោយផ្ទាល់ ក្នុងគោលបំណងធ្វើអ្វីមួយពាក់ព័ន្ធនឹងផ្លូវភេទតាមប្រព័ន្ធអនឡាញ និងមិនប្រាប់អ្នកម្នាក់អំពីវា។ ចំនួន ៧នាក់

* ទូរលេខទាំងនេះតំណាងអោយការឆ្លើយតបដែលទូទៅបំផុតដោយកុមារ
** ទូរលេខទាំងនេះតំណាងអោយការឆ្លើយតបដែលទូទៅច្រើន និងតិចបំផុតជ្រើសរើសដោយកុមារ
† សំណួរពហុជម្រើស

ប្រភព៖ ទិន្នន័យនៃការសិក្សាស្រាវជ្រាវស្ដីពីការបញ្ឈប់គ្រោះថ្នាក់

## ២.២ បទពិសោធន៍របស់កុមារអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារនៅកម្ពុជា

### ការផ្តល់លុយកាក់ ឬអំណោយដល់កុមារ ដើម្បីឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទ

ការល្បួងលោមកុមារតាមប្រព័ន្ធអនឡាញក្នុងគោលបំណងជួបដោយផ្ទាល់ ដើម្បីឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទ គឺជាការគំរាមកំហែងជាក់ស្តែង។ ពីការអង្កេតតាមខ្នងផ្ទះ កុមារចំនួន ៦% (កុមារ ៥៩នាក់) បាននិយាយថា ពួកគេបានទទួលការផ្តល់លុយកាក់ ឬអំណោយ ដើម្បីឱ្យទៅជួបនរណាម្នាក់ដោយផ្ទាល់ ដើម្បីធ្វើសកម្មភាពផ្លូវភេទនៅឆ្នាំមុន។ កុមារអាយុ ១២-១៣ឆ្នាំ (១០%) ទំនងជាងទទួលបានការផ្តល់បែបនេះក្នុងកម្រិតខ្ពស់ជាងកុមារអាយុ ១៤-១៧ឆ្នាំ (១៤-១៥ឆ្នាំ៖ ៥% ១៦-១៧ឆ្នាំ៖ ៣%) ហើយកុមារា (៨%) មានកម្រិតខ្ពស់ជាងកុមារី (៤%)។ ដូចគ្នានឹងរបកគំហើញដទៃទៀតដែរ ចំនួនទាំងនេះអាចត្រូវបានរាយការណ៍មិនគ្រប់គ្រាន់ ដោយសារកុមារអាចគ្មានអារម្មណ៍មានផាសុកភាព ឬមានសុវត្ថិភាពគ្រប់គ្រាន់ ដើម្បីបង្ហាញអំពី បទពិសោធន៍នៃការរំលោភបំពាន ឬការកេងប្រវ័ញ្ចលើពួកគេ ទោះបីជានៅក្នុងការអង្កេតអនាមិកក្តី។

**ក្នុង ឬក្រៅប្រព័ន្ធអនឡាញ?** ក្នុងចំណោមកុមារចំនួន ៥៩នាក់ ដែលបាននិយាយថា ពួកគេបានទទួលការផ្តល់លុយកាក់ ឬអំណោយ ដើម្បីជួបដោយផ្ទាល់ក្នុងគោលបំណងឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទនៅឆ្នាំមុន ការផ្តល់ដល់កុមារចំនួន ៥១% ត្រូវបានធ្វើឡើងតាមប្រព័ន្ធអនឡាញ ភាគច្រើនតាមរយៈបណ្តាញទំនាក់ទំនងសង្គម និងតាមរយៈហ្គេមអនឡាញ។ ចំណុចនេះបង្ហាញឱ្យឃើញថា កុមារចំនួន ៣% (៣០នាក់) នៅក្នុងការអង្កេតតាមខ្នងផ្ទះនៅកម្ពុជាបានទទួលការផ្តល់លុយកាក់ ឬអំណោយតាមប្រព័ន្ធអនឡាញដើម្បីជួបគ្នាដោយផ្ទាល់ក្នុងគោលបំណងឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទ។ ដូចការបង្ហាញនៅក្នុងក្រាហ្វិក ៥៧ ការផ្តល់តាមរយៈបណ្តាញទំនាក់ទំនងសង្គមរមែងតែងត្រូវធ្វើឡើងនៅលើ Facebook ឬ Facebook Messenger ។ កម្មវិធីដទៃទៀតដែលត្រូវបានលើកឡើង រួមមាន Snapchat, Twitter, Instagram និង TikTok ។ គួរឱ្យកត់សម្គាល់ កុមារចំនួន ២៤% បានទទួលការផ្តល់នេះ នៅក្នុងអំឡុងពេលនៃការជួបគ្នាដោយផ្ទាល់ជាមួយនឹងជននោះ ស្របពេលដែល កុមារ ១០% មិនចង់និយាយអំពីរបៀបនៃការផ្តល់នេះ។

ដោយសារការផ្តល់លុយកាក់ ឬអំណោយដល់កុមារ ក្នុងគោលបំណងសកម្មភាពផ្លូវភេទដោយផ្ទាល់ អាចកើតឡើងនៅក្នុងការជួបគ្នាដោយផ្ទាល់ទាំងស្រុង (ដោយគ្មានពាក់ព័ន្ធនឹងបច្ចេកវិទ្យា) សម្រាប់ទិន្នន័យខាងក្រោម កុមារ (ចំនួន ៣០នាក់) ដែលបញ្ជាក់ថា ពួកគេបានទទួលការផ្តល់លុយកាក់ ឬអំណោយតាមរយៈ*បណ្តាញអនឡា*ញ ឧទា. បណ្តាញទំនាក់ទំនងសង្គម និង/ឬនៅក្នុងហ្គេមអនឡាញ ដើម្បីជួបគ្នាដោយផ្ទាល់សម្រាប់សកម្មភាពផ្លូវភេទ គឺជាករណីនៃ OCSEA ។

**តើនរណាដែលជាអ្នកផ្តល់?** នៅពេលដែលកុមារចំនួន ៣០នាក់ ត្រូវបានសួរថា តើនរណាធ្វើការផ្តល់នៅពេលថ្មីៗនេះតាមប្រព័ន្ធអនឡាញ កុមារចំនួនជិតពាក់កណ្តាល (១៤នាក់) បាននិយាយថា ការផ្តល់នេះ គឺមកពីសមាជិកគ្រួសារ បន្ទាប់មក មិត្តភក្តិជាមនុស្សពេញវ័យ (១១នាក់) ឬមិត្តភក្តិដែលជាកុមារដែរ។ កុមារម្នាក់នៅក្នុងចំណោមកុមារប្រាំបីនាក់ បានទទួលការផ្តល់ពីនរណាម្នាក់ ដែលពួកគេមិនស្គាល់។

**តើកុមារនិយាយប្រាប់អ្នក - ប្រសិនបើ មាន៖** ភាគច្រើននៃកុមារទាំង ៣០នាក់ ដែលទទួលបានការផ្តល់លុយកាក់ ឬអំណោយ ដើម្បីជួបគ្នាដោយផ្ទាល់ក្នុងគោលបំណងឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទតាមប្រព័ន្ធអនឡាញ បាននិយាយប្រាប់នរណាម្នាក់ ភាគច្រើន គឺបងប្អូនបង្កើត ឬមិត្តភក្តិ។ កុមារចំនួនតិចតួចបាននិយាយប្រាប់អ្នកថែទាំ ឬគ្រូបង្រៀន។ ដោយមានសង្គតភាពជាមួយនឹងទិន្នន័យសម្រាប់ទម្រង់ដទៃទៀតនៃ OCSEA ជាទូទៅ កុមារជៀសវាងយន្តការរាយការណ៍ផ្លូវការ ជំនួសវិញ ពួកគេពឹងផ្អែកលើបណ្តាញគាំទ្រអន្តរបុគ្គលវិញ។ គួរឱ្យកត់សម្គាល់ កុមារចំនួន៧នាក់ក្នុងចំណោម៣០នាក់មិនប្រាប់នរណាម្នាក់អំពី អ្វីដែលបានកើតឡើងឡើយ ភាគច្រើនដោយសារពួកគេមិនអំពី កន្លែងដែលត្រូវទៅរាយការណ៍ ឬនរណាដែលត្រូវប្រាប់។

### ការគំរាមកំហែងក្នុងគោលបំណងផ្លូវភេទ

នៅពេលខ្លះ ការគំរាមកំហែងក្នុងគោលបំណងផ្លូវភេទត្រូវបានប្រើប្រាស់នៅក្នុងដំណើរការល្បួងលោម។ ជាញឹកញាប់ ជនល្មើសបានទទួលរូបភាពផ្លូវភេទរបស់កុមាររួចហើយ និងគំរាមផ្សព្វផ្សាយជាសាធារណៈ ឬចែកចាយរូបភាពទាំងនោះជាមួយមិត្តភក្តិរបស់ពួកគេ ឬសមាជិកគ្រួសាររបស់ពួកគេ ដែលជាវិធីមួយនៃការបង្ខិតបង្ខំពួកគេឱ្យចែកចាយរូបភាពបន្ថែមទៀត ឬចូលរួមនៅក្នុងសកម្មភាពផ្លូវភេទផ្សេងៗ។ ការគំរាមកំហែងបែបនេះក៏អាចត្រូវបានប្រើប្រាស់ដើម្បីជំរិតយកលុយកាក់ផងដែរ។ នៅកម្ពុជា ទាំងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទាំងក្រមព្រហ្មទណ្ឌមិនទាន់បានកំណត់ជាបទល្មើសជាក់ច្បាស់ចំពោះការគំរាមកំហែងក្នុងគោលបំណងផ្លូវភេទតាមប្រព័ន្ធអនឡាញ នៅឡើយទេ។ ជនរងគ្រោះវ័យក្មេងម្នាក់បាននិយាយអំពីជនល្មើសថា៖

*"ហេតុនេះ គាត់បានចែកចាយព័ត៌មានទាំងអស់របស់ខ្ញុំ។ គាត់បានថតរូបលើស្គ្រីន (Screenshots) នូវមិត្តភក្តិរបស់ខ្ញុំទាំងអស់ ហើយបន្ទាប់ពីនោះ គាត់បានព្យាយាមទាមទាររូបថតរបស់ខ្ញុំ។ បន្ទាប់ពីគាត់បានទាមទាររូបថតរបស់ខ្ញុំ ខ្ញុំបាននិយាយថា ខ្ញុំនឹងមិនផ្ញើឱ្យទេ។ គ្មានផ្លូវទេ។ ពេលនោះ គឺជាពេលដែលគាត់បានចាប់ផ្តើមប្រើប្រាស់ការគំរាមកំហែង។ គាត់បានថតរូបលើស្គ្រីននូវបញ្ជីមិត្តភក្តិរបស់ខ្ញុំទាំងអស់។ គាត់បាននិយាយថា ប្រសិនបើ ខ្ញុំមិនបញ្ជូនរូបថតឱ្យគាត់ទេ*

## ២.២ បទពិសោធន៍របស់កុមារអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារនៅកម្ពុជា

*មិត្តទាំងអស់នៅលើបញ្ជីរបស់ខ្ញុំនឹងទទួលបានរូបថតទាំងអស់ ដែលគាត់បានទទួល។"* (RA៥-CA-0៧)

នៅក្នុងការអង្កេតតាមខ្នងផ្ទះកុមារចំនួន៥% (៥៣នាក់) ក្នុងចំណោមកុមារចំនួន៩៩២នាក់ កំពុងប្រើប្រាស់អ៊ីនធឺណិត ដែលបានចូលរួមនៅក្នុងការអង្កេតនៅកម្ពុជាបាននិយាយថា ពួកគេបានរងការគំរាមកំហែង ឬបោកប្រាស់ឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទយ៉ាងហោចណាស់ម្តង នៅឆ្នាំមុន។ កុមារអាយុ ១២-១៥ឆ្នាំ (៨%) ទំនងជាត្រូវបានកំណត់ជាគោលដៅកម្រិតខ្ពស់ជាងកុមារអាយុ ១៦-១៧ឆ្នាំ (៣%) ហើយកុមារា (៧%) ខ្ពស់ជាងកុមារី (៤%)។ មិនមានព័ត៌មានអំពីប្រភេទនៃការគំរាមកំហែង ដែលត្រូវបានប្រើប្រាស់ឡើយ ឧទាហរណ៍ ប្រសិនបើ រូបភាពផ្លូវភេទដែលទទួលបានពីមុន ត្រូវបានប្រើប្រាស់ ដើម្បីគំរាមយកលុយកាក់ ឬឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទបន្ថែមទៀត ដោយសារគ្មានការសួរសំណួរបន្តឡើយ។

**ក្នុង ឬក្រៅប្រព័ន្ធអនឡាញ?** ក្នុងចំណោមកុមារចំនួន ៥៣នាក់ ដែលបានរាយការណ៍អំពី ករណីនៃការគំរាមកំហែងក្នុងគោលបំណងផ្លូវភេទ ពួកគេចំនួន ៤0%បានបង្ហាញថា ការគំរាមកំហែងត្រូវបានធ្វើឡើងតាមប្រព័ន្ធអនឡាញ ស្របពេលដែល១៥% បានរាយការណ៍ថា ការគំរាមបានកើតឡើងក្នុងការជួបគ្នាដោយផ្ទាល់។ នេះបង្ហាញថា កុមារត្រឹមតែ២% នៃចំនួនកុមារទាំងអស់នៅក្នុងការអង្កេតតាមខ្នងផ្ទះបានជួបប្រទះបទពិសោធន៍នៃការគំរាមកំហែងផ្លូវភេទ។ ជនល្មើសទំនងជាធ្វើការគំរាមកំហែងបែបនេះតាមរយៈបណ្តាញទំនាក់ទំនងសង្គមច្រើនជាងតាមរយៈហ្គេមអនឡាញបន្តិច។ ក្នុងចំណោមកុមារ ដែលត្រូវបានកំណត់ជាគោលដៅនៅលើបណ្តាញទំនាក់ទំនងសង្គម ពួកគេភាគច្រើនបានរាយការណ៍ថា ការគំរាមកំហែងបានកើតឡើងនៅលើកម្មវិធី Facebook (ឬ Facebook Messenger)។ ជាថ្មីម្តងទៀត ដោយសារកុមារអាចរងការបោកប្រាស់ ឬការគំរាមឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទក្នុងជំនួបដោយផ្ទាល់ទាំងស្រុង (ដោយគ្មានពាក់ព័ន្ធនឹងបច្ចេកវិទ្យា) កុមារតែ ២១នាក់ប៉ុណ្ណោះ ដែលបាននិយាយថា ពួកគេរងការគំរាមកំហែង ឬការបោកប្រាស់ឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទ *តាមប្រព័ន្ធអនឡាញ* ឧទាហរណ៍ តាមរយៈបណ្តាញទំនាក់ទំនងសង្គម ឬកម្មវិធីលេងហ្គេមអនឡាញ ត្រូវបានបញ្ចូលក្នុងការវិភាគខាងក្រោម។

**តើនរណាដែលធ្វើការគំរាមកំហែង?** នៅក្នុងចំណោមកុមារចំនួន ២១នាក់ ដែលបានរងការបង្ខិតបង្ខំតាមប្រព័ន្ធអនឡាញ ជនល្មើសទូទៅបំផុតដែលធ្វើការបង្ខិតបង្ខំចុងក្រោយគេ គឺមិត្តភក្តិ ដែលជាកុមារដែរ។ ទិន្នន័យពីការអង្កេតតាមខ្នងផ្ទះក៏បានរកឃើញថា ក្នុងចំណោមកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ទាំង ៩៩២នាក់ ដែលបានចូលរួមនៅក្នុងការអង្កេតនេះ ពួកគេចំនួន ៨% បានបង្ហាញថា ពួកគេបានដាក់សម្ពាធឱ្យកុមារ ដែលមានវ័យស្របាលពួកគេ បញ្ជូនរូបភាព ឬវីដេអូផ្លូវភេទ។

**តើកុមារបាននិយាយប្រាប់នរណា៖** ក្នុងចំណោមកុមារចំនួន ២១នាក់ ដែលរងការបោកប្រាស់ ឬការគំរាមកំហែងតាមប្រព័ន្ធអនឡាញឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទ កុមារទាំងអស់ លើកលែងតែកុមារម្នាក់ បាននិយាយអំពីហេតុការណ៍នេះប្រាប់អ្នកដទៃទៀត។ កុមារទំនងជានិយាយប្រាប់មិត្តភក្តិច្រើនជាងគេ និងបន្ទាប់មកអ្នកថែទាំ។ កុមារចំនួនតិចតួចបាននិយាយប្រាប់បងប្អូនបង្កើត គ្រូបង្រៀន ឬមនុស្សពេញវ័យដែលពួកគេទុកចិត្ត។ កុមារមិនបានធ្វើការរាយការណ៍ផ្លូវការណ៍ទៅកាន់នគរបាល បុគ្គលិកសង្គម ឬបណ្តាញទូរស័ព្ទជំនួយឡើយ។

កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំនៅកម្ពុជា
ពីការស្រាវជ្រាវអំពីការបញ្ឈប់គ្រោះថ្នាក់។ ចំនួន ៩៩២នាក់

OCSEA

នៅឆ្នាំមុន

# នរណាម្នាក់បានគំរាមកំហែង ឬបោកប្រាស់ខ្ញុំឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទ

## បាទ/ចាស[†] ៥%

## ពេលចុងក្រោយរឿងនេះបានកើតឡើងនៅអនឡាញ...

តើនរណាជាអ្នកធ្វើអំពើនេះ*[†]




កុមារដែលរងការគំរាមកំហែង ឬការបោកប្រាស់ឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទតាមប្រព័ន្ធអនឡាញ។ ចំនួន ២១នាក់

### តើវាបានកើតឡើងនៅកន្លែងណា?*[†]

- ២៥% តាមបណ្ដាញទំនាក់ទំនងសង្គម
- ១៥% នៅទល់មុខគ្នាដោយផ្ទាល់
- ១៥% នៅក្នុងហ្គេមអនឡាញ
- ១៣% វិធីផ្សេងទៀត

កុមារដែលរងការគំរាមកំហែង ឬការបោកប្រាស់ឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទ ។ ចំនួន ៥៣នាក់

### តើបានកើតឡើងនៅក្នុងកម្មវិធីណាមួយ?*[†]

- Facebook ឬ Facebook Messeng ៧៧%
- YouTube ៨%
- Twitter ៨%

កុមារដែលរងការគំរាមកំហែង ឬការបោកប្រាស់ឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទតាមរយៈបណ្ដាញទំនាក់ទំនងសង្គម។ ចំនួន ១៣នាក់

### តើអ្នកបាននិយាយប្រាប់នរណា?**[†]

លំដាប់កំពូលទាំង ៣

- មិត្តភក្តិ ៥៧%
- អ្នកថែទាំជាបុរស ២៩%
- អ្នកថែទាំជានារី ៣២%

លំដាប់ក្រោមទាំង ៣

- ១៤% គ្រូបង្រៀន
- ១០% មនុស្សពេញវ័យផ្សេងទៀត
- ៥% គ្មាននរណាម្នាក់

កុមារដែលរងការគំរាមកំហែង ឬការបោកប្រាស់ឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទតាមប្រព័ន្ធអនឡាញ។ ចំនួន ២១នាក់

### ហេតុអ្វីបានជាអ្នកមិនប្រាប់នរណាម្នាក់?*[†]

ខ្ញុំមិនដឹងអំពីកន្លែងដែលត្រូវទៅ ឬអ្នកដែលត្រូវនិយាយប្រាប់ ១០០%

កុមារដែលរងការគំរាមកំហែង ឬការបោកប្រាស់ឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទតាមប្រព័ន្ធអនឡាញ និងមិនប្រាប់នរណាអំពីវា។ ចំនួន ១នាក់

* ទូរលេខទាំងនេះតំណាងអោយការឆ្លើយតបដែលទូទៅបំផុតដោយកុមារ
** ទូរលេខទាំងនេះតំណាងអោយការឆ្លើយតបដែលទូទៅច្រើន និងតិចបំផុតជ្រើសរើសដោយកុមារ
† សំណួរពហុជម្រើស

ប្រភព៖ ទិន្នន័យនៃការសិក្សាស្រាវជ្រាវស្ដីពីការបញ្ឈប់គ្រោះថ្នាក់

## ២.២ បទពិសោធន៍របស់កុមារអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារនៅកម្ពុជា

### ហេតុអ្វីបានជាកុមារនៅកម្ពុជាប្រហែលជាបង្ហាញករណីរំលោភបំពានទៅកាន់អ្នកថែទាំជាបុរសញឹកញាប់ជាងអ្នកថែទាំជាស្ត្រី?

ការពិត ដែលកុមារនៅកម្ពុជាបង្ហាញអំពី ការរំលោភបំពានលើពួកគេទៅកាន់អ្នកថែទាំជាបុរសញឹកញាប់ជាងអ្នកថែទាំជាស្ត្រី គឺជារបកគំហើញដោយឡែកមួយ នៅក្នុងចំណោមបណ្ដាប្រទេស ដែលអនុវត្តគម្រោងស្ដីពីការបញ្ឈប់គ្រោះថ្នាក់។ ការអង្កេតនេះបង្ហាញបន្ថែមទៀតថា សម្រាប់ការបង្ហាញអំពី OCSEA មួយចំនួន កុមារីរិតតែទំនងជានិយាយប្រាប់អ្នកថែទាំជាបុរសជាងកុមារា។ ឧទាហរណ៍ ក្នុងករណីនៃការគំរាមកំហែងក្នុងគោលបំណងផ្លូវភេទ ៥0% នៃកុមារីបាននិយាយប្រាប់អ្នកថែទាំជាបុរស ស្របពេលដែលកុមារតែ ២៨% ប៉ុណ្ណោះ ដែលបានជ្រើសរើសធ្វើបែបនេះ។

បន្ថែមលើចំណង់ចំណូលចិត្តរបស់កុមារកម្ពុជាក្នុងការបង្ហាញបទពិសោធន៍អំពី OCSEA ទៅដល់អ្នកថែទាំជាបុរស ជាជាងអ្នកថែទាំជាស្ត្រី ទិន្នន័យពីការអង្កេតតាមខ្នងផ្ទះបង្ហាញថា ចំណង់ចំណូលចិត្តនេះច្រើនតែកើតឡើងជាទូទៅចំពោះកុមារី។ ឧទាហរណ៍ កុមារីចំនួន ៣៣% ដែលបានទទួលបានការស្នើសុំមិនជាទីចង់បានឱ្យនិយាយអំពីបញ្ហាផ្លូវភេទតាមប្រព័ន្ធអនឡាញ បាននិយាយប្រាប់អ្នកថែទាំជាបុរសរបស់ពួកគេ ស្របពេលគ្មានកុមារីណាម្នាក់បាននិយាយប្រាប់អ្នកថែទាំជាស្ត្រីរបស់ពួកគេឡើយ។ ស្រដៀងគ្នានេះដែរ នៅពេលទទួលបានការផ្ដល់លុយកាក់ ឬអំណោយជាថ្នូរនឹងសកម្មភាពផ្លូវភេទ គ្មានកុមារីណាម្នាក់ដែលទទួលបានការផ្ដល់បែបនេះ បាននិយាយប្រាប់អ្នកថែទាំជាស្ត្រីឡើយ ស្របពេលដែលកុមារីចំនួន ២0% បាននិយាយប្រាប់អ្នកថែទាំជាបុរស។ ជាការប្រៀបធៀប កុមារាទំនងជានិយាយអំពីបទពិសោធន៍របស់ពួកគេប្រាប់អ្នកថែទាំ (បុរស ឬស្ត្រីក្តី) ច្រើនជាងកុមារី ស្របពេលដែលកុមារីទំនងជានិយាយប្រាប់មិត្តភក្តិច្រើនជាង។ ពាក់ព័ន្ធក្រុមអាយុជាទូទៅ កុមារអាយុ ១៦-១៧ឆ្នាំមិនសូវទំនងជានិយាយប្រាប់អ្នកថែទាំដូចកុមារតូចៗឡើយ។

បើទោះបីជាមិនត្រូវសិក្សាយ៉ាងច្បាស់នៅក្នុងការស្រាវជ្រាវបច្ចុប្បន្នក្តី របកគំហើញមួយចំនួនក្នុងចំណោមរបកគំហើញពីការអង្កេតតាមខ្នងផ្ទះ ការសម្ភាសជាមួយជនរងគ្រោះនៃ OCSEA ព្រមទាំងការយល់ដឹងស៊ីជម្រៅពីការសិក្សាស្រាវជ្រាវដែលត្រូវធ្វើឡើងពីមុន ប្រហែលជាពន្យល់អំពី មូលហេតុដែលកុមារនៅកម្ពុជាអាចបង្ហាញកាន់តែញឹកញាប់ទៅដល់អ្នកថែទាំជាបុរស។

ដំបូង ការអង្កេតតាមខ្នងផ្ទះបានបង្ហាញថា អ្នកថែទាំជាស្ត្រីមិនសូវប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ដូចអ្នកថែទាំជាបុរសឡើយ។ ដោយសារអ្នកថែទាំជាបុរសមានការយល់ដឹងច្រើនអំពីប្រព័ន្ធអ៊ីនធឺណិត  កុមារអាចមានអារម្មណ៍ថា ការពន្យល់អំពី អ្វីដែលបានកើតឡើង និងរបៀបដែលបច្ចេកវិទ្យាឌីជីថល/ប្រព័ន្ធអ៊ីនធឺណិត បានសម្របសម្រួលការរំលោភបំពានពួកគេ ទៅកាន់អ្នកថែទាំជាបុរសមានលក្ខណៈងាយស្រួលជាង។ អ្នកថែទាំជាបុរសក៏បានរាយការណ៍ជាញឹកញាប់ជាង (២៥%) ថា ពួកគេនឹងស្វែងរកជំនួយ ឬឱវាទអំពី អ្វីដែលត្រូវធ្វើប្រសិនបើ កូនរបស់ពួកគេបានជួបប្រទះនឹងអ្វីមួយតាមប្រព័ន្ធអ៊ីនធឺណិត  ដែលរំខាន ឬធ្វើឱ្យពួកគេមិនសប្បាយចិត្ត បើធៀបនឹងអ្នកថែទាំជាស្ត្រី (១៩%)។

បន្ថែមលើនេះ ឧត្តរជីវីនៃ OCSEA បានបន្ទរនូវចំណង់ចំណូលចិត្តចំពោះការនិយាយជាមួយអ្នកថែទាំជាបុរសជាងជាមួយអ្នកថែទាំជាស្ត្រី។ ឧត្តរជីវីយក្មេងម្នាក់បាននិយាយថា៖ *"ប្រសិនបើ ខ្ញុំនិយាយប្រាប់ម្ដាយរបស់ខ្ញុំខ្ញុំនឹងមានអារម្មណ៍អាម៉ាស់អំពីខ្លួនឯង។"* (RA៥-CA-0៩). និយាមសង្គម និងយេនឌ័រមានឥទ្ធិពលយ៉ាងខ្លាំងលើអាកប្បកិរិយាដែលត្រូវបានរំពឹងទុក ជាពិសេសអាកប្បកិរិយាពាក់ព័ន្ធនឹងបញ្ហាផ្លូវភេទ និងជាពិសេស សម្រាប់កុមារី និងស្ត្រី។ បរិបទនេះអាចរារាំងការនិយាយប្រាប់អ្នកថែទាំជាស្ត្រី ដែលមិនស្របជាមួយនឹងការរំពឹងទុកដែលមិនផ្លាស់ប្ដូរទាំងនេះ។

និងចុងក្រោយ របកគំហើញពីការសិក្សាអំពីអំពើហិង្សាលើកុមារនៅកម្ពុជានៅឆ្នាំ២០១៣ បានបង្ហាញថា ក្នុងចំណោមកុមារអាយុ ១៣-១៧ឆ្នាំ ដែលបានជួបប្រទះនឹងអំពើហិង្សាពីសំណាក់ឪពុក ឬម្ដាយអ្នកថែទាំ និងសាច់ញាតិជាមនុស្សពេញវ័យដទៃទៀត កុមារភាពច្រើនបានរាយការណ៍ថា អ្នកប្រព្រឹត្តអំពើហិង្សា គឺជាឪពុក ឬម្ដាយហើយម្ដាយប្រព្រឹត្តអំពើហិង្សាញឹកញាប់ជាងឪពុក។

## ២.២ បទពិសោធន៍របស់កុមារអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារនៅកម្ពុជា

### ២.២.២ CSAM និងការផ្សាយបន្តផ្ទាល់នៃការរំលោភបំពានផ្លូវភេទកុមារ

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ កំណត់និយមន័យ CSAM ថា "សម្ភារដែលអាចមើលឃើញនឹងភ្នែក ដូចជា រូបថត ឬខ្សែវីដេអូ រួមទាំងសម្ភារអេឡិចត្រូនិក ដែលបង្ហាញអំពីរូបរាងអាក្រាតរបស់អនីតិជន ដែលធ្វើឱ្យរំភើប ឬរំជួលដល់អារម្មណ៍ផ្លូវភេទ។" ពាក់ព័ន្ធនឹងការធ្វើឱ្យរំភើប ឬការរំជួលដល់អារម្មណ៍ផ្លូវភេទនេះ អាចនាំឱ្យមាននិទណ្ឌភាពចំពោះបទល្មើសលើកុមារ ដោយសារការលំបាកក្នុងការបញ្ជាក់ពីស្ថានភាពទាំងនេះនៅអំឡុងពេលនៃការប្រព្រឹត្តបទល្មើស។ លើសពីនេះ និយមន័យនេះមិនបានគ្របដណ្តប់លើ CSAM ដែលមិនអាចមើលឃើញនឹងភ្នែក ដូចជា សម្លេង សម្ភារគូរ និងសរសេរ CSAM ដែលត្រូវបានបង្កើតឡើងដោយកុំព្យូទ័រ/ប្រព័ន្ធឌីជីថល រួមមានរូបភាពដែលដូចបេះបិទនៃកុមារដែលមិនមានពិតប្រាកដ និងCSAM ដែលបង្ហាញនូវជនម្នាក់ ដែលទំនងជាអនីតិជនចូលរួមនៅក្នុងសកម្មភាពផ្លូវភេទ។ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទហាមឃាត់ការចែកចាយ ការកាន់កាប់ និងការផលិតក្នុងចេតនាចែកចាយ CSAM។ ទោះបីជាយ៉ាងណាក្តី ការទទួលបាន និងការកាន់កាប់ CSAM ដោយគ្មានចេតនាចែកចាយបន្តមិនទាន់ត្រូវបានចាត់ទុកថាជាបទល្មើស នៅឡើយទេ។

ជាការឆ្លើយតបចំពោះសំណួរមួយពាក់ព័ន្ធនឹងភាពសមស្របនៃច្បាប់ដែលមានស្រាប់ អ្នកតំណាងម្នាក់មកពីនិយ័តករទូរគមនាគមន៍កម្ពុជាបានកត់សម្គាល់ថា៖ *ខ្ញុំមិនមើលឃើញថា ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទត្រូវការវិសោធនកម្មនៅឡើយទេ។ ច្បាប់នេះមានភាពច្បាស់លាស់ និងពេញលេញរួចហើយ និងត្រូវបានរៀបចំដោយអនុលោមទៅតាមបទដ្ឋាន និងគោលការណ៍នៃច្បាប់អន្តរជាតិពាក់ព័ន្ធ។ មាត្រាពាក់ព័ន្ធនឹងនិយមន័យនៃអំពើអាសអាភាសកុមារបានកំណត់យ៉ាងច្បាស់ហើយ។ មកដល់ពេលនេះ ខ្ញុំមិនទទួលបានព័ត៌មាន ឬសំណើរឱ្យធ្វើវិសោធនកម្មមាត្រាណាមួយនៃច្បាប់នេះឡើយ។* (RA១-CA-០៩-A) ផ្ទុយទៅវិញ អ្នកមានភារកិច្ចម្នាក់មកពីជួររដ្ឋាភិបាលដែលត្រូវបានសម្ភាស បានជឿជាក់ថា ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទមិនឆ្លើយតបយ៉ាងគ្រប់គ្រាន់ចំពោះ OCSEA ឡើយ ដោយនិយាយថា *"យើងហាក់ដូចជាមានច្បាប់ជាច្រើនរួចហើយ ទោះបីជាយ៉ាងណាក្តី មិនមានមាត្រាជាក់លាក់ និងគ្រប់គ្រាន់ ដើម្បីឆ្លើយតបចំពោះ OCSEA ឡើយ។"* (RA១-CA-១០-A)

ទោះបីជាច្បាប់កម្ពុជាមិនមានបទប្បញ្ញត្តិណាមួយ ដែលកំណត់ជាបទល្មើសចំពោះការផ្សាយបន្តផ្ទាល់អំពីការរំលោភបំពានផ្លូវភេទកុមារក្តី អ្នកតំណាងម្នាក់មកពីនគរបាលជាតិកម្ពុជាបានបង្ហាញថា ការផ្សាយបន្តផ្ទាល់អំពីការរំលោភបំពានផ្លូវភេទកុមារអាចត្រូវបានពិចារណានៅក្រោមបទ "ការចែកចាយ CSAM" ដែលត្រូវបានកំណត់ជាបទល្មើសដោយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ហើយអ្នកទាំងឡាយដែលត្រូវបានរកឃើញថាមានទោសពាក់ព័ន្ធនឹងបទល្មើសនេះ អាចត្រូវបានផ្តន្ទាទោស។ (RA១-CA-០៣-A) វាទំនងជាថា ចំណុចនេះមិនទាន់ត្រូវបានសាកល្បងនៅឡើយ ដោយសារគម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* មិនបានកំណត់ករណីណាមួយនៅកម្ពុជា ដែលត្រូវបានស៊ើបអង្កេតឡើយមកដល់ពេលបច្ចុប្បន្ននេះ ពាក់ព័ន្ធនឹងបទល្មើសនៃការផ្សាយបន្តផ្ទាល់នេះ។

យោងតាមផែនការសកម្មភាពដើម្បីបង្ការ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ ក្រសួងយុត្តិធម៌ត្រូវបានស្នើសុំឱ្យពង្រីកនិយមន័យនៃ CSAM នៅក្នុងច្បាប់ ដើម្បីឆ្លុះបញ្ចាំងនូវនិយមន័យ ដែលមាននៅក្នុងពិធីសារបន្ថែមចំពោះអនុសញ្ញាស្តីពីសិទ្ធិកុមារ ស្តីពីការលក់កុមារ ពេស្យាចារកុមារ និងអំពើអាសអាភាសកុមារ និងធ្វើវិសោធនកម្មច្បាប់ ដើម្បីកំណត់ជាបទល្មើសចំពោះគ្រប់ទម្រង់ទាំងអស់នៃការកាន់កាប់ CSAM ។ បន្ថែមលើនេះ ក្រសួងបានទទួលភារកិច្ចរៀបចំបទប្បញ្ញត្តិថ្មីៗនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា ដើម្បីការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ រួមមាន ការគំរាមកំហែងក្នុងគោលបំណងផ្លូវភេទ ការលួងលោមតាមប្រព័ន្ធអនឡាញ និងការផ្សាយបន្តផ្ទាល់អំពីការរំលោភបំពានផ្លូវភេទកុមារ និងនៅក្នុងក្រមព្រហ្មទណ្ឌ ដើម្បីកំណត់បទល្មើសចំពោះសកម្មភាពរំលោភបំពានផ្លូវភេទ និងលួងលោម ដែលមិនមានលក្ខណជារូបវន្ត។

ត្រឹមខែវិច្ឆិកា ឆ្នាំ២០២១ សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យានៅតែកំពុងស្ថិតនៅក្រោមការពិនិត្យនៅឡើយ។ សេចក្តីព្រាងចុងក្រោយគេដែលមានជាសាធារណៈផ្តល់នូវនិយមន័យអំពី CSAM កាន់តែទូលំទូលាយ (ទោះបីជាមិនមានលក្ខណគ្រប់ជ្រុងជ្រោយក្តី) និងកំណត់ជាបទល្មើសយ៉ាងច្បាស់ចំពោះអំពើពាក់ព័ន្ធនឹង CSAM នៅតាមប្រព័ន្ធអនឡាញ ប៉ុន្តែមិនសំដៅទៅដល់បទល្មើស OCSEA ដទៃទៀតឡើយ។

## ២.២ បទពិសោធន៍របស់កុមារអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារនៅកម្ពុជា

ការកំណត់រកការផ្សាយបន្តផ្ទាល់អំពីការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ មានការលំបាកជាពិសេស។ កម្មវិធីណាមួយដែលមានមុខងារផ្សាយបន្តផ្ទាល់ ដូចជា Facebook, Viber ឬSkype អាចត្រូវបានប្រើប្រាស់។ នៅក្នុងការអង្កេតតាមខ្នងផ្ទះ កុមារដែលបានជួបប្រទះនឹង OCSEA រមែងតែងបានរាយការណ៍ថា ត្រូវបានគេកំណត់ជាគោលដៅលើកម្មវិធីនានា ដោយ Facebook គឺជាកម្មវិធី ដែលត្រូវបានលើកឡើងជាញឹកញាប់បំផុតដោយអ្នកផ្តល់ចម្លើយ។

### តើការអភិវឌ្ឍបច្ចេកវិទ្យាមានឥទ្ធិពលយ៉ាងដូចម្តេចចំពោះ OCSEA

ការមានយ៉ាងទូលំទូលាយនូវលទ្ធភាពទទួលបានប្រព័ន្ធអ៊ីនធឺណិតដែលមានល្បឿនកាន់តែលឿន និងតម្លៃកាន់តែថោក បានបង្កឱ្យមានកំណើនការប្រើប្រាស់ឧបករណ៍ជជែកជាវីដេអូនៅក្នុងការទំនាក់ទំនងគ្នា។ ឧបករណ៍ជជែកជាវីដេអូ និងផ្សាយបន្តផ្ទាល់ ទទួលបានភាពពេញនិយមយ៉ាងឆាប់រហ័ស និងកំពុងផ្លាស់ប្តូររបៀបរបបដែលយើងទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ជាពិសេស សម្រាប់យុវជន។ ការផ្សាយបន្តផ្ទាល់ទទួលបានការប្រើប្រាស់កាន់តែច្រើនឡើងទាំងនៅក្នុងចំណោមក្រុមលក្ខណៈឯកជនតូចៗ និងសម្រាប់ "ការផ្សព្វផ្សាយ" ទៅដល់ទស្សនិកកាន់តែច្រើន ទស្សនិកជនសាធារណៈ ទស្សនិកជនដែលគេមិនស្គាល់។ នៅកម្ពុជា ៤៨% នៃអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំ មើលការផ្សាយបន្តផ្ទាល់យ៉ាងហោចណាស់ជារៀងរាល់សប្តាហ៍។ កុមារា (៥១%) ទំនងជាមើលការផ្សាយបន្តផ្ទាល់ច្រើនជាងកុមារី (៤៦%)។ ៥៧% នៃកុមារអាយុ ១៦-១៧ឆ្នាំ មើលការផ្សាយបន្តផ្ទាល់ជារៀងរាល់សប្តាហ៍ ធៀបនឹងកុមារអាយុ ១២-១៣ឆ្នាំ ដែលមានចំនួន ៤២%។

បើទោះបីជាការមើលការផ្សាយបន្តផ្ទាល់រមែងតែងគ្មានគ្រោះថ្នាក់ និងអាចមានផលប្រយោជន៍ច្រើនក្តី ការប្រើប្រាស់មិនសមស្របចំពោះឧបករណ៍បែបនេះ កំពុងបង្កើតនូវវិធីថ្មីៗនៃការប្រព្រឹត្ត OCSEA ដូចខាងក្រោម៖

**ជនល្មើសដែលផ្សព្វផ្សាយការរំលោភបំពានផ្លូវភេទកុមារ៖** ឧបករណ៍ផ្សាយបន្តផ្ទាល់អាចត្រូវបានប្រើប្រាស់ ដើម្បីបញ្ជូនការរំលោភបំពានផ្លូវភេទកុមារក្នុងលក្ខណៈទាន់ហេតុការណ៍ទៅកាន់អ្នកទស្សនាម្នាក់ ឬច្រើននាក់ ដើម្បីឱ្យពួកគេអាចមើលការរំលោភបំពាននេះ នៅពេលកំពុងកើតឡើង។ អ្នកទស្សនាពីចម្ងាយអាចស្នើ ឬណែនាំចំពោះការរំលោភបំពាន ហើយការផ្ទេរប្រាក់អាចកើតឡើង

រួមជាមួយនឹងការរំលោភបំពាននេះ ឬអាចកើងតឡើងនៅក្នុងកម្មវិធីផ្ទិកាដូចគ្នានេះដែរ។

កម្មវិធីផ្សាយបន្តផ្ទាល់នេះមិនបង្កើតកំណត់ត្រាណាមួយឡើយ ដោយសារគ្មានការទាញយកវីដេអូទុក ឬរក្សាទុកដោយស្វ័យប្រវត្តិឡើយ ទោះបីជាយ៉ាងណាក្តីមានមេតាទិន្នន័យ។ ចំណុចនេះមានន័យថា នៅពេលការផ្សាយបន្តផ្ទាល់បញ្ចប់ CSAM បាត់ទៅដែរ លុះត្រាតែជនល្មើសមានចេតនាថតទុក។ ចំណុចនេះបង្កជាបញ្ហាប្រឈមជាក់លាក់ចំពោះអ្នកស៊ើបអង្កេត ព្រះរាជអាជ្ញា និងតុលាការជាពិសេស នៅពេលដែលនិយមន័យច្បាប់ដែលមានស្រាប់អំពី CSAM និងវិធីសាស្ត្រស៊ើបអង្កេត និងផ្តន្ទាទោសមិនតែងតែមានបច្ចុប្បន្នភាព។

**មាតិកាផ្លូវភេទដែលត្រូវបានបង្កើតឡើងអំពីខ្លួនឯង ដែលពាក់ព័ន្ធនឹងកុមារ៖** ដូចការកត់សម្គាល់នៅក្នុងជំពូក ១.៣.៣ កំណើននៃមាតិកាផ្លូវភេទដែលត្រូវបានបង្កើតឡើងអំពីខ្លួនឯង ទាំងដោយមាន និងគ្មានការបង្ខិតបង្ខំក្តី ក៏រួមមានមាតិកា ដែលត្រូវបានបញ្ជូនតាមរយៈការផ្សាយបន្តផ្ទាល់ផងដែរ។ មាតិកានេះបង្កបញ្ហាប្រឈមយ៉ាងស្មុគស្មាញ។ ទោះបីជាដំបូងមាតិកានេះត្រូវបានផលិតដោយគ្មានការបង្ខិតបង្ខំក្តី មាតិកានេះអាចនៅតែត្រូវបានចែកចាយ ទោះជាតាមរយៈការចែកចាយដោយគ្មានអនុញ្ញាត ឬតាមរយៈមធ្យោបាយទុច្ចរិត ដូចជា ការលួចចូល (Hacking) ក្តី។ រដ្ឋាភិបាល និងសេវាគាំទ្រនៅគ្រប់ទីកន្លែងកំពុងរកមធ្យោបាយដោះស្រាយបញ្ហាទាំងនេះ។

## ២.២ បទពិសោធន៍របស់កុមារអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារនៅកម្ពុជា

### បទពិសោធន៍កុមារអំពីការចែកចាយរូបភាពផ្លូវភេទដោយគ្មានការយល់ព្រម

យោងតាមការអង្កេតតាមខ្នងផ្ទះនៅកម្ពុជា កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ១២-១៧ឆ្នាំចំនួន ៧% (៧២នាក់) បានថ្លែងថា មានគេបានចែកចាយរូបភាពផ្លូវភេទរបស់ពួកគេដោយគ្មានការអនុញ្ញាត នៅឆ្នាំមុន។ បើទោះបីជាគ្មានការសង្កេតឃើញភាពខុសគ្នាផ្នែកយេនឌ័រក្តី កុមារអាយុ ១២-១៣ឆ្នាំ ទំនងជារងផលប៉ះពាល់ច្រើនជាងកុមារអាយុ ១៤-១៧ឆ្នាំ។

រូបភាពផ្លូវភេទរបស់កុមារ ជាពិសេស រូបភាពដែលត្រូវបានចែកចាយតាមប្រព័ន្ធអនឡាញ អាចត្រូវបានចែកចាយយ៉ាងទូលំទូលាយ និងមើលម្តងហើយម្តងទៀតនៅជុំវិញពិភពលោក ដែលបង្កឱ្យមានភាពអាម៉ាស និងការភ័យខ្លាចចំពោះការស្គាល់ជនរងគ្រោះ។ នៅពេលដែលរូបភាព ឬវីដេអូទាំងនេះបង្ហាញនូវករណីនៃការរំលោភបំពានផ្លូវភេទធ្ងន់ធ្ងរ ការប៉ះទង្គិចផ្លូវចិត្តដែលពាក់ព័ន្ធនឹងបទពិសោធន៍ជួបគ្នាដោយផ្ទាល់ ក៏អាចកើតឡើងជាសារជាថ្មីម្តងហើយម្តងទៀត តាមរយៈការចែកចាយមាតិកានេះផងដែរ។ ទោះបីជាយ៉ាងណាក្តី គម្រោងស្តីពី *ការបញ្ឈប់គ្រោះ*ថ្នាក់មិនព្យាយាមទទួលបានទិន្នន័យជាក់លាក់ពីកុមារពាក់ព័ន្ធនឹងការរំលោភបំពានធ្ងន់ធ្ងរឡើយ ភាគច្រើនគឺដោយសារអភិក្រមសីលធម៌ និងអភិក្រមជាវិធីសាស្ត្ររបស់យើងតម្រូវឱ្យយើងចាប់យកតែអ្វីដែលកុមារចែកចាយជាពាក្យពេជន៍របស់ពួកគេផ្ទាល់ប៉ុណ្ណោះ ជាជាងការស្វែងរក និងការជីកកកាយរកទម្រង់ជាក់លាក់នៃការរំលោភបំពាន។ ចំណុចនេះមិនមែនដើម្បីនិយាយថា ជនរងគ្រោះនៃអំពើបែបនេះមិនមែនជាផ្នែកមួយនៃសំណាករបស់យើងឡើយ ប៉ុន្តែជំនួសវិញ ចំណុចនេះមិនត្រូវបានបង្ហាញឡើយ។

**ក្នុង ឬក្រៅប្រព័ន្ធអនឡាញ?** នៅក្នុងចំណោមកុមារចំនួន ៧២នាក់ ដែលបាននិយាយថា រូបភាពផ្លូវភេទរបស់ពួកគេត្រូវបានចែកចាយដោយគ្មានការអនុញ្ញាតពីពួកគេ ពួកគេចំនួន ៣៧% បាននិយាយថា ការចែកចាយនេះបានកើតឡើងនៅតាមប្រព័ន្ធអនឡាញតាមរយៈបណ្តាញទំនាក់ទំនងសង្គម ឬតាមរយៈហ្គេមអនឡាញក្នុងសមាមាត្រស្រដៀងគ្នា។ ក្នុងចំណោមកុមារ ដែលបានរាយការណ៍ថា ការចែកចាយនេះបានកើតឡើងតាមរយៈបណ្តាញទំនាក់ទំនងសង្គម កម្មវិធីទូទៅបំផុតដែលបានប្រើប្រាស់គឺ Facebook ឬ Facebook Messenger ។ កុមារចំនួនជិតមួយភាគបីបាននិយាយថា រូបភាពរបស់ពួកគេត្រូវបានចែកចាយនៅក្នុងការជួបគ្នាដោយផ្ទាល់។ ទង្វើនេះអាចរួមមានការចែកចាយរូបភាពអាក្រាតរបស់កុមារនៅក្នុងចំណោមមិត្តភក្តិនៅក្នុងថ្នាក់រៀន នៅពេលដែលអ្នកគ្រប់គ្នាមានវត្តមាន ជាជាងតាមរយៈបណ្តាញទំនាក់ទំនងសង្គម។

**តើនរណាបានចែកចាយរូបភាពទាំងនេះ?** សម្រាប់កុមារភាគច្រើនក្នុងចំណោមកុមារទាំង ៧២នាក់ ជនល្មើសគឺជាអ្នកដែលកុមារស្គាល់ ដោយកុមារចំនួន ៤១% បានលើកឡើងថា គឺជាសមាជិកគ្រួសារ។ កុមារម្នាក់ក្នុងចំណោមដប់នាក់បានលើកឡើងថា គឺមិត្តភក្តិជាមនុស្សពេញវ័យ មិត្តភក្តិជាកុមារដែរ ព្រមទាំងដៃគូស្នេហានៅពេលបច្ចុប្បន្ន ឬពីអតីតកាល។ កុមារចំនួន ១៣% ប៉ុណ្ណោះ បានរាយការណ៍ថា រូបភាព ឬវីដេអូរបស់ពួកគេត្រូវបានចែកចាយដោយជនដែលពួកគេមិនស្គាល់។ គួរឱ្យកត់សម្គាល់ កុមារចំនួន ១៤% មិនចង់និយាយថា តើនរណាជាអ្នកចែកចាយរូបភាពទាំងនេះ។

**តើកុមារបានិយាយប្រាប់នរណា៖** កុមារជិតម្នាក់ក្នុងចំណោមប្រាំនាក់មិនបាននិយាយប្រាប់នរណាម្នាក់អំពី ហេតុការណ៍នេះឡើយ ភាគច្រើនគឺដោយសារពួកគេមិនដឹងអំពីកន្លែងដែលត្រូវទៅរាយការណ៍ ឬអ្នកដែលត្រូវនិយាយប្រាប់។ កុមារចំនួន ២១% បន្ថែមទៀតមិនចង់និយាយអំពីអ្នកដែលពួកគេទុកចិត្តឡើយ។ ក្នុងចំណោមកុមារដែលបានបង្ហាញអំពីហេតុការណ៍នេះ ពួកគេភាគច្រើនងាកទៅរកបណ្តាញអន្តរបុគ្គលរបស់ពួកគេ ដោយអ្នកដែលពួកគេទុកចិត្តទូទៅ គឺមិត្តភក្តិ បងប្អូនបង្កើត ឬអ្នកថែទាំ។ កុមារចំនួនតិចតួចបាននិយាយប្រាប់គ្រូបង្រៀន ស្របពេលដែលកម្រមានការរាយការណ៍ជាផ្លូវការទៅកាន់បុគ្គលិកសង្គម បណ្តាញទូរស័ព្ទទាន់ហេតុការណ៍ ឬនគរបាលណាស់។

OCSEA

កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំនៅកម្ពុជា
ពីការស្រាវជ្រាវអំពីការបញ្ឈប់គ្រោះថ្នាក់។ ចំនួន ៩៩២នាក់

នៅឆ្នាំមុន

# នរណាម្នាក់បានចែកចាយរូបថតរបស់ខ្ញុំ ដោយគ្មានការយល់ព្រមរបស់ខ្ញុំ

បាទឬចាស៎ ៧%



## ពេលចុងក្រោយរឿងនេះបានកើតឡើង...




កុមារដែលរូបភាពផ្លូវភេទរបស់ពួកគេត្រូវបានចែកចាយដោយគ្មានការយល់ព្រមរបស់ពួកគេ។ ចំនួន ៧២នាក់




កុមារដែលរូបភាពផ្លូវភេទរបស់ពួកគេត្រូវបានចែកចាយដោយគ្មានការយល់ព្រមរបស់ពួកគេ។ ចំនួន ៧២នាក់




កុមារដែលរូបភាពផ្លូវភេទរបស់ពួកគេត្រូវបានចែកចាយតាមរយៈបណ្ដាញទំនាក់ទំនងសង្គម ដោយគ្មានការយល់ព្រមរបស់ពួកគេ ។ ចំនួន ១៤នាក់




កុមារដែលរូបភាពផ្លូវភេទរបស់ពួកគេត្រូវបានចែកចាយដោយគ្មានការយល់ព្រមរបស់ពួកគេ។ ចំនួន ៧២នាក់




កុមារដែលរូបភាពផ្លូវភេទរបស់ពួកគេត្រូវបានចែកចាយដោយគ្មានការយល់ព្រមរបស់ពួកគេ និងដែលមិននិយាយប្រាប់នរណាម្នាក់អំពីវា។ ចំនួន ១៤នាក់

* ទូរលេខទាំងនេះតំណាងអោយការឆ្លើយតបដែលទូទៅបំផុតដោយកុមារ
** ទូរលេខទាំងនេះតំណាងអោយការឆ្លើយតបដែលទូទៅច្រើន និងតិចបំផុតជ្រើសរើសដោយកុមារ
† សំណួរពហុជម្រើស

ប្រភព៖ ទិន្នន័យនៃការសិក្សាស្រាវជ្រាវស្ដីពីការបញ្ឈប់គ្រោះថ្នាក់

# ២.២ បទពិសោធន៍របស់កុមារអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារនៅកម្ពុជា

### ការទទួលលុយកាក់ ឬអំណោយជាថ្នូរនឹងរូបភាព ឬវីដេអូផ្លូវភេទ

នៅពេលកុមារបង្កើតមាតិកាផ្លូវភេទជាថ្នូរនឹងអ្វីមួយ អំពើនេះរួមផ្សំជាការកេងប្រវ័ញ្ចផ្លូវភេទកុមារ ដោយមិនគិតថាតើកុមារទទួលរងការបង្ខិតបង្ខំ ឬចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពនេះ ឬអត់ឡើយ។ ផ្នែកនេះនៃរបាយការណ៍នេះពិចារណាលើករណីនានា នៅពេលដែលលុយកាក់ ឬអំណោយផ្សេងត្រូវបានប្រើប្រាស់ជាថ្នូរនឹងមាតិកាផ្លូវភេទ ដោយមិនគិតពីរបៀបនៃការផ្តួចផ្តើមដំណើរការនេះឡើយ។

ដោយសារភាពរសើបនៃប្រធានបទនេះ មានតែកុមារផ្តល់ការឆ្លើយតបអាយុ១៥-១៧ឆ្នាំនៅក្នុងការអង្កេតតាមខ្នងផ្ទះប៉ុណ្ណោះ ដែលត្រូវបានសួរថាពួកគេបានទទួលយកលុយកាក់ ឬអំណោយជាថ្នូរនឹងរូបភាព ឬវីដេអូផ្លូវភេទអំពីពួកគេដែរឬទេ។ នៅក្នុងចំណោមកុមារផ្តល់ការឆ្លើយតបចំនួន ៥២០នាក់ កុមារចំនួន ១៦នាក់ (៣%) បាននិយាយថា ពួកគេបានធ្វើបែបនេះនៅឆ្នាំមុន។ កុមារមួយចំនួនហាក់ដូចជាមានភាពស្ទាក់ស្ទើរក្នុងការបង្ហាញអំពី ការចូលរួមរបស់ពួកគេនៅក្នុងសកម្មភាពបែបនេះ ទោះបីជានៅក្នុងការអង្កេតអនាមិកក្តី ហេតុនេះ តួលេខពិតប្រាកដអាចខ្ពស់ជាងនេះ។

បើទោះបីជាការអនុវត្តការផ្តោះប្តូរលុយកាក់ ឬអំណោយសម្រាប់សកម្មភាពផ្លូវភេទមិនមែនជារឿងថ្មីក្តី ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរួមទាំងការប្រើប្រាស់ដោយកុមារ និងយុវជន ដើម្បីផ្តល់រូបភាព ឬវីដេអូអំពីខ្លួនឯង និងបញ្ជូនរូបភាព ឬវីដេអូជាថ្នូរនឹងលុយកាក់ ឬគ្រឿងលើកទឹកចិត្តជាសម្ភារដទៃទៀត គឺជានិន្នាការដែលកំពុងលេចឡើងជាសកល។ ការអនុវត្តនេះក៏បង្កើនយ៉ាងខ្លាំងនូវហានិភ័យនៃការចែកចាយបន្ថែមទៀតដោយគ្មានការអនុញ្ញាត។ នៅក្នុងការអង្កេតនៅឆ្នាំ២០១៥ អំពីនិន្នាការដែលកំពុងលេចឡើងនៃការផលិតមាតិកាផ្លូវភេទតាមប្រព័ន្ធអនឡាញ ដែលត្រូវបានធ្វើឡើងដោយមូលនិធិឃ្លាំមើលលើប្រព័ន្ធអ៊ីនធឺណិត  និងក្រុមហ៊ុន Microsoft ៩0% នៃរូបភាព និងវីដេអូបង្កើតឡើងដោយយុវជនដែលត្រូវបានវាយតម្លៃ ត្រូវបាន "ទាញយក"  ពីទីកន្លែងផ្ទុកដើម និងចែកចាយសារជាថ្មីនៅលើគេហ៍ទំព័រភាគីទីបី។

ចំណុចខ្វះចន្លោះទាក់ទងនឹងទម្រង់នៃ OCSEA ទាំងនេះនៅតែកើតមាននៅឡើយ។  ការយល់ដឹងជុំវិញការលើកទឹកចិត្តកុមារឱ្យចូលរួមក្នុងការអនុវត្តនេះនៅតែមានភាពស្មុគស្មាញ ដូចជា ការយល់ដឹងរបស់ពួកគេអំពីហានិភ័យនៃការចូលប្រើប្រាស់ និងរបៀបដែលពួកគេណែនាំដំបូងនៅក្នុងការអនុវត្តនេះ គឺជាសំណួរដែលចាំបាច់សម្រាប់ការស្រាវជ្រាវបន្ត។ "គេបានថតរូបរបស់ខ្ញុំ"

ការសន្ទនាជាមួយឧត្តរជីវីនៃ OCSEA នៅកម្ពុជាសម្រាប់គម្រោង *ការបញ្ឈប់គ្រោះថ្នាក់* បានបង្ហាញថា ជនល្មើសបានប្រមូលរូបភាពផ្លូវភេទរបស់កុមារកម្ពុជា ទាំងដោយគ្មានការយល់ព្រម និងទាំងតាមរយៈការផ្តោះប្តូរការទូទាត់ សម្រាប់ការចែកចាយតាមប្រព័ន្ធអនឡាញ។ មនុស្សប្រុសវ័យក្មេងចំនួនប្រាំនាក់មកពីប្រទេសកម្ពុជាត្រូវបានថតរូបនៅពេលកំពុងហែលទឹកនៅក្នុងស្រះទឹកមួយនៅក្នុងមូលដ្ឋាន និងទទួលបានការផ្តល់លុយកាក់៖ "នៅពេលថ្ងៃត្រង់មួយ នៅពេលយើងកំពុងហែលទឹក និងលេងសប្បាយ គាត់បានមក និងថតរូប។ គាត់ថតរូបរបស់យើងកំពុងលេងបែបធម្មតា" (RA៥-CA-0១) ហើយ "គាត់បានថតរូបនៅពេលខ្ញុំកំពុងហែលទឹក ពោលគឺកំពុងហែលទឹកជាមួយមិត្តភក្តិរបស់ខ្ញុំ។ យើងបានហែលទឹក។ គាត់បានជិះកង់ និងថតរូប ជិះកង់ និងថតរូប។ គាត់បានថតរូប យើងមិនបានដឹងឡើយថា គាត់បានថតរូប ហើយយើងមិនបានលឺឡើយ។ គាត់បានបញ្ចប់ការថតរូប ឱ្យលុយដល់ខ្ញុំ ហើយបន្ទាប់មក បានជិះកង់ចេញទៅ"។ (RA៥-CA-0៣) បុរសពាក់ព័ន្ធនោះមិនមែនជាសមាជិកនៃសហគមន៍របស់ពួកគេឡើយ៖ "ជនបរទេសបានមក និងឃើញយើងហែលទឹក ហើយពេលខ្លះ អ្នកផ្សេងទៀតបានមក និងបាននិយាយអំពីអ្វី ដែលគាត់ចង់ឱ្យយើងធ្វើ ពេលខ្លះ យើងមិនដឹងឡើយ... គាត់ឱ្យលុយ។" (RA៥-CA-0២) យុវជនទាំងនេះអាចឆ្ងល់អំពីមូលហេតុរបស់បុរសនោះ៖ "យើងពិតជាបាននិយាយជាគ្នាទៅវិញទៅមក និងបានលើកឡើងថា ហេតុអ្វីបានជាគាត់ថតរូបបែបនោះ។ ប៉ុន្តែយើងមិនបានដឹងឡើយ។ យើងមិនដឹងមូលហេតុដែលគាត់បានថតរូប ឬយល់... យើងមិនដឹងថា ការថតរូបបែបនោះបានធ្វើឱ្យយើង... បានធ្វើឱ្យយើង... ពេលខ្លះ យើងបានគិតយ៉ាងច្រើន តើវាខុស ឬត្រឹមត្រូវ?" (RA៥-CA-0២) ប៉ុន្តែបន្ទាប់ពីការចាប់ខ្លួនបុរសនោះ ពួកគេទទួលបានការយល់ដឹងខុសៗគ្នាមួយថា តើរូបថតទាំងនោះអាចត្រូវបានប្រើប្រាស់ សម្រាប់៖ "ពួកគេបានថតរូបរបស់ខ្ញុំ ដើម្បីបង្កើតរូបថតអាសអាភាស។" (RA៥-CA-0១).

> “ កុមារ ១៦នាក់ ក្នុងចំណោម ៥២០នាក់ដែលមានអាយុពី ១៥-១៧ឆ្នាំបានទទួលយកប្រាក់ ឬអំណោយជាថ្នូរនឹងរូបភាព ឬវីដេអូផ្លូវភេទរបស់ពួកគេកាលពីឆ្នាំមុន។ ”

## ២.២ បទពិសោធន៍របស់កុមារអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារនៅកម្ពុជា

### "គេបានថតរូបរបស់ខ្ញុំ"

ការសន្ទនាជាមួយឧត្តរជីវីនៃ OCSEA នៅកម្ពុជាសម្រាប់គម្រោង *ការបញ្ឈប់គ្រោះថ្នាក់* បានបង្ហាញថា ជនល្មើសបានប្រមូលរូបភាពផ្លូវភេទរបស់កុមារកម្ពុជា ទាំងដោយគ្មានការយល់ព្រម និងទាំងតាមរយៈការផ្ដោះប្ដូរការទូទាត់ សម្រាប់ការចែកចាយតាមប្រព័ន្ធអនឡាញ។ មនុស្សប្រុសវ័យក្មេងចំនួនប្រាំនាក់មកពីប្រទេសកម្ពុជាត្រូវបានថតរូប នៅពេលកំពុងហែលទឹកនៅក្នុងស្រះទឹកមួយនៅក្នុងមូលដ្ឋាន និងទទួលបានការផ្ដល់លុយកាក់៖ *"នៅពេលថ្ងៃត្រង់មួយ នៅពេលយើងកំពុងហែលទឹក និងលេងសប្បាយ គាត់បានមក និងថតរូប។ គាត់ថតរូបរបស់យើងកំពុងលេងបែបធម្មតា"* (RA៥-CA-0១) ហើយ *"គាត់បានថតរូប នៅពេលខ្ញុំកំពុងហែលទឹក ពោលគឺកំពុងហែលទឹកជាមួយមិត្តភក្តិរបស់ខ្ញុំ។ យើងបានហែលទឹក។ គាត់បានដិះកង់ និងថតរូប ជិះកង់ និងថតរូប។ គាត់បានថតរូប យើងមិនបានដឹងឡើយថា គាត់បានថតរូប ហើយយើងមិនបានលឺឡើយ។ គាត់បានបញ្ចប់ការថតរូប ឱ្យលុយដល់ខ្ញុំ ហើយបន្ទាប់មក បានជិះកង់ចេញទៅ"*។ (RA៥-CA-0៣) បុរសពាក់ព័ន្ធនោះមិនមែនជាសមាជិកនៃសហគមន៍របស់ពួកគេឡើយ៖ *"ជនបរទេសបានមក និងឃើញយើងហែលទឹក ហើយពេលខ្លះអ្នកផ្សេងទៀតបានមក និងបាននិយាយអំពីអ្វី ដែលគាត់ចង់ឱ្យយើងធ្វើ ពេលខ្លះ យើងមិនដឹងឡើយ... គាត់ឱ្យលុយ។"* (RA៥-CA-0២) យុវជនទាំងនេះអាចឆ្លល់អំពីមូលហេតុរបស់បុរសនោះ៖ *"យើងពិតជាបាននិយាយជាគ្នាទៅវិញទៅមក និងបានលើកឡើងថា ហេតុអ្វីបានជាគាត់ថតរូបបែបនោះ។ ប៉ុន្តែយើងមិនបានដឹងឡើយ។ យើងមិនដឹងមូលហេតុ ដែលគាត់បានថតរូប ឬយល់... យើងមិនដឹងថា ការថតរូបបែបនោះបានធ្វើឱ្យយើង... បានធ្វើឱ្យយើង... ពេលខ្លះ យើងបានគិតយ៉ាងច្រើន តើវាខុស ឬត្រឹមត្រូវ?"* (RA៥-CA-0២) ប៉ុន្តែបន្ទាប់ពីការចាប់ខ្លួនបុរសនោះ ពួកគេទទួលបានការយល់ដឹងខុសៗគ្នាមួយថា តើរូបថតទាំងនោះអាចត្រូវបានប្រើប្រាស់ សម្រាប់៖ *"ពួកគេបានថតរូបរបស់ខ្ញុំ ដើម្បីបង្កើតរូបថតអាសអាភាស។"* (RA៥-CA-0១).

### ករណីសិក្សា

#### ករណីសិក្សា៖ ការធ្វើពាណិជ្ជកម្ម CSAM

នៅខែមីនា ឆ្នាំ២០២០ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាបានកំណត់ឃើញករណីមួយពាក់ព័ន្ធនឹងជនសង្ស័យកម្ពុជាអាយុ១៨ឆ្នាំម្នាក់ ដែលបានទិញវីដេអូចំនួន ២៤ នៅខែសីហា ឆ្នាំ២០១៩ ហើយវីដេអូទាំងនោះបង្ហាញអំពីកុមារវ័យក្មេងៗដែលអាក្រាតកាយ។ ការវិភាគបែបចារកម្មបានបង្ហាញថា ជនរងគ្រោះទាំងឡាយគឺមកពីទ្វីបអឺរ៉ុប និងអាស៊ី។ កុមារម្នាក់ត្រូវបានកំណត់អត្តសញ្ញាណចេញពីអត្ថបទនៅក្នុងវីដេអូថា ជាជនជាតិចិន ។ ជនរងគ្រោះទំនងជាទទួលបានការបណ្ដុះបណ្ដាលឱ្យសម្ដែងដើម្បីផលិត CSAM ។ ជនរងគ្រោះមិនមានទំនាក់ទំនងគ្នាឡើយ ហើយពួកគេមិនទំនងជាទទួលរងការរំលោភបំពានផ្លូវភេទដោយប៉ះពាល់ផ្ទាល់ឡើយ។

ជនល្មើសកំពុងលក់សម្ភារទាំងនោះ ក្នុងទម្រង់ជាកម្រងនៃរូបភាព និងវីដេអូនានា ជាមួយនឹងតម្លៃជាក់លាក់ភ្ជាប់ជាមួយនឹងអាលប៊ុមនីមួយៗ។ ជនល្មើសបានប្រើប្រាស់ Telegram និង Facebook Messenger ដើម្បីទិញ និងចែកចាយវីដេអូនោះ។ អ្នកទិញដែលមានចំណាប់អារម្មណ៍ត្រូវបានណែនាំឱ្យផ្ទេរប្រាក់តាមរយៈ Wing ដែលជាក្រុមហ៊ុនផ្ដល់សេវាកម្មធនាគារចល័តរបស់កម្ពុជា។ Telegram ត្រូវបានប្រើប្រាស់ ដើម្បីទំនាក់ទំនងជាមួយក្រុមអតិថិជន ដែលមានចំណាប់អារម្មណ៍ក្នុងការទិញវីដេអូទាំងនោះ។ ជនល្មើសត្រូវបានផ្ដន្ទាទោសនៅឆ្នាំ២០២០ និងជាប់ពន្ធនាគាររយៈពេលបួនឆ្នាំ។ ជនល្មើសត្រូវបានចោទប្រកាន់អំពី បទមានជាកម្មសិទ្ធិ និងចែកចាយ CSAM ។ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាបានធ្វើការងារជាមួយក្រុមហ៊ុនផ្ដល់សេវាកម្មអេឡិចត្រូនិក កម្មវិធីបណ្ដាញទំនាក់ទំនងសង្គម និង Wing ដើម្បីបញ្ចប់ និងបិទក្រុមនេះ ហើយការព្យាយាមកំណត់អត្តសញ្ញាណជនសង្ស័យដទៃទៀតនៅតែបន្តដំណើរការ។ ជនរងគ្រោះដែលត្រូវបានបង្ហាញនៅក្នុងសម្ភារទាំងនោះ មិនត្រូវបានកំណត់អត្តសញ្ញាណឡើយ។

# ២.៣ បទពិសោធន៍ដទៃទៀតរបស់កុមារ ដែលអាចមានទំនាក់ទំនងជាមួយនឹង OCSEA

បន្ថែមលើឧទាហរណ៍នៃ OCSEA ដែលត្រូវបានបង្ហាញរួចហើយ កុមារអាចទទួលរងបទពិសោធន៍ដទៃទៀតតាមប្រព័ន្ធអនឡាញ ដែលអាចមានគ្រោះថ្នាក់ ដូចជា ការបៀតបៀនផ្លូវភេទ ឬការមើលឃើញមាតិកាដោយមិនចង់ឃើញ។ លើសពីនេះ ក្នុងករណីខ្លះ បទពិសោធន៍ទាំងនេះអាចរួមចំណែកចំពោះការធ្វើឱ្យកុមារមានភាពរំជើបរំជួល ដើម្បីឱ្យពួកគេរិតតែទំនងជាចូលរួមនៅក្នុងការនិយាយអំពីបញ្ហាផ្លូវភេទ ឬសកម្មភាពផ្លូវភេទ ឧទាហរណ៍ នៅក្នុងដំណើរការលួងលោម។

### ២.៣.១ ការបៀតបៀនផ្លូវភេទ

ទោះបីជាមិនមានទំនាក់ទំនាក់យ៉ាងជាក់លាក់ចំពោះកុមារ ឬបរិបទអនឡាញក្តី ក្រមព្រហ្មទណ្ឌកំណត់ជាបទល្មើសចំពោះការបៀតបៀនផ្លូវភេទ ដែលត្រូវបានកំណត់និយមន័យថា "អំពើដែលបុគ្គលម្នាក់រំលោភអំណាច ដែលមុខងាររបស់ខ្លួនប្រគល់ឱ្យ ធ្វើការគាបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដទៃ ក្នុងគោលបំណងទទួលបានការអនុគ្រោះខាងផ្លូវភេទ។" ទណ្ឌកម្មចំពោះបទល្មើសនេះ (ការដាក់ពន្ធនាគារពីប្រាំមួយថ្ងៃទៅបីខែ និងការពិន័យពី ១០.០០០ ទៅ ៥០០.០០០រៀល ដែលស្មើនឹងប្រមាណពី ២,៥០ និង ១២៥ដុល្លារអាមេរិក) មិនឆ្លុះបញ្ចាំងចរិតធ្ងន់ធ្ងរនៃបទល្មើសនេះឡើយ ជាពិសេស នៅពេលប្រព្រឹត្តលើកុមារ។

យោងតាមការអង្កេតតាមខ្នងផ្ទះ នៅក្នុងឆ្នាំមុន កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ស្ទើរតែ ១៦% (១៥៤នាក់) បានទទួលយោបល់បែបផ្លូវភេទអំពីពួកគេ ដែលធ្វើឱ្យពួកគេគ្មានអារម្មណ៍ជាសុកភាពឡើយ រួមទាំង ការលេងសើច សាច់រឿង ឬយោបល់អំពីរាងកាយរបស់កុមារ រូបរាង ឬសកម្មភាពផ្លូវភេទ។ ទំនងជាកុមារា (១៧%) ទទួលរងយោបល់បែបនេះច្រើនជាងកុមារី (១៤%) ដូចគ្នាចំពោះកុមារអាយុ ១២-១៥ឆ្នាំ (១៧%) ធៀបនឹងកុមារអាយុ ១៦-១៧ឆ្នាំ (១៣%)។ ស្របពេលដែលកុមារមួយចំនួនបានរាយការណ៍ថា យោបល់បែបផ្លូវភេទអំពីពួកគេមិនប៉ះពាល់ដល់ពួកគេ (២៧%) កុមារភាគច្រើនបានរងផលប៉ះពាល់អវិជ្ជមាន និងជាទូទៅ មានអារម្មណ៍អាម៉ាស តានតឹងក្នុងចិត្ត ឬខឹងចំពោះការប្រព្រឹត្តបែបនេះ។

**ក្នុង ឬក្រៅប្រព័ន្ធអនឡាញ?** ៤៥% នៃករណីបៀតបៀនផ្លូវភេទដែលត្រូវបានធ្វើការរាយការណ៍តាមអនឡាញ តាមរយៈបណ្តាញទំនាក់ទំនងសង្គម និងជាទូទៅ Facebook ឬ Facebook Messenger។ កុមារម្នាក់ក្នុងចំណោម៦នាក់បាននិយាយថា ការបៀតបៀនផ្លូវភេទគឺភាគច្រើនកើតឡើងដោយការជួបផ្ទាល់។

**ជនល្មើស៖** នៅពេលកុមារចំនួន ១៥៤នាក់ ដែលបានរងការបៀតបៀនផ្លូវភេទនៅឆ្នាំមុន ទោះជានៅក្នុង ឬក្រៅប្រព័ន្ធអនឡាញក្តី ត្រូវបានសួរអំពី អត្តសញ្ញាណរបស់ជនល្មើស កុមារចំនួនមួយភាគបីបានកំណត់ថាជាសមាជិកគ្រួសារ។ បុគ្គលដទៃទៀត ដែលកុមារស្គាល់ រួមមាន ដៃគូស្នេហា មិត្តភក្តិជាមនុស្សពេញវ័យ ឬមិត្តភក្តិជាកុមារ ក៏ត្រូវបានលើកឡើងថា ជាជនល្មើសផងដែរ។ កុមារចំនួនជាងមួយភាគបួនបានរាយការណ៍ថា ជនដែលពួកគេមិនស្គាល់ ទទួលខុសត្រូវចំពោះការបៀតបៀននេះ។ ចំនួនកុមារគួរឱ្យកត់សម្គាល់ ពោលគឺ ១៩% មិនមានជាសុកភាពក្នុងការបង្ហាញអត្តសញ្ញាណរបស់ជនល្មើសឡើយ។
 កុមារចំនួនជិតមួយភាគបី ដែលបានជួបប្រទះនឹងការបៀតបៀនផ្លូវភេទ មិនប្រាប់រឿងនេះទៅដល់នរណាម្នាក់ឡើយ ភាគច្រើន គឺដោយសារពួកគេមិនអំពី កន្លែងដែលត្រូវទៅរាយការណ៍ ឬអ្នកដែលពួកគេត្រូវនិយាយប្រាប់។

**ការលាតត្រដាងប្រាប់៖** កុមារចំនួនជិតមួយភាគបី ដែលបានជួបប្រទះនឹងការបៀតបៀនផ្លូវភេទ មិនប្រាប់រឿងនេះទៅដល់នរណាម្នាក់ឡើយ ភាគច្រើន គឺដោយសារពួកគេមិនអំពី កន្លែងដែលត្រូវទៅរាយការណ៍ ឬអ្នកដែលពួកគេត្រូវនិយាយប្រាប់។ កុមារភាគច្រើនបានទុកចិត្តលើនរណាម្នាក់នៅក្នុងរង្វង់នៃទំនុកចិត្តរបស់ពួកគេ ដែលជាទូទៅ ពួកគេលើកឡើងអំពី មិត្តភក្តិ អ្នកថែទាំ ឬបងប្អូនបង្កើត។ ជាថ្មីម្តងទៀត កុមារចំនួនតិចតួចណាស់ ដែលបានរាយការណ៍ជាផ្លូវការអំពី ហេតុការណ៍នេះទៅកាន់នគរបាល បុគ្គលិកសង្គម ឬបណ្តាញទូរស័ព្ទជំនួយ (១%)។

### ២.៣.២ ការទទួលបានរូបភាពផ្លូវភេទដែលមិនចង់បាន

នៅក្នុងសំណាកនៃការអង្កេតតាមខ្នងផ្ទះ កុមារចំនួន១៦១នាក់ (១៦%) បានទទួលរូបភាពផ្លូវភេទដែលពួកគេមិនចង់បាន នៅឆ្នាំមុន។ បញ្ហានេះមានលក្ខណៈទូទៅចំពោះកុមារអាយុ ១៤-១៥ឆ្នាំ (១៦%) និងកុមារអាយុ ១៦-១៧ឆ្នាំ (១៨%) ជាជាងកុមារអាយុ ១២-១៣ឆ្នាំ (១៤%)។ ទោះបីជាយ៉ាងណាក្តី គ្មានការសង្កេតឃើញភាពខុសគ្នាចំពោះយេនឌ័រនៅក្នុងចំណោមកុមារ ដែលបានរាយការណ៍អំពីការទទួលបានរូបភាពផ្លូវភេទដែលមិនចង់បានឡើយ។ នៅពេលសួរអំពីលើកមុន ដែលពួកគេបានទទួលរូបភាពផ្លូវភេទដែលមិនចង់បាន កុមារចំនួន ៤៧% បាននិយាយថា វាបានកើតឡើងនៅតាមប្រព័ន្ធអនឡាញ ភាគច្រើនតាមរយៈបណ្តាញទំនាក់ទំនងសង្គម និងកើតឡើងជាទូទៅបំផុតនៅលើ

Facebook (ឬ Facebook Messenger)។ កុមារប្រហែលម្នាក់ក្នុងចំណោមដប់នាក់បានរាយការណ៍ថា ពួកគេបានទទួលរូបភាពដែលមិនចង់បាននៅក្នុងជំនួបទល់មុខគ្នាដោយផ្ទាល់។

មួយភាគបួននៃកុមារទាំងនេះបានរាយការណ៍ថា ការទទួលបានរូបភាពទាំងនេះមិនមានផលប៉ះពាល់លើពួកគេឡើយ។ ក្នុងចំណោមកុមារទាំងឡាយ ដែលបង្ហាញការឆ្លើយតបអវិជ្ជមានចំពោះការទទួលបានរូបភាពបែបនេះ អារម្មណ៍ទូទៅបំផុត គឺខឹង ម៉ួម៉ៅ និងតានតឹងក្នុងចិត្ត។ ភាគច្រើននៃកុមារបានលើកឡើងអំពីអ្នកដែលពួកគេស្គាល់ថា ជាជនល្មើស ដោយការទទួលបានរូបភាពផ្លូវភេទភាគច្រើនគឺបានមកពីសមាជិកគ្រួសារ បន្ទាប់មក មិត្តភក្តិដែលជាកុមារដែរ។ កុមារចំនួនជិតពីរនាក់ក្នុងចំណោមប្រាំនាក់បានរាយការណ៍អំពី ការទទួលបានរូបភាពផ្លូវភេទពីនរណាម្នាក់ ដែលពួកគេមិនស្គាល់។ នេះគឺជាករណីតែមួយគត់ក្នុងចំណោមករណីទាំងអស់ដែលត្រូវសិក្សានៅក្នុងការស្រាវជ្រាវនេះ ដែលជនដែលកុមារមិនស្គាល់ត្រូវបានកំណត់ថាជាជនល្មើសនៅក្នុងសមាមាត្រដ៏ធំបែបនេះ។

កុមារចំនួនស្ទើរតែមួយភាគបីមិនបានប្រាប់នរណាម្នាក់អំពី អ្វីដែលបានកើតឡើងឡើយ ភាគច្រើនគឺដោយសារពួកគេមិនដឹងពីកន្លែងដែលត្រូវទៅរាយការណ៍ ឬអ្នកដែលត្រូវនិយាយប្រាប់។ កុមារដែលបាននិយាយប្រាប់នរណាម្នាក់ ទំនងជាទុកចិត្តលើអ្នកថៃទាំជាបុរស ឬមិត្តភក្តិបំផុត (និងក្នុងកម្រិតស្មើគ្នា)។ ជាថ្មីម្តងទៀត កុមារចំនួនតិចតួចណាស់បានធ្វើសេចក្តីរាយការណ៍ជាផ្លូវការទោះតាមរយៈបុគ្គលិកសង្គម ឬទៅកាន់នគរបាលក្តី។

### ការបន្តការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និងអូហ្វឡាញ

ទិន្នន័យពីគម្រោងស្តីពីការបញ្ឈប់គ្រោះថ្នាក់បង្ហាញថា ការចាត់ជាប្រភេទយ៉ាងតឹងរឹងចំពោះការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារថា "អនឡាញ" ឬ "អូហ្វឡាញ" មិនឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវការពិតរបស់អំពើហិង្សាផ្លូវភេទ ដែលកុមារកំពុងជួបប្រទះឡើយ។

គម្រោងស្តីពី*ការបញ្ឈប់គ្រោះ*ថ្នាក់ស្វែងរក និងបង្ហាញទិន្នន័យអំពី៖

- ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ដែលកើតឡើងទាំងស្រុងនៅក្នុងបរិយាកាសអនឡាញ។
- ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ដែលកើតឡើងអូហ្វឡាញ (ក្រៅប្រព័ន្ធអនឡាញ) ប៉ុន្តែត្រូវបានសម្របសម្រួលដោយបច្ចេកវិទ្យាឌីជីថលអនឡាញ។
- ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ដែលត្រូវប្រព្រឹត្តនៅក្រៅប្រព័ន្ធអនឡាញ និងបន្ទាប់ឈានទៅរកប្រព័ន្ធអនឡាញតាមរយៈការចែកចាយរូបភាព ឬវីដេអូនៃការរំលោភបំពាន។

របកគំហើញពីការស្រាវជ្រាវនេះបង្ហាញថា បើទោះបីជាករណី OCSEA ទាំងអស់ត្រូវបានកំណត់លក្ខណៈដោយសមាសធាតុអនឡាញក្តី ការរំលោភបំពាន និងការកេងប្រវ័ញ្ចអាច និងរមែងតែងកើតឡើងនៅចំណុចជាច្រើននៅក្នុងការបន្តកើតមាននៅរវាងប្រព័ន្ធអនឡាញ និងអូហ្វឡាញ។ ការរំលោភបំពាន និងការកេងប្រវ័ញ្ចនេះអាចផ្លាស់ទីរវាងប្រព័ន្ធអនឡាញ និងអូហ្វឡាញនៅក្នុងពេលវេលាខុសៗគ្នា។

ឧទាហរណ៍ ជនល្មើសអាចប្រើប្រាស់បរិយាកាសអនឡាញ ដើម្បីភ្ជាប់ទំនាក់ទំនង បញ្ចុះបញ្ចូល និង/ឬបង្ខិតបង្ខំកុមារឱ្យចែកចាយមាតិកាផ្លូវភេទដែលត្រូវបង្កើតដោយខ្លួនឯង ដែលអាចត្រូវបានចែកចាយយ៉ាងទូលំទូលាយនៅពេលក្រោយនៅក្នុងបរិយាកាសអនឡាញ។ ជនល្មើសអាចប្រើប្រាស់បរិយាកាសអនឡាញ ដើម្បីលួងលោមកុមារក្នុងចេតនាជួបគ្នាដោយផ្ទាល់នៅពេលក្រោយ ដើម្បីចូលរួមនៅក្នុងការរំលោភបំពាន ឬការកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងបរិយាកាសក្រៅប្រព័ន្ធអនឡាញ។ ជនល្មើសអាចចូលរួមជាមួយនឹងការរំលោភបំពាន ឬការកេងប្រវ័ញ្ចកុមារជាបន្តបន្ទាប់នៅក្នុងបរិយាកាសក្រៅប្រព័ន្ធអនឡាញ ប៉ុន្តែអាចប្រើប្រាស់ឧបករណ៍អនឡាញ ដើម្បីទំនាក់ទំនងជាមួយកុមារ បង្ខំកុមារ ចាប់យករូបភាព ឬវីដេអូផ្លូវភេទ (និងអាចចែកចាយមាតិកាផ្លូវភេទនៅក្នុងបរិយាកាសអនឡាញ)។ ទាំងនេះគ្រាន់តែជាឧទាហរណ៍មួយចំនួននៃចរិតថាមវន្តនៃ OCSEA និងលក្ខណៈងាយផ្លាស់ទីរវាងការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទកុមារក្នុង និងក្រៅប្រព័ន្ធអនឡាញប៉ុណ្ណោះ។

ការសម្ភាស និងទិន្នន័យនៃការអង្កេត ដែលប្រមូលបានពីអ្នកពាក់ព័ន្ធជាច្រើននៅទូទាំងរដ្ឋាភិបាល ប្រព័ន្ធច្បាប់ និងនៅក្នុងចំណោមបុគ្គលិកសេវាសង្គមជួរមុខបង្ហាញឱ្យឃើញថា ពីការយល់ឃើញជាប្រព័ន្ធ OCSEA មិនត្រូវគេបានយល់ច្បាស់ឡើយ និងតែងតែត្រូវបានយល់ឃើញថា ជា "ការរំលោភបំពានប្រភេទថ្មី" ដែលទាមទារនូវការឆ្លើយតបខុសគ្នាទាំងស្រុង។ *"ការយល់ដឹងរបស់អាជ្ញាធរ អំពី*

*OSCEA] នៅមានកម្រិត"* (RA៣-CA-១០-A)។ ទោះបីជាយ៉ាងណាក្តី នៅពេលបុគ្គលិកជួរមុខត្រូវបានសុំឱ្យកំណត់កត្តានានា ដែលមានផលប៉ះពាល់លើភាពងាយរងគ្រោះរបស់កុមារចំពោះការកេងប្រវ័ញ្ចផ្លូវភេទជាទូទៅ និង OCSEA ជាទូទៅ ពួកគេបានជ្រើសរើសកត្តាដូចគ្នាមួយចំនួន រួមមានការទទួលបាន និងការមើលឃើញរូបភាព ឬវីដេអូអាសអាភាស លទ្ធភាពកាន់តែច្រើនក្នុងការទទួលបានបច្ចេកវិទ្យា និងប្រព័ន្ធអ៊ីនធឺណិត  និងឪពុកម្តាយ/អាណាព្យាបាលទុកកូនចោលដោយសារពួកគេបានធ្វើចំណាកស្រុកទៅធ្វើការងារ។ អ្នកឆ្លើយតបម្នាក់បានកត់សម្គាល់ថា *"[ភាពងាយរងគ្រោះចំពោះ] ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ គឺដូចគ្នានឹងភាពងាយរងគ្រោះរបស់កុមារចំពោះការកេងប្រវ័ញ្ចផ្លូវភេទជាទូទៅ៖ កុមារដែលកំពុងរស់នៅក្នុងតំបន់ក្រុមជាតិពន្ធ ប្រជាជនដែលប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតច្រើន កុមារដែលរស់នៅតាមថ្នល់។ល។"* (RA៣-CA-៨៨-A) អ្នកមានភារកិច្ចម្នាក់មកពីជួររដ្ឋាភិបាលដែលត្រូវបានសម្ភាស បានអះអាងថា ការមើលរូបភាព ឬវីដេអូអាសអាភាសបានលើកទឹកចិត្តកុមារឱ្យសាកល្បងអ្វីដែលពួកគេបានមើលឃើញនៅក្នុងរូបភាព។ (RA១-CA-០៣-A) គួរឱ្យសោកស្តាយ ការសន្និដ្ឋានអំពីហេតុ និងផលរវាងការមើលឃើញរូបភាពអាសអាភាស និងការក្លាយទៅជាជនរងគ្រោះនៃ OCSEA ជាទូទៅបង្កឱ្យមានការបន្ទោសលើជនរងគ្រោះ និងកង្វះការគាំទ្រជាបន្តបន្ទាប់សម្រាប់កុមារ ដែលត្រូវបានគេមើលឃើញថា មានការពាក់ព័ន្ធនឹងការបង្កគ្រោះថ្នាក់ចំពោះខ្លួនឯងផ្ទាល់។ គប្បីកត់សម្គាល់ថា ការយល់ឃើញដែលត្រូវបានបង្ហាញនៅទីនេះត្រូវបានផ្អែកលើការបកស្រាយបែបអត្តនោម័ត។

ទិន្នន័យពីបណ្តាប្រទេសអនុវត្តគម្រោងស្តីពី *ការបញ្ឈប់គ្រោះ*ថ្នាក់បង្ហាញយ៉ាងសង្គតភាពគ្នាថា សមាមាត្រនៃកុមារដែលទទួលរង OCSEA ក៏ប្រឈមមុខនឹងករណីនៃការរំលោភបំពានផ្លូវភេទផ្លូវកាយ ឬផ្លូវចិត្តដោយផ្ទាល់ផងដែរ។ ចំណុចនេះអាចបង្ហាញថា OCSEA គឺការពង្រីកបន្ថែមមួយនៃការរំលោភបំពានដែលមានស្រាប់ ដែលកុមារបានជួបប្រទះរួចហើយ ឬបង្ហាញថា មានកម្រងជាទូទៅមួយនៃភាពងាយរងគ្រោះនានា ដែលធ្វើឱ្យកុមារដែលជួបប្រទះអំពើហិង្សាក្រៅប្រព័ន្ធអនឡាញរិតតែទំនងជាជួបប្រទះអំពើហិង្សានៅក្នុងប្រព័ន្ធអនឡាញផងដែរ និង/ឬផ្ទុយពីនេះទៅវិញ។

នៅឆ្នាំមុន

កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំនៅកម្ពុជា
ពីការស្រាវជ្រាវអំពីការបញ្ឈប់គ្រោះថ្នាក់។ ចំនួន ៩៩២នាក់

# នរណាម្នាក់និយាយពាក់ព័ន្ធនឹងផ្លូវភេទអំពីខ្ញុំ ដែលធ្វើឱ្យខ្ញុំមានអារម្មណ៍គ្មានផាសុកភាព

## បាទឬចាស់ ១៦%

## ពេលចុងក្រោយរឿងនេះបានកើតឡើង...

### តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេច?*

- វាមិនមានឥទ្ធិពលលើខ្ញុំទាល់តែសោះ ២៧%
- ខឹង ១០%
- អាម៉ាស ១៦%
- តានតឹងក្នុងចិត្ត ១៣%

### តើនរណាជាអ្នកបញ្ជូនរូបភាពបែបនេះ?*†

- នរណាម្នាក់នៅក្នុងគ្រួសាររបស់ខ្ញុំ ៣៣%
- មិនចង់និយាយ ១៩%
- ដៃគូស្នេហា (ឬអតីត) ១១%
- មិត្តភក្តិ/អ្នកស្គាល់គ្នា (១៨+) ៩%
- មិត្តភក្តិ/អ្នកស្គាល់គ្នា (ក្រោមអាយុ) ៨%
- នរណាម្នាក់ ដែលខ្ញុំមិនស្គាល់/ជនចម្លែកមុខ ២៦%

កុមារដែលបានជួបប្រទះនឹងយោបល់ផ្លូវភេទអំពីពួកគេ ដែលធ្វើឱ្យពួកគេមានអារម្មណ៍គ្មានផាសុកភាព។ ចំនួន ១៥៤នាក់

### តើវាបានកើតឡើងនៅកន្លែងណា?*†

- តាមបណ្តាញទំនាក់ទំនងសង្គម ៣១%
- នៅទល់មុខគ្នាដោយផ្ទាល់ ១៦%
- នៅក្នុងហ្គេមអនឡាញ ១៤%
- វិធីផ្សេងទៀត ១៣%

កុមារដែលបានជួបប្រទះនឹងយោបល់ផ្លូវភេទអំពីពួកគេ ដែលធ្វើឱ្យពួកគេមានអារម្មណ៍គ្មានផាសុកភាព។ ចំនួន ១៥៤នាក់

### តើបានកើតឡើងនៅក្នុងកម្មវិធីណាមួយ?*†

- Facebook ឬ Facebook Messenger ៨៥%
- YouTube ២៨%
- TikTok ២៦%

កុមារដែលបានជួបប្រទះនឹងយោបល់ផ្លូវភេទអំពីពួកគេតាមរយៈបណ្តាញទំនាក់ទំនងសង្គម ដែលធ្វើឱ្យពួកគេមានអារម្មណ៍គ្មានផាសុកភាព។ ចំនួន ៤៧នាក់

### តើអ្នកបាននិយាយប្រាប់នរណា?**†

លំដាប់កំពូលទាំង ៣

- គ្មាននរណាម្នាក់ ៣១%
- មិត្តភក្តិ ១៩%
- អ្នកថែទាំជាបុរស ១៧%

លំដាប់ក្រោមទាំង ៣

- គ្រូបង្រៀន ៥%
- មនុស្សពេញវ័យផ្សេងទៀតដែលខ្ញុំទុកចិត្ត ៣%
- នគរបាល ៣%
- បុគ្គលិកសង្គម ១%
- បណ្តាញទូរស័ព្ទជំនួយ ១%

កុមារដែលបានជួបប្រទះនឹងយោបល់ផ្លូវភេទអំពីពួកគេដែលធ្វើឱ្យពួកគេមានអារម្មណ៍គ្មានផាសុកភាព។ ចំនួន ១៥៤នាក់

### ហេតុអ្វីបានជាអ្នកមិនប្រាប់នរណាម្នាក់?*†

- ខ្ញុំមិនដឹងអំពីកន្លែងដែលត្រូវទៅ ឬអ្នកដែលត្រូវនិយាយប្រាប់ ៥៦%
- ខ្ញុំមានអារម្មណ៍អាម៉ាស ៨%
- ខ្ញុំមានអារម្មណ៍ថាខ្ញុំបានធ្វើខុស និងមិនចង់និយាយប្រាប់នរណាឡើយ ៨%

កុមារដែលបានជួបប្រទះនឹងយោបល់ផ្លូវភេទអំពីពួកគេ ដែលធ្វើឱ្យពួកគេមានអារម្មណ៍គ្មានផាសុកភាព និងមិនបានប្រាប់នរណាម្នាក់អំពីវា។ ចំនួន ៤៨នាក់

* ទូរលេខទាំងនេះតំណាងអោយការឆ្លើយតបដែលទូទៅបំផុតដោយកុមារ
** ទូរលេខទាំងនេះតំណាងអោយការឆ្លើយតបដែលទូទៅច្រើន និងតិចបំផុតជ្រើសរើសដោយកុមារ
† សំណួរពហុជម្រើស

ប្រភព៖ ទិន្នន័យនៃការសិក្សាស្រាវជ្រាវស្តីពីការបញ្ឈប់គ្រោះថ្នាក់

នៅឆ្នាំមុន

# នរណាម្នាក់បានផ្ញើរូបភាព ផ្លូវភេទដែលខ្ញុំមិនចង់បាន

កុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំនៅកម្ពុជា ពីការស្រាវ ជ្រាវអំពីការបញ្ឈប់គ្រោះថ្នាក់។ ចំនួន ៩៩២នាក់

**បាទ/ចាស ១៦%**

## ពេលចុងក្រោយរឿងនេះបានកើតឡើង...

### តើអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច?*

- វាមិនមានឥទ្ធិពលលើខ្ញុំទាល់តែសោះ: ២៥%
- ខឹង: ១៣%
- តានតឹងក្នុងចិត្ត: ១១%
- ម៉ូម៉ៅ: ១២%

### តើនរណាជាអ្នកបញ្ជូនរូបភាពបែបនេះ?*†

- នរណាម្នាក់នៅក្នុងគ្រួសាររបស់ខ្ញុំ: ២៩%
- មិនចង់និយាយ: ១៦%
- មិត្តភក្តិ/អ្នកស្គាល់គ្នា (១៨+): ១៣%
- មិត្តភក្តិ/អ្នកស្គាល់គ្នា (ក្រោមអាយុ): ៧%
- ដៃគូស្នេហា (ឬអតីត): ６%
- នរណាម្នាក់ ដែលខ្ញុំមិនស្គាល់/ជនចម្លែកមុខ: ៣៩%

កុមារដែលបានទទួលរូបភាពផ្លូវភេទ ដែលពួកគេមិនចង់បាន។ ចំនួន ១៦១នាក់

### តើវាបានកើតឡើងនៅកន្លែងណា?*†

- តាមបណ្ដាញ ទំនាក់ទំនងសង្គម: ៣៦%
- នៅទល់មុខគ្នាដោយផ្ទាល់: ១១%
- នៅក្នុងហ្គេមអនឡាញ: ១១%
- វិធីផ្សេងទៀត: ១៦%

កុមារដលែបានទទួលរូបភាពផ្លូវភេទ ដលែពួកគមេិនចង់បាន។ ចំនួន ១៦១នាក់

### តើបានកើតឡើងនៅក្នុងកម្មវិធីណាមួយ?*†

- Facebook ឬ Facebook Messenger: ៨៣%
- TikTok: ១២%
- YouTube: ១០%

កុមារដែលបានទទួលរូបភាពផ្លូវភេទ ដែលពួកគេមិនចង់បាន តាមបណ្ដាញទំនាក់ទំនងសង្គម។ ចំនួន ៥៨នាក់

### តើអ្នកបាននិយាយប្រាប់នរណា?**†

លំដាប់កំពូលទាំង ៣

- គ្មាននរណាម្នាក់: ៣២%
- អ្នកថែទាំជាបុរស: ១៦%
- មិត្តភក្តិ: ១៦%
- បងប្អូនបង្កើត: ១២%

លំដាប់ក្រោមទាំង ៣

- ម្ដាយ ម្ដាយចុង/ធម៌: ៨%
- គ្រូបង្រៀន: ៨%
- មិនចង់និយាយ: ៤%
- នគរបាល: ២%
- បុគ្គលិកសង្គម: ២%

កុមារដែលបានទទួលរូបភាពផ្លូវភេទ ដែលពួកគេមិនចង់បាន។ ចំនួន ១៦១នាក់

### ហេតុអ្វីបានជាអ្នកមិនប្រាប់នរណាម្នាក់?*†

- ខ្ញុំបារម្ភថាខ្ញុំនឹងមានបញ្ហា: ៤៦%
- ខ្ញុំមានអារម្មណ៍ អាម៉ាស ខ្មាសអៀន ឬវាពិបាកនិយាយខ្លាំងពេក: ១៥%
- ខ្ញុំមិនគិតថា អាចធ្វើអ្វីបានឡើយ: ១១%

កុមារដែលបានទទួលរូបភាពផ្លូវភេទ ដែលពួកគេមិនចង់បាន និងមិនបានប្រាប់នរណាម្នាក់ អំពីវា។ ចំនួន ៥២នាក់

* ទូរលេខទាំងនេះតំណាងអោយការឆ្លើយតបដែលទូទៅបំផុតដោយកុមារ
** ទូរលេខទាំងនេះតំណាងអោយការឆ្លើយតបដែលទូទៅច្រើន និងតិចបំផុតជ្រើសរើសដោយកុមារ
† សំណួរពហុជម្រើស

ប្រភព៖ ទិន្នន័យនៃការសិក្សាស្រាវជ្រាវស្ដីពីការបញ្ឈប់គ្រោះថ្នាក់

# ២.៤ ការយល់ដឹងស៊ីជម្រៅអំពីជនរងគ្រោះ និងជនល្មើសនៃករណី OCSEA និង CSEA ដែលបានដឹង

**ទីភ្នាក់ងារអនុវត្តច្បាប់ជាតិមិនបានផ្តល់ទិន្នន័យអំពីបទល្មើស។ ទោះបីជាយ៉ាងណាក្តី ផ្នែកនេះទទួលបានព័ត៌មានពីរបកគំហើញនានាពីការអង្កេតតាមខ្នងផ្ទះ ទិន្នន័យដែលត្រូវបានចែកចាយជាមួយបណ្តាញរាយការណ៍អំពី CSAM (សូមមើលផងដែរនៅជំពូក ៣.១.៣) ការអង្កេតជាមួយបុគ្គលិកគាំទ្រសង្គមជួរមុខ ការសម្ភាសជាមួយអ្នកមានភារកិច្ចមកពីជួររដ្ឋាភិបាល កុមារ និងអ្នកថែទាំរបស់ពួកគេ។**

### ២.៤.១ ជនរងគ្រោះ

នៅក្នុងចំណោមកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំ កុមារាទំនងជារាយការណ៍អំពីការទទួលរងគ្រប់ទម្រង់នៃ OCSEA ទាំងអស់ ដែលត្រូវសាកសួរនៅក្នុងការអង្កេតតាមខ្នងផ្ទះ ច្រើនជាងកុមារី។ ទិន្នន័យពីបណ្តាញរាយការណ៍អំពី CSAM កម្ពុជា (តារាង ១៩) បានបង្ហាញថា បើទោះបីជាសេចក្តីរាយការណ៍ជាច្រើនដែលបណ្តាញរាយការណ៍ទទួលបានពាក់ព័ន្ធនឹងកុមារី (៣៨%) ក្តី ចំនួននៃសេចក្តីរាយការណ៍ដែលពាក់ព័ន្ធនឹងកុមារា (២៧%) មិនទាបជាងពេកទេ។ ស្របពេលដែលមានកំណើននៃសេចក្តីរាយការណ៍ដែលអាចកំណត់ទំហំបានពាក់ព័ន្ធនឹងកុមារី នៅរវាងឆ្នាំ២០១៧ និងឆ្នាំ២០១៨ ករណីដែលពាក់ព័ន្ធនឹងកុមារាមានការកើនឡើងគួរឱ្យកត់សម្គាល់ នៅរវាងឆ្នាំ២០១៨ និងឆ្នាំ២០១៩។

តារាង ១៩. ការបំបែកសេចក្តីរាយការណ៍ ដែលត្រូវបានដាក់ជូនបណ្តាញរាយការណ៍ទាន់ហេតុការណ៍អំពី CSAM នៅកម្ពុជា ឆ្នាំ២០១៧-២០១៩ ទៅតាមភេទរបស់កុមារ ឬកុមារនៅក្នុង CSAM ដែលត្រូវបានរាយការណ៍។

| ភេទ | ២០១៧ | ២០១៨ | ២០១៩ | សរុប |
|---|---|---|---|---|
| ស្រី | ១១៣ | ៩៩៨ | ៩៨៤ | ២.០៩៥ |
| ប្រុស | | ៧៩ | ១.៤១២ | ១.៤៩១ |
| ទាំងពីរ | | ១៣៧ | ៥៤៤ | ៦៨១ |
| មិនពាក់ព័ន្ធ | ៥៤២ | ២៩៤ | ៤១៤ | ១.២៥០ |
| មិនត្រូវបានកំណត់ | ៤៨ | | | ៤៨ |
| សរុប | ៧០៣ | ១.៥០៨ | ៣.៣៥៤ | ៥.៥៦៥ |

មូលដ្ឋាន៖ សេចក្តីរាយការណ៍អំពី CSAM ទៅកាន់បណ្តាញរាយការណ៍ទាន់ហេតុការណ៍អំពី CSAM របស់ APLE ឆ្នាំ២០១៧-២០១៩ សេចក្តីរាយការណ៍ចំនួន ៥.៥៦៥

ទិន្នន័យពីបណ្តាញរាយការណ៍បង្ហាញថា សេចក្តីរាយការណ៍ប្រមាណ ១២% ទៅកាន់បណ្តាញរាយការណ៍អំពី CSAM នៅកម្ពុជាពាក់ព័ន្ធនឹងទាំងកុមារី និងកុមារាក្នុងរយៈពេលពីឆ្នាំ២០១៧ ទៅ ២០១៩ (មានន័យថា សេចក្តីរាយការណ៍តែមួយត្រូវបានធ្វើឡើងអំពី CSAM ដែលពាក់ព័ន្ធនឹងទាំងកុមារី និងកុមារា)។

ទិន្នន័យពីបណ្តាញរាយការណ៍អំពី CSAM ក៏ផ្តល់នូវការយល់ដឹងស៊ីជម្រៅយ៉ាងមានតម្លៃអំពីការពិតដែល CSAM កំពុងមានផលប៉ះពាល់លើកុមារក្នុងគ្រប់អាយុ (តារាង ២០)។ បើទោះបីជា គប្បីកត់សម្គាល់ថាបុគ្គលនានាទំនងជាមានអារម្មណ៍រងការបង្ខំឱ្យរាយការណ៍អំពីករណី CSAM ដែលពាក់ព័ន្ធនឹងកុមារតូចៗច្រើនជាងកុមារធំៗក្តី ទិន្នន័យបង្ហាញនូវរូបភាពមួយដែលមិនមានភាពរីករាយ។ ក្នុងរយៈពេលបីឆ្នាំចាប់ពីឆ្នាំ២០១៧ ដល់២០១៩ សមាមាត្រធំបំផុតនៃសេចក្តីរាយការណ៍ពាក់ព័ន្ធនឹងកុមារដែលជិតពេញវ័យ (២៩%)។ នៅក្នុងប្រភេទអាយុនេះ សេចក្តីរាយការណ៍ទំនងជាពាក់ព័ន្ធនឹងកុមារីបំផុត (៦៨%) ជាមួយនឹងសេចក្តីរាយការណ៍ចំនួន ៣០% បន្ថែមទៀតពាក់ព័ន្ធទាំងកុមារី និងកុមារា និងសេចក្តីរាយការណ៍ចំនួន ១២% ពាក់ព័ន្ធកុមារា។ CSAM ពាក់ព័ន្ធកុមារតូច មានចំនួន ២៣% នៃសេចក្តីរាយការណ៍ទាំងអស់នៅក្នុងរយៈពេលបីឆ្នាំនេះ។ ភាគច្រើនបំផុតនៃសេចក្តីរាយការណ៍ទាំងនេះពាក់ព័ន្ធកុមារា (៨៨%) បន្ទាប់មកសម្ភារពាក់ព័ន្ធទាំងកុមារា និងកុមារី (៦%) និងពាក់ព័ន្ធតែកុមារី (៦%)។

កុមារពេញវ័យត្រូវបានកំណត់ថាជាជនរងគ្រោះនៅក្នុងសេចក្តីរាយការណ៍ចំនួន ១៩%។ ក្នុងចំណោមកុមារពេញវ័យ កុមារីមានចំនួនច្រើន ដោយមានសេចក្តីរាយការណ៍ចំនួន ៧៧%។ គ្មានសេចក្តីរាយការណ៍ពាក់ព័ន្ធកុមារាពេញវ័យឡើយ នៅក្នុងរយៈពេលបីឆ្នាំនេះដែលផ្ទុយពីទិន្នន័យពីការអង្កេតតាមខ្នងផ្ទះនៃគម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* ដែលត្រូវបានប្រមូលនៅក្នុងចំណោមកុមារពេញវ័យ (អាយុ១២-១៧ឆ្នាំ) ដោយបានរកឃើញថាកុមារាទំនងជារាយការណ៍អំពីការជួបប្រទះនឹង OCSEA ច្រើនជាងកុមារីចំនួនពីរដង។ ជាចុងក្រោយ សេចក្តីរាយការណ៍ចំនួន ២% ទៅកាន់បណ្តាញរាយការណ៍អំពី CSAM នៅរវាងឆ្នាំ២០១៧ និង ២០១៩ ពាក់ព័ន្ធទារក (កុមារាទាំងអស់)។

* ប្រភេទ 'ទាំងពីរ' ត្រូវបានគេសន្មត់ថាសំដៅទៅលើរបាយការណ៍នៃរូបភាពដែលទាំងក្មេងប្រុស និងក្មេងស្រីត្រូវបានបង្ហាញច្បាស់។.

## ២.៤ ការយល់ដឹងស៊ីជម្រៅអំពីជនរងគ្រោះ និងជនល្មើសនៃករណី OCSEA និង CSEA ដែលបានដឹង

តារាង ២០. ការបំបែកសេចក្តីរាយការណ៍ ដែលត្រូវបានដាក់ជូនដល់បណ្តាញរាយការណ៍ទាន់ហេតុការណ៍អំពី CSAM នៅកម្ពុជា ឆ្នាំ២០១៧ដល់២០១៩ ទៅតាមក្រុមអាយុរបស់ជនរងគ្រោះនៅក្នុង CSAM ដែលត្រូវបានរាយការណ៍។

| ក្រុមអាយុ | ២០១៧ | ២០១៨ | ២០១៩ | សរុប |
|---|---|---|---|---|
| ទារក | | | ១៤០ | ១៤០ |
| កុមារតូច | | ៣៨ | ១.២៦៣ | ១.៣០១ |
| កុមារមុនពេញវ័យ | ៧ | ៤០៥ | ១.២០១ | ១.៦១៣ |
| កុមារពេញវ័យ | | ៧២៨ | ៣៣៦ | ១.០៦៤ |
| មិនពាក់ព័ន្ធ | ៦៩៦ | ២៩៤ | ៤១៤ | ១.៤០៤ |
| មិនត្រូវបានចាត់ជាប្រភេទ | | ៤៣ | | ៤៣ |
| សរុប | ៧០៣ | ១.៥០៨ | ៣.៣៥៤ | ៥.៥៦៥ |

មូលដ្ឋាន៖ សេចក្តីរាយការណ៍អំពី CSAM ទៅកាន់បណ្តាញរាយការណ៍ទាន់ហេតុការណ៍អំពី CSAM របស់ APLE ឆ្នាំ២០១៧-២០១៩ សេចក្តីរាយការណ៍ចំនួន ៥.៥៦៥

ការអង្កេតតាមខ្នងផ្ទះបង្ហាញថា ខណៈដែលគ្មានការរកឃើញភាពខុសគ្នាចំពោះអាយុនៅក្នុងចំណោមកុមារបានទទួលបានសំណើដែលពួកគេមិនចង់បាន ឱ្យនិយាយពីបញ្ហាផ្លូវភេទ និងរូបភាពបែបផ្លូវភេទតាមប្រព័ន្ធអនឡាញ កុមារអាយុ ១២-១៣ឆ្នាំចំនួនច្រើនជាងកុមារអាយុ ១៦-១៧ឆ្នាំបានរាយការណ៍ពីបទពិសោធន៍នៃការគំរាមកំហែងក្នុងគោលបំណងផ្លូវភេទ ការចែកចាយរូបភាពផ្លូវភេទរបស់ពួកគេដោយគ្មានការយល់ព្រម និងការផ្តល់លុយកាក់តាមប្រព័ន្ធអនឡាញជាថ្នូរនឹងរូបភាពផ្លូវភេទ ឬការជួបគ្នាដោយផ្ទាល់ ដើម្បីធ្វើសកម្មភាពពាក់ព័ន្ធនឹងផ្លូវភេទ។

ទិន្នន័យពីការអង្កេតតាមខ្នងផ្ទះក៏បង្ហាញថា កុមារាទំនងជាត្រូវបានកំណត់ជាគោលដៅតាមរយៈកម្មវិធីចម្រុះគ្នាច្រើនជាងកុមារីផងដែរ។ ដោយប្រៀបធៀបជាមួយនឹងកុមារា ជាញឹកញាប់បំផុត កុមារីត្រូវបានកំណត់ជាគោលដៅនៅលើកម្មវិធីចំនួនតិចតួច។ កុមារីថែមទាំងរិតតែទំនងជាត្រូវបានកំណត់ជាគោលដៅនៅលើកម្មវិធីពេញនិយមតែប៉ុណ្ណោះ (ពេលខ្លះនៅលើ Facebook តែមួយប៉ុណ្ណោះ និងនៅពេលខ្លះ នៅលើកម្មវិធីល្បីៗដទៃទៀតរួមបញ្ចូលគ្នា ដូចជា Snapchat ឬ WhatsApp អាស្រ័យលើប្រភេទនៃ OCSEA)។ កុមារា (ជាពិសេស កុមារតូចៗ) ក៏ត្រូវបានអូសទាញនៅកម្មវិធីដែលមិនសូវល្បីផងដែរ ដូចជា live.me ឬPeriscope ។ ជាផ្នែក ចំណុចនេះអាចបណ្តាលមកពីប្រភេទសកម្មភាព ដែលកុមារចូលរួមនៅលើប្រព័ន្ធអ៊ីនធឺណិត ដូចជា ហ្គេមអនឡាញមានភាពពេញនិយមខ្លាំងនៅក្នុងចំណោមកុមារាច្រើនជាងកុមារី។

### ២.៤.២ ជនល្មើស

ស្រដៀងគ្នានឹងបណ្តាប្រទេស អនុវត្តគម្រោងស្តីពី*ការបញ្ឈប់គ្រោះថ្នាក់* ដទៃទៀតដែរ ភាគច្រើននៃជនល្មើសនៃ OCSEA ទំនងជាមនុស្សដែលកុមារស្គាល់ ដែលមិនមែនជាជនចម្លែកមុខ ទោះបីជាយ៉ាងណាក្តី ជនចម្លែកមុខនៅតែមានចំនួនប្រមាណម្នាក់ក្នុងចំណោមជនល្មើសបួននាក់។ ភាគច្រើននៃកុមារនៅកម្ពុជា ដែលបានរាយការណ៍អំពី ទម្រង់នានានៃ OCSEA ទំនងជាកំណត់ថា ជនល្មើស គឺជាសមាជិកគ្រួសារ បន្ទាប់មក គឺមិត្តភក្តិ (មនុស្សពេញវ័យ ឬកុមារ)។ បុគ្គលិកជួរមុខបានបង្ហាញថា ជនបរទេស ឬសមាជិកសហគមន៍ជាមនុស្សពេញវ័យ គឺជាជនល្មើសទូទៅបំផុតនៅក្នុងករណី OCSEA ដែលពួកគេបានធ្វើការងារលើ។

ដូចការពណ៌នានៅក្នុងជំពូក ២.១.៣ ការយល់ឃើញជាសាធារណៈអំពីប្រធានបទនេះ ដែលមានឥទ្ធិពលធ្វើឱ្យមនុស្សជាច្រើនគិតថា ជនល្មើសនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទកុមារគឺជាជនបរទេស (ជាពិសេស បុរសមកពីប្រទេសលោកខាងលិច)។ ករណីនានាដែលពាក់ព័ន្ធនឹងជនល្មើសផ្លូវភេទដែលជាអ្នកធ្វើដំណើរ ទំនងជាទាក់ទាញការគ្របដណ្តប់ច្រើននៅតាមប្រព័ន្ធផ្សព្វផ្សាយសំខាន់ៗ និងបង្វែរការយកចិត្តទុកដាក់ចេញពីជនល្មើសក្នុងស្រុក។ បន្ថែមលើនេះ ដោយសារភាពគ្មានជាសុកភាពជុំវិញការជជែកដោយបើកចំហរអំពីបញ្ហាផ្លូវភេទ និងបទល្មើសផ្លូវភេទ ការមានប្រតិកម្មរបស់សហគមន៍ទៅលើការរំលោភបំពានផ្លូវភេទ នៅពេលដែលជនល្មើសជាអ្នកមកពីខាងក្រៅ អាចទទួលយកបានច្រើនជាងមកពីសហគមន៍ផ្ទាល់របស់ជនរងគ្រោះ។ ខណៈពេលដែលការសិក្សាស្រាវជ្រាវបង្ហាញថា ជនបរទេសបានប្រព្រឹត្តការរំលោភបំពានកុមារ គេប៉ាន់ប្រមាណថា ពលរដ្ឋកម្ពុជាបានប្រព្រឹត្ត ៣ភាគ៤នៃករណីកេងប្រវ័ញ្ចផ្លូវភេទកុមារទាំងអស់នៅកម្ពុជា អ្នកតំណាងមកពីអង្គការម្ចាស់ជំនួយម្នាក់បានកត់សម្គាល់ថា៖ *"ក្នុងករណីខ្លះ ជនល្មើស គឺជាសាច់ញាតិរបស់ជនរងគ្រោះ ដូចជា ឪពុកចុង ឪពុកមា។ ល។"* នេះគឺគាំទ្រដល់របកឃើញនៃការអង្កេតតាមខ្នងផ្ទះ។

## ២.៤ ការយល់ដឹងស៊ីជម្រៅអំពីជនរងគ្រោះ និងជនល្មើសនៃករណី OCSEA និង CSEA ដែលបានដឹង

**ករណីសិក្សា**

**ករណីសិក្សា៖ ការបំពានអំណាច**

ព្រះសង្ឃមួយអង្គមានព្រះជន្ម ៣៨វស្សា ត្រូវបានចោទប្រកាន់អំពីការរក្សាទុកសម្ភារំលោភបំពានផ្លូវភេទកុមារ ដែលបង្ហាញនូវកុមារីពីរម្នាក់ ម្នាក់មានអាយុប្រាំមួយឆ្នាំ និងម្នាក់ទៀតមានអាយុ ១៥ឆ្នាំ ដែលរស់នៅជិតវត្ត។ កុមារទាំងពីរនាក់រស់នៅជាមួយជីដូនរបស់ពួកគេ ចំណែកឯឪពុកម្ដាយកំពុងធ្វើនៅប្រទេសថៃ ពួកគេត្រូវបានល្បួងជាមួយនឹងអាហារ និងការទទួលបានទូរស័ព្ទដៃ ដើម្បីលេងហ្គេម។ ព្រះសង្ឃអង្គនេះបានទទួលការនិមន្ត ឱ្យធ្វើពិធីសាសនាសម្រាប់សហគមន៍ ហើយគាត់បានទទួលការគោរពសរសើរ និងបច្ច័យពីសហគមន៍។ ជីដូនធ្វើការងារនៅក្នុងវត្ត ដោយជួយក្នុងការសម្អាត។ គេជឿជាក់ថា រូបភាពទាំងនោះត្រូវបានថត នៅពេលកុមារមានអាយុបួនឆ្នាំ និង១៣ឆ្នាំ នៅពេលដែលពួកគេទៅលេងនៅវត្តជាប្រចាំជាមួយជីដូនរបស់ពួកគេ។ កុមារក៏បានទៅវត្តជាញឹកញាប់ ដើម្បីយកនំអន្សម និងអាហារដទៃទៀត ដែលជាផ្ដល់ឱកាសដល់ព្រះសង្ឃអង្គនោះក្នុងការផលិតសម្ភារំលោភបំពានផ្លូវភេទកុមារ។ ភស្តុតាងដែលទទួលបានពីសម្ភារនេះ បាននាំទៅរកការកំណត់អត្តសញ្ញាណរបស់ព្រះសង្ឃអង្គនោះថា ជាអ្នកផលិតសម្ភារទាំងនោះ។ ក្នុងអំឡុងពេលនៃការស៊ើបអង្កេត និងការសួរចម្លើយជាបន្តបន្ទាប់ មន្ត្រីអនុវត្តច្បាប់ទទួលបានព័ត៌មានថា បងប្រុស/ស្រីបង្កើតត្រូវបានស្នើសុំឱ្យថតរូបប្អូនរបស់ពួកគេ។ ការរំលោភបំពានផ្លូវភេទដោយប៉ះពាល់ផ្ទាល់មិនត្រូវបានថតឡើយនៅក្នុងរូបភាពទាំងនោះ និងមិនទំនងជាបានកើតឡើងឡើយ។

កុមារទាំងពីរនាក់ត្រូវបានបញ្ជូនទៅកាន់អង្គការមិនមែនរដ្ឋាភិបាលមួយ ដើម្បីទទួលបានការផ្ដល់ការប្រឹក្សាយោបល់ និងការស្ដារនីតិសម្បទា។ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាកម្ពុជាត្រូវបានតម្រូវឱ្យស្វែងរកការអនុញ្ញាតពីអគ្គស្នងការនគរបាលជាតិកម្ពុជា និងការអនុម័តពីក្រសួងធម្មការ និងសាសនា ដើម្បីឃុំខ្លួនព្រះសង្ឃអង្គនោះ។ នៅក្នុងពេលនៃការសរសេររបាយការណ៍នេះ ការផ្ដន្ទាទោសនៅមិនទាន់ត្រូវបានធ្វើឡើងឡើយ ដោយសារតុលាការមិនអាចបើកសវនាការបាន ពីព្រោះស្ថានភាពនៃការរាតត្បាតជំងឺកូវីដ ១៩។ ជនល្មើសនៅតែស្ថិតនៅក្នុងមណ្ឌលកែប្រែ។

# ២.៥ ឧបសគ្គនានាចំពោះកុមារក្នុងការនិយាយជាមួយមនុស្សពេញវ័យអំពី OCSEA

យោងតាមទិន្នន័យពីការអង្កេតតាមខ្នងផ្ទះ កុមារនៅកម្ពុជាបានពឹងផ្អែកលើបណ្តាញអន្តរបុគ្គលរបស់ពួកគេ ដើម្បីទទួលបានជំនួយ។ ទិន្នន័យពីការអង្កេតតាមខ្នងផ្ទះបង្ហាញថា កុមារទាំងឡាយ ដែលបានរាយការណ៍អំពីការជួបប្រទះនឹង OCSEA ក្នុងទម្រង់ខុសៗ ភាគច្រើនទុកចិត្តនរណាម្នាក់នៅក្នុងបណ្តាញអន្តរបុគ្គលរបស់ពួកគេ ជាពិសេស មិត្តភក្តិ អ្នកថែទាំជាបុរស ឬបងប្អូនបង្កើត។ នៅក្នុងគ្រប់ទម្រង់នៃ OCSEA ទាំងអស់ដែលត្រូវបានស៊ើបអង្កេត កុមារចំនួនតិចតួច (0-៥%) បានធ្វើសេចក្តីរាយការណ៍ផ្លូវការទៅកាន់បុគ្គលិកសង្គម នគរបាល ឬបណ្តាញទូរស័ព្ទជំនួយ។

សមាមាត្រគួរឱ្យកត់សម្គាល់នៃកុមារ (ប្រហែលម្នាក់ក្នុងចំណោម ៥នាក់) ដែលបានជួបប្រទះនឹង OCSEA មិនបានរាយការណ៍អំពី អ្វីដែលបានកើតឡើងទៅដល់នរណាម្នាក់ឡើយ។ កុមារមិនសូវជាទំនងបង្ហាញទៅដល់អ្នកណាម្នាក់អំពី ករណីនៃការផ្តល់លុយកាក់ ឬអំណោយផ្សេងៗជាថ្នូរនឹងរូបភាពនានា ឬដើម្បីចូលរួមនៅក្នុងសកម្មភាពផ្លូវភេទ ករណីបៀតបៀនផ្លូវភេទ និងករណីទទួលបានរូបភាពផ្លូវភេទដែលពួកគេមិនចង់បានឡើយ។ ក្នុងចំណោមកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ដែលបានជួបប្រទះ OCSEA កុមារាទំនងជាបង្ហាញអំពីអ្វីដែលបានកើតឡើងចំពោះពួកគេច្រើនជាងកុមារី។ ឧទាហរណ៍ ៦0% នៃកុមារីមិននិយាយប្រាប់នរណាម្នាក់អំពី ការផ្តល់លុយកាក់ ឬអំណោយសម្រាប់សកម្មភាពផ្លូវភេទឡើយ ធៀបកុមារាចំនួនតែ១៦%ប៉ុណ្ណោះ ដែលបានទទួលការផ្តល់លុយកាក់។ ដូចការកត់សម្គាល់ខាងដើម និយាមយេនឌ័រយ៉ាងតឹងរឹង ពិតជាអាចបង្កើនអារម្មណ៍អាម៉ាស និងភាពខ្មាសអៀនចំពោះកុមារីដែលបានជួបប្រទះនឹង OCSEA។

### ២.៥.១ មូលហេតុសម្រាប់ការមិននិយាយប្រាប់

ទិន្នន័យពីការអង្កេតតាមខ្នងផ្ទះ ការសម្ភាសជាមួយកុមារដែលបានឆ្លងកាត់ប្រព័ន្ធយុត្តិធម៌ ការអង្កេតជាមួយបុគ្គលិកជួរមុខ និងការសម្ភាសជាមួយអ្នកមានភារកិច្ចមកពីជួររដ្ឋាភិបាល សុទ្ធតែរួមចំណែកចំពោះការយល់ដឹងកាន់តែគ្រប់ជ្រុងជ្រោយអំពី មូលហេតុដែលកុមារនៅកម្ពុជាអាចមិនបង្ហាញអំពីបទពិសោធន៍នៃ OCSEA របស់ពួកគេ។ នៅក្នុងផ្នែកនេះ ឧបសគ្គគន្លឹះៗ ដែលលេចចេញពីការស្រាវជ្រាវនៃគម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* នៅកម្ពុជា ត្រូវបានសិក្សា។

#### កង្វះចំណេះដឹងអំពីយន្តការរាយការណ៍

កុមារចំនួនតិចតួចខ្លាំង (0%-៦%) ដែលបានជួបប្រទះនឹង OCSEA បានរាយការណ៍អំពីបញ្ហានេះតាមរយៈយន្តការរាយការណ៍ផ្លូវការ។ ការមិនដឹងអំពីកន្លែងត្រូវទៅរាយការណ៍ ឬនរណាដែលត្រូវនិយាយប្រាប់ ត្រូវបានលើកយ៉ាងច្រើនបំផុតថា ជាឧបសគ្គចំពោះការរាយការណ៍អំពីហេតុការណ៍ OCSEA ដែលកុមារបានកំណត់នៅក្នុងការអង្កេតតាមខ្នងផ្ទះ។ របកគំហើញនេះក៏ត្រូវបានកត់សម្គាល់ពីបុគ្គលិកជួរមុខផងដែរ ពួកគេចំនួន ៤0នាក់ បានបង្ហាញថា មនុស្សមិនដឹងអំពីយន្តការរាយការណ៍ឡើយ (រូបភាព ២១)។ ឪពុក ឬម្តាយម្នាក់បានកត់សម្គាល់ថា៖ [...] *ខ្ញុំពិតជាចង់ផ្សព្វផ្សាយព័ត៌មានអំពីបញ្ហានេះ ដើម្បីមានការបើកចំហរខ្លាំងជាងពីមុន ដោយសារកុមាររងាយរងគ្រោះមិនដឹងអំពីវា ហេតុនេះពួកគេមិនដឹងអំពី អ្នកដែលអាចជួយពួកគេបានឡើយ។ ការផ្សព្វផ្សាយអំពី បញ្ហានេះ ដើម្បីឱ្យមានការបើកចំហរ ហើយពួកគេអាចមានភាពក្លាហានក្នុងការគេចចេញពីរឿងរ៉ាវនានា ដែលកំពុងកើតឡើងដែលពួកគេកំពុងជួបប្រទះ។* (RA៤-CA-0៩-Parent)។ កុមារក៏អាចគ្មានទំនុកចិត្តចំពោះដំណើរការរាយការណ៍ ឬប្រព័ន្ធយុត្តិធម៌ផងដែរ។ បន្ថែមលើនេះ បុគ្គលិកជួរមុខចំនួន ៤៣នាក់ក្នុងចំណោម ៥0នាក់បាននិយាយថា ចំណេះដឹងទាបអំពីហានិភ័យនៃOCSEAនៅក្នុងចំណោមអ្នកថែទាំអាចបង្កជាឧបសគ្គចំពោះការរាយការណ៍។អ្នកឯកទេសផ្នែកទទួលករណី ដែលត្រូវបានសម្ភាស បានកត់សម្គាល់ថា *"នៅកម្ពុជាយើងមានកម្រិតនៃការអប់រំទាបនៅក្នុងសង្គម។ ហេតុនេះ មនុស្សមិនយល់ច្បាស់អំពីដំណើរការផ្លូវច្បាប់ ដែលពាក់ព័ន្ធឡើយ រួមទាំងដំណើរការបណ្តឹង។"* (RA៤-CA-0៨-A)។ ចំណុចនេះបង្ហាញនូវសេចក្តីត្រូវការការលើកកម្ពស់ការយល់ដឹងនៅក្នុងចំណោមប្រជាពលរដ្ឋទូទៅដែលជាវិធានការមួយដើម្បីពង្រឹងការរាយការណ៍ ហើយជាលទ្ធផល ការទទួលបានភាពយុត្តិធម៌ និងការគាំទ្រសម្រាប់ជនរងគ្រោះនៃ OCSEA ។

#### មូលដ្ឋាន៖ បុគ្គលិកសុខុមាលភាពជួរមុខ ចំនួន ៥0នាក់

**ភាពអាម៉ាស ភាពមាក់ងាយ និងការបន្ទោសជនរងគ្រោះ**

ការពិតដែលកុមារជាច្រើនដែលទទួលរង OCSEA មិនប្រាប់នរណាម្នាក់ ជាពិសេស មនុស្សពេញវ័យ អាចបង្កឡើងជាផ្នែកដោយសារការមាក់ងាយជុំវិញបទពិសោធន៍ផ្លូវភេទ។ ការអង្កេតតាមខ្នងផ្ទះបានបង្ហាញថា មូលហេតុទូទៅទីពីរ សម្រាប់ការមិនបង្ហាញអំពី ការជួបប្រទះនឹង OCSEA គឺអារម្មណ៍អាម៉ាស ការខ្មាសអៀន ឬការភ័យខ្លាច ដែលធ្វើឱ្យពិបាកខ្លាំងក្នុងការនិយាយចេញមក។ បុគ្គលិកជួរមុខចំនួន ៣៥នាក់ក្នុងចំណោម ៥0នាក់ ដែលបានចូលរួមនៅក្នុងការអង្កេត បានជឿជាក់ថា ភាពមាក់ងាយពីសហគមន៍ គឺជាកត្តាគន្លឹះ ដែលមានឥទ្ធិពលលើការរាយការណ៍អំពី OCSEA នៅកម្ពុជា (សូមមើលរូបភាព ២១)។ កង្វល់ពាក់ព័ន្ធនឹងនិយាមបទដ្ឋាន និងភាពមាក់ងាយជុំវិញបញ្ហាផ្លូវភេទ និងអាកប្បកិរិយាផ្លូវភេទ អាចដើរតួនាទីសំខាន់នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តចំពោះការរាយការណ៍អំពីការរំលោភបំពាន។ បុគ្គលិកជួរមុខម្នាក់បានកត់សម្គាល់ថា៖ *ការមិននិយាយអំពីបញ្ហាផ្លូវភេទដូចជាវប្បធម៌មួយដែរ។ ភាគរយនៃករណីរំលោភបំពានផ្លូវភេទដែលមិនត្រូវបានរាយការណ៍ មានកម្រិតខ្ពស់ ដោយសារពេលខ្លះ កុមារភ័យខ្លាច ឬខ្មាសអៀនក្នុងការនិយាយអំពី បញ្ហានេះហើយនៅពេលករណីនេះបានកើតឡើង ពួកគេត្រូវបានគេបិទមិនឱ្យនិយាយ ដោយសារវប្បធម៌នេះ។* (RA៣-CA-១៤-A)

## ២.៥ ឧបសគ្គនានាចំពោះកុមារក្នុងការនិយាយជាមួយមនុស្សពេញវ័យអំពី OCSEA

រូបភាព ២១. ឧបសគ្គផ្នែកសង្គម និងវប្បធម៌ចំពោះការរាយការណ៍អំពី OCSEA




មូលដ្ឋាន៖ បុគ្គលិកសុខុមាលភាពជួរមុខ ចំនួន ៥០នាក់

ឧត្តរជីវិនីយក្មេងម្នាក់បានកត់សម្គាល់នូវអារម្មណ៍អាម៉ាសអំពីរូបភាពនានាដែលត្រូវបានចែកចាយ និងភាពអាម៉ាសមុខចំពោះការដឹងថាអ្នកដទៃទៀតនៅក្នុងសហគមន៍របស់ពួកគេនឹងមើលឃើញរូបភាពផ្លូវភេទរបស់ពួកគេ៖ *"អ្នកនៅផ្ទះបានស្តីបន្ទោសឱ្យខ្ញុំរួចហើយ។ នៅពេលមានរឿងរ៉ាវបែបនោះរួចហើយ អ្នកត្រូវឈរនៅចំពោះមុខសហគមន៍ សូម្បីតែឈរនៅចំពោះមនុស្ស ដែលបានទទួលរូបថតរបស់អ្នក។ តើអ្នកត្រូវដោះស្រាយបញ្ហានេះយ៉ាងដូចម្តេចជាមួយពួកគេ?"* (RA៥-CA-0៧) អ្នកតំណាងម្នាក់មកពីក្រសួងកិច្ចការនារីបានពន្យល់អំពី របៀបដែលឪពុកម្តាយនៅពេលខ្លះស្តីបន្ទោសកូនរបស់ពួកគេ ប្រសិនបើ ពួកគេសារភាពថា ពួកគេកំពុងប្រឈមមុខនឹងការលំបាកនានា៖ *កុមារមួយចំនួនទទួលរងការស្តីបន្ទោសពីឪពុកម្តាយរបស់ពួកគេ នៅពេលពួកគេនិយាយប្រាប់អំពីបញ្ហាអ្វីមួយ ហេតុនេះ ប្រសិនបើ ពួកគេប្រឈមមុខនឹងបញ្ហាជាច្រើនបន្ថែមទៀត ពួកគេនឹងគ្រាន់តែមិននិយាយវាប្រាប់នរណាផ្សេងទៀតប៉ុណ្ណោះ។ ហេតុនេះ មេរៀននេះមានសារសំខាន់ណាស់ និងជួយកុមារក្នុងការស្វែងយល់អំពី ប្រភេទមនុស្ស ដែលពួកគេនឹងនិយាយប្រាប់ និងប្រភេទមនុស្សដែលពួកគេមិននិយាយប្រាប់។* (RA១-CA-0៥-A)

ការស្រាវជ្រាវបែបជាតិពន្ធុសាស្ត្រ ដែលត្រូវបានធ្វើឡើងនៅកម្ពុជា បានបង្ហាញថា ពលរដ្ឋកម្ពុជាមួយចំនួនជឿជាក់លើការពន្យល់មួយអំពីមូលហេតុដែលកុមារម្នាក់បានរងការរំលោភបំពាន គឺថា ជនល្មើស ឬកុមារមាន "សំណាងមិនល្អ" នៅក្នុងជាតិនេះ ឬជាតិមុន។ "សំណាងមិនល្អ" នេះត្រូវបានជឿជាក់ថា ត្រូវបានបង្កឡើងដោយអំពើមិនល្អរបស់ឪពុក ឬម្តាយ ឬដូនតា។ ការស្រាវជ្រាវជាក់លាក់នេះក៏បានកត់សម្គាល់ថា អ្នកថែទាំជាស្ត្រី ដែលកូនស្រីរបស់ពួកគេបានទទួលរងការរំលោភសេពសន្ថវៈពីសំណាក់ឪពុករបស់ពួកគេ បានបន្ទោសទៅលើ "ការកសាងមិនល្អ" របស់ពួកគេផ្ទាល់។ ចំណុចនេះបង្ហាញនូវការពិចារណានៅក្នុងបរិបទនៃការរាយការណ៍អំពី OCSEA ។ ការយល់ឃើញអំពី "ការកសាងមិនល្អ" ឬ "សំណាងមិនល្អ" និងទំនាក់ទំនងជាមួយអំពើមិនល្អរបស់សមាជិកគ្រួសារ ឬដូនតា អាចបង្កភាពអាម៉ាស និងភាពមាក់ងាយច្រើនគ្រប់គ្រាន់ ក្នុងការរារាំងកុមារពីការរាយការណ៍ ឬមានឥទ្ធិពលលើអ្នកថែទាំ និងមនុស្សជាទីទុកចិត្តដទៃទៀតពីការលើកទឹកចិត្តកុមារឱ្យរាយការណ៍។

## ២.៥ ឧបសគ្គនានាចំពោះកុមារក្នុងការនិយាយជាមួយមនុស្សពេញវ័យអំពី OCSEA

### និយាមសង្គមបែបហាមឃាត់ជុំវិញបញ្ហាផ្លូវភេទ និងសិទ្ធិកុមារ

បុគ្គលិកសេវាសង្គមជួរមុខចំនួនប្រាំបីភាគរយដែលបានចូលរួមនៅក្នុងការអង្កេតនេះ បានកំណត់ថា ប្រធានបទដែលគេមិនចង់និយាយជុំវិញការពិភាក្សាអំពីបញ្ហាផ្លូវភេទ និងអាកប្បកិរិយាផ្លូវភេទ និងអំពើហិង្សាផ្លូវកាយលើកុមារកម្រិតខ្ពស់ គឺជាកត្តាសង្គម ដែលមានឥទ្ធិពលធំបំផុតលើភាពងាយរងគ្រោះរបស់កុមារចំពោះ OCSEA ។ បុគ្គលិកជួរមុខម្នាក់បានកត់សម្គាល់ថា *"កត្តាសង្គមហាមឃាត់ការនិយាយអំពីបញ្ហាផ្លូវភេទជាមួយកុមារ និងយុវជន។ ការហាមឃាត់បែបនោះធ្វើឱ្យកុមារមិនដឹងអំពីផលប៉ះពាល់ និងហានិភ័យនៃការរំលោភបំពានផ្លូវភេទ"*។ (RA៣-CA-៤៧-A) ឋានៈទាបរបស់កុមារនៅក្នុងសង្គម និងភាពមាក់ងាយពីសហគមន៍ រួមជាមួយនឹងតួនាទីដែលត្រូវបានរំពឹងទុកចំពោះបុរស និងស្ត្រី ក៏ត្រូវបានលើកឡើងជាកត្តា ដែលធ្វើឱ្យកុមារកម្ពុជាងាយរងគ្រោះចំពោះ OCSEA ផងដែរ។

ការស្រាវជ្រាវពីមុនអំពី សិទ្ធិរបស់កុមារនៅកម្ពុជាបានរកឃើញថា ទោះបីជាកុមារទំនងជាមានការយល់ដឹងជាមូលដ្ឋានអំពី សិទ្ធិរបស់ពួកគេក្តី ការផ្តោតខ្លាំងរបស់វប្បធម៌ទៅលើការការពារកិត្តិយសគ្រួសារ ព្រមទាំងការរំពឹងទុកថា កុមារគោរពរចនាសម្ព័ន្ធឋានានុក្រម និងបិតាធិបតេយ្យនៅក្នុងគ្រួសារ អាចមានភាពលើសលុបជាង ហេតុនេះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់កុមារក្នុងការការពារពីការរំលោភបំពានផ្លូវភេទ។ នៅក្នុងចំណោមកុមារា ដែលបានទទួលការផ្តល់អំណោយ ឬលុយកាក់ជាថ្នូរនឹងរូបភាព/វីដេអូផ្លូវភេទ និងមិនបានប្រាប់នរណាម្នាក់ ពួកគេចំនួន ២២% ភ័យខ្លាចថា ការបង្ហាញអំពីបញ្ហានេះនឹងបង្កជាបញ្ហាចំពោះគ្រួសាររបស់ពួកគេ ចំណែកឯពួកគេចំនួន ១១% ត្រូវបានសមាជិកគ្រួសាររារាំងយ៉ាងសកម្មពីការរាយការណ៍នេះ។ សម្ពាធទាំងនេះរួមជាមួយនឹងភាពគ្មានផាសុកភាពជាបន្តបន្ទាប់ក្នុងការពិភាក្សាអំពីបញ្ហាផ្លូវភេទ និងអាកប្បកិរិយាផ្លូវភេទ។

### ជនល្មើសជាសមាជិកគ្រួសារ

ដូចការបង្ហាញដោយការអង្កេតតាមខ្នងផ្ទះ ក្នុងគ្រប់ប្រភេទនៃ OCSEA ទាំងអស់ដែលត្រូវបានស៊ើបអង្កេត កុមារទំនងជាកំណត់ថាសមាជិកគ្រួសារម្នាក់ គឺជាជនល្មើស ច្រើនជាងប្រភេទដទៃទៀត។ ចំណុចនេះមានភាពពាក់ព័ន្ធយ៉ាងសំខាន់ចំពោះបំណងប្រាថ្នារបស់កុមារក្នុងការបង្ហាញអំពីការជួបប្រទះនឹង OCSEA របស់ពួកគេ និងក្នុងការធ្វើសេចក្តីរាយការណ៍ជាផ្លូវការ។ អំណះអំណាងស្រដៀងគ្នានេះត្រូវបានធ្វើឡើងដោយបុគ្គលិកជួរមុខ នៅពេលឆ្លុះបញ្ចាំងលើករណី OCSEA ដែលពួកគេបានចូលរួម។

# ៣. ការឆ្លើយតបចំពោះការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា

កម្ពុជា។ ភស្តុតាងនេះរួមមានជម្រើសនៃការរាយការណ៍ជាផ្លូវការ និងឆ្លើយតបពីសំណាក់នគរបាល និងប្រព័ន្ធតុលាការ។ ជំពូកនេះពិចារណាលើការរួមចំណែករបស់រដ្ឋាភិបាល សង្គមស៊ីវិល និងឧស្សាហកម្មអ៊ីនធឺណិត  និងបច្ចេកវិទ្យា ក្នុងការប្រយុទ្ធប្រឆាំងនឹង OCSEA នៅកម្ពុជា។ ជំពូកនេះក៏ប្រើប្រាស់សក្ខីកម្មរបស់កុមារបីនាក់ ដែលបានស្វែងរកភាពយុត្តិធម៌ តាមរយៈប្រព័ន្ធយុត្តិធម៌ ( ត្រូវបានយោងថា RA៤-CA-XX-child ) និងអ្នកថែទាំរបស់ពួកគេ។ ទិន្នន័យជាច្រើននៅក្នុងជំពូកនេះបានមកពីការសម្ភាសបែបគុណភាព ហើយការឆ្លើយតបអាចមិនឆ្លុះបញ្ចាំងការក្រមទ ពេញលេញនៃបទពិសោធន៍របស់កុមារទាំងឡាយដែលប្រើប្រាស់យន្តការឆ្លើយតបចំពោះ OCSEA នៅកម្ពុជាឡើយ។

## ៣.១ យន្តការរាយការណ៍ផ្លូវការ

**ដូចការចងក្រងជាឯកសារនៅក្នុងជំពូកមុខ កុមារចំនួនតិចតួចរាយការណ៍ករណី OCSEA តាមរយៈយន្តការរាយការណ៍ផ្លូវការ ដូចជានគរបាល ឬបណ្ដាញទូរស័ព្ទបន្ទាន់នានា។ ស្រដៀងគ្នានេះដែរ អ្នកថែទាំជាច្រើនបានបង្ហាញថា ពួកគេស្ទាក់ស្ទើរក្នុងការរាយការណ៍អំពី OCSEA ទៅដល់នគរបាល។ នៅក្នុងការអង្កេតតាមខ្នងផ្ទះជាមួយអ្នកថែទាំចំនួន ៩៩២នាក់ ដោយនិយាយក្នុងលក្ខណៈសម្មតិកម្ម ពួកគេចំនួន ៦៧% បាននិយាយថា ពួកគេនឹងរាយការណ៍ទៅកាន់នគរបាល ប្រសិនបើ កូនរបស់ពួកគេបានជួបប្រទះនឹងការរំលោភបំពាន ទោះបីជាយ៉ាងណា អ្នកថែទាំដទៃទៀតជាច្រើនបាននិយាយថា ពួកគេនឹងមិនរាយការណ៍ឡើយ ដោយសារកង្វល់អំពីផលវិបាកអវិជ្ជមាន ការភ័យខ្លាចចំពោះការសងសឹក ឬដោយសារពួកគេនឹងមានភាពអាម៉ាស។ នៅក្នុងការអង្កេតជាមួយបុគ្គលិកជួរមុខ អ្នកឆ្លើយតបចំនួន ៧២% បានបង្ហាញឱ្យឃើញថា ករណី OCSEA មិនត្រូវបានរាយការណ៍ ដោយសារគុណភាពនៃយន្តការរាយការណ៍ត្រូវបានគេយល់ថា នៅខ្សោយ ហើយពួកគេចំនួន ៦៨% បាននិយាយថា សេវានានាមិនទទួលបានការទុកចិត្តឡើយ។**

ការសម្ភាសជាមួយអ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ក៏បានបង្ហាញថា តួអង្គអង្គការមិនមែនរដ្ឋាភិបាលគឺជាតួអង្គជាទីទុកចិត្តបំផុត ដោយសារពួកគេមានការឆ្លើយតប មានសមត្ថភាពជាង និងមានការបំពាក់បំប៉នល្អជាងពាក់ព័ន្ធនឹងធនធាន និងឯកទេស។ កុមាររងគ្រោះ និងគ្រួសាររបស់ពួកគេរាយការណ៍អំពី ភាពស្ទាក់ស្ទើរក្នុងការស្វែងរកសេវានានាដោយផ្ទាល់ពីអាជ្ញាធរ ដោយគ្មានការគាំទ្រ។ អ្នកជំនាញផ្នែកកិច្ចការពារកុមារមកពី APLE (RA៤-J-CA-០១-A) បានកត់សម្គាល់ថា កុមារអាចមានអារម្មណ៍ភ័យខ្លាច នៅពេលជួបទំនាក់ទំនងជាមួយនគរបាល។ អ្នកថែទាំមួយចំនួនក៏បានលើកឡើងអំពីកង្វល់នានាអំពី អំពើពុករលួយនៅក្នុងចំណោមអាជ្ញាធរ ដែលទទួលខុសត្រូវចំពោះការទទួលការរាយការណ៍ និងស៊ើបអង្កេតករណីផងដែរ ដោយពួកគេនិយាយអំពី កង្វះទំនុកចិត្តចំពោះអាជ្ញាធរ ហេតុនេះពួកគេស្ទាក់ស្ទើរក្នុងការគាំទ្រកូនៗរបស់ពួកគេ ដើម្បីធ្វើសេចក្ដីរាយការណ៍ជាផ្លូវការ។

ទោះបីជាយ៉ាងណាក្ដី ច្បាប់ជាតិបច្ចុប្បន្នមិនបង្កើតប្រព័ន្ធមួយ សម្រាប់ការទទួល និងការឆ្លើយតបនឹងសេចក្ដីរាយការណ៍ឡើយ រួមទាំងយន្តការកិច្ចការពារ សម្រាប់អ្នកទាំងឡាយ ដែលរាយការណ៍បទល្មើសពាក់ព័ន្ធនឹង OCSEA ។ ក្រមនីតិវិធីព្រហ្មទណ្ឌមានមាត្រាចំនួនបីស្ដីពី ការផ្ដួចផ្ដើមវិធានការ និងបណ្ដឹងព្រហ្មទណ្ឌ តាមរយៈការផ្ដន្ទាទោស និងជនរងគ្រោះ ប៉ុន្តែក្រមនេះមិនមានបទប្បញ្ញត្តិណាមួយអំពី ការបង្ហាញថាបណ្ដឹងអនាមិកជាភស្តុតាងគ្រប់គ្រាន់ ដើម្បីបើកការស៊ើបអង្កេតឡើយ។ ចំណុចនេះមានន័យថា គ្មានចំណាត់ការផ្លូវការអាចធ្វើឡើងបានឡើយ លុះត្រាតែបុគ្គលដែលធ្វើការរាយការណ៍អំពីករណី OCSEA នឹងបង្ហាញអំពីអត្តសញ្ញាណរបស់ពួកគេ។

### ៣.១.១ នគរបាល

អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជាមានលេខទូរស័ព្ទទាន់ហេតុការណ៍ចំនួនពីរខ្សែ ដើម្បីទទួលការហៅទូរស័ព្ទចូលអំពីគ្រប់ទម្រង់នៃការរំលោភបំពាន ដែលដំណើរការ ២៤ម៉ោងក្នុងមួយថ្ងៃ។ គ្មានទិន្នន័យត្រូវបានផ្ដល់ដោយទីភ្នាក់ងារអនុវត្តច្បាប់អំពី ចំនួននៃការហៅទូរស័ព្ទចូល

ពាក់ព័ន្ធនឹង OCSEA ឡើយ។ ការសម្ភាសជាមួយនឹងអ្នកតំណាងនៃទីភ្នាក់ងារអនុវត្តច្បាប់បានបង្ហាញថា ពាក់ព័ន្ធនឹង OCSEA វិធីទូទៅបំផុត ដែលនគរបាលដឹងអំពីករណីកុមារ គឺនៅពេលឪពុកម្ដាយ អង្គការមិនមែនរដ្ឋាភិបាល ឬគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ ដាក់សេចក្ដីរាយការណ៍ដោយផ្ទាល់មកនគរបាល។

ការសម្ភាសជាមួយអ្នកមានភារកិច្ចមកពីជួររដ្ឋាភិបាលបានបញ្ជាក់អះអាងទៅលើទិន្នន័យពីការអង្កេតតាមខ្នងផ្ទះ ដែលបង្ហាញឱ្យឃើញថាជាទូទៅ កុមាររងគ្រោះមិនរាយការណ៍អំពីករណីរបស់ពួកគេដោយផ្ទាល់ទៅដល់នគរបាលឡើយ ដោយអ្នកឯកទេសកិច្ចការពារកុមារមកពី APLE បានកត់សម្គាល់ថា *កុមាររងគ្រោះមួយចំនួនតូចទៅរកនគរបាលដោយផ្ទាល់ ហើយពួកគេភាគច្រើន [អ្នកដែលរាយការណ៍] ទៅតាមរយៈបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ឬនរណាម្នាក់ដែលពួកគេទុកចិត្ត។ បន្ទាប់មក បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលនឹងជួយពួកគេក្នុងការទៅជួបរាយការណ៍ជូននគរបាល។"* (RA៤-CA-០១-A)

ចំណុចនេះត្រូវបានបន្ថែមដោយព្រះរាជអាជ្ញារងមកពីតុលាការរាជធានីដែលបានថ្លែងថា៖ *"ក្នុងករណីរំលោភបំពានផ្លូវភេទកុមារភាគច្រើន ជនរងគ្រោះមានអង្គការមិនមែនរដ្ឋាភិបាល ជួយសម្របសម្រួលដំណើរការដាក់បណ្ដឹងជាមួយនឹងនគរបាល។"* (RA៤-CA-១០-A)

តាមរយៈការសម្ភាសជាមួយអ្នកតំណាងរដ្ឋាភិបាល មានការយល់ថា នៅពេលខ្លះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បញ្ជូនករណីទៅកាន់នគរបាល បន្ទាប់ពីទទួលបានសេចក្ដីរាយការណ៍ពាក់ព័ន្ធនឹង

* ក្រុមប្រឹក្សាឃុំ/សង្កាត់ដើម្បីស្ត្រីនិងកុមារ គឺជាស្ថាប័នផ្ដល់ប្រឹក្សាដល់ក្រុមប្រឹក្សាឃុំ/សង្កាត់នៅថ្នាក់មូលដ្ឋាន ដែលមានតួនាទីតាមដានបញ្ហាទាក់ទងនឹងកុមារ និងស្ត្រី។ ពួកគេអាចដាក់របាយការណ៍ទៅនគរបាលទាក់ទងនឹងការរំលោភបំពានកុមារនៅក្នុងសហគមន៍ ហើយក៏អាចដើរតួជាយន្តការបញ្ជូនទៅកាន់សេវាការពារកុមារផងដែរ។ ពួកគេផ្ដល់ការគាំទ្រដល់កុមារក្នុងអំឡុងពេលដំណើរការយុត្តិធម៌។

CSAM។ ប្រធាននាយកដ្ឋានសន្តិសុខព័ត៌មាន បានចែកចាយការយល់ដឹងស៊ីជម្រៅដូចតទៅ៖ *ដំបូងយើង [ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍] នឹងតាមដានថា តើគេហទំព័រណា ដែលបង្ហោះសម្ភារនោះ។ នាយកដ្ឋានរបស់ខ្ញុំនឹងត្រូវផ្ទៀងផ្ទាត់ថា តើគេហ៍ទំព័រនោះត្រូវបានបង្ហោះនៅទីណា នៅក្នុងប្រទេសយើង ឬប្រទេសមួយទៀត។ ប្រសិនបើនៅក្នុងប្រទេសយើង វានឹងងាយស្រួល។ ខ្ញុំគ្រាន់តែទំនាក់ទំនងទៅនគរបាល ហើយពួកគេនឹងចាត់វិធានការ និងដកវាចេញ* (RA១-CA-០៤-A)

បើទោះបីជាមិនដឹងអំពីចំនួនករណី OCSEA ត្រូវបានរាយការណ៍ទៅដល់នគរបាលនៅកម្ពុជាក្តី ទិន្នន័យដែលលេចឡើងពីបណ្តាញរាយការណ៍ទាន់ហេតុការណ៍អំពី CSAM (រូបភាព ២២) បង្ហាញឱ្យឃើញថា ក្នុងចំណោមសេចក្តីរាយការណ៍ចំនួន ៤៧០ ដែលត្រូវបានបញ្ជូនទៅកាន់នគរបាល សេចក្តីរាយការណ៍ចំនួន ៧៨% បានបង្កឱ្យមានការបើកការស៊ើបអង្កេត ៩% បានបង្កឱ្យមានដកមាតិកាចេញ ៩% បានបង្កឱ្យមានការបិទគេហ៍ទំព័រ និង ៥% គ្មានចំណាត់ការ។ បើទោះបីជាមិនដឹងថា តើការបើកការស៊ើបអង្កេតបាននាំទៅរកចំណាត់ការបន្ថែមឬអត់ក្តី ទិន្នន័យបង្ហាញឱ្យឃើញថា ក្នុងកម្រិតមួយចំនួន នគរបាលចាត់ការ ក្រោយទទួលបានសេចក្តីរាយការណ៍។

គប្បីកត់សម្គាល់ថា សម្រាប់កុមារបួននាក់ ដែលយើងបាននិយាយជាមួយ ពួកគេខ្លួនឯងមិនបានធ្វើសេចក្តីរាយការណ៍ឡើយ ប៉ុន្តែពួកគេត្រូវបានកំណត់ឃើញពីការស៊ើបអង្កេតលើជនល្មើស។ សម្រាប់កុមារទាំងបួននាក់នេះ ការចូលរួមរបស់នគរបាលមិនត្រូវបានរំពឹងទុកជាមុនឡើយ ហើយពួកគេបានរាយការណ៍អំពី ការមានអារម្មណ៍ច្របូកច្របល់ និងភ័យខ្លាចថា ពួកគេនឹងមានបញ្ហា។

> កិច្ចសម្ភាសន៍ជាមួយមន្ត្រីអនុវត្តច្បាប់បានបង្ហាញថា ករណី OCSEA ត្រូវបានរាយការណ៍ជាទូទៅបំផុតតាមរយៈអ្នកថែទាំកុមារ អង្គការមិនមែនរដ្ឋាភិបាល និងក្រុមប្រឹក្សាឃុំ/សង្កាត់ដើម្បីស្ត្រី និងកុមារ។

### បណ្តាញទូរស័ព្ទទាន់ហេតុការណ៍ និងបណ្តាញទូរស័ព្ទជំនួយកុមារ - តើអ្វីជាភាពខុសគ្នា?

មានបណ្តាញរាយការណ៍ជាច្រើនដែលកុមារ និងមនុស្សពេញវ័យអាចរាយការណ៍ករណីនៃ OCSEA ។ ទាំងនេះរួមមាន CSAM ខ្សែទូរស័ព្ទបន្ទាន់ និងខ្សែទូរស័ព្ទជំនួយកុមារ។ បណ្តាញរាយការណ៍អំពី CSAM ផ្តោតលើការធ្វើការជាមួយផ្នែកឧស្សាហកម្ម និងភ្នាក់ងារអនុវត្តច្បាប់ ដើម្បីលុបមាតិកា ហើយពួកគេច្រើនតែប្រើទម្រង់ជាគេហទំព័រជាជាងលេខទូរស័ព្ទសម្រាប់ការរាយការណ៍។ បណ្តាញទូរស័ព្ទជំនួយកុមារមានទំនោរឆ្លើយតបទៅនឹងកង្វល់ដ៏ទូលំទូលាយនៃការការពារកុមារ ទោះបីជា មួយចំនួនអាចផ្តោតជាពិសេសលើការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងការរំលោភបំពានតាមអ៊ីនធឺណិតក៏ដោយ។ បណ្តាញទូរស័ព្ទជំនួយមួយចំនួនផ្តល់ការគាំទ្រវិបត្តិភ្លាមៗ ការបញ្ជូនបន្ត និង/ឬការផ្តល់ប្រឹក្សាយោបល់ និងសេវាគ្រប់គ្រងករណី។

### ៣.១.២ បណ្តាញទូរស័ព្ទជំនួយជាតិ - បណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា

ចាប់តាំងពីឆ្នាំ ២០០៩ មក បណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជាបានផ្តល់សេវាផ្តល់ប្រឹក្សាយោបល់វិជ្ជាជីវៈ និងព័ត៌មានតាមបណ្តាញទូរស័ព្ទដល់កុមារ។ បណ្តាញទូរស័ព្ទនេះបានចុះបញ្ជីក្រោមក្រសួងមហាផ្ទៃ និងប្រតិបត្តិការរយៈពេល ២៤ម៉ោង ជាមួយនឹងខ្សែទូរស័ព្ទឥតគិតថ្លៃ។ ភាគច្រើននៃការហៅទូរស័ព្ទចូលពាក់ព័ន្ធនឹងបញ្ហាអប់រំ បញ្ហាទំនាក់ទំនង បញ្ហាគ្រួសារ និងសុខភាពចិត្តសង្គម។ មានករណីចំនួនមួយប៉ុណ្ណោះ ដែលត្រូវបានកត់ត្រាថាពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និងមួយករណីពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញតាមប្រព័ន្ធបច្ចេកវិទ្យានៅឆ្នាំ២០១៨។ បណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជាបានរាយការណ៍ជូនបណ្តាញទូរស័ព្ទជំនួយកុមារអន្តរជាតិថា ពួកគេទទួលបានការទំនាក់ទំនងចំនួនពីរពាក់ព័ន្ធនឹង OCSEA ករណីទាំងពីរនេះពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញលើកុមារា។

### ៣.១.៣ បណ្តាញរាយការណ៍អំពី CSAM – បណ្តាញរាយការណ៍តាមអ៊ីនធឺណិតកម្ពុជា

បណ្តាញរាយការណ៍តាមប្រព័ន្ធអ៊ីនធឺណិតកម្ពុជា ដែលដំណើរការដោយអង្គការសកម្មភាពដើម្បីកុមារ (APLE) ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៥ ដើម្បីទទួលការរាយការណ៍ពីសាធារណជន វិភាគនិងស្នើសុំដកហូតមាតិកាខុសច្បាប់ចេញ និងផ្តល់ជំនួយដល់ការស៊ើបអង្កេតលើការរាយការណ៍នានាពីសាធារណជន ទីភ្នាក់ងារអនុវត្តច្បាប់ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនឹងសកម្មភាព និងសម្ភាររំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ។ បណ្តាញរាយការណ៍នេះគឺជាសមាជិកនៃ INHOPE ដែលជាបណ្តាញមួយនៃបណ្តាញរាយការណ៍ចំនួន ៤៧ នៅទូទាំងពិភពលោក ដែលមានគោលបំណងជួយដល់ការដកហូត CSAM យ៉ាងឆាប់រហ័សចេញពីអ៊ីនធឺណិត ។ នៅពេលទទួលបានរបាយការណ៍អំពី CSAM អ្នកវិភាគកំណត់នូវនីត្យានុកូលភាព និងចំណាត់ថ្នាក់នៃមាតិកា។ នៅពេលសម្ភារត្រូវកំណត់ថាខុសច្បាប់ សេចក្តីជូនដំណឹងអំពីការដកហូតត្រូវបានបញ្ជូនទៅកាន់ទីភ្នាក់ងារអនុវត្តច្បាប់ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា បណ្តាញរាយការណ៍ដទៃទៀត នៃបណ្តាញរាយការណ៍សកល INHOPE ឬក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត  ដើម្បីសម្របសម្រួលសេចក្តីជូនដំណឹង និងចំណាត់ការដកហូតចេញ។ បណ្តាញរាយការណ៍តាមអ៊ីនធឺណិតកម្ពុជាក៏មានមជ្ឈមណ្ឌលរៀនតាមប្រព័ន្ធអនឡាញ ដែលកុមារ និងយុវជន ឪពុកម្តាយ/អ្នកថែទាំ និងអ្នកវិជ្ជាជីវៈអាចស្វែងរកធនធាន និងឧបករណ៍ដើម្បីយល់ដឹងអំពីហានិភ័យ និងទប់ស្កាត់គ្រោះថ្នាក់តាមប្រព័ន្ធអនឡាញផងដែរ។

រវាងឆ្នាំ២០១៧និង២០១៩ បណ្តាញរាយការណ៍នេះបានទទួលសេចក្តីរាយការណ៍សរុបចំនួន ៥.៥៦៥ (តារាង ២២)។ ក្នុងចំណោមសេចក្តីរាយការណ៍ទាំងនេះ ៦០% គឺពាក់ព័ន្ធរូបភាព និង២៦% គឺពាក់ព័ន្ធវីដេអូ។

តារាង ២២. សេចក្តីរាយការណ៍ទៅកាន់បណ្តាញរាយការណ៍ទាន់ហេតុការណ៍អំពី CSAM នៅកម្ពុជា ឆ្នាំ ២០១៧-២០១៩។

| | ២០១៧ | ២០១៨ | ២០១៩ | សរុប |
|---|---|---|---|---|
| សេចក្តីរាយការណ៍ | ៧០៣ | ១.៥០៨ | ៣.៣៥៤ | ៥.៥៦៥ |

មូលដ្ឋាន៖ សេចក្តីរាយការណ៍អំពី CSAM ទៅកាន់បណ្តាញរាយការណ៍ទាន់ហេតុការណ៍អំពី CSAM របស់ APLE ឆ្នាំ២០១៧-២០១៩ សេចក្តីរាយការណ៍ចំនួន ៥.៥៦៥

រូបភាព  ២៣ បង្ហាញថា សេចក្តីរាយការណ៍ទូទៅបំផុត គឺការចែកចាយ CSAM (៣៩% នៃសេចក្តីរាយការណ៍ទាំងអស់)។ ៣២% នៃសេចក្តីរាយការណ៍ពាក់ព័ន្ធ CSAM ត្រូវបានអ្នកវិភាគកំណត់ឃើញនៅពេលក្រោយថា "CSAM គួរឱ្យសង្ស័យ" ដែលមានន័យថា ស្របពេលដែលមិនមានលក្ខណៈខុសច្បាប់ផ្នែកបច្ចេកទេសនៅប្រទេសដើមមាតិកាអាចត្រូវចាត់ចំណាត់ថ្នាក់ថា ខុសច្បាប់នៅកម្ពុជា។

រូបភាព ២៣. ប្រភេទនៃ CSAM ដែលត្រូវបានរាយការណ៍ទៅកាន់បណ្តាញរាយការណ៍ទាន់ហេតុការណ៍អំពី CSAM ។




មូលដ្ឋាន៖ សេចក្តីរាយការណ៍អំពី CSAM ទៅកាន់បណ្តាញរាយការណ៍ទាន់ហេតុការណ៍អំពី CSAM របស់ APLE ឆ្នាំ២០១៧-២០១៩ សេចក្តីរាយការណ៍ចំនួន ៥.៥៦៥

## ៣.១ យន្តការរាយការណ៍ផ្លូវការ

តារាង ២៤ ខាងក្រោមបង្ហាញនូវចំណាត់ការដែលធ្វើឡើងដោយអង្គការ APLE នៅពេលទទួលបានករណី ដែលត្រូវបញ្ជូនតាមបណ្ដាញរាយការណ៍មកពួកគេ។ សេចក្ដីរាយការណ៍ភាគច្រើន (៦០%) នៃសេចក្ដីរាយការណ៍ទាំង ៥.៥៦៥ ដែលទទួលបាន នៅរវាងឆ្នាំ២០១៧ និងឆ្នាំ២០១៩ ត្រូវបានបញ្ជូនដោយផ្ទាល់ទៅកាន់ម្ចាស់នៃសេវាបង្ហោះ/ដូមេន (Domain) និងភាគច្រើនត្រូវបានដកហូតចេញ។

សេចក្ដីរាយការណ៍ចំនួនម្ភៃបីភាគរយត្រូវបានបញ្ជូនទៅកាន់ INHOPE ដើម្បីចាត់វិធានការ។ INHOPE បានចាត់វិធានការប្រកបដោយជោគជ័យលើសេចក្ដីរាយការណ៍ដែលត្រូវបានបញ្ជូននេះចំនួន ៨០% តាមរយៈការដកហូតមាតិកាចេញ (៤២%) និងការបិទគេហទំព័រ (៣៨%)។ សេចក្ដីរាយការណ៍ដែលត្រូវបានបញ្ជូនចំនួនតែ ៨% ប៉ុណ្ណោះត្រូវបានបញ្ជូនទៅទីភ្នាក់ងារអនុវត្តច្បាប់កម្ពុជា ដើម្បីចាត់វិធានការ ហើយក្នុងចំណោមនោះ សេចក្ដីរាយការណ៍ចំនួន ៩% បានឈានដល់ការលុបមាតិកា ៩% បាននាំឱ្យមានការបិទគេហទំព័រ និង ៧៨% បានឈានដល់ការបើកការស៊ើបអង្កេត។

តារាង ២៤. ចំណាត់ការដែលត្រូវធ្វើឡើងដោយអង្គការទទួល បន្ទាប់ពីការបញ្ជូនមកពីបណ្ដាញរាយការណ៍ទាន់ហេតុការណ៍អំពី CSAM ឆ្នាំ២០១៧-២០១៩។

| ចំណាត់ការដែលត្រូវបានធ្វើ | ២០១៧ | ២០១៨ | ២០១៩ | សរុប |
|---|---|---|---|---|
| ម្ចាស់នៃការបង្ហោះ/ដូមេន | ៤៥៩ | ៩០៩ | ១.៩៥៨ | ៣.៣២៦ |
| មាតិកាមិនត្រូវបានដកចេញ | | ៣៨ | ៧១ | ១០៩ |
| មាតិកាត្រូវបានដកចេញ | ៣៨០ | ៥៧៣ | ១.៨៨៧ | ២.៨៤០ |
| គ្មានចំណាត់ការ | ៧៩ | ២៩៨ | | ៣៧៧ |
| INHOPE | ១០៩ | ២០៤ | ៩៨២ | ១.២៩៥ |
| មាតិកាមិនត្រូវបានដកចេញ | | | ១៣៧ | ១៣៧ |
| មាតិកាត្រូវបានដកចេញ | ៥៣ | ១០៦ | ៣៨៩ | ៥៤៨ |
| គ្មានចំណាត់ការ | ១៩ | ៩៨ | | ១១៧ |
| គេហទំព័រត្រូវបានបិទ | ៣៧ | | ៤៥៦ | ៤៩៣ |
| ការអនុវត្តច្បាប់ | ១៣៥ | ១២៨ | ២០៧ | ៤៧០ |
| មាតិកាត្រូវបានដកចេញ | ៤១ | | | ៤១ |
| ការស៊ើបអង្កេតត្រូវបានបើក | ៣១ | ១២៨ | ២០៧ | ៣៦៦ |
| គ្មានចំណាត់ការ | ២៣ | | | ២៣ |
| គេហទំព័រត្រូវបានបិទ | ៤០ | | | ៤០ |
| មិនពាក់ព័ន្ធ | | ១៣០ | ២០៧ | ៣៣៧ |
| មិនពាក់ព័ន្ធ | | ១៣០ | ២០៧ | ៣៣៧ |
| មិនអាចចាត់ការបាន | | ១៣៧ | | ១៣៧ |
| គ្មានចំណាត់ការ | | ១៣៧ | | ១៣៧ |
| សរុប | ៧០៣ | ១.៥០៨ | ៣.៣៥៤ | ៥.៥៦៥ |

មូលដ្ឋាន៖ សេចក្ដីរាយការណ៍អំពី CSAM ទៅកាន់បណ្ដាញរាយការណ៍ទាន់ហេតុការណ៍អំពី CSAM របស់ APLE ឆ្នាំ២០១៧-២០១៩ សេចក្ដីរាយការណ៍ចំនួន ៥.៥៦៥

# ៣.២ ការឆ្លើយតបរបស់ទីភ្នាក់ងារអនុវត្តច្បាប់

ផ្នែកនេះផ្តោតលើសមត្ថភាពអនុវត្តច្បាប់នៅក្នុងប្រទេស ក្នុងការទប់ស្កាត់ និងឆ្លើយតបចំពោះករណី OCSEA នៅកម្ពុជា និងផ្អែកជាបឋមទៅលើការសម្ភាសនានា ដែលធ្វើឡើងដោយនគរបាលអន្តរជាតិជាមួយអង្គភាពអនុវត្តច្បាប់។ របកគំហើញនានាដែលមាននៅក្នុងជំពូកនេះ ត្រូវបានបំពេញបន្ថែមដោយទិន្នន័យ ដែលទទួលបានពីការសម្ភាសជាមួយអ្នកមានភារកិច្ចមកពីជួររដ្ឋាភិបាល បុគ្គលិកគាំទ្រសង្គមជួរមុខ ព្រមទាំងកុមារ និងអ្នកថែទាំ ដែលបានស្វែងរកភាពយុត្តិធម៌។ គប្បីកត់សម្គាល់ថា ភាពខុសគ្នានៃភាសា គឺជាឧបសគ្គគួរឱ្យកត់សម្គាល់នៅក្នុងការទំនាក់ទំនងរវាងបុគ្គលិកអនុវត្តច្បាប់ជាតិ និងក្រុមស្រាវជ្រាវនៃនគរបាលអន្តរជាតិ។ ឧបសគ្គនេះត្រូវបានកាត់បន្ថយតាមរយៈការគាំទ្ររបស់បុគ្គលិកអង្គការAPLE ដែលបានជួយសម្រួលដល់ការបកប្រែភាសាសម្រាប់ការសម្ភាសទាំងនេះ។ វត្តមានរបស់បុគ្គលិក APLE អាចមានផលប៉ះពាល់លើចម្លើយមួយចំនួនរបស់មន្ត្រីអនុវត្តច្បាប់ ដែលគប្បីគួរកត់សម្គាល់ពាក់ព័ន្ធនឹងរបកគំហើញទាំងនេះ។ (CA-RA៨)

## ៣.២.១ មន្ត្រីអនុវត្តច្បាប់

មានអង្គភាពសំខាន់ៗចំនួនពីរនៅក្នុងនគរបាលជាតិកម្ពុជា (នៅក្រោមក្រសួងមហាផ្ទៃ) ដែលទទួលខុសត្រូវចំពោះការស៊ើបអង្កេតបទល្មើសប្រឆាំងនឹងកុមារនានា គឺនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា។ ជាទូទៅ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន គឺជាអង្គភាពដំបូងដែលទទួលបានករណីកេងប្រវ័ញ្ចកុមារ។ នៅពេលអង្គភាពនេះដឹងច្បាស់ថា ករណីនេះមានធាតុផ្សំបច្ចេកវិទ្យា ករណីនេះអាចត្រូវបានបញ្ជូនបន្តទៅកាន់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា ដើម្បីស៊ើបអង្កេតបន្ថែមទៀត។ អង្គភាពទាំងពីរមាននគរបាលយុត្តិធម៌ និងមានអាណត្តិការងារលើករណី OCSEA ទោះបីជាយ៉ាងណាក្តី ទំនួលខុសត្រូវជាក់លាក់ និងនីតិវិធីសម្រាប់ឆ្លើយតបចំពោះករណី OCSEA មានភាពមិនច្បាស់លាស់ និងជាទូទៅ  មិនស្ថិតនៅក្នុងអាណត្តិរបស់អង្គភាពតែមួយណាឡើយ។

ការសម្ភាសជាមួយអ្នកតំណាងទីភ្នាក់ងារអនុវត្តច្បាប់បានបង្ហាញថា មានការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការគួរឱ្យកត់សម្គាល់រវាងអង្គភាពទាំងពីរនេះ។ (CA-RA៨) អ្នកតំណាងម្នាក់មកពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានពន្យល់ថា៖ "យើងបានមើលឃើញថា នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាតែងតែសហប្រតិបត្តិការគ្នានៅទូទាំងដំណើរការស៊ើបអង្កេត ជាពិសេសករណីនានាពាក់ព័ន្ធនឹងបទល្មើសផ្លូវភេទលើកុមារ។ ឧទាហរណ៍ នៅពេលបទល្មើសផ្លូវភេទមានទំនាក់ទំនងជាមួយការផលិត និងការចែកចាយរូបភាព ឬវីដេអូអាសអាភាសកុមារនៅតាមប្រព័ន្ធអ៊ីនធឺណិត  នាយកដ្ឋានទាំងពីរចាប់ផ្តើមសហប្រតិបត្តិការជាមួយគ្នា ដោយផ្អែកលើតួនាទី និងជំនាញរៀងៗខ្លួនរបស់ពួកគេ។" (RA៩-CA-១០-A)

### រចនាសម្ព័ន្ធ និងធនធានស្ថាប័ន

**នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន**

ការកំណត់នៃចំនួនមន្ត្រីមិនត្រូវបានផ្តល់ឱ្យនគរបាលអន្តរជាតិ (INTERPOL) ក្នុងកំឡុងពេលប្រមូលព័ត៌មាន តែទោះបីជាយ៉ាងណា តាមរយៈការពិភាក្សាជាច្រើនដងជាមួយក្រុមការបច្ចេកទេស និងប្រភពទិន្នន័យជាច្រើនដទៃទៀតដែលបានផ្តល់ដោយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនទាំង២៥ការិយាល័យនៅថ្នាក់ជាតិ និងថ្នាក់រាជធានីខេត្ត ដែលមានមន្ត្រីជាង១00នាក់ដែលជាទូទៅធ្វើការងារលើករណីការរំលោភបំពាន និងការជួញដូរមនុស្ស។  ការបែងចែកធនធានមនុស្ស និងការធ្វើផែនទីបង្ហាញឆ្ពោះទៅរករចនាសម្ព័ន្ធស្ថាប័នដ៏រឹងមាំ ប៉ុន្តែការពិភាក្សាលើសមត្ថភាពរបស់ប្រទេសនៃទីភ្នាក់ងារអនុវត្តច្បាប់នៅតែជួបបញ្ហាប្រឈម។ តម្រូវការគាំទ្រចាំបាច់ក្នុងការពង្រឹងសមត្ថភាពបន្ថែមលើ OCSEA និងផ្នែកប្រតិបត្តិការ។

**នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា**

អង្គភាពនេះដោះស្រាយបទល្មើសបច្ចេកវិទ្យាគ្រប់ប្រភេទទាំងអស់ មិនជាក់លាក់ចំពោះOCSEAឡើយ។ នៅត្រឹមឆ្នាំ២០១៨មន្ត្រីចំនួនប្រមាណដប់នាក់ក្នុងអង្គភាពនេះបានធ្វើការងារពាក់ព័ន្ធនឹងករណី OCSEA។ អ្នកផ្តល់ការសម្ភាសទាំងឡាយ ដែលមកពីនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាបានប្រាប់ថា មន្ត្រីអនុវត្តច្បាប់ធ្វើការងារជាក្រុមផ្សេងៗគ្នាឱ្យឈ្មោះថា ការិយាល័យ ក្នុងនោះដែរការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យាមានតែបួនប៉ុណ្ណោះក្នុងបណ្តារាជធានីខេត្តទាំង២៥ដោយធ្វើការងារជាអ្នកសម្របសម្រួលករណី។ (RA៩-CA-0៣-A) នៅក្នុងរយៈពេលនៃការប្រមូលទិន្នន័យនេះ មន្ត្រីចំនួនពីរ ឬបីនាក់ត្រូវបានគេរាយការណ៍ថា ធ្វើការងារដោយសហការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនលើការស៊ើបអង្កេតពាក់ព័ន្ធនឹងករណី OCSEA ។

## ៣.២ ការឆ្លើយតបរបស់ទីភ្នាក់ងារអនុវត្តច្បាប់

### ការយល់ដឹងអំពី OCSEA

ការសម្ភាសរបស់នគរបាលអន្តរជាតិជាមួយមន្ត្រីអនុវត្តច្បាប់នៅកម្ពុជាបានបង្ហាញថា ពួកគេដឹងអំពីបញ្ហា OCSEA ។ ទោះបីជាយ៉ាងណាក្តី អ្នកតំណាងម្នាក់មកពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានថ្លែងថា៖ *"ខ្ញុំគិតថា ការយល់ដឹងអំពី ទម្រង់ខុសៗគ្នានៃបទល្មើសព្រហ្មទណ្ឌពាក់ព័ន្ធនឹង OCSEA នៅក្នុងចំណោមមន្ត្រីនគរបាល និងមន្ត្រីតុលាការនៅមានកម្រិតនៅឡើយ។"* (RA១-CA-១0-A)។ ការស្រាវជ្រាវនៅឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារក៏កត់សម្គាល់ចំណុចនេះផងដែរ។ បុគ្គលិកគាំទ្រសង្គមជួរមុខបានបង្ហាញស្រដៀងគ្នានេះថា ការយល់ដឹងរបស់មន្ត្រីអនុវត្តច្បាប់អំពី OCSEA គឺមធ្យម (៤៤%) ឬល្អ (៣២%)។

រូបភាព ២៥. ការយល់ឃើញរបស់បុគ្គលិកជួរមុខអំពីការយល់ដឹងរបស់មន្ត្រីអនុវត្តច្បាប់ និងការឆ្លើយតបចំពោះ OCSEA




មូលដ្ឋាន៖ បុគ្គលិកសុខុមាលភាពជួរមុខ ចំនួន ៥០នាក់

### សមត្ថភាពស៊ើបអង្កេត/ប្រតិបត្តិការ

បើទោះបីជាការយល់ដឹងទូទៅនៅក្នុងចំណោមនគរបាលនៅក្នុងចំណោមអង្គភាពជំនាញអាចត្រូវការការកែលម្អក្តី មន្ត្រីអនុវត្តច្បាប់ដែលត្រូវបានសម្ភាសបានបង្ហាញនូវចំណេះដឹងយ៉ាងល្អអំពីបច្ចេកទេសស៊ើបអង្កេតជាមូលដ្ឋាន ការស្រាវជ្រាវនៅពេលបច្ចុប្បន្ន និងពីមុនបានរកឃើញថា អង្គភាពអនុវត្តច្បាប់ទំនងជាភាគច្រើនមានលក្ខណៈតបតរ ជាជាងការត្រៀមទប់ទល់ជាមុន និងរមែងតែងពឹងផ្អែកលើទីភ្នាក់ងារដទៃទៀតរបស់រដ្ឋាភិបាល ដើម្បីដំណើរការការស៊ើបអង្កេត។ មន្ត្រីស៊ើបអង្កេតបានរាយការណ៍ថា ពួកគេមិនទទួលបានការផ្តល់សិទ្ធិអំណាចនៅក្នុងច្បាប់កម្ពុជាឡើយ ហើយក៏គ្មានបទពិសោធន៍លើការស៊ើបអង្កេតដោយសម្ងាត់ ឬការតាមដានត្រួតពិនិត្យបណ្តាញអនាមិកដែរ។ ទោះបីជាយ៉ាងណាក្តី មានការរកឃើញថា ការឃ្លាំមើលលើសន្តិសុខបច្ចេកវិទ្យាត្រូវបានរៀបចំយ៉ាងល្អសមស្រប និងនាំទៅរកការកំណត់ឃើញករណីតាំងពីដំបូង។

នគរបាលប្រឆាំងការជួញដូរមនុស្សឆ្លើយតបចំពោះ OCSEA នៅក្រោមច្បាប់ប្រឆាំងអំពើជួញដូរមនុស្សដែលនៅមានកម្រិត និងជាទូទៅ បញ្ជូនករណីទៅកាន់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា។ បើទោះបីជានាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាមានសមត្ថភាពនៅមានកម្រិតក្នុងការគាំទ្រករណីនានា ដែលលើសពីកោសល្យវិច្ច័យរូបវន្តលើហាដវែរនៅក្នុងការស្វែងរក CSAM ក្តី មន្ត្រីអនុវត្តច្បាប់ម្នាក់ក្នុងចំណោមមន្ត្រីអនុវត្តច្បាប់នានា បានចែកចាយថា អង្គភាពនេះបានជួយព្រះរាជអាជ្ញានៅក្នុងការតាមដានរកអាសយដ្ឋាន IP ឬគណនេយ្យរបស់អ្នកប្រើប្រាស់ដែលអាចត្រូវបានប្រើប្រាស់ជាភស្តុតាងបាន ស្របពេលដែលពេលខ្លះអាចជួយនៅក្នុងដំណើរការស៊ើបអង្កេតកាន់តែទូលំទូលាយបាន។ (RA១-CA-0៣-A)

មន្ត្រីអនុវត្តច្បាប់ក៏បានបង្ហាញឱ្យឃើញថា ការស៊ើបអង្កេតករណីប្រកបដោយជោគជ័យ គឺពឹងផ្អែកលើកម្រងនៃកត្តានានា ដែលរមែងតែងនៅក្រៅវិស័យរបស់នគរបាល ឬអង្គភាពជំនាញ និងដែលពេលខ្លះមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអនុវត្តច្បាប់ឡើយ នេះបើយោងតាមអ្នកឆ្លើយតបនានា។ កត្តាមួយចំនួននៃកត្តាទាំងនេះរួមមាន ប៉ុន្តែកម្រិតត្រឹម កម្រិតនៃកិច្ចសហប្រតិបត្តិការពីជនរងគ្រោះ និងគ្រួសាររបស់ពួកគេ ការគាំទ្រដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល និងជំនួយពីក្រសួងកិច្ចការនារី។ (CA-RA៨)

## ៣.២ ការឆ្លើយតបរបស់ទីភ្នាក់ងារអនុវត្តច្បាប់

### ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍

មន្ត្រីដែលត្រូវបានសម្ភាស បានពន្យល់ថា មាននីតិវិធីសម្រាប់ការស៊ើបអង្កេតករណី ការប្រមូលទិន្នន័យ និងការដោះស្រាយករណី។ ទោះបីជាយ៉ាងណាក្តី អ្នកតំណាងម្នាក់មកពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានចែករំលែកថា បើទោះបីជាមាននីតិវិធីក្តី *"នីតិវិធីស៊ើបអង្កេតរបស់នគរបាលពាក់ព័ន្ធនឹងបទល្មើស OCSEA ប្រភេទនេះ នៅតែមិនទាន់ច្បាស់លាស់ និងស្មុគស្មាញ។ ទាំងមន្ត្រីនគរបាល និងទាំងមន្ត្រីតុលាការ (ព្រះរាជអាជ្ញា ចៅក្រម) ត្រូវការការបណ្តុះបណ្តាលបន្ថែមស្តីពីបរិបទនៃបទល្មើសដែលកំពុងលេចឡើងទាំងនេះ។"* (RA១-CA-១០-A).

អ្នកតំណាងម្នាក់មកពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារក៏បានថ្លែងថា៖ យើងគប្បីបញ្ចូលប្រធានបទ OCSEA នៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់បណ្ឌិតសភានគរបាល ឬរបស់គណៈ*មេធាវី។ ហើយយើងប្រហែលគប្បីបង្កើតក្រុមមេធាវី ដែលមានជំនាញលើ OCSEA ។ យើងក៏បានមើលឃើញឧទាហរណ៍ជោគជ័យជាច្រើននៃកិច្ចសហប្រតិបត្តិការរវាងនគរបាលជាតិ និងទីភ្នាក់ងារក្នុងស្រុកនិងអន្តរជាតិដទៃទៀត រួមទាំងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីឆ្លើយតបចំពោះបញ្ហាទាំងនេះ។* (RA១-CA-១០-A).

ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ (ឆ្នាំ២០១៧-២០២១) រួមបញ្ចូលនូវការរៀបចំមេរៀនបណ្តុះបណ្តាលកិច្ចការពារកុមារអំពី ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និងការស៊ើបអង្កេតករណីបែបនេះសម្រាប់មន្ត្រីអនុវត្តច្បាប់។ អ្នកតំណាងមកពីនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាបានបង្ហាញថា មន្ត្រីស៊ើបអង្កេតមួយចំនួនបានទទួលវគ្គបណ្តុះបណ្តាល រួមមានពីក្រសួងកិច្ចការនារី និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារអំពី បញ្ហា OCSEA ។ ក៏មានការរៀបរាប់អំពី កម្មវិធីបណ្តុះបណ្តាលពីខាងក្រៅ/អន្តរជាតិនានា ដែលត្រូវផ្តល់ដោយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) នៅទីក្រុងបាងកក និងនៅប្រទេសកូរ៉េផងដែរ។ មិនមានការផ្តល់ព័ត៌មានច្បាស់អំពីប្រធានបទនៃការបណ្តុះបណ្តាល និងចំនួនមន្ត្រីដែលបានចូលរួមនៅក្នុងការបណ្តុះបណ្តាលទាំងនេះឡើយ។ នៅក្នុងការស្រាវជ្រាវលើកមុន អ្នកតំណាងនានាមកពីនគរបាលប្រឆាំងការជួញដូរមនុស្ស បានចែកចាយថា ការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់មួយចំនួនអំពី OCSEA ត្រូវបានរៀបចំសម្រាប់នគរបាលជាតិកម្ពុជា ហើយភាពពាក់ព័ន្ធនៃការរៀនសូត្រអំពីបច្ចេកវិទ្យាថ្មី មិនត្រូវបានយល់ច្បាស់ឡើយ ដែលជាហេតុធ្វើឱ្យការចូលរួមមានកម្រិតទាបខ្លាំង។ ការសម្ភាសជាមួយមន្ត្រីនានាមិនបានកំណត់ឃើញផែនការអនាគតច្បាស់លាស់សម្រាប់ការបណ្តុះបណ្តាលដែលមានយ៉ាងទូលំទូលាយ សម្រាប់នគរបាលឡើយ។

### ធនធាន និងការប្រមូលភស្តុតាង

អង្គភាពស៊ើបអង្កេត ស្ថិតនៅក្រោមអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា មានការិយាល័យ ធនធាន និងឧបករណ៍នានា រួមទាំងម៉ាស៊ីនកុំព្យូទ័រ និងតំណភ្ជាប់អ៊ីនធឺណិត។ ឧបករណ៍ធ្វើកោសល្យវិច្ច័យឌីជីថល ឈ្មោះ *Cellebrite* ដែលត្រូវបានផ្តល់ដំបូងដោយនគរបាលសហព័ន្ធអូស្ត្រាលីទៅដល់អាជ្ញាធរជាតិ មិនមាននិរន្តរភាពឡើយ ដោយសារថវិកាជាតិមិនគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការបន្តសិទ្ធិអនុញ្ញាតសម្រាប់ការប្រើប្រាស់ឧបករណ៍នេះជាបន្តបន្ទាប់។

ល្បឿននៃភាពរីកចម្រើនខាងផ្នែកបច្ចេកវិទ្យា ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស OCSEA នៅតែបង្កបញ្ហាប្រឈមសម្រាប់ទីភ្នាក់ងារអនុវត្តច្បាប់កម្ពុជា។ ប្រធាននាយកដ្ឋានសន្តិសុខព័ត៌មានមកពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានរៀបរាប់ថា *"សមត្ថភាពរបស់អ្នកស៊ើបអង្កេតមិនទាន់រីកចម្រើនស្របទៅតាមភាពរីកចម្រើននៃបច្ចេកវិទ្យាឡើយ។"* (RA១-CA-០៤-A) ទស្សនៈនេះក៏ត្រូវបានលើកឡើងដោយអ្នកឆ្លើយតបដទៃទៀតមកពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ផងដែរ ដែលនិយាយថា៖ *"យើងគ្មានធនធាន ឬច្បាប់គ្រប់គ្រាន់ ដើម្បីពង្រឹងការស៊ើបអង្កេតនៅឡើយទេ។ បច្ចេកវិទ្យាមានភាពជឿនលឿនទៅមុខទៀត ប៉ុន្តែសមត្ថភាពរបស់នគរបាលរបស់យើងមិនទាន់បានជឿនលឿននៅឡើយ។ ហេតុដូច្នេះ ចំណុចនេះធ្វើឱ្យមានបញ្ហាប្រឈមខ្លាំងណាស់។"* (RA១-CA-០៤-A)

ការប្រមូលភស្តុតាង ជាពិសេស ភស្តុតាងឌីជីថល ក៏ជាបញ្ហាប្រឈមដែរ ដោយសារទីភ្នាក់អនុវត្តច្បាប់គ្មានឧបករណ៍ដើម្បីធ្វើកោសល្យវិច្ច័យឌីជីថល ហេតុនេះ ពួកគេមិនអាចបញ្ជូនព័ត៌មានសម្ងាត់ទៅដល់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា ដើម្បីបន្តជាមួយនឹងការស៊ើបអង្កេតនានាឡើយ។ ស៊ីមកាតដែលមិនត្រូវបានចុះបញ្ជី គឺជាឧបសគ្គមួយបន្ថែមទៀត នៅពេលពាក់ព័ន្ធនឹងការកំណត់អាសយដ្ឋាន IP និងភ្ជាប់ទំនាក់ទំនងអាសយដ្ឋានទាំងនោះជាមួយនឹងឧបករណ៍របស់ម្ចាស់ស៊ីមកាតនេះ។ ថ្វីបើមានសេចក្តីណែនាំនៅឆ្នាំ២០១៨ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងនគរបាលជាតិកម្ពុជាថា ក្រុមហ៊ុនទូរគមនាគមន៍ទាំងអស់នៅកម្ពុជាត្រូវតែធានាថា អ្នកប្រើប្រាស់ស៊ីមកាតទាំងអស់ត្រូវបានចុះបញ្ជីក្តី និយ័តករអ៊ីនធឺណិត ប៉ាន់ប្រមាណថា ប្រហែលជាប់ភាគរយនៃស៊ីមកាតដែលកំពុងប្រើប្រាស់នៅពេលបច្ចុប្បន្ន

។ អនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងភេរវកម្មមកពីក្រសួងមហាផ្ទៃ បានកត់សម្គាល់ថា៖ *យើងមានការលំបាកក្នុងការស្វែងរកជនល្មើស ដោយសារជនល្មើសរមែងតែងទំនាក់ទំនងតាមប្រព័ន្ធអនឡាញប៉ុណ្ណោះ ហើយអ្នកដឹងហើយ ពេលខ្លះ ពួកគេបានផ្លាស់ប្ដូរគណនីរបស់ពួកគេរួចហើយ ដោយសារពួកគេអាចបង្កើតគណនីមួយខ្លួនឯងបានដោយខុសច្បាប់។ យើងមិនមានឧបករណ៍ សម្រាប់ការរកឃើញវាយហ្វាយ ឬឈ្មោះតាមប្រព័ន្ធអនឡាញដទៃទៀតឡើយ។ ហេតុនេះ នោះគឺជាបញ្ហាប្រឈម ដែលយើងជួបប្រទះ។* - (RA១-CA-០៦-A)

## នីតិវិធីកុមារមេត្រី

អ្នកជំនាញផ្នែកកិច្ចការពារកុមារមកពីអង្គការសកម្មភាពដើម្បីកុមារ (APLE) បានចែករំលែកពីចំណាប់អារម្មណ៍របស់ពួកគេអំពីការអនុវត្តបែបកុមារមេត្រីនៅក្នុងទីភ្នាក់ងារអនុវត្តច្បាប់៖ *"ចំណុចមួយដែលខ្ញុំអាចមើលឃើញថា មានការល្អប្រសើរឡើង គឺការអនុវត្តការសម្ភាសរបស់នគរបាល។ ពួកគេទទួលបានការបណ្ដុះបណ្ដាលជាច្រើនពាក់ព័ន្ធនឹងអនុវត្ត និងនីតិវិធីស៊ើបអង្កេតបែបកុមារមេត្រី។ ឧទាហរណ៍ ក្នុងអំឡុងពេលដំណើរការស៊ើបអង្កេត នគរបាលបានព្យាយាមទំនាក់ទំនងជាមួយអ្នកទាំងឡាយ ជាពិសេស បុគ្គលិកសង្គមមកពីស្ថាប័នរដ្ឋាភិបាល ឬមកពីអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធានានូវការជួយ និងការផ្ដល់ការគាំទ្រដល់កុមារ ដើម្បីធ្វើឱ្យការស៊ើបអង្កេតដំណើរការទៅដោយរលូន។"* (RA៤-CA-០១-A)

ទោះបីជាយ៉ាងណាក្ដី ការសម្ភាសជាមួយកុមារ និងអ្នកថែទាំរបស់ពួកគេបានបង្ហាញឱ្យឃើញថា ថ្វីបើមានវឌ្ឍនភាពក្ដី កុមារមួយចំនួននៅតែពណ៌នាអំពីអារម្មណ៍ច្របូកច្របល់ ភាពភ័យខ្លាច និងភាពអាម៉ាស ដែលសម្រាប់ពួកគេមួយចំនួន បញ្ហានេះមានលក្ខណៈកាន់តែធ្ងន់ធ្ងរ ដោយសារកង្វះបរិយាកាសឯកជន និងរក្សាការសម្ងាត់ នៅកន្លែងដែលពួកគេត្រូវរំពឹងថា នឹងពិភាក្សាអំពីបទពិសោធន៍របស់ពួកគេជាមួយនគរបាល (សូមមើលជំពូក ៣.២.២)។

## កិច្ចសហការជាអន្តរជាតិ

អ្នកតំណាងម្នាក់មកពីនគរបាលជាតិកម្ពុជាបានរាយការណ៍ថា ទីភ្នាក់ងារអនុវត្តច្បាប់សហប្រតិបត្តិការប្រកបដោយប្រសិទ្ធផលជាមួយទីភ្នាក់ងារអន្តរជាតិ។ គាត់បានថ្លែងថា ប្រសិនបើ មានករណីដែលត្រូវបានដឹង ដែលជនណាម្នាក់ពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសលើកុមារចូលមកក្នុងប្រទេស នគរបាលអន្តរជាតិនឹងផ្ដល់ព័ត៌មានដើម្បីឱ្យតាមដាន និងប្រតិបត្តិការការឃ្លាំមើលលើជនសង្ស័យនៅកម្ពុជា។ ពួកគេនឹងផ្លាស់ប្ដូរព័ត៌មាន និងការពិនិត្យសារតាអំពីជនល្មើសដែលចូលមកកម្ពុជា ហើយដូចគ្នានេះដែរ នគរបាលកម្ពុជានឹងផ្ដល់ព័ត៌មានដល់ប្រទេសដទៃទៀត អំពីជនល្មើសកម្ពុជានៅក្នុងប្រទេសទាំងនោះ។ (RA១-CA-០៣-A)

ជាពិសេស នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយទីភ្នាក់ងារអនុវត្តច្បាប់បរទេសជាច្រើន រួមមាន នគរបាលសហព័ន្ធអូស្ត្រាលី នគរបាលនៃក្រសួងសន្តិសុខមាតុភូមិសហរដ្ឋអាមេរិក/FBI នគរបាលចក្រភពអង់គ្លេស នគរបាលអាល្លឺម៉ង់ នគរបាលបារាំង នគរបាលស៊ុយអែត និងនគរបាលអូទ្រីស ដើម្បីស៊ើបអង្កេតការកេងប្រវ័ញ្ចផ្លូវភេទកុមារ នៅក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍ ដែលប្រព្រឹត្តដោយជនបរទេស។ (RA១-CA-១០-A) អ្នកតំណាងម្នាក់មកពីក្រសួងកិច្ចការនារីបានធ្វើការកត់សម្គាល់ថា នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បាននិងកំពុង៖ *បង្ក្រាប និងជួយសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅកម្រិតអន្តរប្រទេស ជាពិសេសនៅថ្នាក់មហាអនុតំបន់មេគង្គ ដោយប្រើប្រាស់យន្តការមួយដែលគេហៅថា COMMIT ។ ពួកគេបានចូលរួមភាគច្រើននៅក្នុងករណីជួញដូរផ្លូវភេទកុមារ ប៉ុន្តែសម្រាប់ការអន្តរាគមន៍លើករណី អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ និងក្រសួងការបរទេស គឺជាទីភ្នាក់ងារដឹកនាំក្នុងការសម្របសម្រួល។ ដៃគូអន្តរជាតិនៅក្នុង COMMIT ក៏បានពិភាក្សាអំពីបញ្ហា OCSEA ផងដែរ។ វាជាការពិបាកក្នុងការទប់ស្កាត់បញ្ហានេះ ដោយសារប្រទេសនីមួយៗត្រូវតែពង្រឹងការគ្រប់គ្រងការភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត  និងការអប់រំអ្នកប្រើប្រាស់។* (RA១-CA-០៥-A)

កិច្ចសហការឆ្លងកាត់ព្រំដែនមួយចំនួនបានចាប់ផ្ដើម ដូចជា ការចុះហត្ថលេខាអនុស្សារណៈនៃការយោគយល់គ្នារវាងការិយាល័យស៊ើបអង្កេតសហព័ន្ធសហរដ្ឋអាមេរិក និងនគរបាលជាតិកម្ពុជានៅឆ្នាំ២០១៩ ដើម្បីប្រយុទ្ធប្រឆាំងនឹងបទល្មើសឆ្លងដែន (រួមទាំងបទល្មើសលើកុមារ) ក្ដី គំនិតផ្ដួចផ្ដើមនេះត្រូវការការពង្រីកបន្ថែមទៀត។ អ្នកឯកទេសផ្នែកកិច្ចការពារកុមារមកពីអង្គការសកម្មភាពដើម្បីកុមារបានផ្ដល់យោបល់ថា៖ *"ចំណុចនេះមានសារសំខាន់ណាស់ ដោយសារ OCSEA មិនត្រូវបានប្រព្រឹត្តតែនៅក្នុងប្រទេសជាក់លាក់ណាមួយប៉ុណ្ណោះទេ វាជាឧក្រិដ្ឋកម្ម សកល។ ហេតុនេះ ការបង្ក្រាបជនល្មើស ឬការដោះស្រាយ OCSEA ត្រូវការកិច្ចខិតខំប្រឹងប្រែងដោយសហការគ្នាមិនត្រឹមតែពីកម្ពុជាប៉ុណ្ណោះឡើយ ប៉ុន្តែពីអ្នកគ្រប់គ្នានៅទូទាំងពិភពលោក។"* (RA៤-CA-០១-A)

### ៣.២.២ ជំនួបជាមួយនគរបាលរបស់កុមារ និងអ្នកថែទាំ

អនុជំពូកនេះផ្អែកលើការវិភាគសំណាកចំនួនតូចដែលមានជនរងគ្រោះចំនួនប្រាំមួយនាក់នៅទីតាំងភូមិសាស្ត្រចំនួនពីនៅកម្ពុជា។ ក្នុងចំណោមកុមារទាំងប្រាំមួយនាក់ដែលត្រូវបានសម្ភាស ករណីចំនួនមួយពាក់ព័ន្ធនឹងការលួងលោមតាមប្រព័ន្ធអនឡាញ ប៉ុន្តែមិនបានបន្តលើសពីការស៊ើបអង្កេបថមរបស់នគរបាលឡើយ ដោយសាររកជនសង្ស័យមិនឃើញ។ ក្នុងចំណោមករណីដទៃទៀត ការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធនឹងការផលិតសម្ភាររំលោភបំពានផ្លូវភេទកុមារ។ នៅក្នុងករណីមួយ ការចោទប្រកាន់បន្ថែមត្រូវបានធ្វើឡើងនៅក្រោមមាត្រា ២៣២ "ការគំរាមកំហែងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ" នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងករណីមួយចំនួន កុមារពណ៌នាអំពីរបៀបដែលជំនួបដំបូងរបស់ពួកគេជាមួយនគរបាលត្រូវកំណត់ថាជាការរំលោភលើឯកជនភាព និងការរក្សាការសម្ងាត់។ កុមារបានពណ៌នាថា នគរបាលបានទៅជួបជាមួយពួកគេនៅក្នុងសហគមន៍របស់ពួកគេ និងសាកសួរជាសាធារណៈដោយមានការពិចារណាតិចតួចលើការគោរពជាមូលដ្ឋានទៅលើសេចក្តីថ្លៃថ្នូររបស់កុមារ និងគ្រួសាររបស់ពួកគេ។

នៅក្នុងករណីមួយផ្សេងទៀត (ដែលយុវជនបានជឿជាក់ថា ការរំលោភបំពាននេះត្រូវបានរាយការណ៍ពីដំបូងទៅកាន់អាជ្ញាធរដោយឪពុក ឬម្តាយរបស់កុមារម្នាក់ផ្សេងទៀត) នគរបាលបានមកដល់ផ្ទះរបស់នាងដើម្បីជូនដំណឹងដល់ឪពុកម្តាយរបស់នាងអំពីបណ្តឹងនោះ និងនាំពួកគេទៅកាន់ស្ថានីយ៍នគរបាល ដើម្បីសាកសួរ។ មតិយោបល់របស់ពួកគេពណ៌នាអំពីថាតើបទពិសោធន៍នេះសម្រាប់ទាំងកុមារ និងឪពុកម្តាយមានការលំបាកប៉ុនណា និងតើចំណាត់ការដោយគ្មានការលាក់បាំងរបស់មន្ត្រីអនុវត្តច្បាប់មានន័យថា សហគមន៍ទាំងមូលរបស់ពួកគេដឹងព័ត៌មាន ដែលគប្បីរក្សាទុកជាលក្ខណៈឯកជន និងរក្សាការសម្ងាត់ដោយរបៀបណា។ កុមារម្នាក់ក្នុងចំណោមកុមារទាំងនេះបានចែកចាយការចងចាំរបស់ពួកគេថា៖

*នគរបាលបានមកជាមួយនឹងកុមារ ដែលត្រូវបានថតរូបជាមួយនឹងខ្ញុំ នគរបាលបាននាំពួកគេមកផ្ទះរបស់ខ្ញុំ...។ អ្នកភូមិទាំងមូលបានអើតមើលក្នុងឡាន ដើម្បីឃើញមុខកុមារទាំងអស់ ដែលត្រូវបានគេថតរូប...។ ពួកគេមកជាមួយកុមារ ដែលនាំពួកគេមកផ្ទះរបស់ខ្ញុំ និងដែលបានដាក់ពាក្យបណ្តឹងលើគាត់...។ បន្ទាប់ពីនោះ មិត្តភក្តិរបស់ខ្ញុំបានហៅខ្ញុំឱ្យដាក់ពាក្យបណ្តឹងលើគាត់ [ជនល្មើស] និងបានប្រាប់ឱ្យខ្ញុំចូលក្នុងឡានជាមួយពួកគេ។ ឡាននោះបាននាំខ្ញុំ និងមិត្តភក្តិមួយចំនួនរបស់ខ្ញុំទៅកាន់ទីនោះក្នុងសភាពណែនពេញឡាញ យើងទាំងអស់គ្នាបានទៅដល់ទីនោះ...។ នៅពេលយើងចូលក្នុងឡាន ភូមិទាំងមូលបានប្រែក្លាយទៅជារញ៉េរញ៉ៃ ដោយមានការស្រែកខ្លាំងៗថា "ប្តឹងគាត់ទៅ ប្តឹងគាត់ទៅ" នៅប៉ុស្តិ៍នគរបាល...។ ឪពុករបស់ខ្ញុំបានលឺពាក្យពេជន៍ទាំងអស់នេះ ហើយគាត់មិនយល់ឡើយ។ បន្ទាប់មក ពួកគេរុញខ្ញុំបញ្ចូលក្នុងឡាន ហើយនៅពេលឪពុករបស់ខ្ញុំឃើញបែបនោះ គាត់ចូលក្នុងឡាន និងមកជាមួយនឹងខ្ញុំ។* (RA៤-CA-០៧-A).

កុមារផ្តល់យោបល់ថា នគរបាល (ព្រមទាំងមេធាវី និងចៅក្រម) បាននិយាយជាមួយពួកគេក្នុងលក្ខណៈ ដែលអាចត្រូវពណ៌នាថា "គម្រោះគម្រើយ និងខឹង" ឬ *"មិនពិរោះស្តាប់"* ដោយកុមារនិយាយថា៖ *"នៅពេលខ្លះ នគរបាលមួយចំនួនខឹង ពួកគេអះអាងថា បេះដូងរបស់ពួកគេមិនងាយស្រួលទេ ហើយមុខរបស់ពួកគេខឹង។ ហេតុនេះ វាពិបាក។"* (RA៤-CA-២-A-Child)

### ដំណើរការសម្ភាស

ដូចការរៀបរាប់ខាងលើបុគ្គលិកសង្គមមួយចំនួនដែលត្រូវបានសម្ភាសបានរៀបរាប់ថាពួកគេបានកត់សម្គាល់នូវភាពប្រសើរឡើងនៅក្នុងដំណើរការសម្ភាសក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ បើទោះបីជានេះជាសញ្ញាវិជ្ជមានក្តី ការសម្ភាសជាមួយកុមារដែលបានឆ្លងកាត់ប្រព័ន្ធយុត្តិធម៌មិនតែងតែនិយាយបន្ទរទស្សនៈនេះឡើយ។

នៅក្នុងស្ថានភាពជាច្រើន ការសម្ភាសដំបូងជាមួយកុមារ និងឪពុកម្តាយបានកើតឡើងនៅក្នុង "ការិយាល័យបើកចំហរ" ជាមួយនឹងមន្ត្រី និងមនុស្សដទៃទៀតនៅជុំវិញ ដែលជាការពិបាកខ្លាំងណាស់ ហើយឪពុក ឬម្តាយម្នាក់បានពន្យល់ថា៖ *"ខ្ញុំចង់បានថា បន្ទប់ដែលត្រូវប្រើប្រាស់សម្រាប់ការសម្ភាស គប្បីមានតែមនុស្ស សម្រាប់ការសម្ភាសប៉ុណ្ណោះ... ដោយគ្រាន់តែមានអ្នកសម្ភាសម្នាក់ នោះគឺគ្រប់គ្រាន់ហើយ។ កុំធ្វើដូចពួកគេធ្វើជាមួយយើង មានមនុស្សជាច្រើននៅទីនោះ មានច្រើននាក់ មិនតិចទេ។"* (RA៤-CA-៤-A-Parent)

កុមារម្នាក់បានពន្យល់អំពី របៀបដែលគាត់មានភាពភ័យខ្លាច និងមានអារម្មណ៍ខ្លាចនគរបាល និងព្រួយបារម្ភចំពោះចម្លើយរបស់ពួកគេ៖ *"នៅពេលខ្ញុំនិយាយ ខ្ញុំខ្លាចថា ពួកគេមួយចំនួននឹងគិតអំពីវា និងសើច និងធ្វើឱ្យខ្ញុំអាម៉ាស មើលងាយខ្ញុំ និងរើសអើសខ្ញុំ... ខ្ញុំភ័យខ្លាច... ខ្ញុំបានគិតអំពី ម៉ឿបាយ នៅពេលពួកគេបានសួរ ខ្ញុំបានឆ្លើយ ពួកគេបានស្រែក ហើយបន្ទាប់មក ពាក្យរបស់ខ្ញុំនឹងមិនចេញមកឡើយ វានឹងបិទ ហើយខ្ញុំមិនដឹងអំពីអ្វី ដែលត្រូវធ្វើឡើយ។"* (RA៤-CA-៣-A-Child)

នៅពេលក្រោយ គាត់បានពណ៌នាអំពី របៀបដែលមន្ត្រីនគរបាលពីរនាក់ផ្សេងទៀតក៏មានវត្តមាននៅក្នុងបន្ទប់នោះដែរ ប៉ុន្តែមិនមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងការសម្ភាសនេះឡើយ ពួកគេបានស្តាប់ និងសើចចំអកចំពោះគាត់ នៅពេលគាត់ឆ្លើយសំណួរ។ គាត់បាននិយាយថា គាត់ *"នឹង [ចង់] ឱ្យបញ្ឈប់ការសើច និងការរើសអើង"* (RA៤-CA-៣-A-Child)

## ៣.២ ការឆ្លើយតបរបស់ទីភ្នាក់ងារអនុវត្តច្បាប់

ឪពុក ឬម្ដាយម្នាក់បានគូសបញ្ជាក់នូវសេចក្ដីត្រូវការយល់ចិត្ត ការប្ដេជ្ញាចិត្ត និងសមត្ថភាពក្នុងការឆាប់យល់អំពីតម្រូវការរបស់អ្នកដទៃ និងបានផ្ដល់អនុសាសន៍ថា អ្នកទាំងឡាយនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌគប្បី "យកចិត្តទុកដាក់ចំពោះការប្រព្រឹត្តលើកុមារដូចជាកូនរបស់ពួកគេដែរ ដែលហាក់ដូចជាជនរងគ្រោះជាកូនរបស់ពួកគេផ្ទាល់ ហេតុនេះ ត្រូវរកភាពយុត្តិធម៌ឱ្យពួកគេយ៉ាងឆាប់រហ័ស។ នៅពេលដែលពួកគេគិតថាជនរងគ្រោះថាជាមនុស្សចាស់ នោះពួកគេអាចមិនព្រួយបារម្ភពីជនរងគ្រោះឡើយ។" (RA៤-CA-៩-A-Parent)

កុមារដទៃទៀតបានពន្យល់អំពី អារម្មណ៍អាម៉ាស ខ្មាសអៀន ភ័យខ្លាចចំពោះផលវិបាក។ ពួកគេបាននិយាយអំពី កង្វះជម្រើស ដែលពួកគេគិតថាពួកគេមាន នៅក្នុងការចូលរួមនៅក្នុងដំណើរការនេះ និងបាននិយាយពាក់ព័ន្ធនឹងភេទរបស់មន្ត្រីនគរបាលដែលធ្វើការសម្ភាសផងដែរ។ កុមារម្នាក់បានកត់សម្គាល់ថា៖ "ខ្ញុំចង់បានស្ត្រីជាង ការនិយាយជាមួយស្ត្រីនឹងមិនធ្វើឱ្យខ្ញុំអាម៉ាសឡើយ។" (RA៤-CA-០៤-A-Child) ម្ដាយរបស់នាងបានបញ្ជាក់ចំណុចនេះ ដោយថ្លែងថា៖ "ខ្ញុំចងចាំអំពី ការមានអារម្មណ៍ភ័យខ្លាចថា កូនស្រីរបស់រងភាពអាម៉ាស ដោយសារជាទូទៅ ជាមួយនឹងរឿងរ៉ាវបែបនោះ ការនិយាយជាមួយបុរស អ្នកពិតជាមានភាពខ្មាសអៀនដោយស្វ័យប្រវត្តិ។" (RA៤-CA-០៤-A-Parent) កុមារីម្នាក់ទៀតបានពន្យល់ថា៖ "ការជួបជាមួយមន្ត្រីនគរបាលជាបុរសធ្វើឱ្យខ្ញុំពិបាកនិយាយ។ ពួកគេគឺជាបុរស ខ្ញុំជាស្រី ហើយជាមួយនឹងរឿងនោះ វាពិតជាពិបាកក្នុងការនិយាយប្រាប់ពួកគេអំពីរឿងរ៉ាវនានា និងឆ្លើយសំណួរ។ ប៉ុន្តែទោះបីជាពិបាកក្ដី ខ្ញុំត្រូវហ៊ាននិយាយ ដើម្បីឱ្យខ្ញុំអាចទទួលបានភាពយុត្តិធម៌ សម្រាប់ខ្លួនខ្ញុំ។" (RA៤-CA-៩-A-Child)

មានការចែកចាយអំពី ឧទាហរណ៍នៃបទពិសោធន៍វិជ្ជមាននានា។ យុវតីម្នាក់បានពណ៌នាអំពី របៀបដែលឪពុករបស់នាងបានធ្វើពាក្យបណ្ដឹងដំបូងនិងបានអមដំណើរនាងនៅទូទាំងដំណើរការសម្ភាស និងប្រមូលភស្តុតាង។ យុវតីនេះបានថ្លែងថា៖ "[...] ខ្ញុំមានអារម្មណ៍ថា ខ្ញុំចង់ឱ្យគាត់នៅទីនោះ [ឪពុករបស់នាង] និងនៅពេលមិននៅម្នាក់ឯង ខ្ញុំមិនភ័យខ្លាចឡើយ។" (RA៤-CA-៩-A-Child) ការគាំទ្រយ៉ាងជិតដិតនេះ គឺជាផ្នែកយ៉ាងសំខាន់នៃបទពិសោធន៍របស់នាង ហើយក៏ជាឱកាស ដើម្បីជួបជាមួយមន្ត្រីនគរបាលនៅក្នុងបន្ទប់ស្ងាត់ និងឯកជនផងដែរ (សូមមើលសាច់រឿងរបស់ស្រីលីននៅទំព័រ ៩៥)

### ភាពពាក់ព័ន្ធនៃប្រតិបត្តិការសង្គ្រោះ*

មានប្រវត្តិនៃការប្រើប្រាស់ការថែទាំកុមារតាមមណ្ឌល សម្រាប់បញ្ហាកិច្ចការពារជាច្រើននៅកម្ពុជា។ អភិក្រមនេះទទួលបានការគាំទ្រពីរដ្ឋាភិបាល ហើយអង្គការមិនមែនរដ្ឋាភិបាលជាច្រើនផ្ដល់សេវាបែបនេះ រួមទាំង ដើម្បី "សង្គ្រោះ និងស្ដារនីតិសម្បទា" កុមារពីអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងការរំលោភបំពាន។

ភស្តុតាងដែលមិនផ្អែកលើការពិត បង្ហាញឱ្យឃើញថា ការរំលោភបំពាន និងការកេងប្រវ័ញ្ចនៅតែជាមូលហេតុទូទៅមួយ សម្រាប់ការទុកដាក់កុមារនៅក្នុងមណ្ឌលថែទាំកុមារ និងថា កិច្ចខិតខំប្រឹងប្រែងតិចតួចត្រូវបានធ្វើឡើង ដើម្បីសមាហរណកម្មកុមារ និងដើម្បីបង្រួបបង្រួមគ្រួសារ រួមទាំងក្នុងករណីដែលសមាជិកគ្រួសារមិនពាក់ព័ន្ធដោយផ្ទាល់នៅក្នុងការរំលោភបំពានរបស់ពួកគេ។ ការស្រាវជ្រាវ ដែលត្រូវបានធ្វើឡើងនៅឆ្នាំ២០១៧ បង្ហាញថា កុមារចំនួនយ៉ាងច្រើនរស់នៅក្នុងមណ្ឌលថែទាំកុមារនៅកម្ពុជា។ បន្ថែមលើនេះ មណ្ឌលចំនួនជិតមួយភាគបី ដែលកុមាររស់នៅ មិនមានអនុស្សារណៈនៃការយោគយល់ជាមួយអាជ្ញាធររាជរដ្ឋាភិបាលពាក់ព័ន្ធក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឡើយ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំមុន ការយល់ដឹងអំពីគ្រោះថ្នាក់សក្ដានុពល និងសេចក្ដីត្រូវការការជៀសវាងការទុកដាក់កុមារក្នុងមណ្ឌលនៅពេលអាចធ្វើបាន បានកើនឡើង រួមជាមួយនឹងការប្ដេជ្ញាចិត្តកាន់តែខ្លាំងចំពោះការថែទាំកុមារនៅតាមសហគមន៍ និងគ្រួសារ កំណើនការទុកដាក់កុមារក្នុងការថែទាំដោយឪពុកម្ដាយធម៌ និងការវិនិយោគកាន់ច្រើនលើគំនិតផ្ដួចផ្ដើមការពង្រឹងគ្រួសារ។ គំនិតផ្ដួចផ្ដើមទាំងនេះពាក់ព័ន្ធនឹងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល និងកំពុងរួមចំណែកចំពោះការផ្លាស់ប្ដូរនៅក្នុង "វប្បធម៌នៃការថែទាំ" សម្រាប់កុមារទាំងអស់។ ការផ្លាស់ប្ដូរនេះត្រូវបានបង្ហាញយ៉ាងច្បាស់ដោយគំនិតផ្ដួចផ្ដើមនៃគម្រោងការថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង ក្រោមការដឹកនាំរបស់ក្រសួងសង្គមកិច្ច

---

* អនុក្រឹត្យលេខ ១១៩ ស្ដីពី 'ការគ្រប់គ្រងការថែទាំនៅក្នុងមណ្ឌល' កំណត់ថា កុមារមួយចំនួនអាចនឹងត្រូវការមើលថែទាំនៅក្នុងបរិក្ខារមណ្ឌល។ ស្ថានភាពដែលទទួលយកបានដូចពិពណ៌នានៅក្នុងមាត្រា ១១ ទាំងនេះ រួមមានកុមារកំព្រា ឬកុមារដែលមិនមានគ្រួសាររស់នៅជាមួយ ឬត្រូវបានបំបែកចេញពីពួកគេដោយហេតុផលផ្សេងៗ រួមទាំងការធ្វើចំណាកស្រុក និងការជាប់ពន្ធនាគារ និងកុមារដែលនៅរស់រានមានជីវិតពីការជួញដូរមនុស្ស អំពើហិង្សា ឬការរំលោភបំពាន ឬការកេងប្រវ័ញ្ចផ្លូវភេទ ក្នុងចំណោមបញ្ហាដទៃទៀត។ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៥) ។
* ទំនាក់ទំនងផ្ទាល់ខ្លួនជាមួយទីប្រឹក្សាបច្ចេកទេសនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ខែធ្នូ ២០២០)។

## ៣.២ ការឆ្លើយតបរបស់ទីភ្នាក់ងារអនុវត្តច្បាប់

អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលបច្ចុប្បន្នមានសកម្មភាព នៅក្នុងប្រាំរាជធានីខេត្ត។

បើទោះបីជាមានជំហានវិជ្ជមាន ដើម្បីជៀសវាងការទុកដាក់កុមារ នៅក្នុងមណ្ឌលថែទាំកុមារ នៅពេលដែលអាចមានតម្រូវការ ស្វែងរកការថែទាំជំនួសក្តី ការសម្ភាសជាមួយកុមារជាផ្នែកនៃ គម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* បង្ហាញថា ការយកកុមារឱ្យ ស្ថិតក្រោមការថែទាំជំនួស សូម្បីតែជាបណ្ដោះអាសន្នក្តី នៅតែ ជាការអនុវត្តមួយ ដែលកើតឡើង។ ចំណុចនេះត្រូវបានបង្ហាញ នៅក្នុងករណីមួយពាក់ព័ន្ធនឹងជនរងគ្រោះ OCSEA មួយចំនួន ដែលកុមារត្រូវបានទុកដាក់នៅក្នុងមណ្ឌលជម្រករយៈពេល ប៉ុន្មានថ្ងៃ ដោយគ្មានឱកាសធ្វើការជ្រើសរើស និងចូលរួមនៅក្នុង ដំណើរការធ្វើសេចក្តីសម្រេចចិត្តឡើយ៖

"ដោយសារគ្មាននរណាម្នាក់សួរសោះ យើងមិនសប្បាយចិត្ត ទាល់តែសោះ យើងទាំងអស់គ្នាបានយំរួមគ្នា។ យើងនឹកផ្ទះ។" (RA៤-CA-៧A)។ កង្វះជម្រើស សម្រាប់កុមាររងគ្រោះ ដែល ជាប់ពាក់ព័ន្ធយ៉ាងជាក់លាក់ជាមួយនឹងការទុកដាក់ពួកគេ នៅក្នុងមណ្ឌលថែទាំកុមារ មានលក្ខណៈគួរឱ្យកត់សម្គាល់។

# ៣.៣ ការទទួលបានយុត្តិធម៌ និងការទទួលបានឧបាស្រ័យ

### ៣.៣.១ ដំណើរការតុលាការ

#### តុលាការកុមារមេត្រី

នៅឆ្នាំ២០១៨ ក្រសួងយុត្តិធម៌បានចេញប្រកាសមួយស្តីពី ការប្រើប្រាស់វាំងនៅតុលាការ និងបន្ទប់តុលាការដែលមានការភ្ជាប់ទូរទស្សន៍ សម្រាប់ការផ្តល់សក្ខីកម្មពីកុមាររងគ្រោះ/ជនរងគ្រោះដែលងាយរងគ្រោះ ឬសាក្សីនានា។ គោលបំណងនៃប្រកាសនេះ គឺដើម្បីផ្តល់បរិយាកាសុវត្ថិភាព និងប្រកបដោយការគាំទ្រ ដែលកុមារចែកចាយព័ត៌មានពាក់ព័ន្ធនឹងបទពិសោធន៍របស់ពួកគេ ដោយអនុលោមទៅតាមកម្រិតនៃការអភិវឌ្ឍរបស់ពួកគេ ដែលកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្ត និងការគំរាមកំហែងចំពោះសុវត្ថិភាពរបស់ពួកគេ។ ប្រកាសនេះកំណត់អំពីវាំងនៅតុលាការថា ជាវិធានការការពារបឋមនៅក្នុងគ្រប់ករណីដែលពាក់ព័ន្ធនឹងកុមារ និងការផ្តល់សក្ខីកម្មតាមទូរទស្សន៍ក្នុងករណី ដែលត្រូវការកិច្ចការពារពិសេស។ យោងតាមលិខិតបទដ្ឋានគតិយុត្តិនេះ សក្ខីកម្មរបស់កុមារគប្បីត្រូវផ្តល់តាមរយៈកាំរ៉េ កុមារអាចត្រូវអមដោយបុគ្គលផ្តល់ការគាំទ្រ ដែលតុលាការអនុញ្ញាត ហើយតុលាការត្រូវធានាថា មានបរិយាកាសប្រកបដោយផាសុកភាពសម្រាប់កុមារ ។

ទោះបីជាយ៉ាងណាក្តី វិធានការផ្លូវច្បាប់ដែលត្រូវផ្តល់នៅក្រោមប្រកាសនេះមិនត្រូវបានអនុវត្តជាស្វ័យប្រវត្តិឡើយ ប៉ុន្តែដោយផ្អែកលើការអនុវត្តដែលត្រូវបានណែនាំដោយព្រះរាជអាជ្ញា ឬមេធាវីតំណាងឱ្យកុមារ នៅពេលចាប់ផ្តើមការជំនុំជម្រះ។ ចេញពីការសម្ភាសជាមួយអ្នកវិជ្ជាជីវៈយុត្តិធម៌ព្រហ្មទណ្ឌ មានការលើកឡើងថា នៅពេលការអនុវត្តវិធានការការពារត្រូវបានធ្វើឡើង ជាទូទៅ វិធានការទាំងនេះត្រូវបានរៀបចំឡើងចំពោះកុមាររងគ្រោះ។ អ្នកឯកទេសផ្នែកកិច្ចការពារកុមារជាមួយនឹង APLE បានពន្យល់ថា៖

មេធាវីរបស់យើងតែងតែស្នើសុំមន្ត្រីតុលាការឱ្យប្រើប្រាស់វាំងសម្រាប់ការពារឯកជនភាព ឬប្រើប្រាស់ការសម្ភាសតាមតំណភ្ជាប់ទូរទស្សន៍ ជាពិសេសនៅក្នុងអំឡុងពេលនៃសវនាការជំនុំជម្រះក្តី ដើម្បីធានាថាកុមារមិនរងការប៉ះទង្គិចផ្លូវចិត្ត តាមរយៈការចូលរួមនៅក្នុងការជំនុំជម្រះក្តី និងបន្ទប់តុលាការដូចគ្នាជាមួយនឹងជនល្មើសឡើយ។ បញ្ហានេះត្រូវបានអនុវត្តពិតជាយ៉ាងល្អនៅក្នុងតុលាការមួយចំនួន ដែលយើងបាន និងកំពុងធ្វើការងារជាមួយ។ ប៉ុន្តែការរៀបចំបែបនោះបានកើតឡើងភាគច្រើននៅក្នុងករណីដែលយើងបានទាមទារ [តាមរយៈព្រះរាជអាជ្ញា ឬមេធាវីដែលតំណាងឱ្យកុមាររងគ្រោះ] ប៉ុណ្ណោះ។ (RA៤-CA-០១-A-justice)

ផ្ទុយទៅវិញ ក៏មានការបង្ហាញពីអ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌផងដែរថា ជនរងគ្រោះជាច្រើន និងគ្រួសាររបស់ពួកគេមិនដឹងអំពីវិធានការការពារទាំងនេះ និងមិនប្រើប្រាស់វិធានការទាំងនោះឡើយ។ (RA៤-CA-០២-A&B).

អ្នកឯកទេសផ្នែកកិច្ចការពារកុមារមកពី APLE ក៏បានកត់សម្គាល់ថា មិនមែនគ្រប់តុលាការទាំងអស់សុទ្ធតែពិតជាមានវាំងសម្រាប់ឯកជនភាពឡើយ។ (RA៤-CA-០១-A-justice)

អ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ម្នាក់ទៀតបានកត់សម្គាល់ថា កុមាររងគ្រោះរមែងតែងរងការប៉ះទង្គិចផ្លូវចិត្ត ប្រសិនបើ ពួកគេមើលឃើញជនល្មើសនៅក្នុងបន្ទប់តុលាការ ជាពិសេស ប្រសិនបើ ជនល្មើស គឺជាសមាជិកម្នាក់របស់គ្រួសារ។ (RA៤-CA-០៤-A&B-justice) ជាការឆ្លើយតបចំពោះស្ថានភាពនេះ អ្នកឆ្លើយតបម្នាក់ដែលជាព្រះរាជអាជ្ញាបានពន្យល់ថា៖ "រហូតមកដល់ពេលនេះ តុលាការបានប្រើប្រាស់វាំងនន ដើម្បីបង្ការមិនឱ្យជនល្មើស និងជនរងគ្រោះពីការមើលឃើញទៅវិញទៅមក។" (RA៤-CA-១០-A-justice)

វិធានការកុមារមេត្រីមួយ ដែលត្រូវបានទទួលស្គាល់យ៉ាងមានសង្គតភាពដោយកុមាររងគ្រោះ និងអ្នកថែទាំ គឺវត្តមានរបស់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល (មេធាវី បុគ្គលិកសង្គម អ្នកផ្តល់ប្រឹក្សា។ល។) នៅទូទាំងដំណាក់កាលនីមួយៗនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ ពួកគេបានបញ្ជាក់ថា បុគ្គលិកផ្តល់ការគាំទ្រផ្លូវចិត្ត និងការគាំទ្រជាក់ស្តែង (ឧទាហរណ៍ ជាមួយនឹងការដឹកជញ្ជូនទៅចូលរួមនៅតុលាការ) រួមទាំងការត្រៀមលក្ខណៈកុមារ និងឪពុកម្តាយសម្រាប់ការចូលរួមនៅក្នុងអង្គជំនុំជម្រះតុលាការ និងការដំណើរការលិខិតស្នាមដែលចាំបាច់ ដើម្បីជួយពួកគេដាក់ពាក្យបណ្តឹងទាមទារសំណង។ កុមារម្នាក់បានថ្លែងថា៖ ពួកគេបានពន្យល់យ៉ាងច្បាស់ ពិតជាផ្តល់ការលើកទឹកចិត្តដល់ខ្ញុំឱ្យមានភាពក្លាហានក្នុងការនិយាយ... ហើយខ្ញុំមានទំនុកចិត្តក្នុងការនិយាយ។ ពួកគេបានប្រាប់ខ្ញុំថា សាច់រឿងអ្វីក៏ដោយ ដែលពួកគេសួរខ្ញុំឱ្យពន្យល់ ដូចជា សាច់រឿងនៃការរំលោភសេពសន្ថវៈ ខ្ញុំត្រូវតែនិយាយអំពី អ្វីដែលពិតជាបានកើតឡើង។ ហើយខ្ញុំអាចមានភាពក្លាហាន ដោយសារពួកគេនៅក្រោយខ្ញុំ។ (RA៤-CA-២-A-Child)។

មន្ត្រីម្នាក់មកពីប្រព័ន្ធយុត្តិធម៌បានពន្យល់ថា៖ នៅពេលបច្ចុប្បន្ន គ្មានចៅក្រមឯកទេស ដើម្បីដោះស្រាយដោយផ្ទាល់ជាមួយករណីដែល

* ប្រកាសគឺជាសេចក្តីសម្រេចរបស់ក្រសួង ឬអន្តរក្រសួងដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីពាក់ព័ន្ធ។ សេចក្តីប្រកាសត្រូវតែអនុលោមតាមរដ្ឋធម្មនុញ្ញ និងច្បាប់ ឬអនុក្រឹត្យដែលយោង។ ទំនាក់ទំនងផ្ទាល់ខ្លួនជាមួយទីប្រឹក្សាបច្ចេកទេសនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ខែធ្នូ ២០២០)។

ពាក់ព័ន្ធនឹងកុមារឡើយ។ ចៅក្រមអាចជាចៅក្រមណាម្នាក់ ដែលធ្លាប់បានជំនុំជម្រះករណីប្លន់។ ចៅក្រមទាំងនោះក៏អាចទទួលបន្ទុកលើកុមារផងដែរ។ ហេតុនេះ នៅពេលខ្លះ បញ្ហានេះគឺជាអ្វីម្យ៉ាងដែលពិបាកសម្រាប់កុមារ ដែលត្រូវឆ្លងកាត់ប្រព័ន្ធយុត្តិធម៌ផ្លូវច្បាប់។ (RA៤-CA-០១-A)

## ការប៉ះទង្គិចសារជាថ្មី

ក្នុងអំឡុងពេលនៃការជំនុំជម្រះរបស់តុលាការ កុមាររងគ្រោះក៏ត្រូវឆ្លើយតបសំណួរពីអ្នកប្រកបវិជ្ជាជីវៈខុសៗគ្នាផងដែរ នៅពេលកំពុងផ្តល់សក្ខីកម្មរបស់ពួកគេ ព្រមទាំងនៅក្នុងការសួរសាក្សីរបស់ភាគីបដិបក្ខ។ អ្នកឯកទេសផ្នែកកិច្ចការពារកុមារមកពីអង្គការ APLE បានកត់សម្គាល់ថា "សំណួរនានាត្រូវបានសួរដោយភាគីខុសៗគ្នានៅក្នុងបន្ទប់សវនាការ ដោយព្រះរាជអាជ្ញា ចៅក្រម និងជាពិសេស ដោយមេធាវីការពារចុងចោទ។ " អ្នកឆ្លើយតបបានបន្តពន្យល់ថា មេធាវីការពារចុងចោទ៖ [...] សួរសំណួរពិបាកៗ ដែលពួកគេអាចសួរបាន ដើម្បីឱ្យមានការទម្លាក់ការចោទប្រកាន់ ឬដើម្បីធ្វើឱ្យអតិថិជនរបស់ពួកគេទទួលទណ្ឌកម្មកាន់តែតិច...។ កុមាររងការប៉ះទង្គិចខ្លាំងណាស់នៅពេលឆ្លើយសំណួរប្រភេទនោះពីមេធាវីការពារចុងចោទ។ (RA៤-CA-០១-A-justice)

## រយៈពេលនៃដំណើរការ និងការជំនុំជម្រះក្តី

អ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌនានាបានបង្ហាញថា ជាទូទៅដំណើរការតុលាការយឺត។ អ្នកឆ្លើយតបម្នាក់ក្នុងចំណោមអ្នកឆ្លើយតបនានាបានពន្យល់ថា៖ ដំណើរការទាំងនេះអាចចំណាយពេលជាច្រើនឆ្នាំ។ ហើយបើទោះបីជាយើងបានមើលឃើញការកែលម្អចំពោះល្បឿននៃដំណើរការជំនុំជម្រះក្តីក្តី ដំណើរការនេះអាចនៅតែត្រូវការការកែលម្អជាច្រើនទៀត។ រយៈពេលដ៏វែងនេះដាក់សម្ពាធបន្ថែមលើកុមារ ដែលត្រូវពាក់ព័ន្ធនឹងដំណើរការនេះរយៈជាច្រើនឆ្នាំ។ (RA៤-CA-០២-A&B-justice)

### ការដោះស្រាយក្រៅផ្លូវការនៅក្រៅប្រព័ន្ធតុលាការ

យោងតាមការស្រាវជ្រាវពីមុនមក ឧបសគ្គសំខាន់មួយក្នុងការទទួលបានភាពយុត្តិធម៌សម្រាប់ជនរងគ្រោះ OCSEA គឺការដោះស្រាយក្រៅផ្លូវការ នៅក្រៅប្រព័ន្ធតុលាការ ដែលជាការអនុវត្តជាទូទៅនៅកម្ពុជា។

ការសម្ភាស ដែលត្រូវធ្វើដោយគម្រោងស៊ើពីការបញ្ឈប់គ្រោះថ្នាក់ បានបញ្ជាក់ថា វប្បធម៌នៃការដោះស្រាយក្រៅប្រព័ន្ធតុលាការនៅតែមានច្រើននៅក្នុងប្រទេសនេះ។ អ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌម្នាក់បានចែកចាយថា៖ គុណតម្លៃនៃសេចក្តីថ្លៃថ្នូរពាក់ព័ន្ធនឹងផ្លូវភេទត្រូវបានចាត់ទុកយ៉ាងខ្ពស់ថាត្រូវទទួលបានការគោរព និងការសរសើរ ហេតុនេះ គ្រួសារជាច្រើននឹងចង់រក្សាការរំលោភបំពានជារឿងឯកជន និងរក្សាភាពស្ងៀមស្ងាត់ជាជាងការឆ្លងកាត់ប្រព័ន្ធតុលាការសាធារណៈ។ ហេតុនេះ ការធ្វើបែបនោះច្រើនផ្តល់លទ្ធផលជាការរៀបអាពាហ៍ពិពាហ៍ជាមួយជនល្មើស ឬការដោះស្រាយនៅក្រៅប្រព័ន្ធតុលាការ។ (RA៤-CA-០២-A&B-justice)

អ្នកឆ្លើយតបរូបនេះក៏បានបន្ថែមថា៖ "មន្ត្រីនគរបាល និងមន្ត្រីតុលាការមួយចំនួនទទួលផលប្រយោជន៍ពីការព្រមព្រៀងទាំងនេះ។ ពួកគេទទួលបានប្រយោជន៍ផ្ទាល់ខ្លួនជាមួយគំនិតនៃការធ្វើឱ្យមានភាពយុត្តិធម៌ ដែលត្រូវបានពង្រឹងបន្ថែមដោយការយល់ឃើញជាវប្បធម៌ចំពោះករណីបែបនេះ។" (RA៤-CA-០២-A&B-justice)។

អ្នកឯកទេសផ្នែកទទួលករណីមកពី Hagar បានបន្ថែមការពន្យល់មួយទៀតចំពោះការអនុវត្តនេះ ដោយថ្លែងថា៖ "នៅកម្ពុជា គ្រួសារដែលមានការអប់រំទាប មិនចង់ទៅកាន់តុលាការឡើយ។ ហេតុនេះ នៅពេលការរំលោភបំពានកើតឡើង អ្នករំលោភបំពាន និងគ្រួសារនឹងព្យាយាមដោះស្រាយ និងជៀសវាងការទៅកាន់តុលាការ។" (RA៤-CA-០៨-A-justice)។

នៅពេលធ្វើការដោះស្រាយក្រៅផ្លូវការហើយ និងនៅពេលករណីត្រូវបានរាយការណ៍ជូនដល់ប្រព័ន្ធយុត្តិធម៌ផ្លូវការរួចហើយ អ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌម្នាក់បានពន្យល់ថា កុមាររងគ្រោះតែងតែងទំនាក់ទំនងអង្គការសង្គមស៊ីវិល ដើម្បីស្នើសុំជំនួយនៅក្នុងការដកករណីវិញ ដោយសារពួកគេភ័យខ្លាចចំពោះការទៅកាន់ប៉ុស្តិ៍នគរបាល បន្ទាប់ពីទទួលបានលុយកាក់។ (RA៤-CA-០២-A&B-justice)

## ៣.៣ ការទទួលបានយុត្តិធម៌ និងការទទួលបានឧបាស្រ័យ

### ជំនួយផ្នែកច្បាប់

ព្រះរាជអាជ្ញារងម្នាក់នៅតុលាការរាជធានីភ្នំពេញបានបង្ហាញថា ការមានតំណាងផ្លូវច្បាប់សម្រាប់កុមាររងគ្រោះនៃ OCSEA មិនមែនជាលក្ខខណ្ឌចាំបាច់នៅក្រោមច្បាប់ឡើយ។ (RA៤-CA-១០-A-justice)។ ចៅក្រមម្នាក់មកពីសាលាដំបូងរាជធានីភ្នំពេញបានពន្យល់ថា៖ "យោងតាមច្បាប់ កុមាររងគ្រោះមិនត្រូវបាន

ផ្តល់មេធាវីឡើយ ពួកគេមានបុគ្គលិកសង្គម ឪពុក ឬម្តាយ/អ្នកថែទាំដែលអាចតំណាងឱ្យពួកគេបាន។" (RA៤-CA-០៩-A-justice)

ទោះបីជាយ៉ាងណាក្តី អ្នកប្រកបវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌនានាពិតជាបានបង្ហាញថា កុមារមកពីគ្រួសារក្រីក្រមានលទ្ធភាពទទួលបានការគាំទ្រផ្នែកច្បាប់ពីនាយកដ្ឋានជំនួយផ្នែកច្បាប់នៃគណៈមេធាវីកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលជាក់លាក់។ អ្នកឯកទេសផ្នែកទទួលករណីមកពី Hagar កម្ពុជាបានថ្លែងថា ជំនួយផ្នែកច្បាប់ភាគច្រើនបានមកពីអង្គការមិនមែនរដ្ឋាភិបាល រួមទាំងអង្គការសកម្មភាពដើម្បីកុមារ (APLE) ដែលផ្តល់ការពិគ្រោះយោបល់ និងការតំណាងផ្លូវច្បាប់ដោយមិនគិតកំរៃដល់កុមាររងគ្រោះ កុមារងាយរងគ្រោះ សាក្សី និងសមាជិកគ្រួសារ (RA៤-CA-០៨-A-justice) អង្គការ Terre des Hommes ប្រទេសហូឡង់ ដែលផ្តល់ការគាំទ្រផ្នែកច្បាប់តាមរយៈការអមដំណើរកុមាររងគ្រោះទៅកាន់ប៉ុស្តិ៍នគរបាល និងតុលាការ (RA៤-CA-០៥-A-justice) និងសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស ដែលផ្តល់សេចក្តីណែនាំផ្នែកច្បាប់អំពី របៀបដាក់ពាក្យបណ្តឹង ប្រសិនបើជនរងគ្រោះពី OCSEA មានបំណងធ្វើបែបនេះ (RA៤-CA-០២-A&B-justice)។

ជនរងគ្រោះ OCSEA និងអ្នកថែទាំដែលត្រូវបានសម្ភាស បានបង្ហាញថា ពួកគេបានទទួលការគាំទ្រផ្នែកច្បាប់ពីមេធាវីរបស់អង្គការមិនមែនរដ្ឋាភិបាល។ ការគាំទ្រនេះបានទទួលការគោរព និងការទទួលស្គាល់យ៉ាងវិជ្ជមានជាខ្លាំង។ កុមារបាននិយាយអំពីអារម្មណ៍ភ័យខ្លាច និងបានកត់សម្គាល់ថា វត្តមាននៃមេធាវី និងបុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាលពិតជាមានសារសំខាន់ណាស់ក្នុងការផ្តល់ការគាំទ្រ និងភាពច្បាស់លាស់អំពីដំណើរការទាំងនេះ។ កុមារម្នាក់បានបង្ហាញថា មេធាវីបានពន្យល់អំពីដំណើរការផ្លូវច្បាប់ ហើយនៅពេលនាងមិនយល់ ឪពុករបស់នាងបានសួរសំណួរជំនួសនាង (RA៤-CA-៧-A-Child)

ទោះបីជាការគាំទ្ររបស់មេធាវីត្រូវបានចាត់ទុកជារួមថាមានលក្ខណៈវិជ្ជមាន និងសមស្របក្តី កុមាររងគ្រោះថ្នាក់បានពណ៌នាអំពី អារម្មណ៍ភ័យខ្លាច នៅពេលជួបជាមួយមេធាវីរបស់គាត់ ដោយសារមេធាវីរបស់គាត់គឺជាស្ត្រី។ គាត់បានថ្លែងថា គាត់ចង់បានមេធាវីប្រុសច្រើនជាងដោយសារគាត់អៀនចំពោះការពិភាក្សាករណីរបស់គាត់ជាមួយស្ត្រី។ កុមាររងគ្រោះក៏បានបង្ហាញថា ភាសាដែលមេធាវីបានប្រើប្រាស់ពិបាកយល់ផងដែរ។ (RA៤-CA-៣-A-Child)។

អ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌបានសង្កេតឃើញថា ជំនួយផ្នែកច្បាប់សម្រាប់កុមាររងគ្រោះពីគណៈមេធាវីកម្ពុជាមិនគ្រប់គ្រាន់ឡើយ ដោយសារសេចក្តីត្រូវការច្រើនលើសលុបពេក ហើយស្រដៀងគ្នានេះដែរ សមត្ថភាពអង្គការមិនមែនរដ្ឋាភិបាលនៅមានកម្រិត ដោយសារធនធានហិរញ្ញវត្ថុដែលមាន។ អ្នកឆ្លើយតបម្នាក់បានបង្ហាញនូវកង្វះមេធាវីសម្រាប់កុមាររងគ្រោះចំពោះគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចនៅកម្ពុជា រួមទាំង OCSEA (RA៤-CA-០៦-A&B-justice)។ ប្រធានកម្មវិធីកិច្ចការពារកុមារនៃអង្គការម្លប់តាប៉ាង បានសង្កត់ធ្ងន់អំពីសារសំខាន់នៃជំនួយផ្នែកច្បាប់ ដោយថ្លែងថា នៅពេលគ្មានវត្តមានរបស់មេធាវី ចៅក្រមមិនយកចិត្តទុកដាក់ចំពោះកុមាររងគ្រោះឡើយ។ (RA៤-CA-០៧-A-justice)។

### ៣.៣.២ សំណង

កុមាររងគ្រោះនៃ OCSEA នៅកម្ពុជាបានស្វែងរកសំណងនៅក្នុងដំណើរការរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ដូចមានចែងនៅក្នុងមាត្រាទី ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយមិនគិតថា តើព្យសនកម្មអាចជាព្យសនកម្មខាងរូបកាយ ឬខាងផ្លូវចិត្តឡើយ។ ទោះបីជាកុមាររងគ្រោះនៃ OCSEA អាចស្វែងរកសំណងតាមរយៈដំណើរការរដ្ឋប្បវេណី ឬព្រហ្មទណ្ឌក្តី បទពិសោធន៍របស់អ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌដែលត្រូវបានសម្ភាសពាក់ព័ន្ធបណ្តឹងទាមទារសំណងទាំងអស់ពីជនរងគ្រោះ OCSEA សុទ្ធតែទំនងជាពាក់ព័ន្ធនឹងដំណើរការរដ្ឋប្បវេណី។

### ការយល់ដឹង និងការអនុវត្តរបស់កុមាររងគ្រោះនៃ OCSEA ក្នុងការស្វែងរកសំណង

ពីការសម្ភាសនៃគម្រោងការបញ្ឈប់គ្រោះថ្នាក់ជាមួយកុមាររងគ្រោះនៃ OCSEA ចំនួនប្រាំមួយនាក់ ពួកគេភាគច្រើនបានដឹង អំពីជម្រើសក្នុងការស្វែងរកសំណង ដោយសារពួកគេទទួលបានព័ត៌មាន ពីអង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រពួកគេ ហើយនៅពេលខ្លះ ចៅក្រម និងមន្ត្រីតុលាការបានពិភាក្សាអំពីបញ្ហាសំណងនៅក្នុងតុលាការ។ យុវជនម្នាក់បានពន្យល់ថា៖ "ខ្ញុំបានដឹង... នៅពេលនៅតុលាការ នៅចំពោះមុខឪពុកម្តាយរបស់ខ្ញុំ នៅពេលដំបូងដែលពួកគេបានសួរថា តើអ្នកចង់ទាមទារប៉ុន្មាន? (RA៤-CA-០៧-A-Child) ការសម្ភាសជាមួយអ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ ក៏បានបញ្ជាក់ថា ជនរងគ្រោះនៃ CSEA រួមទាំង OCSEA នៅកម្ពុជាកំពុងប្រើប្រាស់ច្បាប់យ៉ាងសកម្ម ដើម្បីស្វែងរកសំណងដោយមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល។

## ៣.៣ ការទទួលបានយុត្តិធម៌ និងការទទួលបានឧបាស្រ័យ

ក្នុងចំណោមកុមាររងគ្រោះនៃ OCSEA ទាំងប្រាំមួយនាក់ ដែលត្រូវបានសម្ភាស ពួកគេចំនួនបីនាក់បានបញ្ជាក់ថា ពួកគេទទួលបានសំណង។

### ឧបសគ្គចំពោះការស្វែងរកសំណង

ទោះបីជាមានការយល់ដឹង និងការអនុវត្តការស្វែងរកសំណងនៅកម្ពុជាក្តី អ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌនានាបានបង្ហាញថា ដំណើរការនេះមានត្រូវការការចំណាយច្រើន និងវាពិបាកទទួលបានជំនួយផ្នែកច្បាប់ក្នុងការបណ្តឹងទាមទារសំណង។ បន្ថែមលើនេះ អ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌបានបង្ហាញថា "ដំណើរការទាមទារសំណងមិនងាយស្រួលឡើយ ហើយវារិតតែពិបាកថែមទៀត នៅពេលពាក់ព័ន្ធនឹងជនបរទេស។" (RA៤-CA-0៥-A-justice) កុមាររងគ្រោះ និងអ្នកថែទាំដែលត្រូវបានសម្ភាស បានចែកចាយថា ជាទូទៅការស្វែងរកនិងទទួលបានសំណងជាដំណើរការដ៏វែងឆ្ងាយ និងមានការជំរុញទឹកចិត្ត និងលើកទឹកចិត្តបន្តិចបន្តួច

បញ្ហាប្រឈមបន្ថែមមួយទៀត គឺការដោះស្រាយនៅក្រៅប្រព័ន្ធតុលាការដែលនៅតែបន្តកើតឡើងនៅកម្ពុជា ដែលអាចនាំទៅដល់ការនិទណ្ឌភាពរបស់ជនល្មើស សំណងហិរញ្ញវត្ថុមានចំនួនតិចជាងទម្រង់នៃការខូចខាតរបស់ជនរងគ្រោះ និងសេវាគាំទ្រដល់ជនរងគ្រោះនៅមានការខ្វះខាត។ (សូមមើល៖ ការដោះស្រាយក្រៅផ្លូវការនៅក្រៅប្រព័ន្ធតុលាការ នៅទំព័រ ៩២)

សូម្បីតែនៅទីបំផុត តុលាការបានចេញដីកាបង្គាប់ឱ្យផ្តល់សំណងក្តី អ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌបានកត់សម្គាល់ថា ការអនុវត្តដីកានេះគឺជាការលំបាក ហេតុនេះ ជនល្មើសភាគច្រើនមិនផ្តល់សំណង។ មូលហេតុមួយ ដែលត្រូវបានផ្តល់សម្រាប់ចំណុចនេះ គឺថា នៅពេលខ្លះជនល្មើសមិនមានមធ្យោបាយផ្នែកហិរញ្ញវត្ថុ។

### ៣.៣.៣ សេវាគាំទ្រសង្គម

ពាក់ព័ន្ធនឹងការផ្តល់សេវាគាំទ្រសង្គមដល់កុមាររងគ្រោះនៃ OCSEA យោងតាមអ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌដែលត្រូវបានសម្ភាស ទាំងទីភ្នាក់ងាររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដើរតួនាទីយ៉ាងសំខាន់។ ម្នាក់ក្នុងចំណោមអ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌដែលត្រូវបានសម្ភាស បានពន្យល់ថា "ប្រសិនបើមានការរាយការណ៍ នគរបាលនឹងសហការជាមួយភាគីពាក់ព័ន្ធ ជាពិសេសដៃគូសហការដូចជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី ។ល។ (RA៤-CA-១0-A-justice). បន្ថែមពីនេះ សេវាដែលផ្តល់ដោយក្រសួងកិច្ចការនារី រួមមានការប្រឹក្សាយោបល់ផ្លូវច្បាប់ ការគាំទ្រផ្លូវចិត្ត និងការបញ្ជូនជនរងគ្រោះទៅអង្គការមិនមែនរដ្ឋាភិបាលដៃគូសម្រាប់ជម្រកសុវត្ថិភាព។ សេវាទាំងនេះត្រូវបានផ្តល់តាមរយៈនាយកដ្ឋានការពារផ្លូវច្បាប់នៃក្រសួងកិច្ចការនារី ដែលជួយគាំទ្រដល់ជនរងគ្រោះតាមរយៈការផ្តល់មេធាវីការពារដោយឥតគិតកម្រៃ ការសរសេរពាក្យបណ្តឹង និងគាំទ្រក្នុងការស្វែងរកយុត្តិធម៌សម្រាប់ស្ត្រី និងក្មេងស្រីដែលរងផលប៉ះពាល់ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ។

ទាក់ទងនឹងការផ្តល់ការថែទាំផ្នែកសុខាភិបាលដល់ជនរងគ្រោះនៃ OCSEA នៅកម្ពុជា ក្រសួងសុខាភិបាលបានដាក់ចេញកម្មវិធីផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកថែទាំសុខភាពដើម្បីកសាងចំណេះដឹងអំពីហិង្សាលើកុមារ និងការរំលោភបំពានផ្លូវភេទកុមារ ទោះបីជាមិនផ្តោតលើ OCSEA ក្តី។ ដូចដែលអនុប្រធានក្រុមការងារបង្ការទប់ស្កាត់នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សបានថ្លែងថា "ការបណ្តុះបណ្តាលជាទូទៅផ្តោតលើរបៀបផ្តល់ការថែទាំ និងព្យាបាលជនរងគ្រោះដោយប្រើប្រាស់សៀវភៅដែលយើងបានបង្កើតមានចំណងជើងថា 'សៀវភៅស្តីពីការថែទាំសុខភាពកុមាររងគ្រោះដោយសារអំពើហិង្សា ឬការរំលោភបំពានផ្លូវភេទ'។" (RA១-CA 0២-A). អ្នកឆ្លើយតបនេះបានពន្យល់ថា នៅឆ្នាំ២០១៩ ក្រសួងសុខាភិបាលបានបណ្តុះបណ្តាលគ្រូបង្គោលនៅក្នុងខេត្តចំនួន៨ គ្របដណ្តប់មណ្ឌលសុខភាព១៥0 ហើយដោយសារតែជំងឺកូវីដ១៩ ការបណ្តុះបណ្តាលមិនបានពង្រីកទៅដល់ខេត្តចំនួន១៥ដែលនៅសល់នោះទេ។ (RA១-CA-0២ A). ការថែទាំសុខភាពជាច្រើននៅកម្ពុជាត្រូវបានផ្តល់ដោយឯកជន ហើយអ្នកឆ្លើយតបរូបនេះក៏បានគូសបញ្ជាក់ថា ក្រសួងសុខាភិបាលយឺតយ៉ាវក្នុងការផ្សាភ្ជាប់ជាមួយវិស័យឯកជនដើម្បីដោះស្រាយបញ្ហា OCSEA និងបទល្មើសផ្លូវភេទលើកុមារផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ តំណាងពីក្រសួងសុខាភិបាលបានលើកឡើងថា "យើងនឹងធ្វើការវាយតម្លៃពីលទ្ធភាពដែលវិស័យឯកជនអាចចូលរួមបាន" (RA១-CA-0២-A)។

ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ១៩ ក្រសួងកិច្ចការនារី ក្នុងកិច្ចសហការជាមួយអង្គការដៃគូ ក៏បានធ្វើយុទ្ធនាការឌីជីថលនៅលើបណ្តាញ Facebook របស់ក្រសួងដែលមានអ្នកតាមដានច្រើនជាង១៥ម៉ឺននាក់ ផលិតរឿងអប់រំខ្លី និងសម្ភារៈផ្សព្វផ្សាយមួយចំនួនក្នុងគោលបំណងដាក់លាក់ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការកេងប្រវ័ញ្ចផ្លូវភេទ ជាពិសេសលើកុមារ តាមប្រព័ន្ធអនឡាញ។

* ព័ត៌មានទទួលបានក្នុងអំឡុងពេលពិគ្រោះយោបល់ជាមួយក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងខែឧសភា ឆ្នាំ២០២២ ។

* ព័ត៌មានទទួលបានក្នុងអំឡុងពេលពិគ្រោះយោបល់ជាមួយក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងខែឧសភា ឆ្នាំ២០២២ ។

## ៣.៣ ការទទួលបានយុត្តិធម៌ និងការទទួលបានឧបាស្រ័យ

ពាក់ព័ន្ធនឹងការសេវាគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល ព្រះរាជអាជ្ញារងនៃតុលាការរាជធានីភ្នំពេញបានថ្លែងថា "អង្គការមិនមែនរដ្ឋាភិបាលផ្តល់ការគាំទ្រទៅដល់កុមារ ជាពិសេស ផ្តល់ការគាំទ្រផ្លូវចិត្ត និងការគាំទ្រផ្នែកច្បាប់ដល់កុមាររងគ្រោះ" ។ (RA៤-CA-១០-A-justice)

ពាក់ព័ន្ធនឹងការទទួលបានការគាំទ្រសម្រាប់ករណី OCSEA ទាំងពីអង្គការសកម្មភាពដើម្បីកុមារ (APLE) មានបុគ្គលិកសង្គមផ្តល់សេវាជាច្រើនដែលគាំទ្រដល់កុមាររងគ្រោះដែលបានទទួលរងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ រួមទាំង OCSEA ដែលរួមមានទាំងសេវាផ្សេងៗដូចជា ការថែទាំសុខភាព ការសម្របសម្រួលជម្រកសុវត្ថិភាពបណ្តោះអាសន្ន ការគាំទ្រផ្នែកសង្គម និងការផ្តល់ប្រឹក្សាយោបល់ពីផលប៉ះទង្គិចផ្លូវចិត្ត ជាដើម។ អង្គការ Terre des Hommes ប្រទេសហូឡង់ ផ្តល់ការគាំទ្រផ្លូវចិត្ត និងការគាំទ្រផ្នែកច្បាប់ដល់កុមាររងគ្រោះ។ (RA៤-CA-0៥-A-justice)។

បុគ្គលិកផ្តល់សេវាសង្គមជួរមុខក៏ត្រូវបានសុំឱ្យកំណត់នូវកត្តានានាដែលមានឥទ្ធិពលលើការផ្តល់សេវាគាំទ្រសម្រាប់កុមាររងគ្រោះនៃ OCSEA ផងដែរ។ ទីតាំងគឺត្រូវបានកំណត់ជាទូទៅបំផុត (៩២%) ថាជាកត្តាមួយ ដែលមានផលប៉ះពាល់លើការផ្តល់សេវាគាំទ្រ ដូចជា ការប្រមូលផ្តុំនៃសេវាគាំទ្រនៅតំបន់ទីក្រុង។ ដោយមានភាពចាំបាច់ស្រដៀងគ្នាចំពោះការមានសេវាគាំទ្រ គឺការយល់ឃើញថា សេវានានាមានគុណភាពទាប (៨២%) ដែលអាចមានឥទ្ធិពលលើការទទួលយកសេវាផងដែរ។ តម្លៃត្រូវបានកំណត់ដោយអ្នកឆ្លើយតបចំនួន ៦៨% ថាជាឧបសគ្គចំពោះកុមាររងគ្រោះក្នុងការទទួលបានសេវា រួមទាំងការរើសអើងដែលត្រូវបានយល់ឃើញ ទៅលើអតិថិជន (៥៨%)។

### សាច់រឿងរបស់ស្រីលីន* – បទពិសោធន៍វិជ្ជមាននៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ពីការយល់ឃើញរបស់ជនរងគ្រោះនៃ OCSEA ម្នាក់

គម្រោងស្តីពីការបញ្ឈប់គ្រោះថ្នាក់បានទទួលប្រយោជន៍ពីការយល់ឃើញ និងការយល់ដឹងស៊ីជម្រៅរបស់ឧត្តរជីវីនៃ OCSEA និងអ្នកថែទាំរបស់ពួកគេ ដែលបានចែកចាយបទពិសោធន៍របស់ពួកគេ ដើម្បីពង្រីកការយល់ដឹងអំពី បាតុភូតកំពុងលេចឡើងនេះ និងដើម្បីរួមចំណែកចំពោះការផ្លាស់ប្តូរវិជ្ជមាន។ ការសម្ភាសទាំងនេះបានផ្តោតយ៉ាងជាក់លាក់ទៅលើបទពិសោធន៍នៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ បើទោះបីជាមានរឿងជាច្រើនដែលត្រូវរៀនសូត្រពីបញ្ហាប្រឈម និងការលំបាកនានា ដែលឧត្តរជីវី និងអ្នកថែទាំរបស់ពួកគេពណ៌នាក្តី ការរៀនសូត្រនានាក៏ទទួលបានពីបទពិសោធន៍វិជ្ជមាន និងពីការយល់អំពី "អ្វីដែលដំណើរការទៅបានល្អ" ផងដែរ។"

នៅក្នុងករណីស្រីលីន ជាទូទៅ បទពិសោធន៍របស់នាងនៅទូទាំងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌបន្ទាប់ពីការរាយការណ៍អំពីករណី OCSEA មានលក្ខណៈវិជ្ជមាន។ ឪពុករបស់នាងក៏ត្រូវបានសម្ភាស និងបានចែកចាយការយល់ឃើញស្រដៀងគ្នានេះផងដែរ។ ជារួមទាំងកូនស្រី និងឪពុកពណ៌នាថា ករណីនេះទទួលបានការចាត់ចែងយ៉ាងល្អពីសំណាក់អាជ្ញាធរ ដែលបង្ហាញនូវភាពមានវិជ្ជាជីវៈ និង "ការអនុវត្តល្អ"  នៅទូទាំងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

នៅពេលធ្វើរបាយការណ៍នេះ ឪពុកបានពណ៌នាអំពី របៀបដែលគាត់បានជ្រើសរើសមិនបង្កការចូលរួមរបស់នគរបាលមូលដ្ឋាន ជំនួសវិញគាត់បានរាយការណ៍ដោយផ្ទាល់ទៅកាន់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា ដើម្បីដាក់ពាក្យបណ្តឹងជំនួសកូនស្រីរបស់គាត់។ គាត់ពណ៌នាអំពី ការទទួលបានការលើកទឹកចិត្តពីការឆ្លើយតបរបស់ពួកគេ ដែលគាត់ពណ៌នាថា ទាំងមានលក្ខណៈផ្តល់ព័ត៌មាន និងរក្សាការសម្ងាត់ ដោយគាត់បាននិយាយថា៖ "ពួកគេ [នគរបាលនៅក្នុងនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា] បានស្វាគមន៍ និងសហការជាមួយយើងយ៉ាងល្អ... នគរបាលបានពន្យល់អំពី សិទ្ធិរបស់ឪពុក និងសិទ្ធិរបស់កូន... ដំណើរការរបស់នគរបាលមានលក្ខណៈប្រុងប្រយ័ត្ន និងសុវត្ថិភាព។" (RA៤-CA-៩-A-Parent).

គប្បីកត់សម្គាល់ថា ឪពុករបស់ស្រីលីន គឺជាអ្នកមានការអប់រំ និងមកពីគ្រួសារមានជីវភាពកម្រិតមធ្យម ដែលអាចមានឥទ្ធិពលវិជ្ជមានលើការឆ្លើយតបរបស់អ្នកវិជ្ជាជីវៈផ្នែកយុត្តធម៌ព្រហ្មទណ្ឌខុសៗគ្នា ដែលចូលរួមនៅក្នុងករណីនេះ។ ឪពុកក៏បានបង្ហាញថា គាត់ពិតជាមានជំនឿចិត្តក្នុងការធានាថា កូនស្រីរបស់គាត់ទទួលបានការឆ្លើយតបយ៉ាងសមស្រប៖ "ប្រសិនបើ យើងមិនតឹងតែងជាមួយនគរបាលទេ ពួកគេនឹងមិន [ធ្វើសកម្មភាព] យ៉ាងឆាប់រហ័ស ដើម្បីអាចចាប់ខ្លួនជនល្មើសឡើយ ដោយសារគាត់បានបាត់ខ្លួនទាំងស្រុងពីគណនីរបស់គាត់ នៅលើទូរស័ព្ទរបស់គាត់។"

ការពន្យល់របស់គាត់អំពី ដំណើរការនេះ បង្ហាញថា ជាទូទៅគោលការណ៍ណែនាំ សម្រាប់ការធ្វើការសម្ភាសក្នុងលក្ខណៈកុមារមេត្រី និងរក្សាការសម្ងាត់ ត្រូវបានអនុវត្តតាម ផ្ទុយពីបទពិសោធន៍របស់អ្នកដទៃទៀត ដែលត្រូវបានបង្ហាញផងដែរនៅក្នុងរបាយការណ៍នេះ។ នៅប៉ុស្តិ៍នគរបាលដែលពាក្យបណ្តឹងត្រូវបានដាក់ កុមារ និងឪពុករបស់នាងត្រូវបានសម្ភាសនៅក្នុងបន្ទប់ស្ងាត់ និងមានការរក្សា

ការសម្ងាត់ដោយគ្មានការរំខាន នគរបាលបានប្រើប្រាស់ភាសាសមស្រប ដែលកុមារអាចយល់បាន ហើយឪពុកបានចូលរួមនៅក្នុងការសម្ភាសនោះដែរ ដែលជួយឱ្យគាត់ផ្តល់ការគាំទ្រ និងការលើកទឹកចិត្តដល់កូនស្រីរបស់គាត់។ ស្ត្រីមេធាវីរបស់អង្គការមិនមែនរដ្ឋាភិបាលផ្តល់ការគាំទ្រ និងការលើកទឹកចិត្ត ហើយកុមារបានកំណត់អំពីមេធាវីនោះថា ល្អជាទីចង់បាន ដោយសារនាងចាត់ទុកថា ការពិភាក្សាជាមួយស្ត្រីងាយស្រួលជាង។ កុមារក៏មានលទ្ធភាពទទួលបានបុគ្គលិកសង្គម/អ្នកផ្តល់ប្រឹក្សា ដែលផ្តល់ការគាំទ្រ និងស្វែងរកមតិគាំទ្រសម្រាប់នាងនៅទូទាំងដំណើរការនេះ។

ស្រីលីនក៏បានពណ៌នាថា ការជួបជាមួយនឹងចៅក្រមស៊ើបអង្កេតជាដំណើរការដោយរលូន និងរក្សាការសម្ងាត់៖ នៅពេលនោះ ខ្ញុំបានជួបជាមួយចៅក្រមស៊ើបអង្កេត គ្មានអ្វីដែលត្រូវពន្យល់ម្តងទៀតឡើយ ដោយសារគាត់មានឯកសារទាំងអស់របស់ខ្ញុំរួចហើយ ហេតុនេះគាត់មានសំណួរដែលគាត់បានសួរ និងអាចលឺអំពី អ្វីដែលជនសង្ស័យបាននិយាយ ហើយគាត់បានសួរសំណួរ ដើម្បីបញ្ជាក់ថាតើនោះជាការពិត ឬមិនពិត។ នៅពេលនោះ គ្មានអ្វីដែលពិបាកឡើយ ហើយគ្មានមនុស្សច្រើនឡើយ នៅពេលយើងជួបគ្នា មានតែខាងគាត់ និងខាងយើងប៉ុណ្ណោះ។" (RA៤-CA-៩-A)

បន្ទាប់មក នាងបានពណ៌នាអំពី ដំណើរការតុលាការ ដែលទំនងជាបំពេញទៅតាមលក្ខខណ្ឌនៃគោលការណ៍ណែនាំ ដែលដាក់កម្រិតអ្នកចូលរួមចំពោះតែអ្នកដែលពាក់ព័ន្ធដោយផ្ទាល់នៅក្នុងករណីនេះប៉ុណ្ណោះ ហេតុនេះ គ្មានវត្តមានរបស់សមាជិកនៃសាធារណជនឡើយ៖ នៅតុលាការ មានមនុស្សច្រើននៅរួមគ្នា និងនៅពេលនោះមានតែមន្ត្រីនៅតុលាការ និងអ្នកដទៃទៀតមួយចំនួន ហើយសម្រាប់មនុស្សមកពីខាងក្រៅ តុលាការមិនមានចេតនាឱ្យពួកគេចូលមើលឡើយ។សម្រាប់ខ្លួនខ្ញុំផ្ទាល់មានបន្ទប់មួយនៅខាងក្រៅហើយខ្ញុំអាចអង្គុយនៅទីនោះ ដើម្បីរង់ចាំ និងស្តាប់ ហើយនៅពេលពួកគេត្រូវការសេចក្តីថ្លែងការណ៍របស់ខ្ញុំ ខ្ញុំបានចូលទៅ ហើយពួកគេបានដាក់របាំងនៅពីមុខខ្ញុំ ហេតុនេះគ្មាននរណាម្នាក់អាចមើលឃើញមុខរបស់ខ្ញុំឡើយ។ ហេតុនេះ វាពិតជាងាយស្រួលសម្រាប់ខ្ញុំ។ (RA៤-CA-៩-A)

លទ្ធផលនៃករណីនេះ គឺថា ជនសង្ស័យត្រូវបានចោទប្រកាន់នៅក្រោមមាត្រា ៤១ "អំពើអាសអាភាសលើកុមារ" នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ និងមាត្រា ២៣២ "បទគំរាមកំហែងដោយការមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ" នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ជនសង្ស័យត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលបីឆ្នាំ។ គ្មានការស្វែងរកសំណងឡើយ។

ទោះបីជាការសម្ភាសដទៃទៀតបង្ហាញលទ្ធផលផ្ទុយពីបទពិសោធន៍នេះយ៉ាងច្បាស់ក្តី វឌ្ឍនភាពត្រូវបានធ្វើឡើងយ៉ាងច្បាស់នៅកម្ពុជា។

** ឈ្មោះត្រូវបានផ្លាស់ប្តូរ ដើម្បីការពារអត្តសញ្ញាណរបស់ជនរងគ្រោះ*

# ៣.៤ ការសម្របសម្រួល និងកិច្ចសហការ

## ៣.៤.១ គោលនយោបាយ និងរដ្ឋាភិបាល

ទីភ្នាក់ងាររដ្ឋាភិបាលចម្បងៗដែលធ្វើការងារដើម្បីដោះស្រាយ OCSEA នៅកម្ពុជាគឺ៖ ក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ ផែនការសកម្មភាពដើម្បីបង្ការ-ទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ឆ្នាំ២០២១-២០២៥ ត្រូវបានរៀបចំ និងដឹកនាំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក៏អំពាវនាវឱ្យក្រសួងដូចរាយនាមខាងក្រោមចូលរួមយ៉ាងសកម្មនៅក្នុងការឆ្លើយតបចំពោះ OCSEA ផងដែរ៖ ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងយុត្តិធម៌ និងក្រសួងវប្បធម៌។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក៏កំពុងដឹកនាំការអនុវត្តផែនការសកម្មភាពសម្រាប់ការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ (ឆ្នាំ២០១៧-០២១) ផងដែរ (សូមមើលទិដ្ឋភាពទូទៅនៃច្បាប់ និងគោលនយោបាយ)។

### ការអភិវឌ្ឍ និងគំនិតផ្ដួចផ្ដើមដែលអាចនឹងមានសក្ដានុពល

**ចំណាត់ការនានារបស់ក្រុមការងារក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារក្រៅពីការរៀបចំផែនការរយៈពេលប្រាំឆ្នាំ ដើម្បីឆ្លើយតបចំពោះ** OCSEA ក្រុមប្រឹក្សានេះសម្របសម្រួលកិច្ចខិតខំប្រឹងប្រែង និងការឆ្លើយតបនានារបស់ក្រសួងទាំងអស់ រៀបចំការបណ្ដុះបណ្ដាលអ្នកពាក់ព័ន្ធ និងអនុវត្តកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការយល់ដឹង (RA១-CA-១០-A)។ រួមគ្នាជាមួយ Terre des Hommes ប្រទេសហូឡង់ និង APLE ក្រុមប្រឹក្សានេះបានផ្ដល់ការអនុញ្ញាតឱ្យដឹកនាំសម្របសម្រួលធ្វើការវិភាគស្ថានភាពដំបូងនៃការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជានៅឆ្នាំ២០១៩ ដើម្បីវាយតម្លៃការគំរាមកំហែងបច្ចុប្បន្ននៃ OCSEA និងដើម្បីយល់កាន់តែច្បាស់អំពីភាពងាយរងគ្រោះរបស់កុមាររួមជាមួយនឹងភាពខ្វះចន្លោះដែលមាននៅក្នុងគោលនយោបាយជាតិ បទដ្ឋានច្បាប់ ផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ សេវាសង្គម និងវិស័យឯកជន។ (RA១-CA-១០-A)។

បើទោះបីជាគំនិតផ្ដួចផ្ដើមទាំងនេះអាចនឹងមានសក្ដានុពលក្ដី ប្រសិទ្ធភាពអាចត្រូវបានវាយតម្លៃតែតាមរយៈការវាយតម្លៃ និងភស្តុតាងយ៉ាងគត់ហ្មត់ ដែលកំពុងខ្វះខាតមកដល់ពេលបច្ចុប្បន្ននេះ ប៉ុណ្ណោះ។ អ្នកតំណាងម្នាក់មកពីក្រសួងកិច្ចការនារីបានផ្ដល់យោបល់ថា៖ ប្រសិនបើ យើងចង់វាស់វែងផលប៉ះពាល់ ឧទា.អំពើហិង្សាបានថយចុះ វាជាការពិបាកដោយសារវាត្រូវការពេលវែង។ ហេតុនេះ នៅពេលយើងរៀបចំសំណើថវិកា វាពិតជាបញ្ហាប្រឈម។" (RA១-CA-០៥-A)

**ការចូលរួមរបស់កុមារនៅក្នុងការរៀបចំគោលនយោបាយ និងផែនការដូចការបង្ហាញរបស់ការស្រាវជ្រាវ កុមារបង្ហាញនូវការយល់ដឹងផ្សេងៗគ្នាអំពី ភាពងាយរងគ្រោះ** ដែលពួកគេប្រឈមមុខជាមួយនៅក្នុងបរិយាកាសអនឡាញរបស់ពួកគេ និងវិធីនានា ដែលអាចធ្វើឱ្យបរិយាកាសទាំងនេះកាន់តែមានសុវត្ថិភាពនៅក្នុងបរិបទកម្ពុជា។ ពួកគេគឺជាធនធានដ៏ធំនៃចំណេះដឹងអនុវត្តជាក់ស្ដែងអំពី បរិយាកាសអនឡាញ និងគប្បីទទួលបានឱកាស ដើម្បីមានឥទ្ធិពលលើការរៀបចំគោលនយោបាយ និងការអនុវត្តពាក់ព័ន្ធនឹង OCSE ។ នៅឆ្នាំ២០១៤ រដ្ឋាភិបាលកម្ពុជាបានចេញ "គោលការណ៍ណែនាំសម្រាប់ការអនុវត្តការចូលរួមរបស់កុមារ ដើម្បីលើកកម្ពស់កិច្ចការពារកុមារប្រកបដោយគុណភាពនៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិលើបញ្ហាពាក់ព័ន្ធ ឬកង្វល់នានា ដែលមានឥទ្ធិពលលើកុមារ។" គោលការណ៍ណែនាំនេះមានបំណងសម្របសម្រួលដំណើរការចូលរួមរបស់កុមារ តាមរយៈការថែងអំពីគោលការណ៍សំខាន់ៗ ដែលគប្បីត្រូវអនុវត្ត និងជំហាននានាដែលត្រូវអនុវត្តតាមនៅដំណាក់កាលនីមួយៗនៃដំណាក់កាលនានារបស់ដំណើរការនេះ។

អ្នកតំណាងមកពីក្រសួងមហាផ្ទៃបានកត់សម្គាល់ថា កុមារបានចូលរួមនៅក្នុងការរៀបចំច្បាប់ស្ដីពី កិច្ចការពារកុមារ។ (RA១-CA-០៣-A)

ការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់នៅទូទៅប្រទេស ដើម្បីធានានូវកិច្ចការពារកុមារនៅគ្រប់កម្រិត។ បើទោះបីជាមានសេចក្ដីរាយការណ៍ថា នៅពេលខ្លះសមាជិកនានានៃគណៈកម្មាធិការនេះខ្វះសមត្ថភាព មានមូលនិធិមិនគ្រប់គ្រាន់ដើម្បីបំពេញអាណត្តិរបស់ពួកគេ និងមិនយល់ច្បាស់អំពីការទទួលខុសត្រូវរបស់ពួកគេក្ដី គណៈកម្មាធិការទាំងនេះមានបំណងផ្ដល់ការគាំទ្រចាំបាច់ដល់ជនរងគ្រោះ រួមទាំងការគាំទ្រផ្លូវចិត្ត។ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ តំណាងឱ្យការឆ្លើយតបក្នុងមូលដ្ឋានតែមួយគត់ចំពោះកិច្ចការពារកុមារ រួមទាំងកុមារទាំងឡាយ ដែលរងផលប៉ះពាល់ពី OCSEA ។

### បញ្ហាប្រឈម

ការយល់ដឹងទាបអំពី OCSEA នៅក្នុងចំណោមមន្ត្រីរដ្ឋាភិបាល អ្នកតំណាងរដ្ឋាភិបាលដែលត្រូវបានសម្ភាស បានបង្ហាញនូវការយល់ដឹងនៅមានកម្រិតអំពីបញ្ហា OCSEA ។ ការស្រាវជ្រាវពីមុននៅកម្ពុជាក៏បានរកឃើញថា មន្ត្រីមួយចំនួនក្នុងជួរនគរបាលជាតិមិនទាន់បង្ហាញការយល់ដឹងស៊ីជម្រៅអំពី OCSEA និងតួនាទីសំខាន់នៃប្រព័ន្ធអ៊ីនធឺណិតក្នុងការជួយសម្រួលដល់ការរំលោភបំពាន និងការកេងប្រវ័ញ្ច

ផ្លូវភេទកុមារនៅក្នុងសហគមន៍កម្ពុជា នៅឡើយទេ។ ទីភ្នាក់ងាររដ្ឋាភិបាលក៏នៅមានកង្វះខាតជំនាញបច្ចេកទេសផងដែរ។ ដោយសារតែកម្មវិធីលើកកម្ពស់ការយល់ដឹងអំពី OCSEA នៅមានកម្រិត  ការយល់ដឹង និងចំណេះដឹងនៅក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ដែលរួមមានមន្ត្រីរដ្ឋាភិបាល គ្រូបង្រៀន ឪពុកម្តាយ និងសហគមន៍ ក៏នៅមានកង្វះខាតដែរ។ នៅឆ្នាំ២០១៥ គណៈកម្មាធិការសិទ្ធិកុមារបានកត់សម្គាល់ថា ប្រទេសកម្ពុជាមិនបានដោះស្រាយបុព្វហេតុឬសគល់ និងកត្តារួមចំណែក ដែលនាំឱ្យកុមារងាយរងគ្រោះចំពោះការកេងប្រវ័ញ្ចផ្លូវភេទឡើយ។ ថ្វីបើមានកំណើនចំនួននៃគំនិតផ្តួចផ្តើមក្តី វិធានការទប់ស្កាត់ដែលឆ្លើយតបយ៉ាងជាក់លាក់ចំពោះសម្ភាររំលោភបំពានផ្លូវភេទកុមារ/សម្ភារកេងប្រវ័ញ្ចផ្លូវភេទកុមារ ត្រូវបានពណ៌នាថា នៅរាយប៉ាយ មិនគ្រប់គ្រាន់ និងខ្លីៗ។

ទីភ្នាក់ងារដែលមានអាណត្តិ ធ្វើការងារតែឯង ភស្តុតាងបង្ហាញឱ្យឃើញថា បើទោះបីជាមានកិច្ចសហការគ្នាមួយចំនួនរវាងទីភ្នាក់ងារនានានៅកម្ពុជាក្តី ទីភ្នាក់ងារ និងអង្គការជាច្រើនធ្វើការងារដោយឯករាជ្យពីគ្នាទៅវិញទៅមក និងស្ថិតក្រោមការដឹកនាំរបស់គោលនយោបាយ បទដ្ឋាន និងអាណត្តិខុសៗគ្នា។ អ្នកតំណាងម្នាក់មកពីនគរបាលជាតិកម្ពុជាបានកត់សម្គាល់ថា កិច្ចសហប្រតិបត្តិការជាបន្ទាន់នៅក្នុងចំណោមទីភ្នាក់ងារនានារបស់រដ្ឋាភិបាលគឺជាការចាំបាច់ អ្នកតំណាងរូបនេះបានថ្លែងថា៖ "យើងមិនអាចធ្វើកិច្ចការនេះប្រកបដោយប្រសិទ្ធភាពតែម្នាក់ឯងបានឡើយ។ យើងមិនអាចអនុវត្តយុទ្ធសាស្ត្ររបស់យើងដោយមិនរួមគ្នាឡើយ។ នៅពេលបច្ចុប្បន្ន បញ្ហាប្រឈម គឺថា យើងមិនអាចធ្វើសុខដុមនីយកម្មផែនការសកម្មភាពរបស់យើងនៅឡើយទេ។ ដោយផ្អែកលើការសង្កេតរបស់ខ្ញុំ ការអនុវត្តនៅតែមានលក្ខណៈដោយឡែកពីគ្នាខ្លាំងនៅឡើយ។" (RA១-CA-0៣-A)។

> វាសំខាន់ណាស់ត្រូវមានការគាំទ្រ និងឆន្ទៈនយោបាយ ។ ប្រសិនបើអ្នករាល់គ្នាធ្វើវាជាមួយគ្នា នោះវានឹងសម្រេចបាន។ (RA១-CA-0៤-A)

ប្រធាននាយកដ្ឋានសន្តិសុខព័ត៌មាននៅក្នុងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានបន្ថែមថា "ការមានការគាំទ្រ និងឆន្ទៈនយោបាយ គឺមានសារសំខាន់។ ប្រសិនបើមនុស្សគ្រប់គ្នាធ្វើវារួមគ្នានោះវានឹងត្រូវបញ្ចប់។"  (RA១-CA-0៤-A)។

កង្វះការអប់រំពាក់ព័ន្ធនឹង OCSEA នៅក្នុងសាលារៀន ការសម្ភាសជាមួយអ្នកតំណាងរដ្ឋាភិបាលបានបង្ហាញថា នៅពេលបច្ចុប្បន្ន មានកម្មវិធីលើកកម្ពស់ការយល់ដឹងពាក់ព័ន្ធនឹង OCSEA តិចតួច សម្រាប់សិស្សសាលានៅកម្ពុជា។ កម្មវិធីដែលមានស្រាប់ ភាគច្រើនគ្របដណ្តប់លើ សុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិតទូទៅ។ (RA១-CA-0៤-A)។ អ្នកតំណាងម្នាក់មកពីក្រសួងមហាផ្ទៃបានរៀបរាប់ថា នៅពេលបច្ចុប្បន្ន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងក្រសួងអប់រំ យុវជន និងកីឡា កំពុងរៀបចំធនធាន សម្រាប់សាលារៀនបឋមសិក្សា និងសាលារៀនមធ្យមសិក្សា ដែលនឹង៖ "ផ្តល់ទស្សនទានអំពី ការរំលោភបំពានកុមារ រួមទាំងតាមប្រព័ន្ធអនឡាញ ឬអំពើហិង្សាផ្លូវភេទលើកុមារ [...] ព្រមទាំងផ្នែកនានានៃច្បាប់ និងនីតិវិធី

បណ្តឹង។ ធនធាននេះនឹងត្រូវចងក្រងបញ្ចប់នៅពេលឆាប់ៗនេះ ព្រមទាំងនឹងត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅសាលារៀន។" (RA១-CA-0៦-A) នៅពេលសរសេររបាយការណ៍នេះ សៀវភៅណែនាំនេះមិនទាន់បានបោះពុម្ពនៅឡើយទេ។

ការវិនិយោគមិនគ្រប់គ្រាន់ពីរដ្ឋាភិបាល។ អ្នកផ្តល់ការសម្ភាសមួយចំនួនដែលមកពីជួររដ្ឋាភិបាល បានរៀបរាប់ថា ប្រព័ន្ធកិច្ចការពារកុមាររបស់កម្ពុជានៅតែទន់ខ្សោយ និងមិនសូវមានធនធានគួរឱ្យកត់សម្គាល់ ដោយសារការវិភាជថវិកាមិនគ្រប់គ្រាន់ ដើម្បីវិនិយោគលើធនធានមនុស្ស និងធនធានហិរញ្ញវត្ថុដែលចាំបាច់ ដើម្បីដោះស្រាយកង្វល់ផ្នែកកិច្ចការពារកុមារនៅកម្ពុជា រួមទាំង OCSEA ។  (RA១-CA-0៥-A) (RA១-CA-0៧-A).

### ៣.៤.២ សង្គមស៊ីវិល

អង្គការសង្គមស៊ីវិលដើរតួនាទីសំខាន់មួយនៅក្នុងការឆ្លើយតបចំពោះ OCSEA ។ ពួកគេបានសហប្រតិបត្តិការជាមួយតួអង្គអនុវត្តច្បាប់ និងតួអង្គតុលាការនៅក្នុងការផ្តល់សេវានានា ដូចជា ជម្រក ការផ្តល់ប្រឹក្សាយោបល់ និងជំនួយផ្នែកច្បាប់។ ពួកគេបានចូលរួមនៅក្នុងសកម្មភាពលើកកម្ពស់ការយល់ដឹង និងនៅក្នុងការផ្តល់ការបណ្តុះបណ្តាលសម្រាប់

កម្លាំងការងារកិច្ចការពារកុមារ។ មានបទប្បញ្ញត្តិច្បាប់នៅកម្ពុជា ដើម្បីធានាថា អង្គការមិនមែនរដ្ឋាភិបាលអាចជួយ ឬគាំទ្រជនរងគ្រោះទៅតាមការស្នើសុំរបស់ពួកគេ នៅក្នុងអំឡុងពេលនៃការស៊ើបអង្កេត និងដំណើរការផ្លូវច្បាប់ ហើយអង្គការជំនួយផ្នែកច្បាប់ដើរតួនាទីគួរឱ្យកត់សម្គាល់នៅក្នុងការគាំទ្រកុមារនៅក្នុងដំណើរការទាំងនេះ។ ដូចការរៀបរាប់របស់អ្នកថែទាំមួយចំនួនដែលត្រូវបានសម្ភាស ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងអំឡុងពេលនៃដំណើរការយុត្តិធម៌ គឺចាំបាច់ចំពោះករណីរបស់កូនពួកគេ។ (RA៤-CA-២-A-Parent) បន្ថែមលើនេះ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលរមែងតែងជាអ្នកឆ្លើយតប

ដំបូងចំពោះករណី OCSEA ។ នៅពេលករណីមួយត្រូវបានរាយការណ៍ដល់អង្គការមិនមែនរដ្ឋាភិបាលមួយ ក្នុងករណីជាច្រើន អ្នកតំណាងរបស់អង្គការមិនមែនរដ្ឋាភិបាលនឹងអមដំណើរកុមារទៅកាន់ប៉ុស្តិ៍នគរបាលរួមគ្នាជាមួយនឹងសមាជិកគ្រួសាររបស់កុមារ នៅពេលណាដែលអាចធ្វើបាន។

អង្គការមួយចំនួនក្នុងចំណោមអង្គការនានា ដែលទទួលបានសេចក្តីរាយការណ៍អំពី OCSEA នៅកម្ពុជា រួមមាន៖ អង្គការសកម្មភាពដើម្បីកុមារ (APLE) ដែលមានដំណើរការប្រព័ន្ធរាយការណ៍អំពី CSAM ផងដែរ (សូមមើលអនុជំពូក ៣.១.៣) អង្គការ Terre Des Hommes-ប្រទេសហូឡង់ (TDH), Friends International, និងអង្គការម្លប់តាប៉ាង ដែលដំណើរការប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ សុវត្ថិភាពកុមាររយៈពេល២៤ម៉ោង សម្រាប់កុមារដែលជួបប្រទះនឹងគ្រោះថ្នាក់នៅខេត្តព្រះសីហនុ។

បើទោះបីជាអង្គការដែលទទួលបានការបញ្ជូនករណីពីទីភ្នាក់ងារអនុវត្តច្បាប់នឹងផ្តល់សេវា និងការគាំទ្រដល់កុមារក្តី នៅពេលខ្លះ ពួកគេខ្វះការបណ្តុះបណ្តាលឯកទេស ដែលអាចដាក់កម្រិតចំពោះប្រសិទ្ធភាពរបស់ពួកគេផងដែរ។ ការស្រាវជ្រាវរបស់គម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* ក៏បង្ហាញថា បុគ្គលិកគាំទ្រសង្គមជួរមុខជាច្រើនដឹងតិចតួចអំពី OCSEA ។

នៅពេលបុគ្គលិកគាំទ្រសង្គមជួរមុខត្រូវបានស្នើសុំឱ្យវាយតម្លៃកិច្ចសហការរបស់អង្គការមិនមែនរដ្ឋាភិបាលលើ OCSEA ៦០% នៃអ្នកឆ្លើយតបបានវាយតម្លៃកិច្ចសហការបច្ចុប្បន្នថា ល្អ ឬល្អណាស់ ដោយចំនួន ៤០% បន្ថែមទៀតបានវាយតម្លៃកិច្ចសហការរបស់អង្គការមិនមែនរដ្ឋភិបាលថា មធ្យម។ អ្នកឆ្លើយតបចំនួនតែ ៤% ប៉ុណ្ណោះ ដែលបង្ហាញថា កិច្ចសហការបែបនេះខ្សោយ។

### ៣.៤.៣ ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត និងទូរស័ព្ទចល័ត និងកម្មវិធីនានា (platforms)

កិច្ចសហការជាមួយក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត និងទូរស័ព្ទចល័ត និងកម្មវិធីនានា គឺចាំបាច់ចំពោះការស៊ើបអង្កេតបទល្មើស OCSEA និងការទប់ស្កាត់ការផ្សព្វផ្សាយ CSAM ។ លក្ខខណ្ឌច្បាប់និងនីតិវិធីអនុវត្តជាក់ស្តែងមានលក្ខណៈខុសគ្នា អាស្រ័យលើថា តើប្រតិបត្តិករជាពលរដ្ឋកម្ពុជា ឬជាសកល។

#### ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត ក្នុងស្រុក

**ការប្រមូលភស្តុតាង៖** នៅពេលបច្ចុប្បន្ន កម្ពុជាមិនមានច្បាប់ដែលតម្រូវឱ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតរក្សាទុកទិន្នន័យផ្អែកលើមាតិកា ឬមិនផ្អែកលើមាតិកា ឬផ្តល់ទិន្នន័យបែបនេះ ទៅដល់ទីភ្នាក់ងារអនុវត្តច្បាប់ឡើយ។ ទីភ្នាក់ងារអនុវត្តច្បាប់កម្ពុជាគ្មានសិទ្ធិអំណាចក្នុងការស្នើសុំ ឬតម្រូវឱ្យភាគីឯកជន ដូចជាថ្នាលកម្មវិធីនានារក្សាទុកភស្តុតាងនៃបទល្មើសឡើយ។ (RA៩-CA-0៤-A) សំណៅចុងក្រោយដែលមានជាសាធារណៈនៃសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា មានបទប្បញ្ញត្តិពាក់ព័ន្ធនឹងការរក្សាទិន្នន័យកុំព្យូទ័រ និងទិន្នន័យចរាចរណ៍អ៊ីនធឺណិត។ សេចក្តីព្រាងបទប្បញ្ញត្តិនេះចែងថា ព្រះរាជអាជ្ញា ឬតុលាការអាចបញ្ជាឱ្យមានការរក្សាទុកយ៉ាងឆាប់រហ័សនូវទិន្នន័យកុំព្យូទ័រ និងទិន្នន័យចរាចរណ៍អ៊ីនធឺណិត ប្រសិនបើ មានសញ្ញាថា ទិន្នន័យបែបនេះមានទំនាក់ទំនងជាមួយបទល្មើសបច្ចេកវិទ្យា រួមទាំងបទល្មើសពាក់ព័ន្ធនឹង CSAM ។

រយៈពេលនៃការរក្សាទុកទិន្នន័យយ៉ាងរហ័សនេះមិនអាចមានរយៈពេលវែងជាង១២០ថ្ងៃឡើយ។ ព្រះរាជអាជ្ញា និងតុលាការក៏អាចបញ្ជាឱ្យមានការថតចម្លងទិន្នន័យបែបនេះទុក នៅពេលចាំបាច់ សម្រាប់គោលបំណងជាភស្តុតាង ព្រមទាំងការស្រាវជ្រាវ និងការចាប់យកទិន្នន័យកុំព្យូទ័រ។

ដោយសារសេចក្តីព្រាងច្បាប់នេះកំពុងស្ថិតនៅក្នុងដំណាក់កាលពិនិត្យមើលនៅឡើយនៅពេលបច្ចុប្បន្នការទទួលបានទិន្នន័យពាក់ព័ន្ធដែលចាំបាច់ សម្រាប់ការស៊ើបអង្កេតរបស់ទីភ្នាក់ងារអនុវត្តច្បាប់ គឺជាដំណើរការយ៉ាងវែង និងពិបាក។ អ្នកតំណាងម្នាក់មកពីក្រសួងយុត្តិធម៌បានពន្យល់ថា៖ នៅពេលពាក់ព័ន្ធនឹងការរក្សាទុកទិន្នន័យ អត្តសញ្ញាណរបស់អ្នកប្រើប្រាស់ ដែលត្រូវរក្សាទុកដោយក្រុមហ៊ុនទូរស័ព្ទ ដែលរក្សាទុកទិន្នន័យទាំងអស់នេះនៅលើមូលដ្ឋានទិន្នន័យ ឬServer របស់ពួកគេ ដោយសារពួកគេចង់ឱ្យប្រាកដថា ពួកគេមានអ្វីៗគ្រប់យ៉ាង ហេតុនេះ នៅពេលមានបញ្ហានានា មន្ត្រីអនុវត្តច្បាប់អាចទៅកាន់ទីនោះដើម្បីទទួលបានព័ត៌មានអំពី ជនសង្ស័យ ទោះបីជាយ៉ាងណាក្តី មិនមែនអ្នកគ្រប់គ្នាទទួលបានការផ្តល់សិទ្ធិឱ្យធ្វើបែបនោះ

ឡើយ។ ឧទាហរណ៍ នៅពេលមានការប្រព្រឹត្តបទល្មើសមួយ និងមានការបើកការស៊ើបអង្កេត មន្ត្រីអនុវត្តច្បាប់ត្រូវតែបង្ហាញដីកាតុលាការដើម្បីទទួលបានព័ត៌មានបែបនេះ។ (RA៩-CA-0៨-A)

**ការដកចេញ/ការជូនដំណឹងអំពី CSAM៖** កម្ពុជាគ្មានច្បាប់ដែលតម្រូវឱ្យអ្នកផ្តល់សេវាអ៊ីនធឺណិតច្រោះ បិទ និង/ឬដកហូត CSAM ចេញ និងរាយការណ៍អំពីបុគ្គល ឬក្រុមហ៊ុននានាដែលផ្សព្វផ្សាយ ជួញដូរ ឬចែកចាយសម្ភារបែបនេះឡើយ។ កង្វះច្បាប់នេះនៅតែមាន ថ្វីបើការបង្ហាញនៃផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ ដែលកំណត់ភារកិច្ចឱ្យក្រសួងយុត្តិធម៌បន្ថែមមាត្រាថ្មីមួយចំពោះសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា ដើម្បីធានាថាទីភ្នាក់ងារអនុវត្តច្បាប់មានសិទ្ធិអំណាចក្នុងការ

## ៣.៤ ការសម្របសម្រួល និងកិច្ចសហការ

បិទមាតិកានៃកម្មវិធីអនឡាញណាមួយ ដែលរួមចំណែកផ្សព្វផ្សាយ ឬសម្របសម្រួលការប្រព្រឹត្តករណី OCSEA ក្តី។ យោងតាមសំណៅចុងក្រោយដែលមានសាធារណៈនៃសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា បទប្បញ្ញត្តិនេះមិនទាន់ត្រូវបានបញ្ចូលនៅឡើយ។ នៅពេលដែលគ្មានច្បាប់តម្រូវឱ្យអ្នកផ្តល់សេវាអ៊ីនធឺណិត ប្រោះ និងដកមាតិកា CSAM ចេញពីកម្មវិធីរបស់ពួកគេ ការដាក់ចេញចំណាត់ការនេះគឺជាការល្អ។ ឧទាហរណ៍ ទិន្នន័យនៃប្រព័ន្ធរាយការណ៍អំពី CSAM របស់ APLE បង្ហាញថា ម្ចាស់នៃសេវាបង្ហោះ/ដូមេន បានលុបចោលមាតិកានានាក្នុងចំនួនយ៉ាងលើសលុប នៅពេលមានការស្នើសុំ។ នៅរវាងឆ្នាំ២០១៧ និង ២០១៩ ប្រមាណ៨៥% នៃសេចក្តីរាយការណ៍ដែលត្រូវបានបញ្ជូនទៅកាន់ម្ចាស់ដូមេន ត្រូវបានចាត់ការឱ្យលុបមាតិកាចោល (សូមមើលតារាង ២៤)

### ក្រុមហ៊ុនកម្មវិធីសកល (Global Platforms)

**ការប្រមូលភស្តុតាង៖** សំណៅចុងក្រោយដែលមានសាធារណៈនៃសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាមានបទប្បញ្ញត្តិមួយពាក់ព័ន្ធនឹងជំនួយផ្នែកច្បាប់ទៅវិញទៅមកទាក់ទងនឹងបទល្មើសបច្ចេកវិទ្យារួមទាំងបទល្មើសពាក់ព័ន្ធនឹង CSAM ។ បទប្បញ្ញត្តិបែបនេះសំដៅយ៉ាងគ្រប់ជ្រុងជ្រោយទៅដល់នីតិវិធីខុសៗគ្នានៃករណីព្រហ្មទណ្ឌ ដូចជា ការប្រមូលភស្តុតាង ការស្រាវជ្រាវ ការដកហូត ការរឹបអូស និងការចាប់ខ្លួន។

**បន្ថែមលើនេះ** នៅខែវិច្ឆិកា ឆ្នាំ២០១៩ រដ្ឋាភិបាលបានអនុម័តច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក។ ជំពូកទីប្រាំនៃច្បាប់នេះគ្របដណ្តប់លើទំនួលខុសត្រូវជាសក្តានុពលរបស់អ្នកផ្តល់សេវាកម្មពាណិជ្ជកម្មអេឡិចត្រូនិក និងអន្តរការីនានា ដែលអាចរួមទាំងអង្គភាពអន្តរជាតិចំពោះមាតិកាបរទេស និងសំណើឱ្យដកខ្លឹមសារចេញ។ ចំណុចនេះអាចអនុវត្តបានចំពោះមាតិកាពាក់ព័ន្ធនឹង OCSEA ។

**ការដកចេញ/ការជូនដំណឹងអំពី CSAM៖** ពាក់ព័ន្ធនឹងការដកចេញ/ការជូនដំណឹងអំពី CSAM កម្រមានកិច្ចព្រមព្រៀងផ្លូវការរវាងទីភ្នាក់ងារអនុវត្តច្បាប់ជាតិ និងក្រុមហ៊ុនកម្មវិធីសកលណាស់។ ក្រុមហ៊ុនកម្មវិធីនានានឹងចង់ឃើញសំណើនានាពីដៃគូរដ្ឋាភិបាលទាក់ទងនឹងការជូនដំណឹងអំពីការបំពានជាសក្តានុពលលើលក្ខខណ្ឌនៃការប្រើប្រាស់សេវារបស់ពួកគេច្រើនជាង។ ដោយសារ CSAM ផ្ទុយពីលក្ខខណ្ឌសេវារបស់ក្រុមហ៊ុនកម្មវិធី និងច្បាប់សហរដ្ឋអាមេរិក ហើយក្រុមហ៊ុននឹងមានចំណាប់អារម្មណ៍ក្នុងការដកហូតមាតិកាបែបនេះ
ចេញ។

**នៅពេលខ្លះ៖** អ្នកតំណាងម្នាក់មកពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានពន្យល់ថា "ក្នុងករណីដែល វា [CSAM] ត្រូវបានបង្ហោះនៅក្នុងប្រទេសមួយទៀត ប៉ុន្តែវាពាក់ព័ន្ធនឹងកុមារកម្ពុជា ឬពលរដ្ឋកម្ពុជា យើងអាចបិទការចូលមើលគេហទំព័រនោះនៅទីនេះ ដើម្បីកុំឱ្យប្រជាជនកម្ពុជាអាចមើលឃើញវា។ ឬយើងអាចមានយន្តការដែលអាចមានមួយទៀត តាមរយៈក្រុមឆ្លើយតបនឹងឧប្បត្តិហេតុរបស់យើង ដែលយើងហៅថា CamCert កម្ពុជា។ ក្រុមនេះអាចផ្ញើអ៊ីម៉ែលទៅកាន់ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត នៅប្រទេសដទៃទៀត ដោយស្នើឱ្យលុបចោលលទ្ធភាពចូលមើលគេហទំព័ររំលោភបំពានផ្លូវភេទលើកុមារ។ យើងនឹងគ្រាន់តែត្រូវណែនាំពួកគេថា "យើងបានឃើញឧប្បត្តិហេតុមួយ ដែលរូបភាព/វីដេអូរំលោភបំពានផ្លូវភេទលើកុមារត្រូវបានបង្ហោះនៅក្នុង Server របស់អ្នក តើអ្នកអាចស៊ើបអង្កេត និងដកវាចេញបានដែរឬទេ?" នេះគឺជាអ្វីដែលយើងអាចធ្វើបាន។ (RA១-CA-០៤-A)

## ៣.៤ ការសម្របសម្រួល និងកិច្ចសហការ

### ទិន្នន័យតម្លាភាព

នៅឆ្នាំ២០១៧ ២០១៨ និង២០១៩ របាយការណ៍តម្លាភាពនៃក្រុមហ៊ុនបណ្ដាញទំនាក់ទំនងសង្គមធំៗ បង្ហាញថា អាជ្ញាធរនៅកម្ពុជាបានផ្ញើ៖

- សំណើចំនួនមួយទៅកាន់ Facebook សម្រាប់ការរិតត្បិតចំពោះមាតិកា និងសំណើចំនួនពីរ សម្រាប់ ទិន្នន័យអ្នកប្រើប្រាស់
- សំណើចំនួនមួយ សម្រាប់ទិន្នន័យអ្នកប្រើប្រាស់ Google
- គ្មានសំណើដទៃទៀតទៅកាន់ក្រុមហ៊ុន ឬថ្នាលបច្ចេកវិទ្យានានាដែលពេញនិយមជាសកលឡើយ

តួលេខទាំងនេះបង្ហាញឱ្យឃើញថា ទីភ្នាក់ងារអនុវត្តច្បាប់កម្ពុជាមិនចូលរួមជាប្រចាំនៅក្នុងការប្រមូលភស្តុតាងនិងការប្រមូលព័ត៌មានអេឡិចត្រូនិកឆ្លងកាត់ព្រំដែននៅឆ្នាំ២០១៧-២០១៩ ឡើយ។

* របាយការណ៍តម្លាភាពប្រចាំឆ្នាំនៃវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមសំខាន់ៗផ្តល់ស្ថិតិអំពីចំនួនសំណើសុំទិន្នន័យអ្នកប្រើប្រាស់ និងការដកមាតិកាចេញ ពីអាជ្ញាធររដ្ឋាភិបាលរបស់ប្រទេសនីមួយៗ។ ដោយគ្មានវេទិកាណាមួយបង្ហាញពីចំនួនសំណើជាពិសេសទាក់ទងនឹង OCSEA ទិន្នន័យតម្លាភាពផ្តល់ការចង្អុលបង្ហាញពីវិសាលភាពដែលទីភ្នាក់ងារអនុវត្តច្បាប់នៃប្រទេសផ្សេងៗចូលរួមក្នុងកិច្ចសហប្រតិបត្តិការដោយផ្ទាល់ជាមួយថ្នាលកម្មវិធីពិភពលោកធំៗ ។
* ថ្នាលកម្មវិធីត្រូវបានជ្រើសរើសដោយផ្អែកលើបរិមាណខ្ពស់នៃរបាយការណ៍ទៅកាន់ NCMEC (១០,000+) វត្តមាននៃរបាយការណ៍តម្លាភាព និងប្រជាប្រិយភាពគេបានដឹងនៅក្នុងប្រទេសដែលការសិក្សាស្រាវជ្រាវស្តីពីការបញ្ឈប់គ្រោះថ្នាក់បានផ្តោតការយកចិត្តទុកដាក់។ ក្រៅពីក្រុមហ៊ុនដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក របាយការណ៍តម្លាភាពសម្រាប់ Line និង TikTok ក៏ត្រូវបានពិនិត្យផងដែរ។

# ៤. របៀបក្នុងការបញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា

ការបញ្ឈប់គ្រោះថ្នាក់ពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមតារាងតាមរយៈការបណ្ដាញ នូវចំណាត់ការគ្រប់ជ្រុងជ្រោយ និងដែលមានការទ្រទ្រង់ សម្រាប់យើងទាំងអស់គ្នា ពោលគឺ គ្រួសារ សហគមន៍ អ្នកមានភារកិច្ច មកពីជួររដ្ឋាភិបាល ទីភ្នាក់ងារអនុវត្តច្បាប់ អ្នកប្រកបវិជ្ជាជីវៈសេវាគាំទ្រយុត្តិធម៌ និងសង្គម និងឧស្សាហកម្មបច្ចេកវិទ្យា និងទំនាក់ទំនង។ បើទោះបីជាកុមារគឺជាផ្នែកមួយនៃដំណោះស្រាយក្ដី គ្រោះថ្នាក់ដែលបង្កឡើងដោយ OCSEA កំណត់ឱ្យមនុស្សពេញវ័យត្រូវធ្វើសកម្មភាព ដើម្បីការពារកុមារ ហើយយើងត្រូវតែប្រុងប្រយ័ត្ន ដោយមិនត្រូវដាក់ការទទួលខុសត្រូវច្រើនពេកលើកុមារឡើយ។

អនុសាសន៍លម្អិត សម្រាប់ការធ្វើចំណាត់ការនៅកម្ពុជា ត្រូវបានរៀបចំជាក្រុមនៅក្រោមការយល់ដឹងស៊ីជម្រៅសំខាន់ៗចំនួនប្រាំពីទិន្នន័យនៃគម្រោងស្ដីពី *ការបញ្ឈប់គ្រោះថ្នាក់* និងផ្ដល់ជាសញ្ញា សម្រាប់អ្នកពាក់ព័ន្ធខុសៗគ្នា។ ទោះបីជាយ៉ាងណាក្ដី ចំណាត់ការជាអនុសាសន៍ទាំងអស់នេះមានអន្តរទំនាក់ទំនងគ្នា និងមានប្រសិទ្ធភាពបំផុត ប្រសិនបើ ត្រូវបានអនុវត្តរួមគ្នា។

# ៤.១ ការយល់ដឹងស៊ីជម្រៅជាគន្លឹះចំនួន៦ និងអនុសាសន៍សម្រាប់ធ្វើសកម្មភាព

## ការយល់ដឹងស៊ីជម្រៅទី ១៖

នៅឆ្នាំមុន នៅកម្ពុជា ១១% នៃកុមារកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត អាយុ ១២-១៧ឆ្នាំ គឺជាជនរងគ្រោះនៃការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ ដែលរួមមានការបោកប្រាស់កុមារឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទ ការចែកចាយរូបភាពផ្លូវភេទដោយគ្មានការអនុញ្ញាត ឬការបង្ខិតបង្ខំកុមារឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទ តាមរយៈការសន្យាផ្តល់លុយកាក់ ឬអំណោយផ្សេងៗ។ ប្រសិនបើពង្រីកទៅដល់ចំនួនប្រជាជនទាំងអស់ ចំនួននេះតំណាងឱ្យកុមាប្រមាណ ១៦០.០០០នាក់។ កុមារាបានរាយការណ៍ពីបទពិសោធន៍បែបនេះញឹកញាប់ជាងកុមារីស្ទើរតែពីរដង។

### រដ្ឋាភិបាល

**១.១ កែសម្រួលកម្មវិធីលើកកម្ពស់ការយល់ដឹង និងការអប់រំថ្នាក់ជាតិអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារ** ដើម្បីធ្វើឱ្យមានការយល់ដឹងអំពីតួនាទីដែលបច្ចេកវិទ្យាអាចដើរតួ ក្នុងការសម្របសម្រួលសកម្មភាពរំលោភបំពានប្រភេទនេះ។ ការកែសម្រួល និងការរៀបចំទៅតាមបរិបទចំពោះកម្មវិធីផ្អែកលើភស្តុតាងដែលមានស្រាប់ដែលបង្ហាញថាមានប្រសិទ្ធភាព គប្បីត្រូវបានចាត់ជាអាទិភាព និងទទួលបានការគាំទ្រ។ នៅពេលមានកម្មវិធីបែបនេះ ការអនុវត្តកម្មវិធីទាំងនេះយ៉ាងសមស្រប គប្បីត្រូវបានធានា រួមជាមួយវិធានការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។ ការវាយតម្លៃកិច្ចអន្តរាគមន៍ និងកម្មវិធី គប្បីទាញប្រយោជន៍ពីឧបករណ៍នវានុវត្តន៍ ដូចជា គំរូវាយតម្លៃ នៃកម្មវិធីសុវត្ថិភាពអនឡាញ ដែលត្រូវបានបង្កើតឡើងនៅពេលថ្មីៗនេះដោយក្រុមអ្នកជំនាញសកលស្តីពីសុវត្ថិភាពអនឡាញ។ ក្របខណ្ឌសូចនាករត្រូវបានរចនាឡើងដើម្បីដោះស្រាយបញ្ហាប្រឈមជាក់លាក់នៃតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក និងត្រូវបានសាកល្បងនៅកម្ពុជា។

វាជាការចាំបាច់ត្រូវកែសម្រួល និងសាកល្បងកម្មវិធីទាំងនេះ តាមរយៈការពិគ្រោះយោបល់ជាមួយកុមារ និងអ្នកថែទាំ និងគ្រូបង្រៀន ដើម្បីឆ្លុះបញ្ចាំងការយល់ឃើញរៀងៗខ្លួនរបស់ក្រុមនីមួយៗអំពីហានិភ័យតាមប្រព័ន្ធអនឡាញ និងបច្ចេកទេស ដែលពួកគេប្រើប្រាស់ ដើម្បីធ្វើឱ្យពួកគេ/កូនៗរបស់ពួកគេមានសុវត្ថិភាព។ ការធ្វើបែបនេះនឹងជួយបង្កើតសារសម្រាប់យុទ្ធនាការ ដែលពាក់ព័ន្ធនឹងបទពិសោធន៍ជីវិតរបស់កុមារ ហើយហេតុនេះ វាកាន់តែទំនងជាផ្តល់ការរំលឹកដល់កុមារបន្ថែមទៀត។

គោលបំណងសំខាន់ៗនៃសារទាំងនេះគប្បីរួមមាន៖

- ការផ្តល់ចំណេះដឹង និងជំនាញដល់អ្នកថែទាំ ដើម្បីឱ្យពួកគេប្រើប្រាស់ទំនាក់ទំនងដោយសុវត្ថិភាព និងជាបន្តបន្ទាប់ជាមួយកុមារអំពី សកម្មភាពនៅតាមប្រព័ន្ធអនឡាញ ពោលគឺនៅពេលអាចធ្វើបាន ប្រើប្រាស់កម្មវិធីការចិញ្ចឹមកូនបែបវិជ្ជមានដែលមានស្រាប់នៅកម្ពុជា។
- ជួយគាំទ្រដល់អ្នកថែទាំ ជាពិសេសអ្នកដែលមិនចេះ ឬមិនមានទំនុកចិត្តក្នុងការប្រើប្រាស់អ៊ីនធឺណិតនៅពេលបច្ចុប្បន្ន ឱ្យចេះប្រើប្រព័ន្ធអនឡាញ និងកាន់តែស៊ាំជាមួយកម្មវិធីដែលកុមារកំពុងប្រើប្រាស់។ ផ្តល់ការអប់រំ និងព័ត៌មានផ្អែកលើភស្តុតាងដល់អ្នកថែទាំដើម្បីឱ្យពួកគេចេះកំណត់សម្គាល់ពីអាកប្បកិរិយាកេងប្រវ័ញ្ច ឬរំលោភបំពានពីសំណាក់សមាជិកនៃសហគមន៍ទាំងតាមប្រព័ន្ធអនឡាញ និងក្រៅអនឡាញ។ បែបនេះនឹងជួយពួកគេក្នុងការបង្រៀនដល់កុមារអំពីការកំណត់អាកប្បកិរិយា និងការរក្សាសុវត្ថិភាពតាមប្រព័ន្ធអនឡាញ។
- ជួយមនុស្សពេញវ័យដែលមានទំនាក់ទំនងជាមួយកុមារឱ្យយកឈ្នះលើអារម្មណ៍ដែលមិនមានផាសុកភាពនៅពេលនិយាយអំពីបញ្ហាផ្លូវភេទជាមួយកុមារ និងលើកទឹកចិត្តឱ្យមានការពិភាក្សាដោយបើកចំហអំពីការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចលើប្រព័ន្ធអ៊ីនធឺណិត ឬដោយផ្ទាល់។ នៅក្នុងរយៈពេលវែង កិច្ចការនេះនឹងធ្វើឱ្យអ្នកថែទាំកាន់តែមានភាពងាយស្រួលក្នុងការនិយាយជាមួយកូនៗរបស់ពួកគេ និងគាំទ្រកូនៗរបស់ពួកគេ ព្រមទាំងធ្វើឱ្យកុមារកាន់តែទៅរកអ្នកថែទាំរបស់ពួកគេ ដើម្បីទទួលបានជំនួយ នៅពេលពួកគេត្រូវការ។ ជាការពិត ភាគច្រើននៃអ្នកថែទាំរបស់កុមារដែលកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ក៏ចូលលេងអ៊ីនធឺណិតជាញឹកញាប់ និងភាគច្រើនកុមារចូលលេងអ៊ីនធឺណិតពីផ្ទះ ដូច្នេះវាជាឱកាសសំខាន់សម្រាប់អ្នកថែទាំក្នុងការបង្រៀនកូនៗរបស់ពួកគេអំពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ។

សារទាំងនេះ អាចត្រូវផ្សព្វផ្សាយទៅដល់កុមារ តាមរយៈប្រភពដែលពួកគេចង់បាន។ ទិន្នន័យនៃគម្រោងស្តីពី*ការបញ្ឈប់គ្រោះថ្នាក់* បង្ហាញថាគ្រូបង្រៀននៅសាលា គឺជាប្រភពបឋម (៨៨%) និងជាប្រភពជាទីចង់បាន (៥០%) នៃការអប់រំ និងព័ត៌មានពាក់ព័ន្ធនឹងបញ្ហាផ្លូវភេទ។ សម្រាប់កុមារមួយចំនួន គ្រូបង្រៀនក៏ជាតួអង្គសំខាន់សម្រាប់កុមារនិយាយប្រាប់ មួយក្នុងចំណោមតួអង្គនានាផ្សេងទៀតផងដែរ។ ការបង្កការចូលរួមរបស់គ្រូបង្រៀននៅក្នុងយុទ្ធនាការនានា គឺជាមធ្យោបាយដ៏ចាំបាច់មួយ ក្នុងការផ្សព្វផ្សាយសារគន្លឹះ ប៉ុន្តែក៏ត្រូវកសាងទំនុកចិត្ត និងអារម្មណ៍សុវត្ថិភាព ដើម្បីពង្រឹងឱកាស សម្រាប់ការសន្ទនាដោយបើកចំហរ និងការនិយាយចេញអំពីបញ្ហាផងដែរ។

**១.២ វិនិយោគលើកម្មវិធីអក្ខរកម្មឌីជីថលសម្រាប់ទាំងកុមារ និងអ្នកថែទាំ** ដើម្បីធានាថា កុមារ និងអ្នកថែទាំមិនត្រឹមតែយល់ដឹងអំពីហានិភ័យដែលអាចមានប៉ុណ្ណោះទេ ប៉ុន្តែធានាពួកគេដឹងអំពីអ្វីដែលត្រូវធ្វើចំពោះ

ហានិភ័យទាំងនោះផងដែរ។ មានសេចក្តីត្រូវការចាំបាច់មួយសម្រាប់ការបណ្តុះបណ្តាល អំពីអក្ខរកម្មឌីជីថលគ្រប់ជ្រុងជ្រោយ និងសុវត្ថិភាព។ កិច្ចការនេះគប្បីរួមបញ្ចូលនូវព័ត៌មានអំពីអ្វីដែលកុមារអាចធ្វើបាន ប្រសិនបើពួកគេរងការរំខាននៅតាមប្រព័ន្ធអនឡាញ ប្រភេទនិងមាតិកាដែលសមស្របសម្រាប់ការចែកចាយនៅតាមប្រព័ន្ធអនឡាញជាមួយនឹងអ្នកដទៃទៀត និងជំនាញមូលដ្ឋាននានា របៀបផ្លាស់ប្តូរការកំណត់ឯកជនភាពរបស់ពួកគេ និងការប្លុកមនុស្សទាំងឡាយពីការទំនាក់ទំនងមកកាន់ពួកគេ។ ព័ត៌មាននេះអាចត្រូវបញ្ចូលនៅក្នុងកម្មវិធីការចិញ្ចឹមកូនបែបវិជ្ជមាន។ ដោយសារកុមារចំនួនមួយភាគបីប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត នៅសាលារៀន មានសេចក្តីត្រូវការក្នុងការឱ្យពិចារណាលើការដាក់បញ្ចូលការអប់រំអំពី សុវត្ថិភាពនៃប្រព័ន្ធបច្ចេកវិទ្យាទៅក្នុងកម្មវិធីសិក្សារបស់សាលារៀន។ ទិន្នន័យនៃគម្រោងស្តីពីការបញ្ឈប់គ្រោះថ្នាក់ បង្ហាញថា កុមារ

វ័យក្មេងអាយុ ១២-១៤ឆ្នាំមិនសូវជាទទួលស្គាល់ហានិភ័យតាមប្រព័ន្ធអនឡាញដូចកុមារមានអាយុ ១៦-១៧ឆ្នាំឡើយ ហេតុនេះយុទ្ធនាការលើកកម្ពស់ការយល់ដឹងគប្បីផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះក្រុមអាយុនេះ។

### អ្នកថែទាំ គ្រូបង្រៀន និងសេវាគាំទ្រសង្គម

**១.៣ ចូលរួមជាមួយកុមារដើម្បីលើកទឹកចិត្តឱ្យមានការសន្ទនាដោយបើកចំហរ** និងផ្តល់ការយល់ដឹងស៊ីជម្រៅ អំពីទំនាក់ទំនង និងអាកប្បកិរិយាសមស្របទាំងនៅក្នុង និងក្រៅប្រព័ន្ធអនឡាញ។ ទទួលបានព័ត៌មានអំពី ហានិភ័យបច្ចុប្បន្ន និងហានិភ័យដែលកំពុងលេចឡើងចំពោះកុមារ។ សូមដឹងថា នៅកម្ពុជា ភស្តុតាងបង្ហាញឱ្យឃើញថាកុមារាទំនងជារាយការណ៍អំពីការជួបប្រទះនឹង OCSEA ច្រើនជាងកុមារីចំនួនពីរដង។

## ការយល់ដឹងស៊ីជម្រៅ ២៖

ដោយយោងតាមការអង្កេតតាមខ្នងផ្ទះ ជាញឹកញាប់បំផុត ជនល្មើសនៃ OCSEA គឺជាមនុស្សដែលបានស្គាល់កុមាររួចហើយ។ អ្នកទាំងនេះច្រើនតែជាសមាជិកគ្រួសារ មិត្តភក្តិពេញវ័យ និងមិត្តភក្តិ ឬដៃគូស្នេហា។ ករណី១ក្នុងចំណោម៥ ទាក់ទងនឹង OCSEA ដែលត្រូវបានកំណត់នៅក្នុងការអង្កេតតាមខ្នងផ្ទះ គឺពីដំបូងមិនស្គាល់កុមារទេ។

### រដ្ឋាភិបាល

**២.១ កិច្ចខិតខំលើកកម្ពស់ការអប់រំ និងការយល់ដឹងមិនគួរផ្តោតតែលើគ្រោះថ្នាក់នៃជនចម្លែកមុខដោយមិនសមហេតុផលនោះទេ។** គម្រោងស្តីពីការរបញ្ឈប់គ្រោះថ្នាក់ បានបង្ហាញថា កុមារទំនងជាត្រូវបានស្នើឱ្យនិយាយអំពីការរួមភេទ ឬចែករំលែកនូវសម្ភារផ្លូវភេទដោយមនុស្សដែលកុមារបានស្គាល់ ជាជាងមនុស្សដែលកុមារមិនធ្លាប់ស្គាល់តាមអ៊ីនធឺណិត។ កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនការយល់ដឹងដល់កុមារ អ្នកថែទាំ និងគ្រូបង្រៀនឱ្យយល់ដឹងអំពីហានិភ័យនៃការចែកចាយរូបភាពតាមអនឡាញ គួរចៀសវាងការផ្តោតលើកម្រិតមិនស្មើគ្នាទៅលើ "គ្រោះថ្នាក់ពីមនុស្សចម្លែកមុខ" នោះឡើយ។ រៀបចំសារអប់រំ និងសម្ភារដោយមានជំនួយពីអ្នកជំនាញ និងរួមបញ្ចូលនូវចំណុចសំខាន់ផ្សេងៗនៃ OCSEA រួមមាន ព័ត៌មានអំពីទីកន្លែងដែលសម្រាប់ស្វែងរកជំនួយ ប្រសិនបើកុមារស្ថិតក្នុងគ្រោះថ្នាក់ ឬត្រូវការការគាំទ្រ និងរបៀបដែលអ្នកថែទាំ និងសហគមន៍អាចជម្រុញឱ្យមានបណ្តាញទំនាក់ទំនងប្រកបដោយសុវត្ថិភាពសម្រាប់កុមារ។

**២.២ អភិក្រមអប់រំ និងលើកកម្ពស់ការយល់ដឹងសមស្របទៅតាមអាយុចាំបាច់ត្រូវគ្របដណ្តប់ដល់កុមារទាំងអស់។** នៅពេលកុមារមិនមានព័ត៌មានទាំងអស់ វាជួយឱ្យជនល្មើសងាយទាញប្រយោជន៍បាន។ បរិយាប័ន្នគឺចាំបាច់នៅក្នុងការផ្សព្វផ្សាយសារទាំងនេះ។ យើងត្រូវតែធានាថា ចំណេះដឹងត្រូវបានផ្តល់ទៅដល់កុមារទាំងអស់ និងរួមបញ្ចូលព័ត៌មានអំពីបញ្ហាផ្លូវភេទ ការយល់ព្រម ព្រំដែនផ្ទាល់ខ្លួន អ្វីដែលមនុស្សពេញវ័យ ឬអ្នកដទៃទៀតនៅជុំវិញកុមារអាច ឬមិនអាចធ្វើចំពោះកុមារ។ កុមារវ័យក្មេងអាយុ ១២-១៤ឆ្នាំ មិនសូវចេះសម្គាល់ហានិភ័យចំពោះគ្រោះថ្នាក់សក្តានុពលនៃសកម្មភាពតាមប្រព័ន្ធអនឡាញឡើយ បើធៀបនឹងកុមារធំៗអាយុ ១៦-១៧ឆ្នាំ។ បើទោះបីជាការពិភាក្សាអំពីបញ្ហាទាំងនេះជាមួយកុមារអាចមិនងាយស្រួលក្តី កុមារតូចៗក៏គប្បីជាគោលដៅនៅក្នុងកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការយល់ដឹងផងដែរ។ ភាគច្រើនបំផុតនៃកុមារដែលបានចូលរួមនៅក្នុងការអង្កេតបានលើកឡើងថា គ្រូបង្រៀនគឺជាប្រភពដែលពួកគេចង់បានពាក់ព័ន្ធនឹងការអប់រំអំពីបញ្ហាផ្លូវភេទ ហេតុនេះយន្តការដែលមានស្រាប់របស់ក្រសួងអប់រំ យុវជន និងកីឡា គប្បីត្រូវបានពង្រីក ដើម្បីបញ្ចូលការអប់រំអំពីបញ្ហាផ្លូវភេទដែលពាក់ព័ន្ធនៅក្នុងទាំងសាលារៀនបឋមសិក្សា និងសាលារៀនមធ្យមសិក្សា។

គប្បីយកចិត្តទុកដាក់ជាពិសេសផងដែរ ក្នុងការធានាថា ព័ត៌មាននេះត្រូវបានផ្តល់ដល់កុមារ ដែលស្ថានភាពនោះអាចបង្កើនភាពងាយរងគ្រោះរបស់ពួកគេចំពោះ OCSEA រួមមាន កុមារដែលមានពិការភាព កុមារទេសន្តរប្រវេសន៍ កុមាររស់នៅតាមដងផ្លូវ និងកុមារដែលមិនបានទៅរៀន។ អង្គការមិនមែនរដ្ឋាភិបាលអាចមានតួនាទីយ៉ាងល្អក្នុងការផ្តល់ព័ត៌មានទៅដល់ក្រុមងាយរងគ្រោះទាំងនេះ។ សកម្មភាពចុះដល់មូលដ្ឋាន និងសកម្មភាពអប់រំក្រៅប្រព័ន្ធដែលមានស្រាប់ ដូចជាសកម្មភាពនានា ដែលអនុវត្តដោយកម្មវិធីភាពជាដៃគូ ដើម្បីការពារកុមារអាចត្រូវបានពង្រីក ដើម្បីមានឥទ្ធិពលបែបនោះ។

បន្ថែមពីលើអ្វីដែលមានរួចហើយនៅក្នុងប្រទេសកម្ពុជា មានរបាយការណ៍ និងគំនិតផ្តួចផ្តើមផ្សេងទៀតដែលត្រូវបានបង្កើតឡើងជាអន្តរជាតិ ដែលអាចយកធ្វើជាឯកសារយោងដ៏មានប្រយោជន៍ និងជាឧទាហរណ៍ពីឧត្តម្មានុវត្តទាក់ទងនឹងការបង្កើតធនធានសមស្របតាមអាយុ។

**២.៣ ជួយដល់អ្នកថែទាំដែលមានទំនាក់ទំនងជាមួយកុមារក្នុងការជម្នះភាពគ្មានផាសុកភាពនៅក្នុងការពិភាក្សាអំពីបញ្ហាផ្លូវភេទ និងអត្តសញ្ញាណភេទជាមួយកុមារ។ ការធ្វើបែបនេះអាចលើកទឹកចិត្តឱ្យមានការសន្ទនាដោយបើកចំហរអំពីការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ឬដោយជួបគ្នាផ្ទាល់។** សេចក្តីណែនាំ និងការកសាងជំនាញ សម្រាប់អ្នកថែទាំអាចត្រូវផ្តល់តាមរយៈអន្តរាគមន៍ និងកម្មវិធីលើកកម្ពស់ការចិញ្ចឹមកូនបែបវិជ្ជមានដែលមានស្រាប់របស់រដ្ឋាភិបាល។ នៅក្នុងរយៈពេលវែង កិច្ចការនេះនឹងធ្វើឱ្យអ្នកថែទាំកាន់តែមានភាពងាយស្រួលក្នុងការនិយាយជាមួយកូនៗរបស់ពួកគេ និងគាំទ្រកូនៗរបស់ពួកគេ ព្រមទាំងធ្វើឱ្យកុមារកាន់តែទៅរកអ្នកថែទាំរបស់ពួកគេ ដើម្បីរកជំនួយ នៅពេលពួកគេត្រូវការ។ ផ្តល់ការអប់រំ និងព័ត៌មានផ្អែកលើភស្តុតាងទៅដល់អ្នកថែទាំ ដើម្បីឱ្យពួកគេអាចដឹងអំពី អាកប្បកិរិយាកេងប្រវ័ញ្ច ឬរំលោភបំពានពីសំណាក់សមាជិកសហគមន៍ នៅក្នុង និងក្រៅប្រព័ន្ធអនឡាញ។ ការធ្វើបែបនេះក៏នឹងជួយពួកគេក្នុងការបង្រៀនកុមារអំពី របៀបកំណត់អាកប្បកិរិយាបែបនេះ និងរបៀបរក្សាឱ្យមានសុវត្ថិភាពផងដែរ។ ការអនុវត្តល្អៗមានរួចហើយ និងអាចត្រូវបានកែសម្រួល សម្រាប់ការប្រើប្រាស់នៅក្នុងបរិបទមូលដ្ឋាន។

### អ្នកថែទាំ គ្រូបង្រៀន និងសេវាគាំទ្រសង្គម

**២.៤ បំពេញតួនាទីយ៉ាងសកម្មក្នុងការបង្រៀនកុមារអំពីការរួមភេទ ការយល់ព្រម និងការកំណត់ព្រំដែន និងអ្វីដែលមនុស្សពេញវ័យ ឬអ្នកផ្សេងទៀតនៅជុំវិញពួកគេអាច ឬមិនអាចធ្វើចំពោះពួកគេ និងរបៀបនិយាយថា ទេ ចំពោះអ្នកដទៃ។** ទាំងនេះអាចលើកទឹកចិត្តឱ្យមានការជជែកពិភាក្សាដោយបើកចំហអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ឬដោយផ្ទាល់។ ចំណុចទាំងនេះមានសារៈសំខាន់ណាស់ ពិសេសចាប់តាំងពីទិន្នន័យបង្ហាញថា ជនល្មើសអាចជាមនុស្សជិតស្និទ្ធនឹងកុមារ។ រយៈពេលវែង កិច្ចការនេះនឹងធ្វើឱ្យអ្នកថែទាំកាន់តែមានភាពងាយស្រួលក្នុងការនិយាយជាមួយកូនៗរបស់ពួកគេនិងគាំទ្រកូនៗរបស់ពួកគេ ព្រមទាំងធ្វើឱ្យកុមារកាន់តែទៅរកអ្នកថែទាំរបស់ពួកគេ ដើម្បីរកជំនួយ នៅពេលពួកគេត្រូវការ។

**២.៥ ជួយកុមារ អ្នកថែទាំ គ្រូបង្រៀន និងអ្នកទាំងឡាយ ដែលធ្វើការងារជាមួយកុមារ ឱ្យយល់អំពីកម្រិតពេញលេញនៃហានិភ័យនៃការចែកចាយមាតិកាផ្លូវភេទ** និងរបៀបចូលរួមនៅក្នុងការកាត់បន្ថយគ្រោះថ្នាក់ ដើម្បីដាក់កម្រិតទៅលើផលវិបាកអវិជ្ជមាន។ សមាមាត្រខ្ពស់បំផុតនៃកុមារដែលបានចែកចាយមាតិកាបែបផ្លូវភេទ ដំបូងឡើយពួកគេធ្វើបែបនេះដោយសារពួកគេធ្លាក់ក្នុងសេចក្តីស្រឡាញ់(២៩%)ឬពួកគេបានទុកចិត្តជនដទៃទៀត (២០%) ប៉ុន្តែអាកប្បកិរិយានេះអាចនាំទៅរកគ្រោះថ្នាក់ធ្ងន់ធ្ងរ ដូចជា ការចែកចាយមាតិកានេះដោយគ្មានការយល់ព្រមជាមួយនឹងមនុស្សដទៃទៀត និងការគំរាមកំហែងក្នុងគោលបំណងពាក់ព័ន្ធនឹងផ្លូវភេទ។

## ការយល់ដឹងស៊ីជម្រៅទី ៣៖

**កុមារទទួលរងគ្រោះពី OCSEA ជាចម្បង តាមរយៈបណ្តាញទំនាក់ទំនងសង្គមទូទៅ ដូចជា តាមរយៈ Facebook / Facebook Messenger និង WhatsApp ។**

### រដ្ឋាភិបាល

**៣.១ ដាក់កាតព្វកិច្ចផ្លូវច្បាប់លើក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតក្នុងស្រុក** ឱ្យប្រតិបត្តិជាបន្ទាន់តាមសំណើសុំព័ត៌មានរបស់ទីភ្នាក់ងារអនុវត្តច្បាប់ រក្សាទិន្នន័យសម្រាប់រយៈពេលនៃបទល្មើស និងចម្រោះ ប្លុក និង/ឬលុប សម្ភាររំលោភបំពានផ្លូវភេទកុមារ (CSAM) ចេញ។ ការធ្វើបែបនេះនឹងជួយដល់ការស៊ើបអង្កេតបទល្មើស ព្រមទាំងគ្រប់គ្រងការចែកចាយ CSAM យ៉ាងទូលំទូលាយផងដែរ។ https://www.msn.com/th-th/feed

**៣.២ លើកកម្ពស់ការយល់ដឹងអំពី OCSEA ក្នុងចំណោមវិស័យឯកជន រួមទាំងក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត និងក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័ត** ដើម្បីពង្រឹងការយល់ដឹងអំពីហានិភ័យចំពោះកុមារ និងអ្វីដែលពួកគេអាចធ្វើបាន ដើម្បីប្រយុទ្ធប្រឆាំងនឹង OCSEA ។ លើកកម្ពស់គំនិតផ្តួចផ្តើមពហុវិស័យ ដូចជាកម្មវិធីរបស់ UNICEF និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីរៀបចំ ឬពង្រឹងគោលនយោបាយកិច្ចការពារកុមារផ្ទៃក្នុងរបស់តួអង្គ ICT ដោយធានាថាគោលនយោបាយទាំងនេះស្របជាមួយនឹងបទដ្ឋានអន្តរជាតិ។

---

* កម្មវិធី eSafety Commissioner របស់អូស្ត្រាលី ‘Start the Chat’ ដើម្បីលើកទឹកចិត្តអ្នកថែទាំឱ្យនិយាយជាមួយកូនអំពីជីវិតរបស់ខ្លួនគេនៅលើអ៊ីនធឺណិត ហើយកម្មវិធី eSafety Commissioner's សម្រាប់មនុស្សវ័យចំណាស់ដែលនៅលើអ៊ីនធឺណិតជាលើកដំបូង ‘Be Connected’.

* រដ្ឋាភិបាល ទីភ្នាក់ងារអន្តររដ្ឋាភិបាល និងសង្គមស៊ីវិលចាំបាច់ត្រូវបកប្រែ និងបញ្ជូនសារទាំងនេះទៅដល់អ្នកថែទាំ សហគមន៍ បុគ្គលិកពេទ្យ និងគ្រូបង្រៀន។.

* ចំណុចចាប់ផ្តើមដ៏ល្អសម្រាប់ការរុករកគឺជា ឧបករណ៍ឥតគិតថ្លៃដែលអាចរកបានដោយ eSafety Commissioner របស់អូស្ត្រាលី ក៏ដូចជា ក្របខណ្ឌនេះដែលបានបង្កើតឡើងដោយអង្គការ UNICEF ។.

## ៤.១ ការយល់ដឹងស៊ីជម្រៅជាគន្លឹះចំនួន៦ និងអនុសាសន៍សម្រាប់ធ្វើសកម្មភាព

### ទីភ្នាក់ងារអនុវត្តច្បាប់

៣.៣ ពង្រឹង និងពង្រីកយន្តការសហការដែលមានស្រាប់ជាមួយកម្មវិធីបណ្ដាញទំនាក់ទំនងសង្គមសកល ដើម្បីធានានូវការប្រមូលភស្តុតាងឌីជីថល ដែលផ្ដល់ដោយកម្មវិធីទាំងនេះយ៉ាងទាន់ពេលវេលា និងមានប្រសិទ្ធភាព ជាពិសេស នៅក្នុងទម្រង់ជាសំណើសុំទិន្នន័យ និងនីតិវិធីលុបមាតិកាចេញ។

### ឧស្សាហកម្ម

**៣.៤ ធ្វើឱ្យយន្តការនៃការជូនដំណឹង ប្លុក និងរាយការណ៍នៅក្នុងកម្មវិធីអនឡាញមានលក្ខណច្បាស់លាស់ និងងាយប្រើប្រាស់សម្រាប់កុមារ។** យន្តការទាំងនេះគប្បីមានលក្ខណកុមារមេត្រី និងបង្ហាញយ៉ាងច្បាស់អំពីអ្វីដែលកុមារអាចរំពឹងទុកបាន បន្ទាប់ពីរាយការណ៍។ បណ្ដាកម្មវិធី និងក្រុមហ៊ុនផ្ដល់សេវានានាត្រូវតែបង្ហាញពីតម្លាភាព និងគណនេយ្យភាពចំពោះរបៀបដែលពួកគេធ្វើការឆ្លើយតបយ៉ាងទាន់ពេលវេលាចំពោះសេចក្ដីរាយការណ៍របស់កុមារ។ **ចូលរួមជាមួយទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ** ដើម្បីពង្រឹងការបណ្ដុះបណ្ដាលបុគ្គលិកស្ដីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ និងការរាយការណ៍អំពី OCSEA ។

**៣.៥ ពង្រឹងកិច្ចសហការជាមួយទីភ្នាក់ងាររដ្ឋាភិបាល និងទីភ្នាក់ងារមិនមែនរដ្ឋាភិបាលនៅក្នុងការរៀបចំវិធានការទប់ស្កាត់** ដោយមានការចូលរួមរបស់សាធារណជន និងពង្រឹងការរៀបចំដំណោះស្រាយបច្ចេកវិទ្យាប្រកបដោយនវានុវត្តន៍ ដើម្បីដោះស្រាយបញ្ហា OCSEA ។

**៣.៦ អនុវត្តបទដ្ឋាននានាដើម្បីលុបចោលយ៉ាងសកម្មនូវមាតិកាមិនសមរម្យដែលកុមារអាចមើលឃើញនៅតាមប្រព័ន្ធអនឡាញ ជាពិសេសនៅតាមបណ្ដាកម្មវិធីទំនាក់ទំនងសង្គម។** នៅកម្ពុជា កុមារចំនួនពាក់កណ្ដាលបានមើលឃើញមាតិកាបែបផ្លូវភេទដោយចៃដន្យនៅឆ្នាំមុននៅលើបណ្ដាញទំនាក់ទំនងសង្គម (ការបង្ហោះលើបណ្ដាញទំនាក់ទំនងសង្គមចំនួន ៣៥% ការផ្ញើសារដោយផ្ទាល់តាមរយៈបណ្ដាញទំនាក់ទំនងសង្គមចំនួន ១៥%)។

**៣.៧ ផ្ដល់អាទិភាពដល់តម្រូវការរបស់កុមារក្នុងដំណើរការរចនាផលិតផល។** ការរចនាបែបនេះត្រូវតែពឹងផ្អែកលើភស្តុតាងស្ដីពីការអនុវត្តឌីជីថលរបស់កុមារ និងបទពិសោធន៍របស់ពួកគេ អំពីការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ រួមទាំងការសិក្សាស្ដីពី 'ការបញ្ឈប់គ្រោះថ្នាក់' នេះ។

### ការយល់ដឹងស៊ីជម្រៅទី ៤៖

**កុមារដែលបានទទួលរងគ្រោះពីបទល្មើសពាក់ព័ន្ធនឹង OCSEA ទំនងជាទុកចិត្តមនុស្សនៅក្នុងបណ្ដាញអន្តរបុគ្គលរបស់ពួកគេ ជាពិសេស មិត្តភក្តិ អ្នកថែទាំជាមនុស្សប្រុស និងបងប្អូនបង្កើត របស់ពួកគេ។ កុមារចំនួនតិចតួចណាស់ដែលងាកទៅរកយន្តការរាយការណ៍ផ្លូវការ ដូចជា បណ្ដាញទូរស័ព្ទរាយការណ៍ បណ្ដាញទូរស័ព្ទជំនួយ ឬនគរបាល។**

### រដ្ឋាភិបាល

**៤.១ បង្កើតយន្តការកម្រិតសហគមន៍សម្រាប់ការលាតត្រដាងប្រាប់ និងការរាយការណ៍។** ដោយទទួលស្គាល់ថា កុមារទំនងជាចង់លាតត្រដាងអំពីការរំលោភបំពានចំពោះអ្នកទាំងឡាយនៅក្នុងបណ្ដាញអន្តរបុគ្គលដែលមានស្រាប់របស់ពួកគេច្រើនជាង (ជាញឹកញាប់បំផុតមិត្តភក្តិ និងអ្នកថែទាំ) ការផ្ដល់យន្តការចម្រុះគ្នា ដែលនឹងផ្ដល់ការគាំទ្រល្អបំផុតដល់កុមាររងផលប៉ះពាល់ ក្នុងការចែករំលែកសាច់រឿងរបស់ពួកគេក្នុងលក្ខណមានសុវត្ថិភាព គឺជាការចាំបាច់។ ឧទាហរណ៍ បង្កើតកម្មវិធីនានា ដែលសមាជិកសហគមន៍ទទួលបានការបណ្ដុះបណ្ដាលអាចជួយកុមារ និងគ្រួសាររបស់ពួកគេអំពីដំណើរការរាយការណ៍ និងការស្វែងរកជំនួយ។ យន្តនាការផ្លាស់ប្ដូរអាកប្បកិរិយា Cambodia PROTECT/គ្រួសាររឹងមាំ អាចត្រូវបានប្រើប្រាស់ដើម្បីផ្សព្វផ្សាយព័ត៌មានអំពី យន្តការរាយការណ៍ ហើយទិដ្ឋភាពសហគមន៍អាចត្រូវបានបញ្ចូលជាផ្នែកមួយនៃកម្មវិធីការចូលរួមរបស់សហគមន៍នៃយុទ្ធនាការ Cambodia PROTECT ។

**៤.២ ដោយសារថាកុមារពឹងផ្អែកយ៉ាងខ្លាំងលើបណ្ដាញអន្តរបុគ្គលរបស់ពួកគេ ដើម្បីទទួលបានការគាំទ្រ ជាពិសេស មិត្តភក្តិ ពិចារណាបង្កើតកម្មវិធីនានា ដែលពឹងផ្អែកជាផ្នែកលើការផ្ដល់ភាពអង់អាចដល់កុមារ ដើម្បីលើកទឹកចិត្តមិត្តភក្តិរបស់ពួកគេក្នុងការរាយការណ៍អំពីបទពិសោធន៍នៃការរំលោភបំពានរបស់ពួកគេ។** សំណេរដែលមានស្រាប់បានរកឃើញថា គំនិតផ្ដួចផ្ដើមនានានៅក្នុងតំបន់នេះមានប្រសិទ្ធភាពនៅក្នុងការពង្រឹងការយល់ដឹងរបស់កុមារអំពី OCSEA និងនៅក្នុងការបង្កើនអត្រានៃការលាតត្រដាងអំពីបញ្ហានេះ។

---

* គំរូនៃការឆ្លើយតបជាតិលេខ ៣។
* គំរូនៃការឆ្លើយតបជាតិលេខ ៤។

**៤.៣ បង្កើនកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការយល់ដឹងអំពីបណ្តាញរាយការណ៍បន្ទាន់ និងបណ្តាញ** ទូរស័ព្ទជំនួយ ដែលបណ្តាញទាំងពីរនេះជាយន្តការរាយការណ៍ និងស្វែងរកជំនួយសម្រាប់ករណី OCSEA។ ទិន្នន័យរបស់យើងបង្ហាញថា កុមារពេញចិត្តប្រាប់មនុស្សដែលពួកគេស្គាល់ និងទុកចិត្តអំពី OCSEA។ កិច្ចខិតខំលើកកម្ពស់ការយល់ដឹងអាចទំនាក់ទំនងជាមួយក្រុមមិត្តអប់រំមិត្ត បងប្អូន អ្នកថែទាំ និងគ្រូបង្រៀនដែលពួកគេអាចស្វែងរកព័ត៌មាន សេវាគាំទ្រ និងជំនួយជាមួយបណ្តាញទូរស័ព្ទជំនួយ។ អ្វីដែលជាតម្រូវការសំខាន់នោះគឺ បណ្តាញទូរស័ព្ទជំនួយទាំងនោះត្រូវតែមានធនធាន និងទទួលបានការពង្រឹងសមត្ថភាពគ្រប់គ្រាន់អំពី OCSEA ដូច្នេះពួកគេអាចផ្តល់នូវព័ត៌មាន និងផ្តល់ប្រឹក្សាប្រកបដោយគុណភាពល្អ។

**៤.៤ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃបណ្តាញទូរស័ព្ទជំនួយ និងបណ្តាញរាយការណ៍បន្ទាន់** តាមរយៈការផ្តល់ដល់ពួកគេនូវធនធានគ្រប់គ្រាន់ ការរៀបចំគោលការណ៍ណែនាំប្រតិបត្តិ និងយន្តការសម្របសម្រួល។ ទោះបីជាកុមារបានដឹងអំពីបណ្តាញទូរស័ព្ទជំនួយនេះក្តី ប្រសិនបើ មានការឆ្លើយតបដំបូងខ្សោយចំពោះការបង្ហាញ និងការស្វែងរកជំនួយ កុមារ និងអ្នកដទៃទៀតដែលមើលឃើញករណីនេះនឹងមិនទំនងជាស្វែងរកជំនួយម្តងទៀតឡើយ។

**៤.៥ ការវិនិយោគលើការពង្រឹងចំណេះដឹង និងជំនាញពាក់ព័ន្ធនឹង OCSEA របស់កម្លាំងការងារសេវាសង្គម។** ពង្រឹងសមត្ថភាពរបស់បុគ្គលិកជួរមុខក្នុងការកំណត់ហានិភ័យរបស់កុមារ ឬកុមារដែលបានជួបប្រទះនឹងបញ្ហា OCSEA ឱ្យកាន់តែប្រសើរ។ កម្លាំងការងារទាំងនេះរួមមានគ្រូបង្រៀន បុគ្គលិកសង្គម បុគ្គលិកសុខាភិបាល និងអ្នកទាំងឡាយដែលផ្តល់ការគាំទ្រចិត្តសង្គម។

**៤.៦ ផ្តល់ធនធានដល់បណ្តាញទូរស័ព្ទជំនួយកុមារ និងបណ្តាញរាយការណ៍បន្ទាន់អំពី CSAM ដើម្បីធ្វើឱ្យប្រសើរឡើងនូវការរក្សាកំណត់ត្រា ដូច្នេះពួកគេអាចបង្កើតស្ថិតិលម្អិតអំពី OCSEA ដែលបានរាយការណ៍។** ការបង្កើនសមត្ថភាពរបស់អង្គការទាំងនេះក្នុងការប្រមូល និងវិភាគទិន្នន័យនឹងផ្តល់នូវការយល់ដឹងកាន់តែប្រសើរឡើងអំពីបទពិសោធន៍របស់កុមារអំពី OCSEA រួមទាំងរបៀបដែលវាផ្លាស់ប្តូរក្នុងពេលវេលាណាមួយ ដែលអាចជួយបង្កើតកម្មវិធីបង្ការ និងគោលនយោបាយចាំបាច់នានា និងការធ្វើវិសោធនកម្មច្បាប់។

## អ្នកថែទាំ គ្រូបង្រៀន និងសេវាគាំទ្រសង្គម

**៤.៧ ជំរុញបរិយាកាសប្រកបដោយសុវត្ថិភាព និងមានភាពងាយស្រួលសម្រាប់កុមារ ក្នុងការស្វែងរកព័ត៌មាន ការគាំទ្រប្រឹក្សាយោបល់អំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។** និយាមដែលរឹតត្បិតការជជែកពិភាក្សាអំពីការរួមភេទ ឬដែលអាចធ្វើឱ្យកុមារមានអារម្មណ៍អាម៉ាស់ និងអៀនខ្មាស់នៅពេលពួកគេទទួលរងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ និងមានការលាក់បាំងក្នុងការស្វែងរកជំនួយផ្សេងៗ។

**៤.៨ ការឆ្លើយតបចំពោះការលាតត្រដាងពីបញ្ហា OCSEA គប្បីតែងតែបង្ហាញឱ្យឃើញថា ការរំលោភបំពានមិនមែនជាកំហុសរបស់កុមារឡើយ។** ការស្រាវជ្រាវនៃគម្រោង *ការបញ្ឈប់គ្រោះថ្នាក់* បង្ហាញថា ជាញឹកញាប់ កុមារដែលបានរងគ្រោះនៃ OCSEA តែងតែបន្ទោសខ្លួនឯង និងមានអារម្មណ៍ថា ពួកគេបានធ្វើឱ្យអ្នកថែទាំរបស់ពួកគេ និងអ្នកដទៃទៀត អស់សង្ឃឹម។ កុមារក៏រាយការណ៍អំពីអារម្មណ៍នៃការវាយតម្លៃពីសំណាក់នគរបាលផងដែរ។ ការឆ្លើយតបទាំងអស់ ការទំនាក់ទំនងជាមួយកុមារ ដែលរងផលប៉ះពាល់ពីបញ្ហា OCSEA គប្បីត្រូវធ្វើឡើងដោយគ្មានការវាយតម្លៃ ឬទណ្ឌកម្ម។ ឧទាហរណ៍ សូមមើលគោលការណ៍ណែនាំ អំពីការឆ្លើយតបជួរទីមួយចំពោះការធ្វើបាបកុមារ។

**៤.៩ ជៀសវាងការរិតត្បិតចំពោះការប្រើប្រាស់អ៊ីនធឺណិតរបស់កុមារដើម្បីជាការឆ្លើយតបចំពោះគ្រោះថ្នាក់ដែលអាចកើតមាន។** មួយភាគបីនៃអ្នកថែទាំបាននិយាយថា ពួកគេនឹងដាក់ការរិតត្បិតចំពោះការប្រើប្រាស់ប្រព័ន្ធអ៊ីនធើណិតរបស់កូនពួកគេ ប្រសិនបើ កូនរបស់ពួកគេបានរងការរំខានពីអ្វីមួយនៅតាមប្រព័ន្ធអនឡាញ។ ការដាក់ការរិតត្បិតចំពោះការប្រើប្រាស់បច្ចេកវិទ្យាត្រូវបានមើលឃើញថា ជាទណ្ឌកម្ម។ វាការពារកុមារជាបណ្តោះអាសន្នប៉ុណ្ណោះ និងមិនបង្រៀនពួកគេអំពី របៀបចាត់វិធានការចំពោះស្ថានភាពស្រដៀងគ្នានេះនៅពេលអនាគតឡើយ។ ការឆ្លើយតបនេះក៏ទំនងជារារាំងកុមារពីការទុកចិត្តលើមនុស្សពេញវ័យចំពោះបញ្ហា ដែលពួកគេបានជួបប្រទះផងដែរ។

**៤.១០ ជួយកុមារឱ្យយល់ដឹងពេញលេញអំពីហានិភ័យនៃការចែកចាយមាតិកាផ្លូវភេទ** និងរបៀបចូលរួមនៅក្នុងការកាត់បន្ថយគ្រោះថ្នាក់ ដើម្បីដាក់កំហិតលើផលប៉ះពាល់អវិជ្ជមានដែលអាចមាន។ សមាមាត្រខ្ពស់បំផុតនៃកុមារ ដែលបានចែកចាយមាតិកាផ្លូវភេទ ដំបូងឡើយ ពួកគេធ្វើបែបនេះ ដោយសារពួកគេធ្លាក់ក្នុងសេចក្តីស្រឡាញ់ (២៩%) ឬទុកចិត្តជនដទៃទៀត (២០%) ប៉ុន្តែអាកប្បកិរិយានេះអាចនាំទៅរកគ្រោះថ្នាក់ធ្ងន់ធ្ងរ ដូចជា ការចែកចាយមាតិកានេះដោយគ្មានការយល់ព្រមជាមួយអ្នកដទៃទៀត និងការគំរាមកំហែងក្នុងគោលបំណងពាក់ព័ន្ធនឹងផ្លូវភេទ។

## ទីភ្នាក់ងារអនុវត្តច្បាប់

**៤.១១ បង្កើតគោលការណ៍ណែនាំច្បាស់លាស់អំពី**ការបញ្ជូនករណីរវាងទីភ្នាក់ងារនានា ដែលពាក់ព័ន្ធនៅក្នុងការស៊ើបអង្កេត។ ធ្វើឱ្យប្រាកដ

* គំរូនៃការឆ្លើយតបជាតិលេខ ៥។

ថា ការបញ្ជូនករណី OCSEA ស្របជាមួយនឹងនីតិវិធីប្រតិបត្តិបទដ្ឋានស្តីពីកិច្ចការពារកុមារ ដែលកំណត់តួនាទី និងទំនួលខុសត្រូវរបស់តួអង្គកិច្ចការពារកុមារ។ បង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ ដើម្បីធានានូវការអនុវត្តតាមគោលការណ៍ណែនាំនេះ។ ពង្រឹងបន្ថែមទៅលើធនធានដែលមានស្រាប់ ដូចជាកម្មវិធីគ្រប់គ្រងករណីតាមប្រព័ន្ធ Primero។

**៤.១២ កំណត់អាណត្តិ និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់របស់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៅក្នុងការដោះស្រាយករណី OCSEA ។** នៅពេលកំណត់ហើយ ពង្រឹងសមត្ថភាព និងកិច្ចសហប្រតិបត្តិការរបស់ពួកគេ តាមរយៈការសម្របសម្រួលការបណ្តុះបណ្តាលយ៉ាងទូលំទូលាយ សម្រាប់មន្ត្រីអនុវត្តច្បាប់ (ជាពិសេសនៅថ្នាក់មូលដ្ឋាន) និងអ្នកមានភារកិច្ចដទៃទៀត។ ការបណ្តុះបណ្តាលគប្បីទទួលបានការគាំទ្រជាមួយនឹងធនធាន ទាំងធនធានមនុស្ស និងហិរញ្ញវត្ថុ ដើម្បីឱ្យកុមារ និងគ្រួសារមានផាសុកភាពក្នុងការរាយការណ៍អំពីការរំលោភបំពាន។ ពង្រឹងនីតិវិធីកុមារមេត្រីដែលមានស្រាប់ ដើម្បីធានានូវឧត្តមប្រយោជន៍របស់កុមារ និងកិច្ចការពារសិទ្ធិរបស់ពួកគេ ការស្តាប់លឺ និងការទទួលបានព័ត៌មាន នៅពេលពាក់ព័ន្ធនៅក្នុងដំណើរការព្រហ្មទណ្ឌ។

### ផ្នែកឧស្សាហកម្ម

៤.១៣ បង្កើតយន្តការរាយការណ៍ជាផ្លូវការនៅក្នុងបណ្តាញទំនាក់ទំនងសង្គម និងថ្នាលកម្មវិធីផ្ញើសារភ្លាមៗឱ្យច្បាស់លាស់ និងអាចចូលដំណើរការបានសម្រាប់កុមារ និងលម្អិតអំពីអ្វីដែលកើតឡើងបន្ទាប់ពីកុមារបានរាយការណ៍ ក្នុងពាក្យពេចន៍បែបកុមារមេត្រី។ ថ្នាលកម្មវិធី និងអ្នកផ្តល់សេវាអ៊ីនធឺណិតត្រូវតែឆ្លើយតបយ៉ាងឆាប់រហ័សចំពោះរបាយការណ៍ដែលធ្វើឡើងដោយកុមារ និងបង្ហាញពីតម្លាភាព និងគណនេយ្យភាព។

**៤.១៤ ធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការរវាងអ្នកផ្តល់សេវាអ៊ីនធឺណិត និងទីភ្នាក់ងារអនុវត្តច្បាប់ដោយ៖**

- បង្កើតផ្លូវសម្រាប់ដំណើរការសំណើ និងការសហការ។
- បណ្តុះបណ្តាលបុគ្គលិកដើម្បីឆ្លើយតបទៅនឹងសំណើសុំទិន្នន័យសម្រាប់ករណីដែលកំពុងបន្ត និងកាត់បន្ថយពេលវេលាដំណើរការ។
- ផ្តល់ឱ្យអាជ្ញាធរអនុវត្តច្បាប់នូវព័ត៌មានពាក់ព័ន្ធណាមួយដែលពួកគេមាន ហើយអាចជួយកំណត់អត្តសញ្ញាណជនល្មើស និងជនរងគ្រោះបានទាន់ពេលវេលា។
- តាមរក និងលុបមាតិកាដែលទាក់ទងនឹង OCSEA នៅលើម៉ាស៊ីនមេរបស់ពួកគេ។

**គម្រោងស្តីពីការបញ្ឈប់គ្រោះថ្នាក់ផ្សារភ្ជាប់ជាមួយនឹងគំរូនៃការឆ្លើយតបជាតិ និងផែនការសកម្មភាពថ្នាក់តំបន់ក្នុងកិច្ចការពារកុមារពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ច និងរំលោភបំពានតាមប្រព័ន្ធអនឡាញ នៅក្នុងតំបន់អាស៊ាន**

ប្រទេស ក្រុមហ៊ុន និងអង្គការជាច្រើនបានចូលរួមជាមួយសម្ព័ន្ធសកល WePROTECT ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ។ ក្នុងនាមជាសមាជិកនៃសម្ព័ន្ធភាពសកលនេះ កម្ពុជាអាចប្រើប្រាស់ គំរូនៃឆ្លើយតបជាតិចំពោះការទប់ស្កាត់ និងការដោះស្រាយការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារ ដើម្បីជួយរៀបចំការឆ្លើយតបរបស់ខ្លួនចំពោះ OCSEA។ គំរូនេះគឺជាឧបករណ៍យ៉ាងមានតម្លៃ សម្រាប់រដ្ឋាភិបាល ក្នុងការពង្រឹងកម្រិតនៃការឆ្លើយតបរបស់ពួកគេ។

នៅពេលថ្មីៗនេះ អាស៊ានបានអនុម័តផែនការសកម្មភាពតំបន់សម្រាប់កិច្ចការពារកុមារពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ច និងការរំលោភបំពានតាមប្រព័ន្ធអនឡាញ ដែលរួមមានការប្តេជ្ញាចិត្តសម្រាប់រដ្ឋសមាជិកក្នុងការពង្រឹងកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញនៅក្នុងតំបន់នេះ។ ផែនការនេះរួមមានវិស័យនៃការផ្តោតការយកចិត្តទុកដាក់ចំនួនប្រាំពីរ ដែលមានចាប់ពីការលើកកម្ពស់ការយល់ដឹង ការពង្រឹងការប្រមូលទិន្នន័យ រហូតដល់កំណែទម្រង់ច្បាប់។ ដូចគ្នាជាមួយនឹងគំរូនៃការឆ្លើយតបជាតិដែរ អនុសាសន៍នៃគម្រោងស្តីពីការបញ្ឈប់គ្រោះថ្នាក់ស្របជាមួយវិស័យនៃការផ្តោតការយកចិត្តទុកដាក់ទាំងនេះ និងចែងលម្អិតអំពី ការឆ្លើយតបចំពោះ OCSEA ដែលមានការគាំទ្រ មានលក្ខណៈអនុវត្តជាក់ស្តែង និងផ្អែកលើភស្តុតាង។

ភាគច្រើននៃអនុសាសន៍ នៅក្នុងរបាយការណ៍នេះស្របជាមួយនឹង "សមត្ថភាព" ចំនួន ២១ ដែលត្រូវបានចែងនៅក្នុងគំរូនៃការឆ្លើយតបជាតិ ទោះបីជាយ៉ាងណាក្តី គម្រោងស្តីពីការបញ្ឈប់គ្រោះថ្នាក់ បានកំណត់ វិស័យអាទិភាព សម្រាប់អន្តរាគមន៍នានា ដោយផ្អែកយ៉ាងជាក់លាក់លើទិន្នន័យអំពីស្ថានភាពកម្ពុជា។ អនុសាសន៍ភាគច្រើននៃគម្រោងស្តីពីការបញ្ឈប់គ្រោះថ្នាក់ដោះស្រាយលើកម្មវិធីច្បាប់ ការអនុវត្តច្បាប់ ដោយមានអង្គភាពឯកទេសទទួលបន្ទុកជាក់លាក់ តុលាការ និងព្រះរាជអាជ្ញា និងកម្មវិធីការអប់រំ។

* សេចក្តីសម្រេចដែលបានអនុម័តដោយមហាសន្និបាត [នៅលើរបាយការណ៍របស់គណៈកម្មាធិការទី៣(A/៦៤/៤៣៤)] ៦៤/១៤២. Guidelines for the Alternative Care of Children.

## ការយល់ដឹងស៊ីជម្រៅទី ៥៖

កម្រងនៃគំនិតផ្តួចផ្តើមដែលអាចនឹងមានសក្តានុពល ដែលដឹកនាំដោយទាំងរដ្ឋាភិបាល និងសង្គមស៊ីវិល កំពុងស្ថិតក្នុងដំណើរការអនុវត្តរួចហើយនៅកម្ពុជា ទោះបីជាយ៉ាងណាក្តី បញ្ហាប្រឈមគួរឱ្យកត់សម្គាល់នៅតែមាន។ សន្ទុះ និងការប្តេជ្ញាចិត្តកាន់តែច្រើនក្នុងការធានាថា កុមារកម្ពុជាទទួលបានកិច្ចការពារពី OCSEA គប្បីត្រូវបានប្រើប្រាស់ ដើម្បីបង្កើនការយល់ដឹង ជំនាញ និងធនធាន សម្រាប់ការអនុវត្តច្បាប់ យុត្តិធម៌ និងបុគ្គលិកគាំទ្រសង្គមក្នុងការឆ្លើយតប។

### រដ្ឋាភិបាល

**៥.១ មន្ត្រីអនុវត្តច្បាប់ មន្ត្រីសុខុមាលភាពសង្គមរបស់រដ្ឋាភិបាល និងបុគ្គលិកសង្គមរបស់អង្គការមិនមែនរដ្ឋាភិបាល គប្បីជៀសវាងការដកកុមារដោយមិនចាំបាច់ចេញពីគ្រួសារ និងសហគមន៍របស់ពួកគេ។** ប្រសិនបើកុមារម្នាក់ត្រូវបានគេដកចេញពីគ្រួសារ ឬសហគមន៍របស់ពួកគេ និងការប៉ាន់ប្រមាណគួរត្រូវបានធ្វើឡើងដើម្បីកំណត់ថានេះជាឧត្តមប្រយោជន៍របស់កុមារ។ ស្របពេលដែលកុមារជាច្រើនត្រូវបានការពារក្នុងបរិយាកាសផ្ទះ សេវាសង្គ្រោះ ឬកន្លែងស្នាក់នៅបណ្តោះអាសន្នអាចជៀសមិនរួច ប្រសិនបើស្ថានភាពនៅផ្ទះមិនមានសុវត្ថិភាព ឬការថែទាំតាមគ្រួសារជំនួសមិនអាចរកបានភ្លាមៗបាន។ ប្រសិនជាសេវាកម្មផ្តល់ទីជម្រកវាគួរតែមានរយៈពេលខ្លីបំផុតដែលអាចធ្វើបាន និងអនុលោមតាមស្តង់ដារអន្តរជាតិ។

អភិក្រមមួយ ដែលពាក់ព័ន្ធនឹងការអនុវត្តច្បាប់ និងបុគ្គលិកគាំទ្រសង្គមដែលចូលរួមដោយការគោរព និងសហប្រតិបត្តិការជាមួយកុមារ គ្រួសារ និងសហគមន៍ ក្នុងការរៀបចំដំណោះស្រាយទៅតាមតម្រូវការ គប្បីជាគោលដៅ។ សម្របជាមួយកម្មវិធីសំខាន់ៗនៅក្នុងវិស័យនេះ ដូចជាគម្រោងការថែទាំកុមារនៅក្នុងគ្រួសារជាអាទិភាពចម្បង និងអនុលោមទៅតាមបទដ្ឋានអន្តរជាតិ។ គំនិតផ្តួមផ្តើមទាំងនេះ ដែលពាក់ព័ន្ធនឹងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល កំពុងរួមចំណែកចំពោះការផ្លាស់ប្តូរនៅក្នុង "វប្បធម៌នៃការថែទាំ"  សម្រាប់កុមារទាំងអស់។

**៥.២ បង្កើតក្រុមឆ្លើយតបពហុទីភ្នាក់ងារ** និងចាត់តាំងទីភ្នាក់ងារដឹកនាំពីរដ្ឋាភិបាល ដើម្បីកាត់បន្ថយការធ្វើឱ្យកុមាររងប៉ះទង្គិចផ្លូវចិត្តឡើងវិញនៅក្នុងដំណើរការផ្លូវច្បាប់ផ្សេងៗគ្នា។ ការមានក្រុមឆ្លើយតបជាមជ្ឈមណ្ឌលច្រកចេញចូលតែមួយនៅទូទាំងប្រទេសនឹងជួយអាជ្ញាធរក្នុងការទាញយកព័ត៌មានពីកុមារ ក្នុងពេលតែម្តងប៉ុណ្ណោះ។ កន្លែងនានាដែលកុមារអាចទទួលបានសេវានៅក្នុងការការរៀបចំបែបកុមារមេត្រីនៅតែមួយកន្លែង អាចមានសក្តានុពលក្នុងការពង្រឹងកិច្ចសហការ និងការសម្របសម្រួលរវាងអ្នកផ្តល់សេវា។ មជ្ឈមណ្ឌលទាំងនេះក៏ធានានូវអភិក្រមផ្តោតលើជនរងគ្រោះគ្រប់ជ្រុងជ្រោយក្នុងការលើកកម្ពស់លទ្ធភាពទទួលបានយុត្តិធម៌ និងការគាំទ្រចិត្តសង្គមកាន់តែល្អប្រសើរ។ បើទោះបីជាការស្រាវជ្រាវពីមុនបង្ហាញឱ្យឃើញថា នៅកម្ពុជា សមត្ថភាពស្ថាប័នបច្ចុប្បន្នសម្រាប់ការបង្កើតមជ្ឈមណ្ឌលច្រកចេញចូលតែមួយនៅមានកម្រិតក្តី មានជំហាននានាដែលអាចត្រូវបានធ្វើ ដើម្បីពង្រឹងសមត្ថភាពរបស់ប្រព័ន្ធដែលអាចរៀបចំឱ្យមានមូលដ្ឋានគ្រឹះយ៉ាងចាំបាច់ និងដែលអាចឈានទៅរកការបង្កើតមជ្ឈមណ្ឌលច្រកចេញចូលតែមួយនាពេលអនាគត។

**៥.៣ ជំរុញកិច្ចសហការឱ្យកាន់តែល្អរវាងអ្នកពាក់ព័ន្ធខុសៗគ្នា។** ការពង្រឹងដំណើរការនានា ការចែកចាយព័ត៌មាន និងធនធានដែលប្រមូលបាន និងការកាត់បន្ថយកិច្ចខិតខំប្រឹងប្រែងជាន់គ្នា នឹងពង្រឹងសមត្ថភាពរបស់ភាគីទាំងអស់ក្នុងការឆ្លើយតបចំពោះ OCSEA ។ ធ្វើការងារជាមួយក្រសួង និងអង្គភាពរដ្ឋបាលដែលមានការចាត់តាំង ដើម្បីរចនាអភិក្រមជាគោលដៅ។ ក្នុងចំណោមឧបករណ៍ដទៃទៀត ចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា ដើម្បីជំរុញកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ។

**៥.៤ វិនិយោគលើការកសាងចំណេះដឹងបច្ចេកទេសអំពី OCSEA របស់មន្ត្រីនគរបាល ព្រះរាជអាជ្ញា តុលាការ មេធាវី មន្ត្រីនៅក្នុងបន្ទប់សវនាការ មន្ត្រីកិច្ចការពារកុមារ និងបុគ្គលិកសង្គមជួរមុខ** និងការបង្ហាញខុសៗគ្នានៃ OCSEA ។ ដោយពិចារណាលើឧបករណ៍អនឡាញ និងឱកាសដែលវិវឌ្ឍយ៉ាងឆាប់រហ័ស អ្នកវិជ្ជាជីវៈចាំបាច់ត្រូវស្វែងយល់ និងដឹងអំពី របៀបដោះស្រាយបញ្ហា OCSEA នៅក្នុងវិជ្ជាជីវៈដោយឡែករបស់ពួកគេ នៅក្នុងលក្ខណៈផ្ទាល់ខ្លួន និងក្នុងលក្ខណៈជាសហគមន៍។ គំនិតផ្តួចផ្តើមកសាងសមត្ថភាពត្រូវទទួលបានមូលនិធិ និងបញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់រដ្ឋាភិបាលកម្ពុជា។ ការធ្វើបែបនេះនឹងជួយក្នុងការរក្សាធនធាន និងការវិភាជថវិកាជាបន្តបន្ទាប់ជំនួសឱ្យការពឹងផ្អែកលើកិច្ចសហការ /ការផ្តល់មូលនិធិ បរទេសដែលមិនទៀងទាត់។

**៥.៥ បញ្ចូលការបណ្តុះបណ្តាលអំពី** OCSEA ទៅក្នុងគំនិតផ្តួចផ្តើមការបណ្តុះបណ្តាលជាបន្តបន្ទាប់អំពី អំពើហិង្សាលើកុមារ និងការរំលោភបំពានផ្លូវភេទកុមារ ដែលរៀបចំឡើងដោយក្រសួងសុខាភិបាល និងបញ្ចូល OCSEA នៅក្នុងគោលការណ៍ណែនាំ សម្រាប់មន្ត្រីថែទាំសុខភាពរៀបចំឡើងដោយក្រសួងសុខាភិបាល។

**៥.៦ អនុវត្តនីតិវិធីព្រហ្មទណ្ឌរហ័ស** នៅពេលដែលកុមាររងគ្រោះស្ថិតក្រោមការថែទាំរបស់ទីភ្នាក់ងាររដ្ឋាភិបាលនៅក្នុងអំឡុងពេលដំណើរការនីតិវិធីតុលាការ។ ការធ្វើបែបនេះអាចត្រូវបានធ្វើឡើង តាមរយៈការកំណត់ឱ្យក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិតចាត់តាំងមន្ត្រីទំនាក់ទំនងជាមួយទីភ្នាក់ងារអនុវត្តច្បាប់ ដើម្បីទទួលខុសត្រូវចំពោះការចាត់ចែងឆ្លើយតបចំពោះការស្នើសុំទិន្នន័យពីទីភ្នាក់ងារការអនុវត្តច្បាប់ សំដៅពន្លឿនការស៊ើបអង្កេត និងការផ្តន្ទាទោសករណី OCSEA ។

**៥.៧ តាមដាន និងត្រួតពិនិត្យការអនុវត្ត**សេចក្តីណែនាំឆ្នាំ២០១៨ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងនគរបាលជាតិ ដែលកំណត់ថាក្រុមហ៊ុនទូរគមនាគមន៍ទាំងអស់នៅកម្ពុជាត្រូវតែ**ធានាថាអ្នកប្រើប្រាស់ស៊ីមកាតទាំងអស់ត្រូវចុះបញ្ជី**។ និយ័តករទូរគមនាគមន៍ប៉ាន់ប្រមាណថា ប្រមាណដប់ភាគរយនៃស៊ីមកាតនៅ ពេលបច្ចុប្បន្ននៅតែមិនទាន់ចុះបញ្ជីនៅឡើយ ដែលជាឧបសគ្គមួយនៅពេលកំណត់អាសយដ្ឋាន IP និងការភ្ជាប់ទំនាក់ទំនងអាសយដ្ឋានទាំងនេះជាមួយនឹងម្ចាស់ទូរស័ព្ទ។

**៥.៨ បង្កើនការសម្របសម្រួលលើគ្រប់កម្មវិធីដែលផ្តោតលើអំពើហិង្សាតាមប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ** ហើយក្នុងកម្រិតដែលសមហេតុផល ទូទាំងកម្មវិធីដែលផ្តោតលើអំពើហិង្សាចំពោះស្ត្រី និងកុមារ។

## អ្នកថែទាំ គ្រូបង្រៀន និងសេវាគាំទ្រសង្គម

**៥.៩ បណ្តុះបណ្តាលបុគ្គលិកទាំងអស់នៃសេវាគាំទ្រសង្គម (មិនត្រឹមតែសេវាឯកទេសប៉ុណ្ណោះឡើយ) ក្នុងការយល់ដឹងអំពីហានិភ័យ និងគ្រោះថ្នាក់ក្នុងលក្ខណៈដោយឡែកនៃ OCSEA** និងផ្តល់ដល់ពួកគេនូវការអនុវត្តល្អៗដែលផ្អែកលើភស្តុតាងសម្រាប់ការឆ្លើយតប។ កិច្ចការនេះអាចត្រូវធ្វើតាមរយៈការបញ្ចូលព័ត៌មាន អំពី OCSEA ទៅក្នុងការបណ្តុះបណ្តុះបណ្តាលសេវាសង្គមស្តីពីកិច្ចការពារកុមារ ដែលមានស្រាប់។ នៅពេលកុមារមានភាពក្លាហានគ្រប់គ្រាន់ក្នុងការស្វែងរកជំនួយ អ្នកទាំងឡាយ ដែលកុមារទៅស្វែងរកជំនួយ ត្រូវតែមានការបំពាក់បំប៉ន ដើម្បីផ្តល់ជំនួយនោះ។

**ទីភ្នាក់ងារអនុវត្តច្បាប់ Resolution adopted by the General Assembly [on the report of the Third Committee (A/៦៤/៤៣៤)] ៦៤/១៤២. Guidelines for the Alternative Care of Children**

**៥.១០ បង្កើតអង្គភាពឯកទេសទទួលបន្ទុក ឬមន្ត្រីឯកទេសទទួលបន្ទុកនៅក្នុងអង្គភាពមួយ ដើម្បីស៊ើបអង្កេតករណី OCSEA ។** អង្គភាពបែបនេះគប្បីមានមន្ត្រីនានា ដែលមានបទពិសោធន៍ពាក់ព័ន្ធនឹងបទល្មើសលើកុមារទាំងនៅក្នុង និងនៅក្រៅប្រព័ន្ធអនឡាញ ។ យកល្អបំផុត អង្គភាពឯកទេសនេះមានកន្លែងងាយការណ៍ដែលអាចប្រើប្រាស់ជាសាធារណៈ ទីកន្លែងបែបកុមារមេត្រី ការភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត និងឧបករណ៍ និងសមត្ថភាពបច្ចេកទេសនៅនឹងកន្លែង។ ដោយសារកង្វះអង្គភាពឯកទេសទទួលបន្ទុក ក្រុមការងារមួយដែលមន្ត្រីទទួលបន្ទុកពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា អាចមានភាពគ្រប់គ្រាន់។

**៥.១១ ពង្រឹងការប្រមូលទិន្នន័យ និងការតាមដានត្រួតពិនិត្យករណី OCSEA** ទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ ការកត់ត្រា និងចាត់ចំណាត់ថ្នាក់ជាប្រព័ន្ធនៃករណីនានានឹងសម្រួលនៅក្នុងការរៀបចំយន្តការដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះ OCSEA ដោយផ្អែកលើភស្តុតាង។ ភ្ជាប់ទំនាក់ទំនងទិន្នន័យ OCSEA ជាមួយនឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារដែលមានស្រាប់។

**៥.១២ វិនិយោគលើបរិក្ខារបន្ថែម** និងឧបករណ៍នានា ដើម្បីតាមរក ចាត់ចំណាត់ថ្នាក់ និងវិភាគមាតិកា CSAM ។ នៅពេលបច្ចុប្បន្ន ទីភ្នាក់ងារអនុវត្តច្បាប់របស់កម្ពុជាមិនទាន់មានឧបករណ៍ចាំបាច់ ដើម្បីប្រមូល និងត្រួតពិនិត្យភស្តុតាងឌីជីថលយ៉ាងរហ័សនៅឡើយទេ ដើម្បីឱ្យដោះស្រាយបាននូវឧបសគ្គនៃពេលវេលា ក្នុងលក្ខណៈដែលនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាអាចបន្តការស៊ើបអង្កេតបាន។ បណ្តុះបណ្តាលមន្ត្រីអំពីរបៀបប្រើប្រាស់ឧបករណ៍ទាំងនោះ ។

**៥.១៣ បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យអំពីជនល្មើសនៃ OCSEA** និងកត់ត្រា រក្សាទុកឯកសារ និងតាមដានជាប្រព័ន្ធលើការបំលាស់ទីរបស់ពួកគេនៅក្នុងប្រទេស និងលើសពីនេះ។

**៥.១៤ ពិចារណាភ្ជាប់បណ្តាញជាមួយប្រព័ន្ធផ្ទុកទិន្នន័យ ICSE របស់នគរបាលអន្តរជាតិ (INTERPOL)**។ បង្កើតការតភ្ជាប់ទៅកាន់ប្រព័ន្ធផ្ទុកទិន្នន័យរូបភាពនិងវីដេអូថ្នាក់អន្តរជាតិ សម្រាប់ការកំណត់តាំងពីដំបូងនៃការប្រព្រឹត្តបទល្មើស/កត្តាគំរាមកំហែង ដើម្បីជៀសវាងភាពជាន់គ្នានៃការអនុវត្តច្បាប់ និងដើម្បីធានាទាំងការឆ្លើយ តបប្រកបដោយប្រសិទ្ធភាព និងការឃ្លាំងមើលបែបបុរេសកម្ម ។

**៥.១៥ ផ្តល់យន្តការប្រកបដោយប្រសិទ្ធភាព និងធនធានគ្រប់គ្រាន់** ដើម្បីធានាថា ការបញ្ជូនករណី OCSEA ជាលក្ខណអន្តរជាតិ រួមទាំងរបាយការណ៍ NCMEC ត្រូវបានស៊ើបអង្កេតក្នុងកម្រិតសមស្រប និងទាន់ពេលវេលា។

**៥.១៦ ធានាថាមន្ត្រីនគរបាល ព្រះរាជអាជ្ញា តុលាការមានកញ្ចប់ព័ត៌មានជាបទដ្ឋាន** ដើម្បីផ្តល់ដល់ជនរងគ្រោះទាំងអស់ និងអ្នកថែទាំរបស់ពួកគេ អំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារ (រួមទាំង OCSEA) ហេតុនេះ ការធានាថា នីតិវិធី និងសិទ្ធិពាក់ព័ន្ធទាំងអស់ រួមទាំងសិទ្ធិរបស់ពួកគេក្នុងការទទួលបានសំណង ត្រូវបានពន្យល់យ៉ាងច្បាស់លាស់។ ការធ្វើបែបនេះនឹងជួយកុមាររងគ្រោះ និងអ្នកថែទាំរបស់ពួកគេក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ ព្រមទាំងធ្វើឱ្យពួកគេយល់អំពីនីតិវិធីខាងមុខ។ **លើកកម្ពស់ការអនុវត្តនីតិវិធីកុមារមេត្រីក្នុងអំឡុងពេលដំណើរការស៊ើបអង្កេត។** ការយល់ដឹង និងការអនុវត្តនីតិវិធីកុមារមេត្រីនៅមានកម្រិត អាចធ្វើឱ្យកុមារងាយរងគ្រោះជាពិសេសនៅក្នុងដំណើរការយុត្តិធម៌។ បញ្ចូលប្រធានបទ OCSEA នៅក្នុងកម្មវិធីបណ្តុះបណ្តាលនៃបណ្ឌិតសភាននគរបាល។

**៥.១៧ វិនិយោគលើធនធានដើម្បីធ្វើការស៊ើបអង្កេតបែបបុរេសកម្មលើករណី OCSEA ។** គម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* បានរកឃើញថា អង្គភាពអនុវត្តច្បាប់ទំនងជាបានអនុវត្តក្នុងលក្ខណប្រតិកម្មតបតរជាជាងលក្ខណបុរេសកម្ម និងជាញឹកញាប់ ពឹងផ្អែកលើទីភ្នាក់ងារដទៃទៀតរបស់រដ្ឋាភិបាល។

**៥.១៨ ទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយថ្នាលកម្មវិធីបច្ចេកវិជ្ជាសកល និងពង្រឹងលើយន្តការសហការមានស្រាប់** ដើម្បីធានាថា ភស្តុតាងឌីជីថលដែលចាំបាច់នៅក្នុងករណី OCSEA អាចត្រូវបានប្រមូលយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព រួមទាំងការឆ្លើយតបនឹងសំណើសុំទិន្នន័យ ហើយមាតិកាខុសច្បាប់ត្រូវបានដកចេញភ្លាមៗ។

## អ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌

**៥.១៩ បណ្តុះបណ្តាលតួអង្គផ្នែកយុត្តិធម៌ទាំងអស់ រួមទាំងព្រះរាជអាជ្ញា និងចៅក្រម** អំពីរបៀបដោះស្រាយករណី OCSEA និងផ្តល់យុត្តិធម៌បែបកុមារមេត្រី។ កុមារបានបង្ហាញថា នៅទូទាំងដំណើរការនេះ នៅពេលអាចធ្វើបាន ជម្រើសយេនឌ័រ គប្បីត្រូវបានផ្តល់នៅពេលកុមារជួបជាមួយនគរបាល មេធាវី និងបុគ្គលសំខាន់ៗដទៃទៀត។ ចំពោះកុមារជាច្រើន បទពិសោធន៍របស់ពួកគេដែលនាំទៅរកអារម្មណ៍អាម៉ាសគួរឱ្យកត់សម្គាល់ និងការសម្ភាសអាចជាដំណើរការដ៏ពិបាក និងប្រកបដោយភាពអាម៉ាសមួយ។ កុមារ ទាំងកុមារា និងកុមារី បានរាយការណ៍ថា ការមានអ្នកផ្តល់សេវាដែលមានភេទដូចគ្នាគឺជាជម្រើសមួយជាទីចង់បាន។

**៥.២០ រៀបចំ និងអនុវត្តកម្មវិធីនានាដែលត្រៀមលក្ខណសម្រាប់កុមាររងគ្រោះ** និងផ្តល់ដល់ពួកគេនូវជំនួយផ្លូវច្បាប់គ្រប់គ្រាន់ ក្នុងការចូលរួមនៅក្នុងប្រព័ន្ធតុលាការ និងតួអង្គខាងផ្នែកយុត្តិធម៌។ ពង្រីកការចូលរួមរបស់ក្រុមពហុវិស័យនៅក្នុងអំឡុងពេលនៃដំណើរការនេះ។

**៥.២១ ទប់ស្កាត់ផលប៉ះទង្គិចផ្លូវចិត្តសារជាថ្មីដែលបង្កឡើងដោយសារការសាកសួរដដែលៗនៅចំពោះមុខតុលាការ/ជនល្មើស។** កិច្ចការនេះអាចត្រូវធ្វើតាមរយៈការបង្កើតមជ្ឈមណ្ឌលច្រកចេញចូលតែមួយនៅទូទាំងប្រទេស ជាកន្លែងដែលអ្នកប្រកបវិជ្ជាជីវៈផ្នែកយុត្តិធម៌ពាក់ព័ន្ធទាំងអស់អាចសម្ភាសកុមារ និងទទួលបានព័ត៌មានពាក់ព័ន្ធនានាពីកុមារក្នុងពេលតែម្តងប៉ុណ្ណោះ ជំនួសឱ្យការសម្ភាសម្តងហើយម្តងទៀតជាមួយកុមារជាច្រើនដង ឬតាមរយៈការថតវីដេអូអំពីការសម្ភាសជាមួយកុមាររងគ្រោះ។

**៥.២២ ដាក់ឱ្យអនុវត្តជាបទដ្ឋាននូវការប្រើប្រាស់របាំងក្នុងបន្ទប់សវនាការ និងការផ្តល់សក្ខីកម្មតាមទូរទស្សន៍ពីជនរងគ្រោះ ឬសាក្សីទៅកាន់បន្ទប់សវនាការ ដើម្បីផ្តល់**បរិយាកាសប្រកបដោយសុវត្ថិភាព និងការគាំទ្រសម្រាប់កុមាររងគ្រោះ។ នៅពេលបច្ចុប្បន្ន វិធានការផ្លូវច្បាប់ពាក់ព័ន្ធនឹងឧបករណ៍កុមារមេត្រីទាំងនេះមិនត្រូវបានអនុវត្តជាស្វ័យប្រវត្តិឡើយ ប៉ុន្តែត្រូវបានផ្អែកលើការអនុវត្ត ដែលត្រូវបានព្រះរាជអាជ្ញា ឬមេធាវីណែនាំជំនួសមុខកុមារ នៅពេលចាប់ផ្តើមការជំនុំជម្រះ។

**៥.២៣ ផ្តល់ព័ត៌មានដល់ជនរងគ្រោះពី OCSEA និងអ្នកថែទាំរបស់ពួកគេអំពីសិទ្ធិដែលត្រូវប្រើប្រាស់ដើម្បីទទួលបានសំណង** តាមរយៈដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ និងមិនត្រឹមតែជាដំណើរការរដ្ឋប្បវេណីដោយឡែកឡើយ ដែលជាដំណើរការមានចំណាយខ្ពស់ និងស្មុគស្មាញ។ រៀបចំ និងអនុវត្តប្រព័ន្ធគាំទ្រផ្លូវច្បាប់សម្រាប់កុមាររងគ្រោះ/គ្រួសាររបស់ពួកគេ នៅក្នុងដំណើរការទាមទារសំណង។

## ឧស្សាហកម្ម

**៥.២៤ ចាត់អាទិភាពលើការឆ្លើយតបចំពោះសំណើសុំទិន្នន័យ** នៅក្នុងករណីដែលពាក់ព័ន្ធនឹងកុមារ ដើម្បីជួយកាត់បន្ថយរយៈពេលនៃដំណើរការស៊ើបអង្កេត។ កិច្ចការនេះអាចត្រូវធ្វើតាមរយៈការកំណត់ឱ្យក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត ចាត់តាំងមន្ត្រីទំនាក់ទំនងជាមួយទីភ្នាក់ងារការអនុវត្តច្បាប់ ដើម្បីទទួលខុសត្រូវចំពោះការចាត់ចែងលើសំណើសុំទិន្នន័យពីទីភ្នាក់ងារអនុវត្តច្បាប់ ដើម្បីពន្លឿនការស៊ើបអង្កេត និងការផ្តន្ទាទោសករណី OCSEA ។

**៥.២៥ ពិគ្រោះជាមួយអ្នកផ្តល់សេវាអ៊ីនធឺណិត អ្នកអនុវត្តច្បាប់ អ្នកជំនាញខាងផ្នែកឯកជនភាព និងក្រុមហ៊ុនបច្ចេកវិទ្យា** ដើម្បីបង្កើតបទប្បញ្ញត្តិចាំបាច់ សម្រាប់ការចម្រោះ ដកចេញ និងបិទខ្ទប់មាតិកា

CSAM និងការដោះស្រាយអំពើលួងលោមក្នុងគោលបំណងផ្លូវភេទ និងអំពើផ្សាយបន្តផ្ទាល់នៃការរំលោភបំពានផ្លូវភេទ ព្រមទាំងការអនុលោមតាមសំណើដែលបានអនុម័តដោយច្បាប់ សម្រាប់ផ្តល់ព័ត៌មានអំពីអ្នកប្រើប្រាស់ដែលពាក់ព័ន្ធក្នុងករណី OCSEA ។ តាមដានការអនុលោមតាមឱ្យទាន់ពេលវេលា និងដាក់ផលវិបាកចំពោះការមិនគោរពតាម។

**៥.២៦ ក្រុមហ៊ុនបច្ចេកវិទ្យា និងអ្នកផ្តល់សេវាហិរ**ញ្ញវត្ថុតាមអ៊ីនធឺណិត គួរតែពិចារណាលើការតាមរកដោយបុរេសកម្ម និងកាត់បន្ថយមាតិកា CSAM ដោយកំណត់រកការប៉ុនប៉ងលួងលោមក្នុងគោលបំណងផ្លូវភេទ និងការរំលោភបំពានផ្លូវភេទកុមារដែលផ្សាយបន្តផ្ទាល់ ដោយប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាដូចជា PhotoDNA  ឬ API Arachnid ។

**៥.២៧ លើកកម្ពស់ការយល់ដឹងអំពី OCSEA ក្នុងចំណោមក្រុមហ៊ុនឯកជនពាក់ព័ន្ធ** រួមទាំងអ្នកផ្តល់សេវាអ៊ីនធឺណិត ទូរស័ព្ទ និងហិរញ្ញវត្ថុ ដើម្បីធានាថាក្រុមហ៊ុនគ្រប់ទំហំទាំងអស់មានការយល់ដឹងកាន់តែច្បាស់អំពីហានិភ័យដែលកុមារប្រឈម និងអ្វីដែលពួកគេអាចធ្វើបាន ដើម្បីប្រយុទ្ធប្រឆាំងនឹង OCSEA ។ លើកកម្ពស់គំនិតផ្តួចផ្តើមពហុវិស័យ ដើម្បីបង្កើត និង/ឬពង្រឹងគោលនយោបាយការពារកុមារផ្ទៃក្នុង។

## ការយល់ដឹងស៊ីជម្រៅទី ៦៖

**បើទោះបីជាការប្រកាសឱ្យអនុវត្ត និងការអនុវត្តជាបន្តបន្ទាប់នូវផែនការសកម្មភាពស្តីពី OCSEA ដែលជាជំហានយ៉ាងសំខាន់ក្តី ច្បាប់ គោលនយោបាយ និងបទដ្ឋានដទៃទៀតនៅកម្ពុជានៅតែចាំបាច់ត្រូវតែអនុម័ត។**

### រដ្ឋាភិបាល

**៦.១ ពិចារណាធ្វើវិសោធនកម្មច្បាប់ដើម្បីឱ្យស្របទៅតាមផែនការសកម្មភាពតំបន់ ព្រមទាំងអនុសញ្ញាអន្តរជាតិ** ដែលផ្តល់សេចក្តីណែនាំយ៉ាងល្អ សម្រាប់ដោះស្រាយបញ្ហា OCSEA ដូចជា អនុសញ្ញាស្តីពីកិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ (អនុសញ្ញា Lanzarote) និងអនុសញ្ញាស្តីពីបទល្មើសបច្ចេកវិទ្យា (អនុសញ្ញា Budapest) នៃក្រុមប្រឹក្សាអឺរ៉ុប។ អនុសញ្ញាទាំងនេះផ្តល់នូវវិធានការយ៉ាងមានសារប្រយោជន៍នៃក្របខណ្ឌច្បាប់ជាតិពាក់ព័ន្ធនឹង OCSEA និងបើកចំហរចំពោះការចូលរួមពីរដ្ឋនានា ដែលមិនមែនជាសមាជិករបស់ក្រុមប្រឹក្សាអឺរ៉ុប។

**៦.២ កំណត់ជាបទល្មើសព្រហ្មទណ្ឌច្បាស់លាស់ចំពោះបទល្មើសជាក់លាក់ពាក់ព័ន្ធនឹង OCSEA ដូចជា ការផ្សាយបន្តផ្ទាល់អំពីការរំលោភបំពានផ្លូវភេទកុមារ ការលួងលោមតាមប្រព័ន្ធអនឡាញក្នុងគោលបំណងផ្លូវភេទ និងការគំរាមកំហែងខាងផ្លូវភេទ ព្រមទាំងធ្វើវិសោធនកម្មច្បាប់ស្តីពី CSAM** ដើម្បីគ្របដណ្តប់យ៉ាងច្បាស់លើរូបភាពពណ៌នារាងកាយអាក្រាតរបស់កុមារក្នុងគោលបំណងផ្លូវភេទ និងសម្ភារដែលបង្ហាញនូវបុគ្គលណាម្នាក់ដែលទំនងជាកុមារនៅក្នុងសកម្មភាពផ្លូវភេទជាក់លាក់។ កិច្ចការនេះអាចត្រូវធ្វើតាមរយៈការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា ដែលនឹងកំណត់ឱ្យកាន់តែទូលំទូលាយអំពី CSAM និងកំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្ម និងបទល្មើសពាក់ព័ន្ធនឹង CSAM ទម្រង់ផ្សេងៗគ្នាដែលត្រូវប្រព្រឹត្តនៅលើប្រព័ន្ធអនឡាញ និង/ឬតាមរយៈការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ ឬឧបករណ៍ឌីជីថលដទៃទៀត។ ក៏មានឱកាស ដើម្បីកំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះបទល្មើសពាក់ព័ន្ធនឹង OCSEA នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារដែលកំពុងស្ថិតនៅដំណាក់កាលនៃការអនុម័ត ហើយកំពុងមានវឌ្ឍនភាពលឿនជាងសេចក្តីព្រាង ច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា។

**៦.៣ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពជាតិដើម្បីបង្ការ-ទប់ស្កាត់ និងឆ្លើយតប ចំពោះការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា ឆ្នាំ២០២១-២០២៥** ថ្មី និងផែនការ សកម្មភាពដទៃទៀត។ ពង្រឹងប្រព័ន្ធសម្រាប់ការផ្សព្វផ្សាយពីគំហើញ និងមេរៀនដែលទទួលបាននានា។

**៦.៤ ផ្តល់សេចក្តីណែនាំដល់ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត**  អំពីពេលវេលា និងរបៀបកត់ត្រាទិន្នន័យ IP និងរក្សាទិន្នន័យដែលផ្អែកលើមាតិកា ឬមិនផ្អែកលើមាតិកា។ កិច្ចការនេះអាចត្រូវបានធ្វើឡើងតាមរយៈការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា ដែលមានបទប្បញ្ញត្តិពាក់ព័ន្ធនឹងការរក្សាទុកទិន្នន័យកុំព្យូទ័រ និង ចរាចរណ៍អ៊ីនធឺណិត (ចែងថា ព្រះរាជអាជ្ញា ឬតុលាការអាចបញ្ជាឱ្យមានការរក្សាទុកយ៉ាងឆាប់រហ័សនៃការរក្សាទុកទិន្នន័យកុំព្យូទ័រ និងចរាចរណ៍អ៊ីនធឺណិត ប្រសិនបើមានសញ្ញាបង្ហាញថាទិន្នន័យបែបនេះមានទំនាក់ទំនងជាមួយបទល្មើសបច្ចេកវិទ្យា រួមទាំងបទល្មើសពាក់ព័ន្ធនឹង CSAM ដែលត្រូវបានប្រព្រឹត្ត)។

**៦.៥ ដកចេញនូវលក្ខខណ្ឌផ្តន្ទាទោសទ្វេដង** នៅពេលអនុវត្តយុត្តាធិការបត្យាប័នសម្រាប់បទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ។

* API គឺជាអក្សរកាត់តំណាងឱ្យ Application Programming Interface ដែលជាអន្តរការីកម្មវិធីអនុញ្ញាតឱ្យកម្មវិធីពីរនិយាយគ្នាទៅវិញទៅមក។ សូមមើល  See, Mulesoft, What is an API (Application Programming Interface)?

# ឯកសារយោង


- Action Pour Les Enfants (2018). The Current Perception of Child Sexual Abuse and Exploitation in Cambodia: A Study in Five Provinces.
- APLE. (2014). Investigating Travelling Child Sex Offenders.
- APLE. (2019). Impact Report 2019.
- APLE Cambodia. (2020). From Operation Oriented to Child-Centered.
- APLE Cambodia. (n,d). Online Courses.
- Bracket Foundation. (2019). Artificial Intelligence: Combating Online Sexual Abuse of Children
- Borgström, J., Larsson, C. (2020). Sexual Exploitation of Children in Travel and Tourism. The Cambodian Case.
- Cambodia National Council for Children. (2019). Initial Situational Analysis on Online Child Sexual Exploitation (OCSE) in Cambodia.
- Cambodia National Council for Children (2021). Action Plan to Prevent and Respond to Online Child Sexual Exploitation 2021–2015.
- Child Helpline Cambodia. (2019). Annual Report
- Committee on the Rights of the Child. (2015). Concluding Observations on the Report Submitted by Cambodia, Paragraph 16(a).
- Council of Europe´s Lanzarote Committee. (2015). Opinion on Article 23 of the Lanzarote Convention and its explanatory note. Para 20.
- Cooper, K., Quayle, E., Jonsson, L. & Svedin, C.G. (2016). Adolescents and self-taken sexual images: A review of the literature. Computers in Human Behavior, vol. 55, 706–716.
- Eisenbruch, M. (2019). ´His body is human, but he has a tiracchana heart´: An ethnographic study of the epigenesis of child abuse in Cambodia. Child Abuse & Neglect, 88, 129–143.
- ECPAT International. (2017). Regional Overview: Sexual Exploitation of Children in Southeast Asia. ECPAT International.
- ECPAT International. (2018). ECPAT Country Overview: Cambodia. Bangkok: ECPAT International.
- ECPAT International. (2018). Global Study on Sexual Exploitation of Children in Travel and Tourism.
- ECPAT International. (2020). Summary Paper on Sexual Exploitation of Children in Prostitution. Bangkok: ECPAT International.
- ECPAT International. (2021). Summary Paper on Sexual Exploitation of Children in Travel and Tourism.
- EUROPOL. (2019, 9 October). Internet Organised Crime Threat Assessment 2019.
- First Step Cambodia. (2019). Caring For Boys Affected by Sexual Violence.
- Government of Cambodia. (1993). Constitution of the Kingdom of Cambodia, Article 5.
- Government of Cambodia. (2007). Code of Criminal Procedure of the Kingdom of Cambodia

## តារាងឯកសារយោង


- Government of Cambodia. (2008). Prakas No. 62/08 on the Use of Court Screen and Courtroom TV-Linked Testimony from Child/Vulnerable Victims or Witnesses
- Government of Cambodia. (2008). Law on Suppression of Human Trafficking and Sexual Exploitation, Royal Kram NS/RKM/0208/005.
- Government of Cambodia. (2009). Criminal Code of the Kingdom of Cambodia.
- Government of Cambodia. (2014). Decision on Guideline for Applying Child Participation
- Government of Cambodia. (2016). ICT Development Policy 2016-2020.
- Government of Cambodia. (2017). Action Plan to Prevent and Respond to Violence Against Children (2017-2021), 24.
- Government of Cambodia – Working Group of Council of Ministers. (Undated). Cybercrime Law Draft V.1.
- Gourley, S. (2009). The Middle Way: Bridging the Gap between Cambodian Culture and Children's Rights.
- Interagency Working Group on Sexual Exploitation of Children. (2016). Terminology Guidelines for the Protection of Children from Sexual Exploitation and Sexual Abuse. Bangkok: ECPAT International.
- International Telecommunication Union. (2017). ICT Development Index 2017.
- International Telecommunication Union. (2019). Global Cybersecurity Index (GCI) 2018.
- International Telecommunications Union. (2020). Country ICT data: Percentage of Individuals Using the Internet.
- Internet Watch Foundation & Microsoft. (2015). Emerging Patterns and Trends Report #1 Online-Produced Sexual Content.
- Internet Watch Foundation. (2021). The Annual Report 2020.
- Joamets, K., & Ngouv, M. (2019). A Child's Right to be Heard and be Represented in the Criminal Procedure: A Comparative Analysis of Estonian and Cambodian Law To CRC. Baltic Journal of European Studies, 9(4), 141.
- Khmer Times. (2019). New Commerce Laws Come into Effect
- Livingstone, S., Kardefelt Winther, D., & Saeed, M. (2019). Global Kids Online Comparative Report. Innocenti Research Report. UNICEF Office of Research – Innocenti, Florence.
- May-Chahal, C., & Palmer, C. (2018). Rapid Evidence Assessment: Characteristics and vulnerabilities of victims of online-facilitated child sexual abuse and exploitation. Independent Inquiry into Child Sexual Abuse. UK: Lancaster University.
- Madrid, B. et al. (2020). Safe schools for teens: preventing sexual abuse of urban poor teens, proof-of-concept study - Improving teachers' and students' knowledge, skills and attitudes. Heliyon 6(6).
- National Society for the Prevention of Cruelty to Children. (2017). Talk PANTS with Pantosaurus and his PANTS song #TalkPANTS – YouTube.
- National Institute of Statistics. (2019). General Population Census of the Kingdom of Cambodia 2019.
- OECD. (2018). Economic Outlook For Southeast Asia, China And India 2019: Towards Smart Urban Transportation. Structural Policy Country Notes.
- Ramadanti, D. (2020). Telling stories with Google Trends using Pytrends in Python.
- Resolution adopted by the General Assembly [on the report of the Third Committee (A/64/434)] 64/142. Guidelines for the Alternative Care of Children.

# ឯកសារយោង


- Smahel, D., MacHackova, H., Mascheroni, G., Dedkova, L., Staksrud, E., Olafsson, K., Livingstone, S., & Hasebrink, U. (2020). EU Kids Online 2020: Survey results from 19 countries. London School of Economics and Political Science, London, UK.

- Stark, L., Rubenstein, B.L., Pak, K., Sok, K. (2017). National estimation of children in residential care institutions in Cambodia: a modelling study | BMJ Open.
- Stoilova, M., Livingstone, S., Khazbak, R. (2021). Investigating Risks and Opportunities for Children in a Digital World: A rapid review of the evidence on children's internet use and outcomes. Innocenti Discussion Papers no. 2021-01, Florence: UNICEF Office of Research – Innocenti.
- The Steering Committee on Violence Against Women and Violence Against Children. (2017). Action Plan to Prevent and Respond to Violence Against Children 2017-2021.
- Tilleke & Gibbins. (2019). Cambodia Enacts a New E-Commerce Law and a Consumer Protection Law.
- Terre des Hommes. (2020). The evolution of SECTT in Northwest Cambodia: Situation Analysis of the Sexual Exploitation of Children in Travel and Tourism in Poipet and Siem Reap.
- Thorn & Benson Strategy Group. (2020). Self-Generated Child Sexual Abuse Material: Attitudes and Experiences.
- The World Bank. (n.d.) GDP per capita (current US$) - Cambodia.
- The World Bank. (n.d.). Poverty & Equity Data Portal.
- United Nations. (n.d.) Sustainable Development Goals. See: Goals 5.2, 8.7 and 16.2.
- UNICEF. (2013) Findings from Cambodia's violence against children survey 2013, Phnom Penh: UNICEF
- UNICEF. (2021). The State of the World's Children 2021. UNICEF, New York.
- UNICEF Cambodia. (February 15, 2021). Interoperability between Primero and OSCaR goes live.
- NICEF (forthcoming). Evaluating Online Safety: What Works to Keep Children Safe Online.
- United Nations Population Division. (2018). World Population Prospects 2019 File 1: Population of Urban and Rural Areas at Mid-Year (thousands) and Percentage Urban, 2018.
- United Nations Population Division. (2019). World Population Prospects 2019.
- United Nations Girls' Education Initiative. (2020). Bodily autonomy and SRHR.
- United Nations Population Fund (UNFPA). (2021). My Body is My Own.
- World Vision and Save the Children. (2009). Sex Offenders without Borders: An Investigation into sexual abuse and exploitation of children in Thailand, Cambodia and Burma in relation to travel and tourism.
- HO (2016). INSPIRE: Seven Strategies for Ending Violence Against Children.
- WeProtect Global Alliance (2016). Preventing and Tackling Child Sexual Exploitation and Abuse: A model national response. London: WeProtect Global Alliance.
- WeProtect Global Alliance (2018). Global Threat Assessment 2018: Working together to end the sexual exploitation of children online. London: WeProtect Global Alliance.

# សេចក្តីថ្លែងអំណរគុណ

នគរបាលអន្តរជាតិ ECPAT អន្តរជាតិ និងការិយាល័យស្រាវជ្រាវរបស់ UNICEF – Innocenti សូមថ្លែងអំណរគុណចំពោះឱកាសក្នុងការធ្វើការងារកៀកស្មាគ្នា ដើម្បីវាយតម្លៃ OCSEA នៅកម្ពុជា។ របាយការណ៍គ្រប់ជ្រុងជ្រោយនេះ គឺជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងសហការគ្នារយៈពេលពីរឆ្នាំក្នុងការរចនាការស្រាវជ្រាវ ប្រមូលទិន្នន័យ និងបង្កើតភស្តុតាងវិសាមញ្ញ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះនឹងមិនទទួលបានជោគជ័យឡើយ ប្រសិនបើគ្មានការចូលរួមរបស់អ្នកពាក់ព័ន្ធ និងដៃគូយ៉ាងច្រើន។ ជាដំបូង និងសំខាន់បំផុតសូមថ្លែងអំណរគុណដ៏ធំបំផុតដល់កុមារដែលបានចូលរួមចំណែកជាពិសេសយុវជនដែលមានបទពិសោធន៍ពី OCSEA ហើយបាននិយាយដោយក្លាហានជាមួយក្រុមស្រាវជ្រាវ។ បទពិសោធន៍របស់កុមារគឺជាគន្លឹះក្នុងការយល់ដឹង និងដឹកនាំផ្លូវរបស់យើងឆ្ពោះទៅខាងមុខ។ ដៃគូគម្រោងនេះសូមសម្តែងនូវការថ្លែងអំណរគុណរបស់ពួកគេចំពោះអ្នកគ្រប់គ្នា ដែលបានចូលរួមនៅក្នុងគម្រោងស្តីពី *ការបញ្ឈប់គ្រោះថ្នាក់* តាមរយៈ៖

- ការរៀបចំគំហើញទៅតាមបរិបទ៖ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងអប់រំយុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល ក្រសួងផែនការ ក្រសួងកិច្ចការនារី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ ក្រសូងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គនាយកដ្ឋានពន្ធនាគារ គណៈកម្មការប្រឆាំងការជួញដូរមនុស្ស (NCCT) នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និយ័តករទូរគមនាគមន៍កម្ពុជា FBI សាលាដំបូងរាជធានីភ្នំពេញ អង្គការ UNICEF ប្រចាំប្រទេសកម្ពុជា អង្គការ APLE កម្ពុជា អង្គភាពកិច្ចការពារកុមារ (CPU) និងអង្គការ Terre des Hommes ប្រទេសហូឡង់។
- ការគាំទ្រដល់ការប្រមូលទិន្នន័យ៖ ការិយាល័យកណ្តាលជាតិនៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា ក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC)  អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា អង្គការ APLE កម្ពុជា អង្គការ UNICEF ប្រចាំប្រទេសកម្ពុជា, និង UNICEF East Asia and Pacific Regional Office, Indochina Research Ltd, Ipsos MORI ។
- ការចែករំលែកឯកទេស និងបទពិសោធន៍តាមរយៈការសម្ភាស និងការបំពេញទម្រង់ស្រង់មតិ៖ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងយុត្តិធម៌ ក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល និយ័តករទូរគមនាគមន៍កម្ពុជា សាលាដំបូងរាជធានីភ្នំពេញ អង្គការ APLE កម្ពុជា អង្គការបេសកកម្ម Agape អន្តរជាតិ មន្ទីរពេទ្យកុមារអង្គរ សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (លីកាដូ) អង្គការកម្ពុជាដើម្បីជួយស្រ្តីមានវិបត្តិ  មជ្ឈមណ្ឌលកម្ពុជាសម្រាប់កិច្ចការពារសិទ្ធិកុមារ អង្គការចាប់ដៃ អង្គការ Chai កម្ពុជា អង្គភាពកិច្ចការពារកុមារ (CPU) អង្គការកុមារក្នុងគ្រួសារ អង្គការសង្គ្រោះជោគវាសនាកម្ពុជា, អង្គការ Free to Shine អង្គការជំហានដំបូងកម្ពុជា អង្គការ HAGAR ប្រចាំកម្ពុជា អង្គការ Hard Place Community អង្គការក្តីសង្ឃឹមយុត្តធម៌ អង្គការកល្យាណមិត្ត អង្គការម្លប់តាប៉ាង អង្គការ PSE ) អង្គការ Terre des Hommes ប្រទេសហូឡង់។

ប្រសិនបើគ្មានកិច្ចខិតខំប្រឹងប្រែងសហការពីបុគ្គលិក អ្នកប្រឹក្សា អ្នកបកប្រែ និងអ្នកហាត់ការទាំងអស់ដែលពាក់ព័ន្ធក្នុងរបាយការណ៍នេះទេ ការស្រាវជ្រាវដ៏អស្ចារ្យនេះនឹងមិនអាចរួមគ្នាបានឡើយ។ ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ៖

ECPAT International៖ Tiago Afonso, Victoria Baines, Alice Beaven, Will Beaven, Rebecca Boudreaux, Willy Buloso, Yermi Brenner, Dr Mark P. Capaldi, Narciso Cumbe, Dorothea Czarnecki, Jarrett Davis, Rangsima Deespallarka, Julia Durska , Anneka Farrington, Liam Foley, Beatrice Gacengo, Thiyagu Ganesan, Susanna Greijer, Zipporah Goetze, Josefin Hagstrom, Alastair Hilton, Maria Ibañez Beltran, Worrawan Jirathanapiwat, Supriya Kasaju, Mark Kavenagh, Bernard van Kenderreston, Guillaume Landry, Marie Laure Lemineur, Raphaelle Lecler, Katrina Mariswamy, John McGill, Mark McKillop, Stella Motsi, Florence Mueni, Thomas Müller, Manida Naebklang, Cathrine Napier, Rumbidzai Ngindi, Freddie Nickolds, , Nativity , Kirsten Pontalti, Marie Joy Pring, Ethel Quayle, Marita Rademeyer, Kieran Rumsby, Jennifer Schatz, Guncha Sharma, Nong Socheat, Chitrapon Vanaspong, Andrea Varrella, Kirsten Walkom, Timothy Williams ។

ការិយាល័យស្រាវជ្រាវ UNICEF - Innocenti៖ David Anthony, Dr Daniel Kardefelt-Winther, Marie Nodzenski, Marium Saeed, Rogers Twesigye ។

អង្គភាពឧក្រិដ្ឋកម្មប្រឆាំងនឹងកុមារនៃនគរបាលអន្តរជាតិ

ដៃគូនានាក៏សូមថ្លែងអំណរគុណចំពោះសេចក្តីណែនាំរបស់ក្រុមទីប្រឹក្សាព្រមទាំងដៃគូសកលដើម្បីបញ្ចប់អំពើហិង្សា និងមូលនិធិ (the Fund)។ យើងសូមថ្លែងអំណរគុណចំពោះ the Fund សម្រាប់ការវិនិយោគហិរញ្ញវត្ថុរបស់ពួកគេនៅក្នុងគម្រោងនេះ និងចំពោះក្រុមសុវត្ថិភាពអនឡាញ សម្រាប់ការរៀបចំទស្សនទាននៃគម្រោងស្តីពី*ការបញ្ឈប់គ្រោះថ្នាក់* ការរួមវិភាគទានបច្ចេកទេសរបស់ពួកគេ និងការគាំទ្រឥតងាករេរបស់ពួកគេ។